# អ្នករបាំ និង រឿងជាតក

## រជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧



បណ្ឌិត កែវ ណារុំ

www.elibraryofcambodia.org

បណ្ឌិត កែវ ណារុំ

# អ្នការចាំ និង រឿងជាតក

រជ្ជកាលព្រះបាទជ័យវរ្ម័នទី៧



15360/12
3/5
បណ្ណាល័យជាតិ
National Library of Cambodia
00028466

រក្សាសិទ្ធគ្រប់យ៉ាង

បោះពុម្ពលើកទី១ ចំនួន ១៥០០ច្បាប់
ព.ស. ២៥៥៦ គ.ស. ២០១២

www.elibraryofcambodia.org

# មាតិកា

ទំព័រ


អារម្ភកថា .................................................... ណ
បទឧទ្ទិស .................................................... ប
សេចក្តីថ្លែងអំណរគុណ .................................................... ទ
សេចក្តីផ្តើម .................................................... ១
អតីតព្រះមាតាខ្មែរ .................................................... ៣
១_ត្រីពោធិសត្វ .................................................... ១៧
២_ត្រីពោធិសត្វ (មច្ឆជាតក) .................................................... ១៩
៣_ត្រីពោធិសត្វ (មិត្តចិន្តីជាតក) .................................................... ២០
៤_ត្រីពោធិសត្វ (ពកជាតក) .................................................... ២២
៥_ហង្សពោធិសត្វ (ហំសជាតក) .................................................... ២៣
៦_ស្តេចហង្ស និងព្រះរាជា .................................................... ២៥
៧_រាជហង្សពោធិសត្វ (ជវនហំសជាតក) .................................................... ២៨
៨_សុវណ្ណហង្ស(សុវណ្ណហំសជាតក) .................................................... ៣០
៩_ហង្សពោធិសត្វ(នច្ចជាតក) .................................................... ៣២
១០_ក្អែកពោធិសត្វ (កាកជាតក) .................................................... ៣៤




www.elibraryofcambodia.org

១១_ក្អែកពោធិសត្វ(សុបត្តជាតក) ..............................៣៨
១២_ក្អែកទឹកពោធិសត្វ(វីរកភាព) ..............................៤១
១៣_សេកពោធិសត្វ (មង្គលត្ថទីបនីប្រែ) ..............................៤៣
១៤_សេកពោធិសត្វ (មង្គលត្ថទីបនីប្រែ) ..............................៤៤
១៥_ស្តេចសេកពោធិសត្វ សត្វមៀម
និងសារិកា (តេសកុណជាតក) ..............................៤៦
១៦_ស្តេចសេកពោធិសត្វ (សាលិកេទារជាតក) ..............................៥៣
១៧_សេកពោធិសត្វ..............................៥៩
១៨_សេកពោធិសត្វ(សុវកជាតក) ..............................៦០
១៩_ក្ងោកមាសពោធិសត្វ(មោរជាតក) ..............................៦២
២០_ស្តេចក្ងោកពោធិសត្វ(មហាមោរជាតក) ..............................៦៥
២១_ស្វាពោធិសត្វ (មហាកបិជាតក) ..............................៦៩
២២_ស្វាពោធិសត្វ (មហាកបិជាតក) ..............................៧០
២៣_ស្វាពោធិសត្វ (មហាកបិជាតក) ..............................៧៤
២៤_ស្វាពោធិសត្វ(វានរិន្ទជាតក) ..............................៨៤
២៥_ស្វាពោធិសត្វ (គរិហិតជាតក) ..............................៨៦
២៦_ស្វាពោធិសត្វ (ទឡ្ហបានជាតក) ..............................៨៨



www.elibraryofcambodia.org

២៧_ស្វាពោធិសត្វ (តិន្ទុកជាតក) ..................................៩១
២៨_ត្មាតពោធិសត្វ (គិជ្ឈជាតក) ..................................៩៣
២៩_ត្មាតពោធិសត្វ (ទុកនិបាត) ..................................៩៥
៣០_កូនក្រួចពោធិសត្វ ..................................៩៧
៣១_កូនក្រួចពោធិសត្វ ..................................៩៩
៣២_កូនក្រួចពោធិសត្វ (វដ្តកជាតក) ..................................១០២
៣៣_ចាបជៀបកប្បាស ..................................១០៧
៣៤_ចាបពោធិសត្វ ..................................១១២
៣៥_ចាបពោធិសត្វ ..................................១១៣
៣៦_ចាបពោធិសត្វ ..................................១១៥
៣៧_ព្រាបពោធិសត្វ ..................................១១៦
៣៨_ព្រាបពោធិសត្វ (រោមជាតក) ..................................១២០
៣៩_រឿងសត្វមៀម (ឧលូកជាតក) ..................................១២២
៤០_រឿងសត្វមៀម ..................................១២៤
៤១_កង្កែបស្តាប់ធម៌ ..................................១២៥
៤២_កង្កែបខៀវ (ហរិតមណ្ឌូកជាតក) ..................................១២៦
៤៣_ស្តេចមាន់ព្រៃ (កុក្កុដជាតក) ..................................១២៨



www.elibraryofcambodia.org

៤៤_ស្តេចមាន់ព្រៃ និង សំពោច(កុក្កុដជាតក).........១៣០
៤៥_ទទាពោធិសត្វ(តិត្តិរជាតក).............................១៣១
៤៦_បក្សីព្រៃ(អនុសាសិកជាតក).............................១៣២
៤៧_ស្តេចបក្សី(យតាសនជាតក).............................១៣៤
៤៨_បក្សីអាចម៍បំណះ(សកុណគ្ឃជាតក)...............១៣៥
៤៩_បក្សីត្រសេះ(កន្ទគលកជាតក)..........................១៣៦
៥០_ត្រសេះពោធិសត្វ(ជវសគុណជាតក)...............១៣៨
៥១_គ្រលេងគ្រលោងពោធិសត្វ(កុដិទុសកជាតក)..១៣៩
៥២_ប្រវឹក(ចក្កវាកជាតក)...........................................១៤០
៥៣_សត្វភេពីរ.........................................................១៤៣
៥៤_កំប្រុកពោធិសត្វ..................................................១៤៤
៥៥_ការសេពនិងមិនសេព ពាលនិងបណ្ឌិត............១៤៥
សេចក្តីសន្និដ្ឋាន.........................................................................១៤៩
អត្ថបទបន្ថែម:
_របាំក្អែកប៉ៃលិន...........................................................១៥៦
_ព្រះបដិមា ព្រះនាងឥន្ទ្រទេវី និងជ័យរាជទេវី..........១៦១
_ផែនប្រាសាទចង្អុលទីតាំងនៃរូបចម្លាក់នាដកា.........១៦៥



www.elibraryofcambodia.org

# មាតិការរូបភាព

## I. ប្រាសាទតាព្រហ្ម ទំព័រ


លេខ១ រូបត្រី ...................................................... ១៧១

លេខ២ រូបកង្កែប ................................................ ១៧២

លេខ៣ រូបប្រវឹក ................................................ ១៧៣

លេខ៤ រូបគ្រលេងគ្រលោង .................................. ១៧៤

លេខ៧ រូបទទា .................................................. ១៧៥

លេខ៨ រូបមាន់ .................................................. ១៧៦

លេខ៩ រូបត្រសេះ ................................................ ១៧៧


## II. ប្រាសាទព្រះខ័ន


លេខ១០ រូបស្វា ................................................ ១៧៨

លេខ១២ រូបក្ងោក( បើកពង់) .................................. ១៧៩

លេខ១៤ រូបក្រាប ................................................ ១៨០

លេខ១៥ រូបហង្ស ................................................ ១៨១

លេខ១៦ រូបក្ងោក( កន្ទុយវែង) ................................ ១៨២

លេខ១៨ រូបសេកពីរ ............................................ ១៨៣

លេខ២១ រូបចាបប្រចៀច ...................................... ១៨៤





www.elibraryofcambodia.org

លេខ២២ រូបភ្នាត.......................................................១៨៥

លេខ២៣ រូបចាបជៀបកប្បាស..........................................១៨៦

III. ប្រាសាទបាយ័ន

លេខ៣០ រូបព្រាប និង ក្អែក..........................................១៨៧

លេខ៣៧ រូបភេពីរ.....................................................១៨៨

IV. ប្រាសាទបន្ទាយក្តី

លេខ៤១ រូបភ្នាត.......................................................១៨៩

V. ប្រាសាទតាសោម

លេខ៤៨ រូបកូនក្រួច...................................................១៩០

លេខ៤៩ រូបកូនមៀម.................................................១៩១

លេខ៥០ រូបកំប្រុក....................................................១៩២

លេខ៥៣ រូបក្អែកពីរ...................................................១៩៣

VI. ព្រះបដិមា

លេខ៣៨ រូបព្រះនាងឥន្ទ្រទេវីរាំ..?.(ប្រាសាទបាយ័ន)....១៩៤

លេខ៥៤ រូបព្រះនាងឥន្ទ្រទេវី..?.(ប្រាសាទព្រះខ័ន)......១៩៥

លេខ៥៥ រូបព្រះនាងជ័យរាជទេវី.?.(ប្រាសាទព្រះខ័ន)...១៩៦



www.elibraryofcambodia.org

លេខ៥៦ រូបព្រះបាទជ័យវរ្ម័នទី៧ ព្រះនាងជ័យរាជទេវី.?
(ប្រាសាទបាយ័ន)............................................................១៩៧
រូបបង្រួមតូចៗ..........................................................១៩៨



www.elibraryofcambodia.org

# ឯកសារយោង

-កុល ផេង : ២០០៨, *មាគ៌ាជីវិតរបស់ព្រះពោធិសត្វ*, ភ្នំពេញ។

-កែវ ណារុំ : ១៩៩៥, *តន្ត្រី និងជីវិតខ្មែរ*, ភាគ១, រោងពុម្ពមិត្តភាពកម្ពុជា_ជប៉ុន, ភ្នំពេញ។

-**ក្រុមជំនុំព្រះត្រៃបិដក សុត្តន្តបិដក** ខុទ្ទកនិកាយជាតក លេខ៥៩ ប្រែពីភាសាបាលីមកខ្មែរ, ១៩៩៤, ភ្នំពេញ។

-**ក្រុមជំនុំព្រះត្រៃបិដក សុត្តន្តបិដក** ខុទ្ទកនិកាយជាតក, ១៩៩៤, អដ្ឋកថា( អធិប្បាយ) ជាភាសាខ្មែរដោយលោក លីម លឿម៖ សត្តមភាគ លេខ៥៨, អដ្ឋមភាគ លេខ៥៩, នវមភាគលេខ៦០។

-ជួន ណាត : ១៩៦៧, *វចនានុក្រមខ្មែរ, ភាគ១_២*, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ។

-ឈឹម ក្រុច : ១៩៤០, *កតញ្ញូគុណ*, ភ្នំពេញ។

-ត្រឹង ងា : ១៩៧២, *ប្រវត្តិសាស្ត្រខ្មែរ*, ភាគ១_២, ភ្នំពេញ។

-ធៀវ វិចិត្រ : ២០១០, *ចម្លាក់រឿងជាតក*, សារណាបញ្ចប់បរិញ្ញាប័ត្របុរាណវិទ្យា, ភ្នំពេញ។

-ពេជ្រ ជុំក្រវិល : ២០០១, *របាំខ្មែរ*, ភ្នំពេញ។

-មីសែល ត្រាណេ : ១៩៩៦, *ព្រះបាទជ័យវរ្ម័នទី៧*, ភ្នំពេញ។

២០០៣, *ប្រវត្តិសាស្ត្រនៃកម្ពុជា សង្គមខ្មែរក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧*, ភ្នំពេញ។



www.elibraryofcambodia.org

២០០៦, *ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជទេស ពីស.វទី៩ _ ស.វទី១៣ នៃគ.ស,* ភ្នំពេញ។
២០០៨, *ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា វប្បធម៌ អារ្យធម៌សម័យបាយ័ន ស.វទី១២ ដើមស.វទី១៣, ភាគ១,* ភ្នំពេញ។
_*ព្រះបាទជ័យវរ្ម័នទី៧ ព្រះមហាក្សត្រគំរូ,* អក្ខរបទស្រាវជ្រាវ។
_យិនយឿន : ១៩៩៥, *មង្គលត្ថទីបនី,* ប្រែភាគ២, ភ្នំពេញ។
_លីម លឿម : *កំប្រុកពោធិសត្វ*, និទានកថា។
_វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យភ្នំពេញ, *ធម្មបទដ្ឋកថា,* ប្រែពីភាសាបាលីមកខ្មែរ អដ្ឋកថាដោយលោក លីម លឿម។
_សរ សារុន : ១៩៧០ , *វប្បធម៌និងអារ្យធម៌ខ្មែរ, ភាគ១_២,* ភ្នំពេញ។
_អ៊ុជ មាន : ១៩៧៤, *ព្រះពុទ្ធសាសនា និងសង្គមកម្ពុជា,* កម្ពុជសុរិយា, លេខ៧, ពុទ្ធសាសនបណ្ឌិត, ភ្នំពេញ។
_ឯក ញ៉ម : ១៩៥៦, *មង្គលសូត្រ ៣៨ ប្រការ,* សៀមរាប។



www.elibraryofcambodia.org

# ជីវប្រវត្តិសង្ខេប

អ្នកស្រី **កែវ ណារុំ** បណ្ឌិតទស្សនវិជ្ជា វិទ្យាសាស្ត្រសិល្បៈ (២០១០)
កើតថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ១៩៤៦ សង្កាត់លេខ៣ ក្រុងភ្នំពេញ
ឪពុកនាម : **កែវ ជួព** ស្នងការនគរបាល (ស្លាប់សម័យប៉ុលពត)
ម្តាយនាម : **ជុំ សំប៊ុន** មេផ្ទះ (ស្លាប់សម័យប៉ុលពត)
ប្តីនាម : **ពត ឡុងឌី** អនុបណ្ឌិតតន្ត្រីសកល ឆ្នាំ ១៩៧០
នៅអភិរក្សដ្ឋានតន្ត្រីជាន់ខ្ពស់នៃទីក្រុងប្រាក (ស្លាប់សម័យប៉ុលពត)
កូន៤នាក់ (ស្លាប់) និងបងប្អូន ៨ នាក់ (ស្លាប់៧នាក់សម័យបុលពត)

## គ្រឿងឥស្សរិយយស

- ២០០៤-២០០៥ : ទទួលសញ្ញាប័ត្រកិត្តិយសជាវរៈសិល្បការិនី ផ្តល់ដោយ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។ ឯកទេស: មានទេពកោសល្យការងារស្រាវជ្រាវ សិល្បៈ-វប្បធម៌ និងតន្ត្រី។
- ២០០៦ : ទទួលសញ្ញាប័ត្រកិត្តិយសជាអ្នកអភិរក្សវប្បធម៌-សិល្បៈខ្មែរ ផ្តល់ដោយរាជបណ្ឌិតសភាកម្ពុជា។ ឯកទេស: មានទេពកោសល្យស្រាវជ្រាវតន្ត្រីខ្មែរ
- ឆ្នាំ២០០៩ : ទទួលមេដាយមុនីសារភណ្ឌាធិបឌិន ផ្តល់ដោយ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។



www.elibraryofcambodia.org

# ស្នាដៃ

**ក – ការងារស្រាវជ្រាវ**


១_ឧបករណ៍តន្ត្រីខ្មែរមួយ

២_តន្ត្រី និង ជីវិតខ្មែរ ភាគ១_២

៣_កម្រងវប្បធម៌ខ្មែរ

៤_កេបកេបកូនល្អ (ល្ខោនសម្រាប់កុមារទម្រង់បាមោទ្ធទ័យ)

៥_របាំអប្សរា

៦_ឧបនិស្ស័យខ្មែរ

៧_មរតកតន្ត្រីខ្មែរ ឬតន្ត្រីនៅប្រទេសខ្មែរ

៨_សន្តិនិទានខ្លីៗ

៩_រឿងព្រេងខ្មែរលើ

១០_ នាដការ និង អ្នករបាំ

១១_នាដកាស្ងួត(មិនទាន់បោះពុម្ព)

១២_រតនតន្ត្រីខ្មែរ(កំពុងចង់ក្រង)


**ខ – រឿងសម្រាប់កុមារ**


១_ក្អែកក្បាលពីរ    ២_ពពកនិងកូនផ្កា

៣_បងប្អូនប្រុសពានាក់    ៤_ដើមទៀប និងដើមស្វាយ

៥_តម្បាញកន្ទែលក្រហមខ្មែរ    ៦_មកុដ និងស្វាញី




www.elibraryofcambodia.org

៧_របាំអប្សរា(សម្រាប់កុមារ) ៨_ល្បែងប្រជាប្រិយខ្មែរ
៩_បឹងយក្សឡោម ១០_ភ្នំជោះក្រមុំ
១១_ប្រាសាទកោះកេរ ១២_ប្រាសាទព្រះវិហារ
១៣_ល្បែងប្រចាំថ្ងៃសម្រាប់កុមារ ១៤_គុណដើមឫស្សី
១៥_ចំរៀងប្រជាប្រិយកុមារ ១៧_ស្ត្រីបីកូនជ្រូក
១៨_សំពត់សូត្រខ្មែរ ១៩_ស្វា និងអារក្សទឹក
២០_សេះនិងចំរៀងចង្រិត ២១_ខ្លាអស់សំណើច
២២_បក្សីមាស ២៣_អំពិលអំពែក
២៤_កូនទា និងម្លូកចំរុះពណ៌ ២៥_ភ្នំបិណ្ឌ
២៦_កំណើតសត្វរំពេ ២៧_ចំរៀងចាបដង្កូវ
២៨_សារិកាស្អប់អ្នកកុហក
២៩_អាចំបាំ និងអាត្នោតចង់បានផ្ទះ(ឬគោចង់បានផ្ទះ).....



www.elibraryofcambodia.org

# អារម្ភកថា

ព្រះសក្យមុនីគោតម ជាព្រះបរមគ្រូនៃពុទ្ធសាសនិកជន ។ ក្រោយពីការត្រាស់ដឹង ព្រះអង្គបានយាងទេសនាសម្ដែងព្រះធម៌ ពន្យល់អស់ពពួកសត្វ មនុស្ស និងទេវតា ប្រាប់នូវរឿងជាតក ពីការដឹងជាតិរបស់ព្រះអង្គ។ ព្រះអង្គជាទស្សនវិទូអច្ឆរិយៈដែលបានលុះនូវញាណវិសេសចាក់ធ្លុះអស់អាថ៌កំបាំង លើស្ថានសួគ៌ ស្ថានកណ្ដាល និងស្ថាននរក។

ព្រះអង្គមិនមែនជាអាទិទេព ដែលអ្នកកាន់សាសនាខ្លះតែងដើរពន្យល់ឱ្យគេជឿតាមនោះទេ។ ព្រះអង្គធ្លាប់មានព្រះបន្ទូលថា តថាគតមិនមែនប្រាប់ឱ្យអ្នកជឿតាមឡើយ តែប្រាប់ឱ្យយល់ពិចារណាដោយបញ្ញា។ ប៉ុន្តែប្រការឱ្យចេះពិចារណា ត្រូវឆ្លងកាត់ចំណេះដឹង និងបញ្ញា។ ទន្ទឹមនេះក៏ត្រូវឆ្លងកាត់បទពិសោធន៍ផងដែរ។

បទពិសោធន៍កន្លងមក ដែលយើងខ្ញុំខិតខំប្រតិបត្តិឈ្វេងយល់តាមគន្លងធម៌ ដោយកសាងតែអំពើល្អ ហើយចៀសចាកអំពើអាក្រក់ ឬអំពើបាបនោះ ពិតជាបានទទួលកុសលដូចប្រាថ្នាមែន។ ប៉ុន្តែអាចទទួលលឿន ឬ យឺតមិនទាន់តាមចិត្ត គឺព្រោះត្រូវទទួលបាបកម្មដែលយើងបានកសាងកន្លងមកសិនដែរ។ នៅពេលទូទាត់បានខ្លះ កុសលកម្មល្អ និងផ្ដល់ផលឱ្យវិញ។ ការកសាងល្អក៏ត្រូវតែ



www.elibraryofcambodia.org

កសាងបន្តជារៀងរហូតប្រៀបដូចយើងសន្សំប្រាក់ដាក់ធនាគារ សម្រាប់ជាតិនេះផង និងសម្រាប់អនាគតជាតិផង។

ពេលឧទ្ទិសប្រាថ្នា សូមកុំឱ្យកើតមានចិត្តលោភ ត្រូវឱ្យចេះល្មមនឹងអ្វីដែលអាចទទួលបាន។ ព្រោះធម៌បីប្រការ គឺលោភៈ ទោសៈ មោហៈនឹងមិនបានធ្វើឱ្យយើងមានសេចក្តីសុខផ្លូវកាយ និងសេចក្តីសុខផ្លូវចិត្តឡើយ។

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១២

**កែវ ណារុំ**



www.elibraryofcambodia.org

# បទឧទ្ទិស

សូមឧទ្ទិសកុសលជូន និងថ្វាយ ចំពោះ៖

- លោកឪពុក **កែវ ជួព** អ្នកម្ដាយ **ជុំម សំប៊ុន**

- អ្នកម្ដាយធំ **ជុំម មន្ដារី** និង **ជា សាមី**

- លោកពូ **ព្រាំ ស៊ីសាពេញ** អ្នកមីង **ស៊ុក ខាន់សាវ៉ា**

មួយអន្លើ ជូនចំពោះលោកតាហ្លួងមហាវិសេសអក្សរ **ជុំម** ដែលបានណែនាំចៅឱ្យមានពន្លកផ្នែកការនិពន្ធ។ ជាពិសេសសូមថ្វាយ និងជូនចំពោះព្រះវិញ្ញាណក្ខន្ធព្រះបាទជ័យវរ្ម័នទី៧ ព្រមទាំងព្រះជាយា និងបុព្វបុរសខ្មែរស្នេហាជាតិទាំងអស់មានជាអាទិ៍ សម្ដេចព្រះសង្ឃរាជជួនណាត និងអ្នកដែលបានពលីកម្មដើម្បីបុព្វហេតុជាតិខ្មែរ។ ជូនញាតិកាទាំងប្រាំពីរសន្ដាន ព្រមទាំងអ្នកដែលជាទីស្រឡាញ់ មានប្ដី កូនប្រុសស្រីទាំង៤នាក់ បងប្អូនប្រុសស្រី៧នាក់ ដែលបានស្លាប់ក្នុងរបបប្រល័យពូជសាសន៍ខ្មែរក្រហម។



www.elibraryofcambodia.org

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ចំពោះ លោកអ្នកដែលបានឧបត្ថម្ភជាថវិកាក្នុងការបោះពុម្ព ក៏ដូចជាការងារស្រាវជ្រាវដោយយកចិត្តទុកដាក់ជាទីបំផុត រហូតបានសម្រេចចេញជាលទ្ធផលនោះ គឺ:

- **សមាគមខ្មែរវិចតូរីយ៉ា នៅប្រទេសអូស្ត្រាលី**
- ឯកឧត្តម **ប៊ិច សុខិន** ទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាធិបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង ជាអភិបាលខេត្តឧត្តរមានជ័យ
- លោក **ជា យូហ៊ន** ទីប្រឹក្សាសាលាក្រុងក្រេធីដាដឹណុង និងលោកស្រី
- លោក **ហូ សម្បត្តិដ៏រុងរឿង** និងលោកស្រី **កែវ មុនី** នៅមែលប៊ន
- លោក **លីម មុយហុង** សមាជិកសភារដ្ឋវិចតូរីយ៉ា លោកស្រី **បុប្ផា លីម** ប្រទេសអូស្ត្រាលី
- លោក ANDER JIRAS (ថតរូបភាព)
- ឯកឧត្តម **បណ្ឌិត មីសែល ត្រាណេ** និងលោកជំទាវ
- ឯកឧត្តម បណ្ឌិត **កុល ផេង**



www.elibraryofcambodia.org

- ឯកឧត្តម **ព្រឿង ប្រណីត**
- លោក **ឃឹម លាងហោ** នៅម៉ៃលប៊ិន
- លោក **សួន វិជ្ជា** នៅម៉ៃលប៊ិន
- លោក **តាំង តេន** នៅម៉ៃលប៊ិន
- ឧបាសិកា **វ៉ាន់ យ៉ាណូរ៉េត** នៅម៉ៃលប៊ិន
- លោក **សួន ប៊ុណ្ណារិទ្ធិ** អង្គការសិល្បៈអម្រឹតា នៅភ្នំពេញ
- **អង្គការ យេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា** នៅភ្នំពេញ

ជាពិសេសអរគុណចំពោះលោកកូន **លឹម លឿម** មន្ត្រីនៃក្រុមជំនុំព្រះត្រៃបិដកនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ប្អូនស្រី **កែវ ចន្ធរី ព្រំ ស៊ីសាផាន្នា** ព្រមទាំងកូនក្មួយ **មួន សុភាព ហ៊ី ចិន្តា កាអម មាសរក្សអង្គារ៉ា ចាន់ សោភ័ណ ហ៊ម វុទ្ធី សៀង វិបុត្រ ហ៊ុយ សាណង់ អ៊ុំ ម៉េង សំណាង សំណាក់ ណេង កន្និដ្ឋា លួន ស្រីខួច**។

ម្យ៉ាងវិញទៀត នាងខ្ញុំសូមបួងសួងនិងជូនកុសលចំពោះអ្នកទាំងអម្បាលមានដែលបានជួយក្នុងការកសាងសៀវភៅនេះ សូមឱ្យបានជួបតែព្រះពុទ្ធ ព្រះធម៌ ព្រះអរិយសង្ឃ ទទួលបានសេចក្តីសុខខាងផ្លូវកាយ ខាងផ្លូវចិត្ត និងសេចក្តីចម្រើនចំណេះដឹង ទ្រព្យសម្បត្តិ បុណ្យសក្តិ កិត្តិយស ចាប់ពីពេលនេះតរៀងរហូតដល់អនាគតជាតិផង។



www.elibraryofcambodia.org



ព្រះបាទជ័យវរ្ម័នទី៧



www.elibraryofcambodia.org

# សេចក្ដីផ្ដើម

ចាប់ពីសតវត្សទី១នៃគ្រីស្តសករាជ រហូតមកដល់សម័យអង្គរ ព្រះរាជាខ្មែរភាគច្រើនគោរពព្រហ្មញ្ញសាសនា។ តែក៏មានព្រះរាជាតិចតួចគោរពប្រណិប័តន៍ព្រះពុទ្ធសាសនា ក្នុងនោះមានព្រះរាជាដែលមានព្រះនាមល្បីល្បាញមួយព្រះអង្គ គឺព្រះបាទជ័យវរ្ម័នទី៧ ព្រះអង្គគោរពប្រណិបត័តន៍ព្រះពុទ្ធសាសនាមហាយាន គ្រីស្តសករាជ ១១៨១ _ ១២១៨។

ទន្ទឹមនោះ ព្រះនាងឥន្ទ្រទេវីដែលជាព្រះជាយា បានជួយកិច្ចការព្រះស្វាមី ទាំងការងារអាណាចក្រ និង ពុទ្ធចក្រ។ ភស្តុតាងបញ្ជាក់យ៉ាងច្រើន ពិសេសគឺសិលាចារឹកភិមានអាកាស K. ៤៨៥ និពន្ធឡើងដោយព្រះនាងផ្ទាល់ ជាកំណាព្យចំនួន ១០២ ឃ្លា បានចារពីបុណ្យកុសលផ្សេងៗ ព្រមទាំងការងាររបស់ព្រះស្វាមី និងព្រះរាជកន្និដ្ឋា គឺព្រះនាងជ័យរាជទេវីបានកសាង។

ដោយសារសទ្ធាជ្រះថ្លា និងការប្រតិបត្តិធម៌ ព្រះនាងឥន្ទ្រទេវី បានបំពេញការងារយ៉ាងសកម្មតាមគន្លងព្រះពុទ្ធសាសនាជាច្រើន។ ក្នុងនោះមានដូចជា ៖ ការសម្ដែងរឿងដែលបានលើកឡើងពីជាតក (ឃ្លាទី ៧៥) ត្រូវបានព្រះនាងចាត់ចែងឱ្យសម្ដែងដោយក្មេងស្រីទុគ៌ត ឬត្រូវបានម្ដាយឪពុកបោះបង់ចោល (ឃ្លាទី ៧៩_៨០)។ ម្យ៉ាងទៀតក្មេងស្រីទាំងនោះត្រូវបានព្រះនាងផ្ដល់ជាជម្រក ថែទុក



www.elibraryofcambodia.org

ដូចជារាជបុត្រីរបស់ព្រះនាងផ្ទាល់ ហើយបានផ្តត់ផ្គង់ជាសម្លៀក បំពាក់ និងអំណោយជាច្រើន ព្រមទាំងអប់រំឱ្យចេះប្រតិបត្តិសីលទាន តាមរយៈនៃការបំបួសឱ្យទៅជាសីលវតី។

ក្នុងចំណោមរឿងជាតក ៥៤៧រឿង យើងខ្ញុំឃើញមានចម្លាក់ នៅលើផ្តែរទ្វារប្រាសាទ សសរផ្តោប និងនៅលើហោជាងនៃប្រាសាទ ក្នុងរាជព្រះបាទជ័យវរ្ម័នទី៧។ នៅប្រាសាទបន្ទាយសំរែ ប្រាសាទចៅសាយទេវតា ប្រាសាទធម្មានន្ទ ប្រាសាទបេងមាលា... កសាងក្នុង រាជព្រះបាទសូរ្យវរ្ម័នទី២ មានចម្លាក់រឿងទសជាតកខ្លះដែរ។ រឿងព្រះ វេស្សន្តរជាតក ឃើញមានចម្លាក់ច្រើនជាងគេ ហើយក៏មានប្រជាប្រិយ ភាពរហូតដល់បច្ចុប្បន្ន។ ឈុតខ្លះត្រូវបានគេដកស្រង់យកមកសម្តែង ក្នុងសិល្បៈទស្សនីយភាពមាន៖ ល្ខោនបាសាក់ ល្ខោន ឬរបាំព្រះរាជ ទ្រព្យ ដោយចែកចេញជាកណ្ឌ គឺរហូតដល់១៣កណ្ឌ។ ចម្លាក់ដែល យើងខ្ញុំស្រាវជ្រាវនៅក្នុងរចនាប័ទ្មបាយ័ន មានចម្លាក់នាដកាជាមួយ រូបសត្វនានា ក៏យើងខ្ញុំមិនបានយល់ ថាពិតមួយរយភាគរយដែរ ប៉ុន្តែវាអាចជាការពិតច្រើន។

បើយោលតាមរូបនៃនាងនាដកាដ៏ច្រើនចម្លាក់រួមជាមួយសត្វ ផ្សេងៗក្នុងរចនាប័ទ្មបាយ័ន យើងខ្ញុំយល់ថាអាចមានសម្តែងរឿង ជាតកច្រើនទៀត ។ ប្រការនេះយើងខ្ញុំយល់ថានោះគឺជាមធ្យោបាយ ដែលងាយទាក់ទាញចំពោះការអប់រំទូន្មានប្រៀនប្រដៅ...? ដើម្បី ពន្យល់ជាឧទាហរណ៍ ពីការដឹងជាតិកំណើតរបស់ព្រះសមណ-គោតម ធ្លាប់យោនយកកំណើតជាសត្វផ្សេងៗកាលពីអតីតជាតិ។



www.elibraryofcambodia.org

# អតីតព្រះមាតាខ្មែរ

អ្នកសិក្សាស្រាវជ្រាវពីប្រវត្តិរបស់ព្រះបាទជ័យវរ្ម័នទី៧ គ្រីស្តសករាជ ១១៨១_១២១៨ សុទ្ធតែដឹងថា ព្រះអង្គកាន់ព្រះពុទ្ធសាសនាមហាយាន។ តែទោះជាយ៉ាងដូច្នេះក្តី ក៏ព្រះអង្គមិនបោះបង់ចោលពួកព្រាហ្មណ៍ពិសេសព្រាហ្មណ៍បុរោហិត ដែលជាអ្នកប្រាជ្ញ ឬធ្វើទុក្ខបុកម្នេញចំពោះប្រជារាស្ត្រដែលកាន់ព្រហ្មញ្ញសាសនាឡើយ។ មិនតែប៉ុណ្ណោះខាងព្រហ្មញ្ញសាសនានេះ នៅត្រូវបានគេឱ្យតម្លៃដោយមានឆ្លាក់នៅតាមប្រាសាទនានាខ្លះ ពិសេសប្រាសាទបាយ័ន។ មរតកវប្បធម៌របស់ព្រះបាទជ័យវរ្ម័នទី៧ មានយ៉ាងច្រើនឥតគណនាជាងសម័យណាៗទាំងអស់។ ប្រាសាទដែលព្រះអង្គបានកសាងមានជាអាទិ៍៖ ប្រាសាទបាយ័ន ប្រាសាទព្រះខ័ន ឬជ័យស្រី ប្រាសាទតាព្រហ្ម ឬរាជវិហារ ប្រាសាទនាគព័ន្ធ ប្រាសាទបន្ទាយក្តី ប្រាសាទតាសោម ប្រាសាទក្រោលគោ ប្រាសាទក្រោលរមាស ប្រាសាទបន្ទាយព្រៃ... ស្ថិតនៅខេត្តសៀមរាប។ ប្រាសាទព្រះខ័ននៅកំពង់ស្វាយ ខេត្តកំពង់ធំ ប្រាសាទវត្តនគរ ខេត្តកំពង់ចាម ប្រាសាទតាព្រហ្មទន្លេបាទី ខេត្តតាកែវ។ ប្រាសាទបាប៊ួ និង កុដិមហាឥសី នៅខេត្តបុរីរម្យ ប្រាសាទប្រាសាទបន្ទាយតូច នៅខេត្តស៊ីសាកេត ប្រាសាទកំពង់លែង ខេត្ត



www.elibraryofcambodia.org

ពេជ្របុរី ។ ពិសេសប្រាសាទបន្ទាយឆ្មារ[១] នៅខេត្តបន្ទាយមានជ័យ ប្រទេសកម្ពុជា ដែលនៅក្នុងបរិវេណនោះមានប្រាសាទវណបជាច្រើន។ គេសង្កេតឃើញស្ពានបុរាណជាច្រើនកន្លែងមាននៅសេសសល់រហូតដល់បច្ចុប្បន្ន។ រជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ មានសាលាសំណាក់សម្រាប់ឱ្យអ្នកដំណើរស្នាក់បណ្តោះអាសន្នចំនួន ១២១ និងមន្ទីរពេទ្យចំនួន ១០២ កន្លែង និងការងារបណ្តុះបណ្តាលរហូតមានដល់ថ្នាក់ឧត្តមសិក្សាដោយមានមហាវិទ្យាល័យ ៣[២]។

ទស្សនៈស្តីពីការធ្វើបុណ្យដាក់ទានរបស់ព្រះពុទ្ធសាសនាក្នុងពេលនោះ មានដូចជា៖ ការដាក់ទានជាម្ហូបអាហារ បាយទឹក ថ្នាំសង្កូវ សម្លៀកបំពាក់ព្រមទាំងការជីកស្រះ ជីកអណ្តូងទឹក កសាងផ្លូវ វត្តអារាម កុដិ ព្រះវិហារ សាលា ពិតជាផ្តល់ប្រយោជន៍ឱ្យសម្បូរបែបដល់សង្គម។ ឯការសាងប្រាសាទដ៏ច្រើននេះវិញ ក៏ជាមូលហេតុចម្បង និងជាមូលដ្ឋានគ្រឹះនៃពុទ្ធសាសនាផងដែរ។

---

[១]_នៅក្នុងបរិវេណប្រាសាទបន្ទាយឆ្មាររួមមាន៖ ប្រាសាទកំណប់ ប្រាសាទយាយជូ ប្រាសាទតាឃ្លាំង ប្រាសាទតានឹម ប្រាសាទសំណាងតាសុខ ប្រាសាទចិញ្ចឹមត្រី ប្រាសាទតាព្រហ្ម ប្រាសាទបន្ទាយឆ្មារខាងកើត ប្រាសាទបន្ទាយឆ្មារខាងជើង ប្រាសាទបន្ទាយទ័ព ប្រាសាទមេបុណ្យ ប្រាសាទកសិណ.....។

[២]_បណ្ឌិត មីសែល ត្រាណេ, *"ព្រះនាងឥន្ទ្រទេវី និងព្រះនាងជ័យរាជទេវី"*, ទស្សនាវដ្តីវប្បធម៌ និងវិចិត្រសិល្បៈ, ឆ្នាំទី១ លេខ២ ខែកញ្ញា ឆ្នាំ២០០០។



www.elibraryofcambodia.org

បញ្ហានេះបានជួយបំបាត់នូវភាពអវិជ្ជា និងបានកាត់បន្ថយនូវទុក្ខលំបាកផ្សេងៗ។ ព្រះបាទជ័យវរ្ម័នទី៧ បានយកទ្រឹស្តីព្រះពុទ្ធសាសនាមកធ្វើជនទួល់ទល់ទ្រ និង ជាត្រីវិស័យធ្វើឱ្យប្រទេសរីកលូតលាស់។

មនោគមវិជ្ជា ដែលសំដៅលើនិមិត្តរូបនៃសិល្បៈតាមរយៈចម្លាក់ព្រះពោធិសត្វអវលោកេស្វរ[៣] ដែលជាគ្រឿងអាងខាងព្រះពុទ្ធសាសនាមហាយាននោះ បានធ្វើឱ្យប្រជាជនខ្មែរមានជំនឿជឿទុកចិត្តលើខ្លួនឯងឡើងវិញហើយគាំទ្ររាជបល្ល័ង្ក។ ទ្រឹស្តីព្រះពុទ្ធសាសនាបានប្រោសសត្វលោកឱ្យរួចចាកផុតពីភាពអវិជ្ជា ដែលជាប្រភពនៃទុក្ខ ប្រភពនៃទោស ប្រភពនៃភាពក្រីក្រ ហើយនាំឱ្យមានការអភិវឌ្ឍ និង សីលធម៌ថ្លៃថ្នូរ។ ដោយការសន្សំបុណ្យកុសលសម្រាប់បច្ចុប្បន្ននេះផង និងអនាគតជាតិផង ដែលអាចនឹងសម្រេចព្រះនិព្វានក្រោយពេលរំលត់ខន្ធ។

[៣]_ អវលោកេស្វរ ព្រះនាមជាភាសាសំស្ក្រឹត បានចូលមកប្រទេសចិនតាមរយៈពុទ្ធសាសនាមហាយាន នៅសតវត្សទី១ នៃគ្រឹស្តសករាជ។ ចូលទៅប្រទេសជប៉ុនតាមរយៈប្រទេសកូរ៉េ នៅដើម ស.វ.ទី៧នៃគ្រឹស្តសករាជ។ គេឃើញរូបព្រះពោធិសត្វអង្គនេះ នៅក្នុងរជ្ជកាលសុង(គ.ស. ៩៦០_ ១២៧៩) ជារូបមនុស្សប្រុស។ ក្រោយមកគេបង្ហាញរូបភាពជាប្រុសផង ស្រីផង។ ដោយហេតុថា ព្រះអង្គជានិមិត្តរូបនៃធម៌មេត្តា និងករុណា ជាម្ចាស់នោះ ចាប់ពីស.វ.ទី១២ ព្រះរូបនេះបានតំណាងដោយរូបស្រីគ្រងសំពត់សដែលប្រទេសខ្លះគេនិយមហៅថា "ព្រះនាងគង់ស៊ីអ៊ឹម"។



www.elibraryofcambodia.org

ពុទ្ធសាសនាមហាយានទាក់ទាញពុទ្ធសាសនិកជនឱ្យមើលឃើញស្ថានសួគ៌ដែលជាទីសុខសាន្ត និងមានលក្ខណៈសប្បាយ។ កំពូលព្រហ្មមុខបួន តែងសម្លឹងមើលមកសត្វលោកក្នុងក្តីមេត្តា ករុណា មុទិតា និង ឧបេក្ខា។ ពេលយើងឡើងទៅឈរនៅជិតមុខព្រហ្មធ្វើឱ្យយើងសុខស្រួលស្បើយពីការនឿយហត់។

ព្រះបាទជ័យវរ្ម័នទី៧ កសាងប្រាសាទបាយ័នមុខបួននេះនៅចំកណ្តាលទីក្រុងអង្គរធំ មានកំពែងព័ទ្ធជុំវិញបួនជ្រុង មួយជ្រុងៗមាន៣គីឡូម៉ែត្រ ព្រមទាំងមានកសិណទឹក ទទឹង១០០ម៉ែត្រ និងមានជម្រៅពី៥ទៅ៦ម៉ែត្រ។ អង្គរធំមានទ្វារប្រាំសម្រាប់ចេញចូលតាមទិសទាំងបួន ដែលត្រូវឆ្លងកាត់ស្ពានថ្មបាយក្រៀម អមដោយរូបចម្លាក់ទេវតា៥៤ និងយក្ស៥៤ កំពុងទាញព្រ័ត្រនៃផ្នែកម្ខាងៗ ដែលផ្នែកខាងកើតមានទ្វារពីរ។ ឯទ្វារជ័យនៅទិសខាងកើតចូលតម្រង់ប្រាសាទភិមានអាកាស តាមផ្លូវទាំងបួនមកប្រសព្វកាត់គ្នានៅចំកណ្តាលទីក្រុងគឺចំប្រាសាទបាយ័ននេះឯង។ ការកសាងប្រាសាទទាំងអស់នេះគឺសម្រាប់ឧទ្ទិស ជាពិសេសថ្វាយចំពោះព្រះពោធិសត្វអវលោកេស្វរៈ និងសម្រាប់បុព្វការីជន មានមាតាបិតាជាដើម ព្រមទាំងសម្រាប់ព្រះអង្គផ្ទាល់ផង។

ឯចម្លាក់វិញមានច្រើនសណ្ឋានគឺ៖ ឈុតខ្លះមានបរិយាយអំពីជីវភាពប្រចាំថ្ងៃរបស់ប្រជាជន ពីប្រពៃណី ពីបរិស្ថានធម្មជាតិនាសម័យនោះ និង រឿងជាតកផ្សេងៗ។ តែប្រការគួរឱ្យចាប់អារម្មណ៍



www.elibraryofcambodia.org

គឺរូបនាងរបាំ ឬទេពអប្សរ(អប្សរា) ដូចជា៖ ប្រាសាទបាយ័ន ប្រាសាទព្រះខ័ន ប្រាសាទតាព្រហ្ម ប្រាសាទតាសោម ប្រាសាទបន្ទាយក្ដី ខេត្តសៀមរាប។ នាងទេពអប្សរ ជួននាងឈរម្នាក់ឯងក្នុងស៊ុំអង្កែលុង ប្រកបដោយទឹកមុខញញឹមស្ងប់ ដៃកាន់កញ្ចក់ឆ្លុះមុខ ដែលមានតិចតួចនៅប្រាសាទតាសោម។ រូបខ្លះគេឃើញមានកាន់តែផ្កាឈូក កាន់កម្រងផ្កាម្លិះ ហើយថែមទាំងមានសត្វប្រតោងលើទងផ្កា ឬ ឈរលើស្មា ឬនាងបីទៅនឹងដៃក៏មាន។ ត្រង់នេះធ្វើឱ្យយើងយល់ថា៖ ទំនងជានាងរក្សាសីលប្រាំ ដែលជាសីលទីមួយក្នុងចំណោមសិក្ខាបទទាំងប្រាំ ?។ ពោល ភាសាបាលីថា៖ **បាណាតិបាតា វេរមណីសិក្ខាបទំ សមាទិយាមិ**។ នេះជាព្រះធម៌ដែលប្រជាជនខ្មែរ ជាអ្នកកាន់ព្រះពុទ្ធសាសនារេះស្ទូត្ររត់មាត់។ ប្រែជាភាសាខ្មែរថា៖ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុ វៀរចាកកិរិយាធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះគន្លងសម្លាប់។

ប៉ុន្តែដោយការមើលឃើញរូបចម្លាក់អ្នករបាំស្រីបីសត្វ ឬសត្វប្រតោង ឬសត្វឈរលើស្មាច្រើនពេក ធ្វើឱ្យយើងនឹកឃើញដល់ឯកសារសិលាចារឹកភិមានអាកាសលេខ K.៤៨៥ ដែលបានរៀបរាប់ពីសកម្មភាពរបស់ព្រះជាយាព្រះបាទជ័យវរ្ម័នទី៧ បានដឹកនាំអ្នករបាំស្រីឱ្យសម្ដែងរឿងល្ខោនជាច្រើនដែលបានដកស្រង់ចេញពីរឿងជាតក។ រឿងជាតកនេះ គឺជារឿងដែលព្រះសក្យមុនីគោតមសម្ដែងព្រះធម៌ទេសនា ដើម្បីពន្យល់ជាឧទាហរណ៍ពីការដឹងជាតិកំណើតរបស់



www.elibraryofcambodia.org

ព្រះអង្គ ធ្លាប់យោនយកកំណើតជាសត្វផ្សេងៗកាលពីអតីតជាតិ។ តាមរយៈការត្រាស់ដឹង ព្រះអង្គបានដឹងរឿងតាំងពីជាតិមុនៗ ពេលដែលព្រះអង្គនៅជាពោធិសត្វ។ ទោះបីព្រះអង្គអន្ទោលកើតទៅជាសត្វក្តី ក៏ព្រះអង្គខំបំពេញបារមី។ ប្រការដែលធ្វើឱ្យយើងយល់ឃើញថានាងនាដការាំរឿងជាតកផ្សេងៗទៀត អាចទំនងជាពិតមែន...? នោះ គឺនៅពេលយើងឃើញអ្នករបាំស្រីម្នាក់ស្លៀកសំពត់តែមួយផ្ទាំងផ្នែកខាងស្តាំ ហើយបីសត្វត្រី។ រូបចម្លាក់នេះឆ្លាក់នៅប្រាសាទតាព្រហ្ម ដែលជាសាកលវិទ្យាល័យឬរាជវិហារសម្រាប់បណ្តុះបណ្តាល។ ឯរូបចម្លាក់ដែលមានរូបសត្វផ្សេងៗ ដោយអ្នករបាំបី ឬដាក់ឱ្យឈរលើស្មានោះ មានច្រើននៅប្រាសាទព្រះខ័ន ដែលតាមសិលាចារឹកថា៖ មានអ្នករបាំស្រីដល់ទៅចំនួនមួយពាន់នាក់។ ឯប្រាសាទបាយ័ន ក៏មានច្រើនដែរ តែច្រើនជារូបសត្វសេក។

រូបអ្នករបាំឆ្លាក់រួមជាមួយសត្វនានា ជារូបចម្លែក ហើយល្អដោយការតុបតែងគ្រឿងអលង្ការ ពិសេសការលំអកេសា ហើយស្លៀកសំពត់ល្អឯក ខុសពីអ្នករបាំទាំងឡាយ។ ប្រសិនបើសត្វនោះជាព្រះពោធិសត្វយោនយកកំណើត ចម្លាក់សត្វត្រូវបានគេឆ្លាក់ឱ្យទំនៅលើស្មា ឬយ៉ាងហោចណាស់ក៏បីនៅនឹងដៃដែរ។ តែយើងឃើញខុសតែកំប្រុកពោធិសត្វ ដែលបានប្រគោងទងឈូកព្រោះមានលក្ខណៈនិងចរិតខុសពីសត្វស្លាប?



www.elibraryofcambodia.org

សិលាចារឹកភិមានអាកាស K.៤៨៥ ដដែល និពន្ធឡើងដោយព្រះនាងឥន្ទ្រទេវី ព្រះនាងបានក្លាយជាព្រះអគ្គមហេសីរបស់ព្រះបាទជ័យវរ្ម័នទី៧ ក្រោយពេលព្រះអនុជរបស់ព្រះនាង គឺព្រះនាងជ័យរាជទេវីបានសោយទីវង្គត។ ព្រះនាងឥន្ទ្រទេវីបានចារឹកសរសើរពីព្រះនាងជ័យរាជទេវី ដោយរៀបរាប់ពីបុណ្យកុសលដែលព្រះរាជកន្និដ្ឋាបានកសាងយ៉ាងច្រើនសន្ធឹកសន្ធាប់។ សិលាចារឹកនេះ មិនមានកាលបរិច្ឆេទទេ។ ក៏ប៉ុន្តែ គេអាចសន្និដ្ឋានថាចារឹកនៅចន្លោះឆ្នាំឡើងសោយរាជ្យរបស់ព្រះបាទជ័យវរ្ម័នទី៧ ចាប់ពី គ.ស. ១១៨១ និងឆ្នាំព្រះអង្គសោយព្រះទីវង្គត។

ក្រោយពីការបួងសួងចំពោះគុណព្រះរតនត្រៃ និងព្រះអវលោកេស្វរៈហើយនោះ មានកំណាព្យ ៣៦ ឃ្លាត្រូវបានឧទ្ទិសចំពោះព្រះបាទជ័យវរ្ម័នទី៧ ព្រមទាំងសន្តតិវង្សរបស់ទ្រង់ និង ការយាងចេញដំណើរទៅកាន់ប្រទេសចម្ប៉ារបស់ព្រះអង្គ (ស្ថិតនៅក្នុងប្រទេសវៀតណាមបច្ចុប្បន្ន) ដើម្បីធ្វើសឹកសង្គ្រាមរំដោះមាតុភូមិពីការគ្រប់គ្រងដោយជនជាតិចាម ។

ផ្ទាំងសិលាចារឹកនេះ បានបង្ហាញថាព្រះនាងឥន្ទ្រទេវីបានដើរតួនាទីយ៉ាងសំខាន់បំផុតរបស់ស្ត្រីក្នុងសង្គមខ្មែរ។ ការពិតអាចជាលើកទីមួយក្នុងប្រវត្តិសាស្ត្រខ្មែរ ដែលគេឃើញមានស្ត្រីដ៏ល្បីល្បាញម្នាក់មានចំណេះដឹងខ្ពង់ខ្ពស់ ហើយមានព្រហ្មវិហារធម៌។ ឯឯកសារចារពីប្រវត្តិរបស់ព្រះនាង និង ព្រះអនុជនៅក្នុងប្រវត្តិសាស្ត្រ



www.elibraryofcambodia.org

នៃប្រទេសកម្ពុជា គឺគេតែងតែទទួលស្គាល់ព្រះនាម ព្រះនាងឥន្ទ្រទេវី ថាជាស្ត្រីខ្មែរដែលមានព្រះនាមល្បីល្បាញក្នុងកម្រិតខ្ពស់បំផុតនាសតវត្សរ៍ទី១២។ ព្រះនាងបានជួយកិច្ចការប្រទេសជាតិជាមួយព្រះស្វាមី ដែលមានលំដាប់តួនាទីជាមេដឹកនាំជាន់ខ្ពស់របស់ប្រទេស។ ព្រះនាងបានរួមចំណែកជួយព្រះស្វាមី ដូចសុភាសិតខ្មែរបុរាណបានចែងថា " សំណាបយោងដី ស្រីយោងប្រុស " ឡើយ។ ព្រះនាងបានជំរុញឱ្យព្រះបាទជ័យវរ្ម័នទី៧ កាន់តែមានអានុភាពខ្លាំងក្លា ល្បីរន្ទឺក្នុងការបង្រួបបង្រួមជាតិ ជីវភាពថ្កុំថ្កើងឡើងវិញក្រោយពីការខ្ទេចខ្ទាំដោយសត្រូវចម្ប៉ានៅ គ.ស ១១៧៧ ។

មុននឹងឈានដល់តំណាក់ការថ្កុំថ្កើង គឺនៅពេលដែលព្រះបាទជ័យវរ្ម័នទី៧ បានយាងតស៊ូដើម្បីឧត្តមប្រយោជន៍ជាតិ។ ព្រះនាងឥន្ទ្រទេវីបានបង្ហាត់ និងណែនាំព្រះអនុជឱ្យបេះប្រណិបត្តិតាមគន្លងធម៌របស់ព្រះពុទ្ធសមណគោតម ។ ដំបូងឡើយព្រះនាងជ័យរាជទេវីបានរក្សាចិត្តភក្តីចំពោះព្រះស្វាមី ដោយការធ្វើទុក្ករកិរិយា គឺតាំងយោគៈតាមប្រពៃណីព្រាហ្មណ៍។ ព្រះនាងបានសម្តែងពីភាពសោកសៅក្រៀមក្រំបំផុតដ៏យូរអង្វែង ដោយធ្វើតបៈ(សមាធិ) និង ចំពោះការអាណិតអាសូរ ព្រមទាំងភាពស្មោះត្រង់ដែលបានឃ្លាតឆ្ងាយពីព្រះស្វាមី ជាទីសក្ការៈរបស់ព្រះនាង។ ក្រោយមកបានប្រែមកអនុវត្តតាមព្រះរៀម គឺប្តូរមកដើរតាមធម៌ព្រះពុទ្ធ ដោយរៀនវិធីមួយអាចមើលឱ្យឃើញរូបព្រះស្វាមីបានពីចម្ងាយផង។



www.elibraryofcambodia.org

ខ្លឹមសារនៃសិលាចារឹកនោះបានចារថា៖ "**ព្រះនាងព្រះ គញ្ញាលនឹងគបធម៌ ស្គាំងស្គមដោយការប្រតិបត្តិធម៌តាម បទបញ្ញត្តិសាសនា(...) កាលបានជួបព្រះស្វាមីដែលជាស្ដេច លើកំពូលស្ដេចទាំងឡាយ** "ព្រះនាងឥន្ទ្រទេវី បានប្រែក្លាយប្អូនស្រីឱ្យទៅជាអ្នកប្រតិបត្តិធម៌តាមគន្លងព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួន ដោយខិតខំធ្វើបុណ្យទានយ៉ាងទូលំទូលាយ។ ឃ្លាបន្ដនៃកំណាព្យត្រូវបានរលុបបាត់ ធ្វើឱ្យពិបាកយល់ន័យ។ ព្រះនាងឥន្ទ្រទេវី បានណែនាំព្រះអនុជស្រីឱ្យប្រកាន់នូវភាពស្ងប់ស្ងាត់ក្នុងចិត្ត និងតាមការប្រៀនប្រដៅរបស់ព្រះពុទ្ធអង្គ ដោយឱ្យចៀសវាងឆ្ងាយ ពីភ្លើងនៃក្ដីកង្វល់នានា។ ហេតុនេះ ព្រះនាងក៏ប្រព្រឹត្តដើរតាមគន្លងព្រះធម៌របស់ព្រះពុទ្ធជាទីសក្ការៈ។

ដោយសារការប្រតិបត្តិធម៌នេះហើយ បានជាក្នុងកែវភ្នែករបស់ព្រះនាង ព្រះនាងបានមើលឃើញនូវរូបភាពរបស់មនុស្សម្នាក់ដែលជាទីស្រឡាញ់បំផុតរបស់ព្រះនាងបានផុសឡើង។ ព្រះរូបនោះគឺព្រះស្វាមីរបស់ព្រះនាងល្អស្រស់ជាងបស្មិៈទៅទៀត។ ក្នុងអារម្មណ៍របស់ព្រះនាង ដែលធ្លាប់ទទួលរងនូវការឈឺចាប់បានប្រែទៅជាកើតក្ដីរំភើបរីករាយ(កំណាព្យឃ្លាទី៥៩_៦២)[៤]។ គេអាចដឹងហេតុការណ៍បន្ថែមថា៖ ព្រះនាងប្រាថ្នាប្រារព្ធពិធីមួយ ដែលព្រះនាងអាច

---

[៤]_សូមបញ្ជាក់ថា៖ ចាប់ពីត្រង់នេះទៅពាក្យជាច្រើននៃកំណាព្យក្នុងសិលាចារឹកត្រូវបានរលុបបាត់ ពិបាកនឹងយល់ន័យ។



www.elibraryofcambodia.org

ដឹងជាមុននូវអ្វីៗនឹងកើតឡើងចំពោះមុខ (ជារូបភាពពេលអវត្តមានព្រះស្វាមី) កំណាព្យពីវឃ្លាបានពណ៌នាថា៖ ប្រសិនបើថ្លើយតបទៅនឹងការអង្វររបស់ព្រះនាង ព្រះស្វាមីរបស់ព្រះនាងនឹងយាងមកប្រទេសវិញភ្លាម ដូចទេវតានិម្មិតឱ្យឃើញតាមរយៈបុណ្យភក្តីភាពដ៏ខ្លាំងក្លាចំពោះព្រះស្វាមី និងដោយកម្លាំងនៃការបន់ប្រាថ្នារបស់ព្រះនាង (ឃ្លាទី៦៣_៦៥)។

ដើម្បីបញ្ជាក់ពីការដឹងគុណចំពោះការបានយាងត្រឡប់មកវិញរបស់ព្រះស្វាមី ព្រះនាងជ័យរាជទេវីបានបង្កើតការងារជួយសង្គ្រោះនិងការគួរឱ្យស្រឡាញ់។ នៅមានសកម្មភាពមួយទៀត ដូចជាការសម្តែងដំណើររឿងដែលបានលើកឡើងពីជាតក (ឃ្លាទី៧៥ នៃកំណាព្យ) ត្រូវបានសម្តែងដោយក្រុមសីលវតីនៃចំណោមក្មេងស្រីទុរគត ឬត្រូវបានម្តាយឳពុកបោះបង់បោល(ឃ្លាទី៧៩_៨០)។ នារីទាំងនោះ ត្រូវព្រះជាយាទទួលយកមកថែទុកដូចជារាជបុត្រីរបស់ព្រះនាងផ្ទាល់ ហើយបានផ្តត់ផ្គង់សម្លៀកបំពាក់ និងអំណោយជាច្រើន ព្រមទាំងទទួលបានការអប់រំឱ្យចេះប្រតិបត្តិសីលទានទៀតផង។ ម្យ៉ាងទៀតព្រះនាងជ័យរាជទេវីបានផ្តល់ជម្រកឱ្យដល់ក្មេងស្រីទុគ៌តតាមរយៈនៃការបំបួសឱ្យទៅជាសីលវតី។

នៅឃ្លាទី៩៤នៃកំណាព្យ ក៏មានការកត់ត្រាដោយអធិប្បាយពីជីវិតរស់នៅ និងស្វាមីភក្តិ ព្រមទាំងកិច្ចការរបស់ព្រះនាងជ័យរាជទេវីរហូតដល់ព្រះនាងយាងចូលព្រះទីវង្គត។ គេអាចដឹងថាព្រះនាង



www.elibraryofcambodia.org

ជ័យរាជទេវីបានសោយព្រះទីវង្គតក្រោយឆ្នាំឆ្លងប្រាសាទតាព្រហ្ម (គ.ស. ១១៨៦) ឬឆ្លងប្រាសាទព្រះខ័ន (គ.ស.១១៩១)។

ក្រោយពេល ព្រះនាងជ័យរាជទេវីយាងចូលព្រះទីវង្គត (ឃ្លាទី៩៣) ព្រះនាងឥន្ទ្រទេវី ដែលជាព្រះរៀមបានឡើងជាអគ្គមហេសីបន្តពីព្រះអនុជ(ឃ្លាទី៩៥)។ ផ្ទាំងសិលាចារឹកដែលសរសេរជាកំណាព្យមាន ១០២ ឃ្លាជាភាសាសំស្ក្រឹតនេះ ថ្វីត្បិតតែត្រូវអន្តរាយយ៉ាងធ្ងន់ធ្ងរក៏ដោយ ក៏នៅបង្ហាញឱ្យឃើញនូវភាសាដ៏ល្អឥតខ្ចោះរបស់ព្រះនាងឥន្ទ្រទេវី ព្រមទាំងទេពកោសល្យផ្នែកអក្សរសាស្ត្ររបស់ព្រះនាង បានចង្អុលបញ្ជាក់ឱ្យឃើញថាការប្រើប្រាស់ជើងកាព្យមានលក្ខណៈដ៏ល្អកម្ររកបាន។

ក្នុងនោះមានអត្ថបទសិលាចារឹក បានចារសរសើរព្រះនាងឥន្ទ្រទេវី ដែលប្រកបដោយព្រះបញ្ញាញាណពីកំណើត មានប្រាជ្ញាខ្ពង់ខ្ពស់ និងទឹកចិត្តបរិសុទ្ធដោយជ្រះថ្លាបំផុត។ ទន្ទឹមនឹងនេះយើងដឹងពីព្រះរាជជីវភាពរបស់ព្រះរាជាខ្មែរនាសម័យបុរាណ ក៏ដូចជាសតិសម្បជញ្ញៈរបស់អ្នកនិពន្ធនៃសិលាចារឹកនេះផងដែរ។

ព្រះនាងឥន្ទ្រទេវី ត្រូវបានប្រសិទ្ធិនាមថាជាប្រមុខសាស្ត្រាចារ្យ ឬជាសាកលវិទ្យាធិការគ្រប់គ្រងមហាវិទ្យាល័យបី។ ព្រះនាងជាអ្នកប្រាជ្ញ ពោរពេញដោយចំណេះដឹងខ្ពង់ខ្ពស់ នេះសបញ្ជាក់ថាប្រទេសកម្ពុជាមានមហាវិទ្យាល័យតាំងពី ស.វ.ទី ១២ នៃគ្រឹស្តសករាជមកម្ល៉េះ។ មហាវិទ្យាល័យទាំងអស់ទំនងជាបង្ហាត់ចំណេះ



www.elibraryofcambodia.org

ខាងនាដសាស្ត្រ តន្ត្រី ចម្លាក់ គំនូរ ស្ថាបត្យកម្ម សុខាភិបាល កសិកម្ម ធារាសាស្ត្រ តារាសាស្ត្រ... ព្រមទាំងទស្សនវិទ្យាបែបពុទ្ធនិយមផងដែរ។ ស្ថានភាពវប្បធម៌បែបនេះ មិនខុសគ្នាប៉ុន្មានពីប្រទេសជឿនលឿននានាក្នុងសម័យបុរាណទេ។ ហេតុការណ៍បន្ថែមទៀត គឺព្រះនាងបានបំពេញភារកិច្ចដ៏ថ្លៃថ្លារបស់ព្រះនាងដូចជាប្រស្នាវតី ដែលជាទេវតាខាងប្រាជ្ញា។

មហាវិទ្យាល័យជេន្ទ្រទុង បានពណ៌នាថាជាមហាវិទ្យាល័យទីមួយ បង្រៀនអំពីសិទ្ធិវិជ្ជានៃលទ្ធិព្រះពុទ្ធសាសនាសម្រាប់នារីខ្មែរ។ មហាវិទ្យាល័យពីរទៀត គឺមហាវិទ្យាល័យនរេន្ទ្រាស្រម(ឬនរិន្ទ្រាអាស្រម) និងមហាវិទ្យាល័យនិលោកុត្តរៈ(ជាធម៌ចម្លងសត្វឱ្យចាកផុតលោក គឺមគ្គបួន ផលបួន និងនិព្វានមួយ)។ មហាវិទ្យាល័យនេះក៏បានអប់រំដល់ស្ត្រីទាំងឡាយ ដោយរៀងរាល់ថ្ងៃព្រះនាងឥន្ទ្រទេវីមិនត្រឹមតែបង្រៀនស្ត្រីក្នុងព្រះរាជវង្សានុវង្ស ឬកូនចៅក្នុងត្រកូលអភិជនប៉ុណ្ណោះទេ។ តែព្រះនាងបានបង្រៀនចំពោះស្ត្រីទាំងឡាយដែលមកពីគ្រួសារសាមញ្ញ។ អ្វីៗដែលបានពោលខាងលើអាចបញ្ជាក់ឱ្យយើងដឹងនូវគុណសម្បត្តិដ៏ធំធេងរបស់ព្រះនាងឥន្ទ្រទេវី នេះជាតួនាទីជាប្រវត្តិសាស្ត្រដែលពុំអាចកាត់ថ្លៃបាន ព្រោះព្រះនាងជាព្រះមាតានៃសង្គមខ្មែរ។

ព្រះមាតាខ្មែរនេះ បានបញ្ជាក់ប្រាប់នូវរូបចម្លាក់អ្នករបាំស្រីដែលយើងខ្ញុំបានស្រាវជ្រាវនៅតាមប្រាសាទក្នុងរបនាប័ទ្មបាយ័ននេះ



www.elibraryofcambodia.org

ទំនងជាកើតមានការរាំនៃរឿងជាតក នៅចុងស.វ. ទី១២ និងដើម ស.វ. ទី១៣ ដែលជាសម័យដ៏រុងរឿងដល់កំពូលនៃ ពុទ្ធសាសនាមហាយាន។ ប៉ុន្តែការឆ្លាក់រូបអ្នករបាំស្រីបីសត្វស្លាប ក៏មាននៅប្រាសាទអង្គរវត្តឧទ្ទិសចំពោះព្រហ្មញ្ញសាសនាដូច្នេះដែរ។ ត្រង់ចំណុចនេះ យើងខ្ញុំសូមបញ្ជាក់ថា ប្រការបីសត្វស្លាបនេះ បានរស់ស្ថិតស្ថេររហូតមកដល់សម័យចតុមុខ(អំឡុងដើមស.វ.ទី២០) ដែលស្ត្រីក្នុងត្រកូលក្សត្រ ឬត្រកូលអភិជននិយមបី ឬកាន់សត្វស្លាប ពិសេសសត្វសេកដែលមានសម្រស់ពណ៌ល្អស្រស់ស្អាតគួរឱ្យបេតី។ ការបីសត្វស្លាបនេះ វាក៏ជាការកំសាន្តផង វាជាមនោសញ្ចេតនានៃការរួមរស់ជាមួយជីវិតដោយគ្មានការបៀតបៀនគ្នា និងជាការលើកសម្រស់ម្ចាស់ឬច្នះបញ្ជាំងឱ្យឃើញពីត្រកូលខ្ពង់ខ្ពស់ ដូចបច្ចុប្បន្នដែលគេដឹកបណ្តើរឆ្កែល្អៗ ...។

រូបចម្លាក់នៃនាងនាដការទាក់ទងនឹងសត្វក្នុងរចនាប័ទ្មបាយ័នទាំងអស់នោះ តាមការសង្កេតឃើញមានឆ្លាក់ច្រើននូវសត្វសេក ហើយក៏មានឆ្លាក់តែ១ ឬ២នូវរូបសត្វស្វា ត្រសេះ...តែទោះជាមានឆ្លាក់រូបតែ១ ឬ២ក្តី ក៏យើងខ្ញុំបានលើកយករឿងដែលទាក់ទងនឹងរូបសត្វនានានោះ មកបរិយាយច្រើនជាងចម្លាក់ ដែលយើងខ្ញុំបានស្រាវជ្រាវរកឃើញក្នុងឯកសារផ្សេងៗ។ ពិសេសក្នុងគម្ពីរព្រះត្រៃបដិកជាដើម ព្រោះជារឿងប្រកបដោយឧត្តមគតិខ្ពស់គួរមនុស្សលោកប្រណិបត្តិតាមដំបូន្មាននៃការប្រៀនប្រដៅរបស់ព្រះពុទ្ធអង្គ



www.elibraryofcambodia.org

ដើម្បីទទួលបានសេចក្ដីថ្លៃថ្នូរ ព្រមទាំងផ្ដល់ឱ្យមនុស្សនូវសេចក្ដីសុខ និងសេចក្ដីចម្រើនទៀតផង។

មុននឹងបរិយាយពីរឿងជាតកជាបន្តបន្ទាប់ យើងខ្ញុំសង្ឃឹមថា ក្នុងនាមជាពុទ្ធសាសនិកជន និងជាអ្នកមានឯកទេសសិល្បៈទាំងអស់ ឬដោយចំពោះអ្នកមានឯកទេសរបាំបុរាណ លោកអ្នកច្បាស់ជានឹងពង្រោះ គឺធ្វើឱ្យរស់ឡើងវិញតាមគន្លងបុព្វបុរស។ ការត្រងត្រាប់តាមនេះ វានឹងជាផលនៃការកសាងកុសល ឬការកសាងអំពើល្អសម្រាប់មនុស្សលោក ដើម្បីឱ្យបានប្រកបដោយសុខសន្តិភាព។



www.elibraryofcambodia.org

# ១. ត្រីពោធិសត្វ

នៅសម័យកាលមួយ មានកើតគ្រោះទុរ្ភិក្សដោយការរាំងស្ងួតគ្មានភ្លៀងបង្អុរមកសោះ។ ឯចំណែកទឹកក្នុងស្រះបោក្ខរណី (ស្រះមានជុះឈូក) នៅក្នុងវត្តជេតពនក៏រីងហួតដែរ ។ បញ្ហានេះបានធ្វើឱ្យពពួកសត្វត្រី ក្តាម ខ្យង ខ្ចៅ... រស់នៅក្នុងទឹកដែលសេសសល់តិចតួចនោះ មានចិត្តភិតភ័យយ៉ាងខ្លាំងព្រោះអាចនឹងមានសត្វបក្សាបក្សី មានក្អែកជាដើម នឹងមកចឹកស៊ីពួកគេមិនខាន។ ពេលទតឃើញយ៉ាងដូច្នេះ ព្រះពុទ្ធអង្គមានសេចក្តីអាណិតមេត្តាដល់ពពួកសត្វក្នុងទឹកយ៉ាងខ្លាំង។ ព្រះអង្គក៏មានព្រះតម្រិះគិតថា៖ តើគួរធ្វើយ៉ាងណាដើម្បីឱ្យមានភ្លៀង? បន្ទាប់មកព្រះអង្គបានមានព្រះបន្ទូលឱ្យព្រះអានន្ទយកសំពត់ងូតដើម្បីស្រង់ទឹក។ តែព្រះអានន្ទបានទូលតបថា៖

-ព្រះអង្គ! ឥតមានទឹកស្អាតទេ គឺមានតែទឹកល្អក់ខ្វល់!

-ព្រះពុទ្ធអង្គមានព្រះបន្ទូលតឿនម្តងទៀត ដោយឱ្យព្រះអានន្ទយកសំពត់ងូត និងសំពត់មួយទៀត ដើម្បីព្រះអង្គឃ្លុំព្រះកេសក៏បណ្តាល ឱ្យក្តៅដល់អាសនៈរបស់ព្រះឥន្ទ្រ។ រំពេចនោះទេវតាដែលជាអ្នកគ្រប់គ្រងទឹកភ្លៀង ឈ្មោះ *វលាហកៈ* ក៏បង្អុរភ្លៀងធ្លាក់ជាបន្ទាន់ភ្លាមដែរ។

ព្រះភិក្ខុសង្ឃទាំងឡាយ មានព្រះទ័យរីករាយយ៉ាងខ្លាំង។



www.elibraryofcambodia.org

ព្រះអង្គជំនុំជជែកគ្នាថា៖ សូម្បីតែក្តៅរាំងប៉ុណ្ណឹងហើយ ក៏ព្រះពុទ្ធអង្គធ្វើឱ្យភ្លៀងធ្លាក់បានដែរ! បន្ទាប់មកព្រះភិក្ខុសង្ឃក៏ទូលសួរព្រះដ៏មានព្រះភាគអំពីមូល ហេតុនេះ ។ ព្រះសមណគោតមបានមានព្រះបន្ទូលថា៖

-កាលតថាគត កើតជាសត្វត្រីក៏ធ្លាប់ជួបប្រទះនឹងគ្រោះរាំងស្ងួតដែរ។ ពេលនោះធ្វើឱ្យញាតិដែលកើតជាត្រីដែរ មានអាការក្តៅក្រហល់ក្រហាយយ៉ាងខ្លាំង។ តថាគត ដែលធ្លាប់តែកាន់សីលមេត្តា ករុណា តែងសង្គ្រោះញាតិ ក៏អធិដ្ឋានបន់ស្រន់ឧទ្ទិសដល់បជ្ជុន: ដែលជាអ្នកគ្រប់គ្រងនៅសម័យកាលនោះ ។ បន្ទាប់មកក៏មានភ្លៀងបង្អុរមកដូចប្រាថ្នា ។

តថាគតកើតជាត្រីមែនពិត តែតថាគតតែងប្រកបដោយសីល គឺមិនដែលយកត្រីគ្នាឯងធីជាអាហារឡើយ ឬសូម្បីសត្វមានជីវិតតូចប៉ុនគ្រាប់អង្ករក៏ដោយ ក៏តថាគតមិនសម្លាប់ដែរ។ ហេតុនេះហើយបានជាតថាគត ធ្វើកិច្ចបួងសួងពីភាពរាំងក្តៅខ្លាំង ព្រមទាំង សួរថា៖

-ហេតុអ្វី ក៏ព្រះវលាហកៈ មិនមើលខ្ញុំផង!



www.elibraryofcambodia.org

## ២. ត្រីពោធិសត្វ (មច្ឆជាតក)[១]

ក្នុងអតីតកាល ព្រះពោធិសត្វកើតជាត្រី មានហ្វូងត្រីជាបរិវារក្នុងបឹងមួយ។ ក្នុងគ្រាមួយនៃដែនទគរគ្មានភ្លៀងសោះ។ ស្រូវដំណាំរបស់មនុស្សក៏ហួតហែង ស្វិតស្រពោន។ ក្នុងបឹងរីងទឹកអស់ពួកត្រីអណ្ដើក រួលត្បុលភក់។ ហ្វូងក្អែកនាំគ្នាមកចឹកទាញស៊ីប្រញាប់។

ព្រះពោធិសត្វឃើញសេចក្ដីវិនាសរបស់ញាតិក៏គិតថា៖ អ្នកដទៃក្រៅអំពីអញ មិនអាចនឹងរំដោះទុក្ខរបស់ញាតិបានទេ។ ពេលនេះអញនឹងធ្វើសច្ចកិរិយាឱ្យភ្លៀងធ្លាក់ដ៏វាបដល់រំដោះទុក្ខពួកញាតិបាន។ ព្រះពោធិសត្វពោលហើយ ក៏ស្ទុះចេញពីភក់មក កាយមានពណ៌ដូចផ្កាអញ្ចាន ធ្មេញក្អែកទាំងពីរប្រៀបបាននឹងកែវមណីពណ៌ក្រហម សម្លឹងមើលអាកាសបញ្ចេញសម្លេងពោលទៅស្ដេចទេវតាទឹកភ្លៀងឈ្មោះបជ្ជុន្នៈថា៖ បពិត្រព្រះបជ្ជុន្នៈដ៏ចម្រើន! ខ្ញុំនិងពួកញាតិអាស្រ័យនៅក្ដៅខ្លាំងណាស់។ ក្នុងពេលទូលបង្គំរក្សាសីលយ៉ាងលំបាក ហេតុដូចម្ដេចលោកមិនជួយឱ្យភ្លៀងស្រក់ចុះមក! ទូលបង្គំកើតក្នុងកន្លែងនេះអាចខាំស៊ីពួកគ្នាឯង តែទូលបង្គំមិនបានស៊ីនូវមច្ឆជាតិដទៃ។ សូម្បីត្រីតូចដែលមានរូបប៉ុនគ្រាប់អង្ករ ក៏ទូលបង្គំមិនបានសម្លាប់ជីវិតរបស់គេឡើយ។ ដោយសច្ចវាចានេះ សូមលោកមេត្តាបង្អុរភ្លៀង

---

[១]- ក្រុមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, សត្តមភាគលេខ ៥៨ ទំព័រ ៣២។



www.elibraryofcambodia.org

ឱ្យស្រក់មក ដើម្បីរំដោះទុក្ខពួកញាតិរបស់ទូលបង្គំ។ ការស្រែកហៅទេវតាបង្ហុនៈ បានពោលជាពាក្យគាថាដូច្នេះថា៖ បពិត្រលោកម្ចាស់! សូមញ៉ាំងទូលបង្គំឱ្យរួចចាកសេចក្ដីសោក! បពិត្រមេឃ សូមអ្នកញ៉ាំងផ្គរឱ្យលាន់ឡើង! សូមបំផ្លាញកំណប់ទ្រព្យរបស់ក្អែកឱ្យវិនាស! ពោលចប់ភ្លៀងក៏បង្អុរមក។

## ៣. ត្រីពោធិសត្វ (មិត្តចិន្តីជាតក)[១]

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជ្យក្នុងនគរពារាណសី ហើយមានត្រីបីក្បាលរស់នៅក្នុងព្រះនគរ។ ត្រីទាំងបីនោះមានឈ្មោះ ពហុចិន្តី អប្បចិន្តី និងមិត្តចិន្តី។ ត្រីទាំងបីបាននាំគ្នាចេញពីទឹកក្នុងព្រៃមកកាន់ដែនទឹកដែលមនុស្សរស់ ។ ត្រីមិត្តចិន្តីប្រាប់ត្រីពីរទៀតថា៖ ដែនដីមនុស្សពេញដោយក្ដីរង្កៀស មានភ័យចំពោះមុខណាស់។ ពួកអ្នកនេសាទ តែងតែបង់សំណាញ់ វាយមង អួសអួន និងប្រការផ្សេងៗ ទៀតដើម្បីចាប់យកត្រី ។ ពួកយើងកុំទៅអី! គួរតែត្រឡប់ទៅក្នុងព្រៃវិញ ។ តែត្រីពហុចិន្តី និងអប្បចិន្តី នៅតែរឹងចចេសហែលទៅមុខ ហើយនិយាយថា៖ កុំអាលសិន! ពួកយើងនឹង

---

[១] - ក្រុមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, សត្តមភាគលេខ ៥៨ ទំព័រ ៥១។



www.elibraryofcambodia.org

ត្រឡប់ទៅព្រៃជាមួយគ្នាវិញនៅព្រឹកថ្ងៃស្អែក ។... ព្រោះតែក្តីចចេស ពីមួយថ្ងៃទៅមួយថ្ងៃ ពួកគេបានរស់នៅរហូតអស់រយៈពេលបីខែ។

ថ្ងៃមួយ ត្រីទាំងបីបានចេញទៅរកអាហារ ។ ត្រីពហុចិន្តី និង អប្បចិន្តី គិតតែពីនាំគ្នាហែលទៅខាងមុខ ដោយមិនបានកំណត់ក្លិន អួនសោះ ។ ព្រោះតែក្តីល្ងង់ ក៏ធ្លាក់ចូលទៅក្នុងអួនដែលអ្នកនេសាទ នាំគ្នារាយ ។ ឯត្រីមិត្តចិន្តីមកតាមក្រោយ អាចកំណត់ក្លិនអួនបាន ដឹងថាត្រីទាំងពីរនោះធ្លាក់ចូលទៅក្នុងអួនហើយ ។ គេគិតថាយើង នឹងឱ្យជីវិតដល់ត្រីវង្វេងចចេសទាំងពីរនោះចុះ! ហើយក៏ហែលទៅ ខាងក្រៅអួន ធ្វើឱ្យទឹកក្អួចបណ្តាលឱ្យផ្អើលអួនដាច់ ។ ពួកអ្នកនេសាទ បានដឹងថា ត្រីនាំគ្នាទម្លាយអួនហើយ ទើបនាំគ្នាចាប់ជាយអួនលើក ឡើង ត្រីទាំងពីរក៏បម្រះរបូតចេញពីអួនរួចខ្លួនធ្លាក់ទៅក្នុងទឹក ។ នេះគឺអាស្រ័យដោយត្រីមិត្តចិន្តីជួយ ទើបមានជីវិត។

ព្រះសាស្តានាំយករឿងនិទាននេះមកទេសនាឱ្យស្តាប់ ទើប ត្រាស់គាថាថា៖ គឺត្រីពហុចិន្តី និងអប្បចិន្តីជាប់ក្នុងអួន ឯត្រីឈ្មោះ មិត្តចិន្តីបាននាំឱ្យចាកផុតអួន ហើយបានមកព្រមជាមួយគ្នានឹងត្រីមិត្ត ចិន្តី ដែលធ្លាប់រស់នៅក្នុងទឹកជាមួយគ្នា។



www.elibraryofcambodia.org

## ៤. ត្រីពោធិសត្វ (ពកជាតក)[៧]

ក្នុងកាលកន្លងទៅព្រះពោធិសត្វបានកើតជាសត្វត្រីមានបរិវារជាច្រើនរស់នៅក្នុងស្រះមួយនាហេមវន្តប្រទេស។ គ្រានោះមានកុកមួយក្បាលគិតថាអញនឹងស៊ីត្រី ទើបឈរងើយក្បាលសម្រួបស្លាបមិនខ្វល់ខ្វាយសម្លឹងមើលត្រីក្នុងទីជិតៗ។ ខណៈត្រីពោធិសត្វ មានត្រីច្រើនចោមរោមរកសត្វល្អិតស៊ីបានទៅដល់ទីនោះ ហ្វូងត្រីឃើញកុកនិយាយថា៖ សត្វស្លាបនេះស្រួលបួលពេកប្រៀបដូចផ្កាឈូកមានស្លាបទាំងពីរសម្រួបហើយឈរសំកុកហាក់ដូចជាមិនមានកម្លាំង។ ត្រីពោធិសត្វនិយាយថា៖ អ្នកទាំងឡាយមិនដឹងច្បាស់ល្បិចកុកនោះទេ។ អ្នកទាំងឡាយនាំគ្នាសរសើរចំពោះសត្វស្លាបដែលមិនមែនជាអ្នករក្សាពួកយើងហេតុដូច្នេះទើបសត្វស្លាបនោះរឹតតែមិនកម្រើកខ្លួន។

---

[៧]- ក្រុមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, សត្តមភាគលេខ ៥៨ ទំព័រ ១២៦។



www.elibraryofcambodia.org

## ៥. ហង្សពោធិសត្វ (ហំសជាតក)[១]

សម័យកាលមួយ គ្រាដែលព្រះពោធិសត្វយោនយកកំណើតជាស្តេចហង្សបានជាប់អន្ទាក់ ពួកបក្សីជាញាតិបានហោះហើរចោលទៅ។ តែមានហង្សមួយឈ្មោះ សុមុខៈ ដែលមានសម្បុរដូចមាស ពុំព្រមហោះចោលស្តេចហង្សឡើយ[២]។

ស្តេចហង្ស ៖

_ពួកហង្សមានក_ក្ងក់ទាំងនោះ លុះត្រូវភ័យគ្របសង្កត់ហើយ ក៏ហើរអស់ទៅ។ ពួកបក្សីជាញាតិបានលះបង់យើងដោយឥតអាឡោះអាល័យ ខុសតែខ្លួនអ្នកតែម្នាក់ឯងសម្ងំនៅ។ ឯការដើរហើរចេញទៅរបស់ពួកសត្វស្លាបវាជាការប្រសើរ។ ឯការប្រព្រឹត្តនៅជាមួយអ្នកជាប់ចំណងមិនជាការប្រសើរទេ។ ចូរអ្នកកុំធ្វើសេចក្តីព្យាយាមឱ្យសាបសូន្យ។ ម្នាលសុមុខៈ ចូរអ្នកភៀសខ្លួនចេញទៅ!

សុមុខៈហង្ស ៖

_បពិត្រស្តេចហង្សឈ្មោះ ធតរដ្ឋ ព្រះអង្គត្រូវសេចក្តីទុក្ខ

---

[១] _ក្រមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតកលេខ ៥៩, ១៩៩៤, ទំព័រ ៦០។

[២] _គឺជាការនិទានរបស់សត្វហង្ស ថ្វាយចំពោះព្រះរាជាមួយអង្គ ដើម្បីព្រះអង្គបានជ្រាប។



www.elibraryofcambodia.org

គ្របសង្កត់ខ្ញុំព្រះអង្គមិនលះបង់ចោលព្រះអង្គទេ។ ការរស់ ឬការស្លាប់របស់ខ្ញុំព្រះអង្គនឹងមាននៅជាមួយព្រះអង្គ។

ស្ដេចហង្ស ៖

-ម្នាល សុមុខៈ អ្នកពោលនូវពាក្យនេះ ជាពាក្យល្អរបស់អរិយជន។ ចំណែកខាងខ្ញុំ ខ្ញុំចង់ល្បងមើលអ្នក ទើបពោលពាក្យយ៉ាងនេះ។

-កូនព្រានព្រៃពោលថា ៖ សត្វបក្សី ជាសត្វត្រាច់នៅក្នុងអាកាសរមែងទៅតាមផ្លូវអាកាស។ ចុះហេតុអ្វីបានជាអ្នកមិ‌ៃ.ទៅតាមផ្លូវអាកាស? អ្នកដ៏ប្រសើរជាងពួកបក្សី ហេតុយ៉ាងម៉េចបានជាអ្នកមិនដឹងថាមានអន្ទាក់ពីចម្ងាយ ?

ស្ដេចហង្ស ៖

-បើសេចក្ដីវិនាសនឹងមានមក កាលបើជីវិតនឹងត្រូវអស់នោះរមែងមិនដឹងថាមានអន្ទាក់ ឬសំណាញ់ឡើយ។

កូនព្រានព្រៃពោលទៅកាន់សុមុខៈហង្សថា៖ ពួកបក្សីមានក-ក្ងក់ទាំងនោះ លុះត្រូវភ័យគ្របសង្កត់ហើយ ក៏ហើរអស់ទៅ។ ឯអ្នកមានស្បែកខៀវ មានរោមដូចមាស ម្ដេចអ្នកឯងសម្ងំនៅ ? ពួកបក្សីទាំងអស់ជាសត្វហើរតាមអាកាស ហើរទៅដោយឥតមានអាល័យ ពេលស៊ីផឹកហើយក៏ហើរចេញទៅ។ មានតែអ្នកម្នាក់ឯងហើរចូលមកវិញ តើបក្សីនេះត្រូវជាអ្វីនឹងអ្នក ?

សុមុខៈហង្ស ៖



www.elibraryofcambodia.org

-បក្សីនេះ ជាស្តេចរបស់យើងផង ជាមិត្តរបស់យើងផង ជាសម្លាញ់ស្មើជីវិតរបស់យើងផង ។ ខ្លួនយើងនឹងមិនលះបង់បក្សីនេះដរាបដល់អស់ជីវិត។

កូនព្រានព្រៃ ៖

-អ្នកណាប្រាថ្នាលះបង់ជីវិត ព្រោះហេតុមិត្តសម្លាញ់ យើងនឹងលែងមិត្តសម្លាញ់របស់អ្នកក្នុងពេលឥឡូវនេះ ។ សូមឱ្យស្តេចរបស់អ្នកទៅជាមួយនឹងអ្នកចុះ !

សុមុខៈហង្ស ៖

-ម្នាលព្រានព្រៃ ក្នុងថ្ងៃនេះយើងត្រេកអរណាស់ព្រោះបានឃើញស្តេចរបស់យើងរួចចាកចំណង ។ ឯអ្នកក៏ចូលត្រេកអរជាមួយនឹងពួកញាតិទាំងអស់យ៉ាងនោះដែរ។

## ៦. ស្តេចហង្សនិងព្រះរាជា

ស្តេចហង្ស៖ ព្រះអង្គមានសេចក្តីសុខទេឬ ? ព្រះអង្គមិនមានជំងឺតម្កាត់ទេឬ ? ព្រះអង្គតែងប្រៀនប្រដៅចំពោះអ្នកក្នុងដែនដីដ៏ធំទូលាយនេះតាមធម៌ឬទេ ?

ព្រះរាជា ៖ - ម្នាលហង្ស ! យើងមានសេចក្តីសុខស្រួល និងមិនមានជម្ងឺតម្កាត់អ្វីទេ។ ខ្លួនយើងក៏បានប្រៀនប្រដៅអ្នកក្នុងដែនដីដ៏ធំទូលាយតាមធម៌ដែរ។



www.elibraryofcambodia.org

ស្ដេចហង្ស ៖ _ ពួកអាមាត្យរបស់ព្រះអង្គ មិនបានប្រព្រឹត្ត កំហុសណាមួយទេឬ? ពួកសត្រូវរបស់ព្រះអង្គក្នុងទីឆ្ងាយ ដូចជា ស្រមោលដែលមិនមានក្នុងទិសខាងត្បូងទេឬ?

ព្រះរាជា ៖ _ ពួកអាមាត្យរបស់យើង មិនមានប្រព្រឹត្តកំហុស ណាមួយទេ។ ឯសត្រូវរបស់យើងក្នុងទីឆ្ងាយ ក៏ដូចស្រមោលដែល មិនមានក្នុងទិសខាងត្បូងដូច្នោះដែរ។

ស្ដេចហង្ស ៖ _ ភរិយារបស់ព្រះអង្គមានចិត្តស្មើគ្នា ជាស្រី ស្ដាប់បង្គាប់ព្រះអង្គ ចូលចិត្តស្រដីនូវពាក្យជាទីស្រឡាញ់ បរិបូណ៌ ដោយបុត្រ នឹងរូបសម្បត្តិ យស និងបរិវារ លុះក្នុងអំណាចនៃសេចក្ដី ប្រាថ្នារបស់ព្រះអង្គដែរទេឬ?

ព្រះរាជា ៖ _ ភរិយារបស់យើងមានចិត្តស្មើគ្នា ជាស្រីស្ដាប់ បង្គាប់យើង ចូលចិត្តស្រដីពាក្យជាទីស្រឡាញ់ ប្រកបដោយបុត្រ យស និងបរិវារ លុះក្នុងអំណាចតាមសេចក្ដីប្រាថ្នារបស់យើង។

ស្ដេចហង្ស ៖ _ បពិត្រព្រះអង្គ អ្នកញុំាំងដែនដីឱ្យចម្រើន ព្រះ អង្គមានព្រះរាជបុត្រច្រើន កើតឡើងល្អបរិបូណ៌ដោយសន្ទុះនៃប្រាជ្ញា ស្រុះស្រួលរកគ្នាដែរឬទេ?

ព្រះរាជា ៖ _ ម្នាលស្ដេចហង្សធតរដ្ឋ យើងមានកូនមួយរយមួយ នាក់ ដែលអ្នកជង់ពួស្មុះសាយថា យើងជាអ្នកមានកូនច្រើន។ កូន។ រមែងមិនខឹងនឹងសម្ដីរបស់អ្នកទេ? សូមអ្នកប្រាប់នូវអំពើល្អ ដែល ពួកគេត្រូវធ្វើនោះចុះ។



www.elibraryofcambodia.org

ស្ដេចហង្ស៖_ បុគ្គល បើទុកជាបរិបូណ៌ខ្ពង់ខ្ពស់ដោយជាតិ និងច្បាប់ តែបើក្នុងកាលជាខាងក្រោយ គឺកាលដែលខ្លួនចាស់ តែមិនធ្វើនូវសេចក្ដីព្យាយាមក្នុងកិច្ចការ រមែងលិចចុះក្នុងសេចក្ដីអន្តរាយ។ កាលបុគ្គលចាស់នោះមានចិត្តរវើរវាយ ទោសក៏កើតឡើងយ៉ាងច្រើន។ បុគ្គលចាស់នោះ យើងឃើញបានតែរូបធំ ដូចបុគ្គលងងឹតក្នុងវេលាយប់។ ឯបុគ្គលចាស់ដឹងនូវសេចក្ដីព្យាយាម តែក្នុងលទ្ធិមិនមានខ្លឹម ថាមានខ្លឹម ក៏រមែងមិនបាននូវសេចក្ដីប្រាជ្ញា និងតែងលិចចុះក្នុងសេចក្ដីអន្តរាយមិនខាន។ ដូចជាសត្វ សរភៈ លិចចុះក្នុងជ្រោះនៃភ្នំ។ ចំពោះជនណាមានជាតិថយថោក តែជាអ្នកមានការប្រឹងប្រែងមានប្រាជ្ញាបរិបូណ៌ដោយការប្រព្រឹត្តតាមសីល រមែងរុងរឿងដូចជាភ្លើងក្នុងពេលរាត្រី។ សូមព្រះអង្គធ្វើសេចក្ដីនេះឯងឱ្យជាគ្រឿងប្រៀបធៀប ហើយញ៉ាំងព្រះរាជបុត្រឱ្យប្រតិស្ឋានក្នុងវិជ្ជាទាំងឡាយ ត្បិតអ្នកប្រាជ្ញតែងលូតលាស់ល្អ ដូចពូជ ស្រូវដែលលូតលាស់ក្នុងស្រែ ក្នុងកាលដែលមានភ្លៀង។



www.elibraryofcambodia.org

## ៧. រាជហង្សពោធិសត្វ (ជវនហំសជាតក)[10]

ព្រះរាជាពារាណសីមានព្រះរាជឱង្ការថា៖

-នែហង្ស! ចូរឯងមកទំលើតាំងមាស[11] នេះចុះ ព្រោះពេលដែលអញឃើញឯង អញគិតថាឯងសមគួរជាធំ បើឯងពេញចិត្តរបស់ណាមានក្នុងទីនេះ ចូរឯងប្រាប់មកចុះ។

រាជហង្ស៖

-បុគ្គលខ្លះគ្រាន់តែឮហើយ ស្រឡាញ់ក៏មាន ខ្លះគ្រាន់តែឃើញគ្នាហើយស្រឡាញ់ក៏មាន ខ្លះឃើញផងឮផង ទើបស្រឡាញ់ក៏មាន។ ចុះព្រះអង្គគ្រាន់តែឃើញ តើស្រឡាញ់ខ្ញុំដែរឬទេ?

ព្រះរាជា៖

-អញគ្រាន់តែបានឮស្រឡាញ់ឯងទៅហើយ លុះបានឃើញអញរឹតតែស្រឡាញ់ឡើង។ នែហង្ស! អញឃើញឯងហើយ ស្រឡាញ់យ៉ាងនេះ ចូរឯងនៅក្នុងដំណាក់អញចុះ!

រាជហង្ស៖

-ខ្ញុំនៅក្នុងដំណាក់ព្រះអង្គ ព្រះអង្គធ្វើការបូជាអស់កាល

---

[10]- ក្រុមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតកលេខ ៥៩, ១៩៩៤។

[11]- ពានមាស



www.elibraryofcambodia.org

ជានិច្ច តែក្រែងពេលណាមួយព្រះអង្គស្រវឹងដោយទឹកស្រវឹង ហើយទ្រង់ត្រាស់ថា៖ នាយពិសេស! ចូរចម្អិនសាច់ស្តេចហង្សយកមកឱ្យយើង!

ព្រះរាជា៖

-ថ្មីយ! ខ្លើមផឹកទឹកស្រវឹងណាស់! បើឯងនៅក្នុងដំណាក់អញដរាបណា អញនឹងមិនផឹកទឹកស្រវឹងដរាបនោះ។

រាជហង្ស៖

-សម្តីរបស់ពួកចចក និងពួកបក្សីងាយយល់ណាស់។ តែសម្តីរបស់ពួកមនុស្សកម្រយល់បានជាងសម្តីសត្វនោះទៅទៀត។ ម្យ៉ាងទៀតកាលដើមឡើយបុរសម្នាក់មានចិត្តល្អសម្គាល់ថានោះ ជាញាតិជាមិត្តឬជាសម្លាញ់។ តែលុះដល់ពេលខាងក្រោយត្រឡប់ជាសត្រូវនឹងគ្នាទៅវិញក៏មាន។ សម្លាញ់ណាជាអ្នកមានចិត្តជ្រះថ្លារកគ្នា បើទុកជានៅឯត្រើយសមុទ្រខាងនាយ ក៏ឈ្មោះថានៅក្នុងសមុទ្រជាមួយគ្នា។ សម្លាញ់ដែលមានចិត្តប្រទូស្តគ្នានោះ បើទុកជានៅក្នុងសមុទ្រជាមួយគ្នា ក៏ឈ្មោះថានៅត្រើយសមុទ្រខាងនាយវិញ។ បុគ្គលជាទីស្រឡាញ់រមែងមិនស្រឡាញ់វិញ ព្រោះតែនៅជាមួយគ្នាយូរពេក។ ខ្ញុំសូមថ្វាយបង្គំលាព្រះអង្គទៅវិញ មុនពេលដែលខ្ញុំនៅជាទីស្រឡាញ់របស់ព្រះអង្គ។

ព្រះរាជា៖

-កាលបើយើងអង្វរយ៉ាងនេះ អ្នកមិនទទួលដឹងនូវអញ្ជលីមិនធ្វើតាមពាក្យយើងជាអ្នកបម្រើទេ យើងសូមអង្វរថា៖ អ្នកគប្បីធ្វើនូវការត្រឡប់មកវិញទៀតណា!



www.elibraryofcambodia.org

## ៨. សុវណ្ណហង្ស(សុវណ្ណហំសជាតក)[១២]

ក្នុងសម័យកាលមួយ ព្រះពោធិសត្វបានយោនយកកំណើតក្នុងត្រកូលព្រាហ្មណ៍នៃក្រុងពារាណសី។ កាលព្រះពោធិសត្វមានវ័យពេញកម្លោះ បានរៀបការជាមួយស្ត្រីដែលជាត្រកូលព្រាហ្មណ៍ដូចគ្នា មានឈ្មោះថាព្រាហ្មណី ហើយមានកូនស្រីបីនាក់គឺ៖ នន្ទា នន្ទាវត្តី និងសុន្ទរីនន្ទា។ ក្រោយមកព្រះពោធិសត្វបានធ្វើមរណកាលហើយបានកើតជាសត្វហង្ស មានពណ៌ដូចមាសហៅថាសុវណ្ណហង្ស។

សុវណ្ណហង្សបានពិចារណានូវអត្តភាពរបស់ខ្លួនកើតពីទីណាទើបរលឹកជាតិបានថា ពីជាតិមុនខ្លួនជាព្រាហ្មណ៍ដែលមានភរិយានិង កូនស្រីបីនាក់។ ចំណែកនាងព្រាហ្មណី និងកូនកំពុងរស់នៅក្នុងជីវភាពក្រលំបាកធ្វើការស៊ីឈ្នួលអ្នកដទៃដើម្បីចិញ្ចឹមជីវិត។ សុវណ្ណហង្សកើតមានចិត្តករុណា គិតថាអាត្មាអញជាឪពុកបានស្លាប់ចោលកូនទាំងបីនាក់ និងភរិយាឱ្យគ្នាកំព្រារងទុក្ខវេទនា ចិញ្ចឹមជីវិតសែនលំបាកពេកក្រៃ។ បើដូច្នោះ គួរតែអាត្មាអញទៅជួយសង្គ្រោះដល់កូននិង ភរិយានោះឱ្យមានជីវភាពរស់នៅបានស្រួល។ ក្នុងកាលនោះសុវណ្ណហង្សបានហើរចុះក្នុងគេហដ្ឋានរបស់ភរិយា។ ស្ត្រីទាំងនោះភ្ញាក់ផ្អើលហើយសួរថា៖

---

[១២] - ក្រមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, សត្តមភាគលេខ ៥៨ ទំព័រ ៦០។



www.elibraryofcambodia.org

-អ្នកជានរណា ? មកពីណា ?

សុវណ្ណហង្សប្រាប់ថា៖

-យើងត្រូវជាស្វាមី និងជាឪពុករបស់ពួកនាង !យើងបានស្លាប់ទៅកើតជាហង្សនេះឯង។ យើងមកទីនេះ គឺដើម្បីមកផ្ដល់ទ្រព្យដល់ពួកនាងសម្រាប់ចិញ្ចឹមជីវិត។ សុវណ្ណហង្សក៏បានជម្រុះស្លាបមួយដែលជាមាសសុទ្ធដល់ភរិយានិងកូនស្រីសម្រាប់យកទៅលក់បានប្រាក់ចិញ្ចឹមជីវិត។

សុវណ្ណហង្សតែងតែមកជម្រុះស្លាបមួយៗជារឿយៗ ហើយក៏ហើរទៅវិញបាត់ទៅ។ ស្ត្រីទាំងនោះក៏បានក្លាយជាអ្នកមានទ្រព្យសម្បត្តិស្ដុកស្ដម្ភ មានជីវភាពរស់នៅខ្ពង់ខ្ពស់ លែងធ្វើការជាអ្នកស៊ីឈ្នួលអ្នកដទៃទៀត ដោយសារភាពករុណារបស់សុវណ្ណហង្ស។

ប៉ុន្តែថ្ងៃមួយ នាងព្រាហ្មណីជាម្ដាយ និង កូនស្រីទាំងបីនាក់បានពិភាក្សាគ្នាថា៖ ធម្មតាសត្វតិរិច្ឆានមានចិត្តអាក្រក់ណាស់ ថ្ងៃណាមួយវានឹងលែងយកស្លាបមាសមកឱ្យយើងទៀតហើយ។ បើដូច្នោះមានតែយើងរកឧបាយចាប់សត្វហង្សនេះឱ្យបាន ហើយចាប់បោចយកស្លាបមាសឱ្យអស់ ទុកជាទ្រព្យសម្បត្តិរបស់យើង។ លុះដល់ថ្ងៃកំណត់យកស្លាបមាសមកជម្រុះ សុវណ្ណហង្សក៏បានហើរមកចុះត្រង់គេហដ្ឋានរបស់ស្ត្រីទាំងនោះដូចសព្វដង។ នាងព្រាហ្មណី និង កូនស្រីក៏នាំគ្នាចាប់សុវណ្ណហង្សបាន ហើយបោចយកស្លាបរហូតអស់ពីរាងកាយ។ តែស្លាបដែលបោចបានទាំងនោះ មិនបានក្លាយជាមាស



www.elibraryofcambodia.org

-អ្នកជានរណា ? មកពីណា ?

សុវណ្ណហង្សប្រាប់ថា៖

-យើងត្រូវជាស្វាមី និងជាឪពុករបស់ពួកនាង ! យើងបានស្លាប់ទៅកើតជាហង្សនេះឯង។ យើងមកទីនេះ គឺដើម្បីមកផ្តល់ទ្រព្យដល់ពួកនាងសម្រាប់ចិញ្ចឹមជីវិត។ សុវណ្ណហង្សក៏បានជម្រុះស្លាបមួយដែលជាមាសសុទ្ធដល់ភរិយានិងកូនស្រីសម្រាប់យកទៅលក់បានប្រាក់ចិញ្ចឹមជីវិត។

សុវណ្ណហង្សតែងតែមកជម្រុះស្លាបមួយៗជារឿយៗ ហើយក៏ហើរទៅវិញបាត់ទៅ។ ស្ត្រីទាំងនោះក៏បានក្លាយជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ មានជីវភាពរស់នៅខ្ពង់ខ្ពស់ លែងធ្វើការជាអ្នកស៊ីឈ្នួលអ្នកដទៃទៀត ដោយសារភាពករុណារបស់សុវណ្ណហង្ស។

ប៉ុន្តែថ្ងៃមួយ នាងព្រាហ្មណីជាម្តាយ និង កូនស្រីទាំងបីនាក់បានពិភាក្សាគ្នាថា៖ ធម្មតាសត្វតិរិច្ឆានមានចិត្តអាក្រក់ណាស់ ថ្ងៃណាមួយវានឹងលែងយកស្លាបមាសមកឱ្យយើងទៀតហើយ។ បើដូច្នោះមានតែយើងរកឧបាយចាប់សត្វហង្សនេះឱ្យបាន ហើយចាប់បោចយកស្លាបមាសឱ្យអស់ ទុកជាទ្រព្យសម្បត្តិរបស់យើង។ លុះដល់ថ្ងៃកំណត់យកស្លាបមាសមកជម្រុះ សុវណ្ណហង្សក៏បានហើរមកចុះត្រង់គេហដ្ឋានរបស់ស្ត្រីទាំងនោះដូចសព្វដង។ នាងព្រាហ្មណី និង កូនស្រីក៏នាំគ្នាចាប់សុវណ្ណហង្សបាន ហើយបោចយកស្លាបរហូតអស់ពីរាងកាយ។ តែស្លាបដែលបោចបានទាំងនោះ មិនបានក្លាយជាមាស



www.elibraryofcambodia.org

ដូចមុនឡើយ គឺវាបានក្លាយមកជាស្លាបធម្មតាវិញ។ ឯសុវណ្ណហង្ស ឈឺខ្លួនជាខ្លាំង ហើយពុំអាចហើរត្រឡប់ទៅកាន់ព្រៃបាន។ បន្ទាប់មក ពួកគេបាននាំគ្នាចិញ្ចឹមសុវណ្ណហង្សនោះដោយសង្ឃឹមថាសុវណ្ណហង្ស អាចនឹងដុះស្លាបមាសឡើងវិញ។ តែក្រោយមកសុវណ្ណហង្សដុះចេញ ជាស្លាបសល្មមអាចហើរបាន ក៏ហើរទៅកាន់លំនៅរបស់ខ្លួនបាត់ទៅ ដោយមិនបានហើរត្រឡប់មកកាន់ទីនោះវិញអស់មួយជីវិត។

នាងព្រាហ្មណី និងពួកកូនៗទាំងនោះក៏វិនាសទ្រព្យសម្បត្តិ អស់ ដោយសារភាពលោភលន់ ជាអ្នកប្រាថ្នាច្រើនឥតពិចារណា ខ្វះការសន្តោសចំពោះទ្រព្យសម្បត្តិដែលបានផ្តល់ឱ្យ។

## ៩. ហង្សពោធិសត្វ (នច្ចជាតក) [១៣]

មានស្តេចហង្សមួយ មានកូនស្រីម្នាក់ប្រកបដោយរូបសម្បត្តិ ស្អាតល្អណាស់។ ស្តេចហង្សបានឱ្យពរដល់កូនស្រីក្នុងសិទ្ធិរើសរកស្វាមី តាមចិត្តដែលខ្លួនស្រឡាញ់ ហើយហៅបក្សីទាំងឡាយឱ្យមកប្រជុំគ្នា។ ហ្វូងបក្សីមានគ្រប់ប្រភេទ មានហង្ស និងក្ងោកជាដើម មកប្រជុំគ្នា នៅលើផ្ទាំងថ្មដ៏ធំមួយកន្លែង។ ស្តេចហៅធីតារបស់ខ្លួនមកប្រាប់ថា៖ ចូរកូនជ្រើសរើសយកស្វាមីតាមចិត្តស្រឡាញ់ចុះ។ ធីតានោះបាន

---

[១៣] - ក្រុមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, សត្តមភាគលេខ ៥៨ ទំព័រ ១៥។



www.elibraryofcambodia.org

គ្រុតពិនិត្យមើលហ្វូងបក្សី ក៏បានឃើញសត្វក្ងោកមួយមាន_កពណ៌ដូចកែវមណី មានកន្ទុយស្អាតវិចិត្រទើបនាងនិយាយថា៖ បក្សីនេះសមជាស្វាមីរបស់ខ្ញុំម្ចាស់។ ហ្វូងបក្សីទាំងឡាយបានចូលទៅរកសត្វក្ងោក ហើយនិយាយថា៖ លោកក្ងោកជាសម្លាញ់! រាជធីតានេះពេញចិត្តរើសស្វាមីក្នុងកណ្ដាលហ្វូងពួកបក្សីដ៏ច្រើន ហើយបានពេញចិត្តចំពោះតែអ្នកម្នាក់។ បក្សីក្ងោកគិតថា៖ ពួកបក្សីទាំងនេះមិនទាន់ស្គាល់កម្លាំងរបស់អញទេ ទើបហ៊ានលះបង់សេចក្ដីខ្មាសបាបនិងខ្លាចបាប។ ដោយសេចក្ដីមោទនៈក្នុងចិត្តយ៉ាងខ្លាំង ក្ងោកបានបញ្ចេញចំពុះក្នុងកណ្ដាលហ្វូងដ៏ធំ ហើយរាំពត់ពេនយ៉ាងពេញទំហឹង មិនមានលាក់បាំងអ្វីឡើយ។ ស្ដេចក្ងោកមានសេចក្ដីខ្មាសក៏និយាយថា៖ សត្វក្ងោកនេះ មិនមានសេចក្ដីអៀនខ្មាសក្នុងចិត្តបន្តិចបន្តួចឡើយ។ យើងនឹងមិនឱ្យធីតារបស់យើងដល់បក្សីក្ងោកនេះ ដែលគ្មានសេចក្ដីខ្មាសបាប និងសេចក្ដីខ្លាចបាបបន្តិចសោះ។ ស្ដេចក្ងោកពោលគាថាកណ្ដាលហ្វូងបក្សីថា៖ សំឡេងរបស់អ្នកកពីរោះ ខ្នងរបស់អ្នកក៏ស្អាត ករបស់អ្នកប្រៀបដូចកែវពិទូរ្យ ឯកន្ទុយរបស់អ្នកក៏វែង តែយើងមិនឱ្យកូនស្រីរបស់យើងដល់អ្នកទេ ព្រោះការរាំពត់ពេនអួតអាងរបស់អ្នក គឺជាអ្នកឥតមានការអៀនខ្មាស។



www.elibraryofcambodia.org

# ១០. ក្អែកពោធិសត្វ (កាកជាតក)[១៤]

ក្នុងអតីតកាល ព្រះពោធិសត្វបានសោយព្រះជាតិជាសត្វក្អែក។ មានក្អែកប្រមាណ៨ ម៉ឺនចោមរោម ហើយរស់នៅក្នុងព្រៃដ៏ធំ។ មានថ្ងៃមួយបុរោហិតរបស់ព្រះរាជាក្រុងពារាណសី កំពុងងូតទឹកក្នុងស្ទឹងខាងក្រោយនគរ។ កាលនោះមានសត្វក្អែកពីរទំលើកំពូលក្លោងទ្វារព្រះនគរ។

បណ្តាក្អែកទាំងពីរនោះ ក្អែកមួយពោលថា ៖

-នែសម្លាញ់! ខ្ញុំនឹងបន្ទោរបង់ឧច្ចារៈលើក្បាលព្រាហ្មណ៍នេះ។

ក្អែកមួយទៀតបានហាមថា ៖

-ចូរអ្នកកុំធ្វើអី បុគ្គលនេះជាឥស្សរជន ធម្មតាពៀរវេរាជាមួយឥស្សរជនមានបាបធ្ងន់ ព្រោះថាព្រាហ្មណ៍នោះក្រោធហើយ ក៏នឹងញ៉ាំងឱ្យវិនាសទាំងអស់។ ក្អែកនោះមិនជឿតាម ក៏បានធ្វើយ៉ាងដូច្នោះ។ ព្រាហ្មណ៍ក្រោធហើយបានគុំចងពៀរវេរាចំពោះក្អែកទាំងឡាយ។

គ្រានោះ មានស្ត្រីម្នាក់ហាលស្រូវក្រោមកំដៅថ្ងៃ បានយកអង្កត់ភ្លើងមកវាយពពែដែលមកស៊ីស្រូវ។ ភ្លើងបានចាបឆេះរោមសត្វពពែនោះ។

សត្វពពែគិតថា៖

---

[១៤] - ក្រុមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, សត្តមភាគលេខ ៥៨ ទំព័រ ៦១។



www.elibraryofcambodia.org

-អញនឹងធ្វើឱ្យភ្លើងរលត់ គិតហើយក៏ចោលទៅរោងដំរីយ៉ាងលឿន រួចត្រដុសខ្លួនត្រង់ខ្ទមស្មៅមួយក្បែររោងដំរី ខ្ទមនោះក៏ឆេះឡើង។ អណ្តាតភ្លើងក៏ឆេះឆ្លងអំពីខ្ទមស្មៅ រួចក៏ចាបឆេះទៅដល់រោងដំរី។ កាលបើរោងដំរីត្រូវភ្លើងឆេះ ដំរីជាច្រើនក៏រលាកខ្លួនចេញជាផ្លែដំបៅ។ ពួកពេទ្យដំរីមិនអាចព្យាបាលឱ្យជាបាន ទើបទៅក្រាបទូលព្រះរាជា។

ព្រះរាជាទ្រង់ត្រាស់សួរបុរោហិតថា៖

-តើអ្នកចេះថ្នាំព្យាបាលអ្វីខ្លះឬទេ?

បុរោហិតក្រាបទូលថា៖

-បពិត្រព្រះមហារាជា ទូលព្រះបង្គំចេះ ប្រសិនបើបានខ្លាញ់រាវរបស់ក្អែកមកផ្សំថ្នាំទើបបាន។

ព្រះរាជាបានត្រាស់បញ្ជាថា៖

បើដូច្នោះចូរពួកអ្នកសម្លាប់ក្អែក ហើយនាំយកខ្លាញ់រាវមក។ ពួកមនុស្សបាននាំគ្នាសម្លាប់ក្អែកទាំងឡាយ ហើយនៅតែមិនបានខ្លាញ់រាវ សត្វក្អែកកើតការភិតភ័យយ៉ាងខ្លាំង។ ព្រះពោធិសត្វដឹងហេតុអស់ ហើយមានចិត្តប្រាថ្នានឹងធ្វើការសង្គ្រោះញាតិទើបនឹករលឹកដល់បារមីទាំងឡាយ ដែលបានធ្វើមេត្តាបារមីឱ្យប្រព្រឹត្តទៅខាងមុខហើយហើរទៅយ៉ាងលឿន ចូលទៅតាមប្រឡោះបង្អួចដ៏ធំរួចក៏ចូលទៅក្រោមព្រះទីនាំងរបស់ព្រះរាជា។ គ្រានោះមានមនុស្សម្នាក់បានប្រាថ្នានឹងចាប់ព្រះពោធិសត្វ តែព្រះរាជាទ្រង់ត្រាស់ហាមមនុស្សនោះ។



www.elibraryofcambodia.org

ព្រះពោធិសត្វបានឈប់សម្រាកបន្តិច ហើយក៏ចេញពីក្រោមព្រះទីនាំងមកក្រាបទូលថា៖ បពិត្រព្រះមហារាជ ! ធម្មតាព្រះរាជាមិនទ្រង់លុះអគតិដោយអំណាចឆន្ទាគតិជាដើមទើបត្រឹមត្រូវ។ ព្រះរាជកិច្ចណានីមួយៗជាព្រះរាជកិច្ច ដែលព្រះអង្គត្រូវបំពេញព្រះរាជកិច្ចទាំងអស់នោះ ព្រះអង្គតែងពិចារណាជាមុន ហើយទ្រង់បំពេញទើបត្រឹមត្រូវ។ ម្យ៉ាងទៀត ព្រះរាជកិច្ចឯណាកាលព្រះអង្គបំពេញនឹងសម្រេចប្រយោជន៍ ព្រះរាជកិច្ចនោះឯងព្រះអង្គបំពេញទើបត្រឹមត្រូវ។ ព្រះរាជកិច្ចក្រៅអំពីនេះព្រះអង្គបំពេញមិនត្រឹមត្រូវឡើយ។ ព្រះរាជកិច្ចដែលព្រះអង្គបំពេញទៅមិនបានសម្រេចប្រយោជន៍នោះគឺបុរោហិតជាអ្នកលុះក្នុងអំណាចនៃពៀរវេរា ទើបបានពោលមុសាវាទ ធម្មតាខ្លាញ់រាវរបស់សត្វក្អែកទាំងឡាយមិនមានទេ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់ពាក្យអស់ហើយ ទ្រង់មានព្រះរាជហឫទ័យត្រេកអរ បានឱ្យក្អែកព្រះពោធិសត្វទំនៅលើព្រះទីនាំងមាសដ៏ប្រសើរ ទ្រង់ត្រាស់ឱ្យរាជបុរសលាបចន្លោះស្លាបទាំងឡាយដោយប្រេងដែលស្លហើយ១០០ដង ១០០០ដង។ បន្ទាប់មកព្រះអង្គត្រាស់ឱ្យព្រះរាជទានទូវភោជនដ៏ប្រសើរសមគួរក្នុងចានមាស ទ្រង់ឱ្យផឹកទឹកហើយ ទើបព្រះរាជាត្រាស់សួរព្រះពោធិសត្វដែលឆ្អែតស្កប់ស្កល់ថា៖

-ម្នាលបណ្ឌិត ! ហេតុអ្វីទើបខ្លាញ់រាវរបស់ក្អែកទាំងឡាយមិនមាន? ព្រះពោធិសត្វបានសម្ដែងធម៌ដែលប្រកាសហេតុដល់ព្រះ



www.elibraryofcambodia.org

រាជា៖

-ក្អែកទាំងឡាយជាសត្វមានចិត្តភ្ញាក់ផ្អើលជានិច្ច ព្រោះត្រូវមនុស្សលោកទាំងពួងបៀតបៀន ហេតុនេះបានជាខ្លាញ់រាវនៃពួកក្អែកជាញាតិនៃទូលព្រះបង្គំមិនមាន។

ព្រះរាជាទ្រង់ព្រះសណ្តាប់ពាក្យនេះហើយ ទ្រង់បូជាព្រះពោធិសត្វដោយរាជ្យសម្បត្តិ។ តែព្រះពោធិសត្វបានថ្វាយនូវរាជ្យសម្បត្តិដល់ព្រះរាជាត្រឡប់ដូចដើមវិញនឹងញ៉ាំងព្រះរាជាឱ្យព្រះអង្គស្ថិតនៅក្នុងបញ្ចសីល។ រួចក៏បានទូលសូមអភ័យដល់សព្វសត្វ ហើយក៏ហើរចេញទៅ។ ឯព្រះរាជាបានប្រទានអភ័យដល់ពួកសព្វសត្វ ព្រះអង្គបានតាំងនូវទានជាប្រចាំដល់ក្អែកទាំងឡាយ។ ព្រះអង្គបានឱ្យដាំបាយផ្សំដោយអាហារដែលមានរសជាតិដ៏ឆ្ងាញ់ផ្សេងៗ ឱ្យដល់ពួកក្អែករៀងរាល់ថ្ងៃ។ ចំណែកព្រះក្រយាស្ងោយនៃព្រះរាជានោះឯង ព្រះអង្គក៏ព្រះរាជទានដល់ព្រះពោធិសត្វ។



www.elibraryofcambodia.org

## ១១. ក្អែកពោធិសត្វ(សុបត្តជាតក)[១៩]

ក្នុងអតីតកាលព្រះពោធិសត្វបានកើតជាសត្វក្អែក ចម្រើនវ័យធំបានជាប្រធានលើក្អែក៨ម៉ឺនក្បាល មានឈ្មោះថាសុបត្ត។ ឯអគ្គមហេសីរបស់ស្តេចក្អែកនេះមានឈ្មោះថាសុបស្សា ហើយមានសេនាឈ្មោះថាសុមុខៈ។ ស្តេចក្អែកនោះរស់នៅជិតនគរពារាណសី បាននាំមហេសីទៅស្វែងរកចំណី ហោះរំលងរោងចុងភៅរបស់ស្តេចក្រុងពារាណសី។ នាយ ពិសេស(មេចុងភៅប្រចាំរាជវាំង) បម្រុងភោជនដែលមានត្រីនិងសាច់ផ្សេងៗស្រេចហើយ ក៏គ្របភាជន៍តម្កល់ទុកក្នុងទីម្នាងប្រកបដោយក្លិនឈ្ងុយឆ្ងាញ់ចេញទៅក្រៅ។ នាងក្អែកសុបស្សាធុំក្លិន ក៏ប្រាថ្នាចង់ចីភោជនរបស់ព្រះរាជា មិននិយាយស្តីពេញមួយថ្ងៃ ទើបស្តេចក្អែកសួរមហេសីថា៖ នាងដ៏ចម្រើនពួកយើងគួរនឹងទៅរកចំណីឬ? ទើបមហេសីពោលថា៖ លោកទៅចុះ! ខ្ញុំមានអាការៈចាញ់ផ្ទៃ។ ស្តេចក្អែកសួរវិញថា៖ នាងឃ្លានអ្វី? មហេសីឆ្លើយតបថា៖ ខ្ញុំចង់ចីភោជនរបស់ព្រះរាជាក្រុងពារាណសី បើមិនបានចីខ្ញុំនឹងអស់ជីវិត សូមលោកដ៏ប្រសើរទ្រង់យល់អំពីខ្ញុំម្ចាស់ផង។ ក្អែកពោធិសត្វកំពុងតែសញ្ជប់សញ្ជឹងគិត សេនាបតីសុមុខៈមកទូលសួរថា៖ បពិត្រមហារាជ ! ព្រះអង្គមិនសប្បាយព្រះទ័យ

---

[១៩] - ក្រុមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, សត្តមភាគលេខ ៥៨ ទំព័រ ១៣៦។



www.elibraryofcambodia.org

ព្រោះរឿងអ្វី? ព្រះរាជាតបថា៖ មហេសីយើងចង់សោយព្រះស្ងោយរបស់ព្រះរាជាក្រុងពារាណសី។ សេនាបតីសុមុខៈទូលថា៖ បពិត្រមហារាជ! ព្រះអង្គកុំព្រះវិតក្កឡើយ ថ្ងៃនេះទូលព្រះបង្គំនឹងនាំព្រះស្ងោយនោះមកថ្វាយ។ ពេលចប់ហើយ សុមុខៈក៏នាំក្អែកជាបរិវារចូលទៅនគរពារាណសី ដោយបែងចែកក្អែកជាពួកៗ ទុកក្នុងទីជិតរោងចុងភៅ។បន្ទាប់មកខ្លួនឯងហើរទៅទំលើដំបូលរោងចុងភៅជាមួយនឹងទ័ពក្អែកចម្បាំងប្រាំបីក្បាល។ ក្អែកសុមុខៈនិយាយថា៖ ពេលនាយពិសេសកំពុងនាំព្រះស្ងោយទៅថ្វាយព្រះរាជា យើងនឹងទៅធ្វើភាជន៍ឱ្យធ្លាក់ចុះមកដី ពេលធ្លាក់ចុះយើងនឹងត្រូវអស់ជីវិតហើយ ចូរក្អែកបួនក្បាលចូលទៅពាំភោជនឱ្យពេញមាត់។ ឯបួនក្បាលទៀតចូលទៅពាំត្រី សាច់ រួចនាំយកទៅថ្វាយស្ដេចយើង និងមហេសីសោយចុះ បើស្ដេចយើងសួរថា៖ សេនាបតីទៅណា? ចូរអ្នកប្រាប់ថា៖ យើងនឹងមកតាមក្រោយ។

វេលានោះ នាយពិសេសចាត់ចែងព្រះស្ងោយគ្រប់ប្រភេទរបស់ព្រះរាជាស្រេចហើយ ទើបកាន់ភាជន៍ចេញទៅ។ ក្អែកសុមុខៈហោះយ៉ាងរហ័សចូលទៅកាន់រោងរាជត្រកូល។ ក្នុងពេលនាយពិសេសដើរដល់ព្រះលានហ្លួង ក្អែកសេនាបតីឱ្យសញ្ញាដល់ក្អែកទាំងឡាយហើយខ្លួនឯងធាបចុះទៅចាប់ខ្ទាំមុខរបស់នាយពិសេសក៏ធ្វើឱ្យធ្លាក់ពីដៃ។ ព្រះរាជាកំពុងយាងចេញពីប្រាសាទ ព្រះនេត្រទតទៅឃើញហេតុការណ៍ ទើបឱ្យនាយពិសេសបោះភាជន៍ចោល ហើយឱ្យចាប់ក្អែកនោះឱ្យបាន។ ខណៈក្អែកទាំងឡាយទៅចឹកស៊ី ក្អែកចម្បាំងហើរ



www.elibraryofcambodia.org

ពាំយកភោជនដែលសេសសល់ទៅថ្វាយស្តេចរបស់ខ្លួន ស្វែកបួនក្បាលទៀតក៏ធ្វើដូច្នោះដែរ។ ចំណែកស្វែកសេនាបតីត្រូវនាយពិសេសចាប់បានយកទៅថ្វាយព្រះរាជា។ លំដាប់នោះ ព្រះរាជាទ្រង់ត្រាស់សួរថា៖ ម្នាលស្វែកដ៏ចម្រើន! អ្នកមិនរៀនខ្លាស មិនខ្លាចយកជើងចឹកខ្វាំមុខនាយពិសេស ទំលាយភាជន៍ឱ្យបែក និង មិនរក្សាជីវិតរបស់ខ្លួន ព្រោះហេតុអ្វីបានជាអ្នកធ្វើយ៉ាងដូច្នេះ? ស្វែកសេនាបតីទូលថា៖ បពិត្រមហារាជ! ស្តេចរបស់ពួកទូលបង្គំអាស្រ័យក្នុងព្រៃជិតក្រុងពារាណសីនេះដែរ ខ្ញុំព្រះអង្គជាសេនាបតីរបស់ស្តេចអង្គនោះ មហេសីរបស់ព្រះអង្គចាញ់ផ្ទៃចង់សោយភោជនរបស់ព្រះអង្គ។ ស្តេចទូលបង្គំប្រាប់ពីការចាញ់ផ្ទៃមហេសីរបស់ព្រះអង្គដល់ទូលបង្គំ ទើបទូលបង្គំលះបង់ជីវិតដើម្បីស្តេចអង្គនោះ ហើយក៏បានមកដល់ទីនេះ។ ឥឡូវទូលបង្គំបានបញ្ជូនព្រះស្ងោយទៅថ្វាយមហេសីរបស់ស្តេចនោះហើយ។ សេចក្តីប្រាថ្នារបស់ទូលបង្គំចប់ហើយ។ ដោយសារហេតុនេះទើបទូលបង្គំបានធ្វើកម្មយ៉ាងដូច្នេះ រួចពោលគាថាថា៖ បពិត្រមហារាជ! ស្តេចស្វែកឈ្មោះសុបត្តអាស្រ័យនៅក្បែរក្រុងពារាណសី មានស្វែកប្រាំបីម៉ឺនជាបរិវារ នាងសុបស្សាជាមហេសីរបស់ស្តេចស្វែក មានអាការចាញ់ផ្ទៃចង់សោយព្រះស្ងោយដ៏មានតម្លៃ ដែលនាយពិសេសចម្អិនដើម្បីថ្វាយព្រះអង្គសោយ។ ខ្ញុំព្រះអង្គជារាជទូតរបស់ស្តេចស្វែកត្រូវស្តេចបញ្ជូនមកក្នុងទីនេះ។ ខ្ញុំព្រះអង្គធ្វើសេចក្តីគោរពចំពោះម្ចាស់ ហើយបានធ្វើឱ្យមានរបួសត្រង់ច្រមុះរបស់នាយពិសេស។



www.elibraryofcambodia.org

# ១២. ក្អែកទឹកពោធិសត្វ(វីរកភាព)[៦៦]

ក្នុងអតីតកាលព្រះពោធិសត្វបានកើតជាក្អែកទឹក រស់ក្នុងហិមវន្តប្រទេស អាស្រ័យនៅនឹងស្រះមួយឈ្មោះវីរកៈ។ គ្រាមួយ ក្នុងដែនកាសីកើតគ្រោះទុរ្ភិក្ស ពួកមនុស្សមិនអាចឱ្យចំណីដល់ក្អែក ព្រមទាំងមិនអាចធ្វើការបួងសួងដល់យក្ខ និងនាគបានទៀត។ ក្អែកទាំងឡាយបានចាកចេញពីដែនដីនោះសំដៅទៅព្រៃ។ ក្អែកមួយឈ្មោះសវិដ្ឋកៈ(ជាក្អែកគោក) រស់នៅក្នុងនគរពារាណសីបាននាំនាងក្អែកជាប្រពន្ធដើម្បីទៅជួបនឹងក្អែកមួយទៀត ឈ្មោះវីរកៈ(ជាក្អែកទឹក) ដើម្បីអាស្រ័យនៅក្នុងស្រះជាមួយគ្នា។ ថ្ងៃមួយក្អែកសវិដ្ឋកៈ ឃើញក្អែកវីរកៈមុជចុះក្នុងស្រះស៊ីត្រីហើយឡើងមកវិញជាធម្មតា។ ក្អែកគោកឃើញ ក្អែកទឹកវីរកៈមុជទឹកចាប់ត្រីស៊ីហើយហោះហើរបាន ក៏គិតថា៖ យើងអាស្រ័យនៅនឹងក្អែកនេះហើយ ព្រោះគេរកត្រីបានច្រើន ឯខ្លួនអញត្រូវគោរពប្រណិបត្តិក្អែកនេះ។ គិតហើយក៏ចូលទៅរកក្អែកឈ្មោះវីរកៈនោះ រួចនិយាយថា៖ លោក ! ខ្ញុំសូមប្រណិប័តន៍លោក។ ក្អែកទឹកតបថា៖ ល្អហើយ!។ តាំងពីថ្ងៃនោះមក ក្អែកគោកតែងគោរពប្រណិប័តន៍ ក្អែកទឹក ឯក្អែកវីរកៈស៊ីត្រីឆ្អែតហើយតែងពាំយកឱ្យ ក្អែកសវិដ្ឋកៈ។ ឯក្អែកសវិដ្ឋកៈស៊ីឆ្អែត ហើយក៏តែងនាំយកត្រី

---

[៦៦] - ក្រមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, សត្តមភាគលេខ ៥៨ ទំព័រ ១០៩។



www.elibraryofcambodia.org

ដែលនៅសល់មកផ្ញើប្រពន្ធទៀត។ តមកក្អែកសរិដ្ឋកៈកើតសេចក្តីតម្កើងខ្លួន គិតថាក្អែកទឹកនេះជាក្អែកខ្មៅ អញក៏ជាក្អែកខ្មៅ ក្អែកចំពុះ មាត់របស់ក្អែកទឹកនេះក៏ដូចអញដែរ។ ចាប់ពីថ្ងៃនេះទៅ អញមិនត្រូវការក្អែកទឹកចិញ្ចឹមទេ អញនឹងរកចាប់ត្រីខ្លួនអញវិញ។ ក្អែកសរិដ្ឋកៈបានជួបនឹងសម្លាញ់ហើយ ក៏និយាយថា៖ ចាប់ពីថ្ងៃនេះទៅ យើងនឹងចាប់ត្រីដោយខ្លួនឯង។ ក្អែកទឹកហាមថា៖ អ្នកឯងមិនកើតក្នុងត្រកូលដែល ធ្លាប់ចាប់ត្រីក្នុងទឹកទេ អ្នកកុំធ្វើខ្លួនឯងឱ្យវិនាស។ តែក្អែកគោកមិនស្តាប់ពាក្យ ក៏ចុះក្នុងស្រះមុជទឹករួចផុសឡើងវិញមិនបាន គេប្រឹងវែកសារាយចេញក៏មិនបាន ព្រោះជាប់ក្នុងសារាយច្រើន ដោយលេចចេញតែចុងចំពុះ។ ក្អែកគោកក៏ដល់នូវសេចក្តីស្លាប់ក្នុងទឹកនោះឯង។

គ្រានោះ នាងប្រពន្ធមិនឃើញប្តីវិលមកវិញ ទើបទៅសួររកក្អែកទឹកជាសម្លាញ់។ កាលបើបានដឹងប្តីស្លាប់ក្នុងទឹកហើយ ទើបប្រពន្ធរបស់ក្អែកគោកសួរថា៖ នៃក្អែកទឹកវិរកៈ! អ្នកឃើញសត្វស្លាបដែលពោលពាក្យពិរោះ ផ្នួកដូចជាកនៃសត្វក្ងោក ជាក្អែកគោកឈ្មោះសរិដ្ឋកៈជាប្តីរបស់ខ្ញុំដែរឬទេ? ក្អែកទឹកពោធិសត្វពោលថា៖ ក្អែកសរិដ្ឋកៈរបស់អ្នក កាលធ្វើតាមសត្វស្លាបដែលត្រាច់ក្នុងទឹកនិងលើគោកបានបរិភោគត្រីស្រស់ជានិច្ច នោះត្រូវសារាយព័ទ្ធព័ទ្ធស្លាប់ទៅហើយ។



www.elibraryofcambodia.org

## ១៣. សេតពោធិសត្វ (មង្គលត្ថទីបនីប្រែ)[១៣]

ក្នុងអតីតកាល ព្រះពោធិសត្វសោយរាជ្យជាស្ដេចសេកក្នុងព្រៃល្វា ក្បែរមាត់ច្រាំងទន្លេគង្គា។ កាលបើផ្លែឈើរបស់ខ្លួនអស់ហើយ ក៏ចឹកស៊ីតែពន្លកត្រួយ សន្លឹក សំបក ឬក្រមរ ដែលនៅសល់ប៉ុណ្ណោះ ហើយនិងផឹកទឹកក្នុងទន្លេគង្គា។ ជាសត្វមានសេចក្ដីប្រាថ្នាតិច មានសេចក្ដីសន្ដោសយ៉ាងក្រៃលែង មិនហើរទៅក្នុងទីស្ថានដទៃឡើយ។ ដោយគុណនៃភាពជាអ្នកមានសេចក្ដីប្រាថ្នាតិច និងសេចក្ដីសន្ដោសរបស់ស្ដេចសេកនោះ ភពរបស់ស្ដេចសក្កទេវរាជបានកម្រើក។ ស្ដេចសក្កទេវរាជជ្រាបហេតុនោះហើយ ព្រះអង្គបានញាំងដើមឈើនោះឱ្យក្រៀមស្ងួតអស់ទៀត។ ដោយអនុភាពរបស់ព្រះអង្គ ដើម្បីនឹងសាកល្បងនូវស្ដេចសេកនោះ។ ដើមឈើមាននៅត្រឹមតែដង្គត់ធ្លុះដាច់អស់ហើយ កាលបើខ្យល់បក់បោកមកក៏បញ្ចេញសំឡេងដូចជាត្រូវគេគោះ។ លំអងទាំងឡាយក៏ហើរចេញមកអំពីប្រហោងនៃដើមឈើនោះ។ សត្វសេកបានចឹកស៊ីលំអងទាំងនោះ ហើយមិនបានហើរទៅក្នុងទីស្ថានដទៃទៀត។ មិនបានទឹកគិតដល់ខ្យល់ និងកំដៅថ្ងៃឡើយ គឺនៅទំលើចុងដង្គត់ដើមល្វា។ ស្ដេចសក្កទេវរាជបានជ្រះថ្លា ហើយទើបដងទឹកក្នុងទន្លេគង្គាមកស្រោចលើដង្គត់ឈើនោះ។ ក្នុងពេលជាមួយគ្នា ដើមឈើក៏បានសម្បូរដោយមែកនិងមានផ្លែផ្អែមដុះឡើងវិញ។

---

[១៣] - ក្រមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, សត្តមភាគលេខ ៥៨ ទំព័រ ៦៤។



www.elibraryofcambodia.org

## ១៤. សេតពោធិសត្វ (មង្គលត្ថទីបនីប្រែ)

ក្នុងកាលព្រះពោធិសត្វយោនយកកំណើតជាស្តេចសេកមានខ្លួនធំប៉ុនដុំរទេះ តែងនាំចំណីអំពីព្រៃហេមពាន្តមកចិញ្ចឹមមាតាបិតា។ គ្រាមួយមានព្រាហ្មណ៍ម្នាក់ឈ្មោះ កោសិយគោត្រ ឱ្យគេព្រោះស្រូវសាលី១០០ ករីស ហើយឱ្យមនុស្សម្នាក់ចាំស្រែ។ ស្តេចសេកតែងនាំបរិវារចុះក្នុងស្រែ។ អ្នកថែស្រែមិនអាចហាមឃាត់បាន ក៏ទៅប្រាប់ព្រាហ្មណ៍ម្ចាស់ស្រែ ហើយនិយាយជម្រាបបញ្ជាក់ប្រាប់ម្ចាស់ពីការបានឃើញសេកមួយធំប៉ុនដុំរទេះ មិនត្រឹមតែស៊ីមួយចម្អែតទេ ថែមទាំងធ្វើក្មួរស្រូវសាលីជាច្រើន រួមចូលគ្នាពាំនឹងចំពុះរួចហើរចេញទៅ។ ស្តាប់ឮហើយ ម្ចាស់បានបញ្ជាក់ថា៖ បើដូច្នោះ ចូរអ្នកវិញរោមកន្ទុយសេះដាក់អន្ទាក់ក្នុងទីដែលស្តេចសេកចុះ ហើយចាប់វាទាំងរស់នាំយកមក។ អ្នកបម្រើធ្វើតាមបញ្ជា ហើយក៏ចាប់បាននាំយកមកជូនម្ចាស់។ ពេលឃើញស្តេចសេកភ្លាម ព្រាហ្មណ៍កើតចិត្តស្រឡាញ់ ហើយឱ្យព្រះពោធិសត្វទំនៅក្នុងទ្រុងរួចពោលថា ៖ ម្នាលសេក! អ្នកស៊ីស្រូវយើងហើយ ហេតុអ្វីក៏នៅខាំពាំយកស្រូវសាលីទៅទៀត? តើអ្នកមានជង្រុក ឬក៏មានចងពៀរនឹងយើង?

ស្តេចសេកស្តាប់ហើយពោលថា ៖

_ខ្ញុំមិនចងពៀរទេ! ហើយក៏មិនមានជង្រុកដែរ តែខ្ញុំខំដោះបំណុលផងនិងឱ្យបុលផងទៀត។ ខ្ញុំហើរទៅដល់ចុងព្រៃរកា ក៏កប់



www.elibraryofcambodia.org

កំណាប់នៅក្នុងព្រៃនោះទៀត។ ព្រាហ្មណ៍ម្ចាស់ស្រែបង្ហាញនូវទឹកមុខចូល់ តែស្ដេចសេកពោលបន្តទៀតថា៖ ខ្ញុំមានកូនតូចៗមិនទាន់ដុះស្លាប។ ដូច្នេះខ្ញុំត្រូវបុលដល់កូនតូចៗទាំងនោះ។ ម្យ៉ាងទៀត ខ្ញុំមានមាតាបិតាចាស់ជរា។ ដូច្នេះខ្ញុំត្រូវដោះបំណុលដែលលោកធ្លាប់បានចិញ្ចឹមខ្ញុំ។ ទន្ទឹមនេះនៅឯព្រៃរកាដែលពួកខ្ញុំនៅ មានបក្សាបក្សីដែលជ្រុះស្លាបអស់ ហើយថមថយកម្លាំង។ ដូច្នេះខ្ញុំត្រូវការបុណ្យដោយឱ្យចំណីដល់ពួកគេ។

ដូចបណ្ឌិតទាំងឡាយពោលថា៖

-បុញ្ញកម្មនោះជាកំណាប់ទ្រព្យដែលមានប្រក្រតីយកទៅតាមខ្លួន។

ព្រាហ្មណ៍ស្ដាប់មានចិត្តជ្រះថ្លា ក៏ពោលថា៖

-តាំងពីថ្ងៃនេះទៅ អ្នកព្រមទាំងពួកញាតិ ចូរកុំឱ្យមានភ័យស៊ីស្រូវសាលីចុះ! ពោលប្រគល់រួចហើយ ក៏យកចេញពីទ្រុង និងស្រាយចំណងជើងចេញ។ តែព្រះពោធិសត្វជាអ្នកដឹងប្រមាណក៏ទទួលយកត្រឹមតែ៨ ករីសប៉ុណ្ណោះ ព្រមទាំងប្រគល់ស្រែដែលសេសសល់ជូនព្រាហ្មណ៍វិញ រួចឱ្យឱវាទថា៖ ម្នាលមហាព្រាហ្មណ៍! ចូរអ្នកកុំប្រមាទឡើយ។ បន្ទាប់មកក៏ពាំស្រូវសាលីទៅកាន់សំណាក់មាតាបិតា។ ឯព្រាហ្មណ៍ក៏បោះបង្គោលសសរមានប្រមាណ ៨ ករីស ហើយប្រាប់អ្នកថែរក្សាស្រែថា៖ ចូរអ្នកកុំហាមឃាត់សេកទាំងឡាយដែលពាំស្រូវពីស្រែនោះឡើយ។ តាំងពីថ្ងៃនោះមក ពពួកសេកបានពាំស្រូវសាលីពីទីនោះឯង។



www.elibraryofcambodia.org

## ១៥. ស្តេចសេតពោធិសត្វ សត្វមៀម និងសារិកា (តេសកុណជាតក)[១៩]

ព្រះបាទព្រហ្មទត្តសួរថា៖

-ម្នាលសត្វស្លាប យើងសូមសួរអ្នកឈ្មោះវេស្សន្តរៈថា៖ កិច្ចដូចម្តេចដែលយើងជាអ្នកប្រាថ្នា ដើម្បីសោយរាជ្យហើយធ្វើឱ្យប្រសើរ?

មៀមឈ្មោះវេស្សន្តរៈទូលថា៖

-កន្លងទៅជាយូរលង់ណាស់ហើយ ដែលបិតារបស់ខ្ញុំព្រះអង្គព្រះនាមកំសៈ ព្រះអង្គធ្លាប់ជាអ្នកសង្គ្រោះក្រុងពារាណសីបានចោទសួរខ្ញុំព្រះអង្គដែលជាកូនមិនធ្វេសប្រហែស។

ខ្ញុំបានទូលព្រះអង្គថា៖

-មុនដំបូងព្រះរាជាត្រូវហាមឃាត់នូវពាក្យឃ្លៀងឃ្លាតសេចក្តីក្រោធ និងការសើចរឡេះរឡោះ។ តពីនោះគប្បីធ្វើនូវកិច្ចទាំងឡាយដែលបណ្ឌិតបានពោលនូវពាក្យថាជាវត្ត។ ឯចំពោះអំពើដ៏ក្តៅក្រហាយណាដែលព្រះអង្គធ្លាប់ធ្វើហើយក្នុងកាលមុន ព្រះអង្គត្រេកត្រអាលក្តី ទ្រង់ខ្វាល់ក្តី ព្រះអង្គមិនត្រូវធ្វើនូវអំពើនោះតទៅទៀតឡើយ។ ព្រះអង្គជាអ្នកញ៉ាំងរាស្ត្រឱ្យចម្រើន កាលបើព្រះអង្គ

---

[១៩] -ក្រុមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, នវមភាគលេខ ៦០ ទំព័រ ២២៥។



www.elibraryofcambodia.org

ប្រហែស ភោគទ្រព្យទាំងអស់ក្នុងនគរនឹងវិនាសទៅ។ សេចក្ដីវិនាសនោះលោកពោលថាជាទុក្ខរបស់ព្រះរាជា។

បុគ្គលមានសិរី និងបុគ្គលមានបុណ្យបានពោលពាក្យនេះថា៖ ខ្ញុំត្រេកអរចំពោះបុរសមានសេចក្ដីខ្មីឃ្មាត មានសេចក្ដីប្រឹងប្រែង ជាអ្នកមិនប្រណែន។ ឯបុគ្គលកាឡកណ្ណី ជាអ្នកកាច់បំបាក់នូវចក្រគឺអកុសលតែងអបអរចំពោះអ្នកមានចិត្តអាក្រក់ ចិត្តប្រណែន ជាអ្នកប្រទូស្តចំពោះកល្យាណកម្ម។ សូមព្រះអង្គមានហឫទ័យ ល្អរក្សានូវជនទាំងពួង។ តែព្រះអង្គត្រូវបណ្ដេញនូវបុគ្គលឥតបុណ្យចេញ ដោយយកបុគ្គលមានបុណ្យមកជាទីពំនាកវិញ។ បពិត្រព្រះអង្គជាម្ចាស់នៃដែនកាសី បុរសមានបុណ្យបរិបូណ៌ដោយតាំងនៅអធ្យាស្រ័យដ៏ធំ រមែងកាត់បង់នូវគល់ និងចុងនៃសត្រូវទាំងឡាយបាន។ បពិត្រព្រះអង្គជាម្ចាស់នៃមនុស្ស ដូចយ៉ាងព្រះឥន្ទ្រក៏មិនប្រហែសក្នុងការខ្មីឃ្មាតដែរ។ លោកតែងធ្វើនូវការព្យាយាមចំពោះអំពើល្អ ព្រមទាំងមានព្រះហឫទ័យក្នុងការខ្មីឃ្មាតជាដរាប។ ពួកគន្ធព្វ ពួកព្រហ្ម ពួកទេវតា មានអាជីវអាស្រ័យនឹងព្រះរាជា ហើយមានអំណរនឹងបុញ្ញកម្មយ៉ាងនោះ។ ពួកទេវតាតែងតាមថែរក្សាព្រះរាជាជាអ្នកខ្មីឃ្មាតមិនប្រហែស។ ព្រះអង្គត្រូវជាអ្នកមិនប្រហែស មិនក្រោធ សូមធ្វើនូវកិច្ចការទាំងឡាយដោយការប្រឹងប្រែង។ បុគ្គលខ្ជិលច្រអូសរមែងមិនបានសេចក្ដីសុខ។ ព្រះរាជា កាលណាប្រព្រឹត្តយ៉ាងនេះ ទើបអាចញ៉ាំងពួកមិត្តឱ្យបានសុខផង និងអាចញ៉ាំងសត្រូវឱ្យបានទុក្ខផង។ នេះ



www.elibraryofcambodia.org

ជាវត្តបទក្នុងបញ្ហានោះឯង។

ព្រះរាជា ៖

-យើងសុំសួរទៅនាងសារិកាកុណ្ឌលិនី នាងអាចឆ្លើយនឹងប្រស្នាបាន ព្រោះនាងជាពង្សនៃមហាសេនគុត្តដែរ។ កិច្ចដូចម្ដេចដែលយើងជាអ្នកប្រាថ្នាដើម្បីសោយរាជ្យ ហើយធ្វើឱ្យប្រសើរ?

នាងសារិកាឈ្មោះ គុណ្ឌលិនីទូលថា ៖

-ប្រយោជន៍និងសេចក្ដីសុខទាំងអស់ តាំងនៅក្នុងបទណាបទនោះមានពីរយ៉ាងគឺ ៖ ការបាននូវរបស់ដែលមិនធ្លាប់បាន ១ រក្សានូវរបស់ដែលបានមកហើយនោះ១។ សូមព្រះអង្គជ្រាបថា អាមាត្យទាំងឡាយដែល មានប្រាជ្ញាឈ្លាសវៃចំពោះប្រយោជន៍នោះ សូមព្រះអង្គជ្រាបនូវអាមាត្យទាំងឡាយដែលមិនលេងល្បែង មិនបោកប្រាស់ មិនជាអ្នកស៊ីផឹក មិនជាអ្នកបំផ្លាញព្រះរាជទ្រព្យ។ ឯអាមាត្យណារក្សានូវទ្រព្យរបស់ព្រះអង្គ មានដូចជានាយសារថី តែងប្រុងប្រយត្នូនូវរថ។ អាមាត្យនោះព្រះអង្គគប្បីឱ្យធ្វើនូវកិច្ចការទាំងឡាយរបស់ព្រះអង្គ។ ព្រះអង្គគប្បីជ្រាបនូវសេចក្ដីចម្រើន និងសេចក្ដីវិនាសដោយព្រះអង្គឯង។ គប្បីជ្រាបនូវកិច្ចការដែលបានធ្វើ និងការធ្វើដោយព្រះអង្គឯង ហើយសង្កត់សង្កិននូវបុគ្គលដែលគួរសង្កត់សង្កិន ឬគួរលើកតម្កើងនូវបុគ្គលដែលគួរលើកតម្កើង។ បពិត្រព្រះអង្គដែលជាធំលើរដ្ឋ សូមព្រះអង្គប្រៀនប្រដៅនូវប្រយោជន៍ដល់អ្នកជនបទដោយព្រះអង្គឯង។ ពួករាជបុរសអ្នកប្រកបការមិនត្រឹមត្រូវតាមធម៌



www.elibraryofcambodia.org

សូមកុំញាំង ទ្រព្យក្នុងដែនរបស់ព្រះអង្គឱ្យវិនាស។ មួយទៀត សូមព្រះអង្គកុំធ្វើ ឬឱ្យគេធ្វើនូវរាជកិច្ចដោយរួសរាន់។ ព្រោះមនុស្សល្ងង់ខ្លៅតែងក្តៅក្រហាយរឿយៗ ក្នុងកាលខាងក្រោយចំពោះការងារដែលខ្លួនធ្វើដោយរួសរាន់។ សូមព្រះអង្គកុំបញ្ចេញនូវព្រះហឫទ័យក្រោធខ្លាំងពេក ចំពោះភាពអកុសលរបស់អ្នកដទៃដែលប្រព្រឹត្តកន្លងមកនូវការកុសល។ ព្រោះថាត្រកូលទាំងឡាយដែលថ្កុំថ្កើងហើយច្រើនផ្តល់នូវភាវៈមិនមែនជាត្រកូលទៅវិញ ព្រោះសេចក្តីក្រោធ។ បពិត្រព្រះអង្គ សូមកុំបណ្តោយឱ្យមហាជនធ្លាក់ទៅក្នុងសេចក្តីវិនាស ដោយគិតថាខ្លួនអញជាឥស្សរជន។ ការកើតនៃទុក្ខលំបាកកុំឱ្យមានដល់បុរស ស្ត្រីទាំងឡាយក្នុងដែនរបស់ព្រះអង្គ។ ភោគទ្រព្យទាំងឡាយរបស់ព្រះរាជា ជាការប្រាសចាកឥតកោតញញើតតាមចំណង់ នឹងវិនាសទៅដោយពិត។ ការវិនាសនោះលោកពោលថាជាទុក្ខរបស់ព្រះរាជា ជាវត្ថុបទក្នុងការបញ្ហានោះឯង។ឥឡូវសូមព្រះអង្គសង្វាតធ្វើបុណ្យកុំជាអ្នកលេង កុំញាំងប្រយោជន៍ឱ្យវិនាស។ បពិត្រមហារាជ សូមព្រះអង្គមានសីល ព្រោះថាបុគ្គលអ្នកទ្រុស្តសីលឈ្មោះថា ជាអ្នកញាំងខ្លួនឱ្យធ្លាក់ចុះ។

ព្រះរាជា៖

-យើងបានសួរវស្សន្តរៈជាកោសិយគោត្រនិងនាងកុណ្ឌលិនីដោយប្រការដូច្នោះហើយ។ ដូច្នេះម្នាលកម្ពុកៈ ឥឡូវនេះចូរអ្នកពោលនូវកម្លាំងដ៏ឧត្តមជាងកម្លាំងទាំងឡាយ។



www.elibraryofcambodia.org

ស្តេចសេកកម្ពុកៈ៖

_ពោធិសត្វពោលតបថា ៖ កម្លាំងក្នុងលោកមាន ៥ យ៉ាង រមែងមានក្នុងបុរសដែលមានអធ្យាស្រ័យធំ។ បណ្តាកម្លាំងទាំងឡាយនោះ កម្លាំងកាយ ឬកម្លាំងដៃ បណ្ឌិតពោលថា ៖ ជាកម្លាំងថោកទាប។ បពិត្រព្រះអង្គមានព្រះជនវែង កម្លាំងភោគៈបណ្ឌិតពោលថា៖ ជាកម្លាំងទី ២។ កម្លាំងអាមាត្យ បណ្ឌិតពោលថា៖ ជាកម្លាំងទី ៣។ កម្លាំងជាតិខ្ពស់ ជាកម្លាំងទី៤ ឥតសង្ស័យឡើយ។ បុគ្គលជាបណ្ឌិតរមែងគ្របសង្កត់នូវកម្លាំងទាំងនេះ។ កម្លាំងប្រាជ្ញាជាកម្លាំងដ៏ប្រសើរ ជាកម្លាំងខ្ពង់ខ្ពស់ជាងកម្លាំងទាំងឡាយ។ បណ្ឌិតដែលមានកម្លាំងប្រាជ្ញាជ្រៅជ្រះហើយ រមែងបាននូវសេចក្តីចម្រើន។ បុគ្គលមានបញ្ញាទន់ទោះបីបាននូវផែនដីស្តុកស្តម្ភប្រសើរ កាល បើបុគ្គលមានបញ្ញាទន់នោះមិនមានប្រាជ្ញា បុគ្គលដែលមានបញ្ញាដទៃ តែងធ្វើនូវការកំហែង ហើយគ្រប់គ្រងនូវផែនដីនោះ។ បពិត្រព្រះអង្គជាម្ចាស់នៃដែនកាសី បើទុកជាបុគ្គលនោះមានជាតិខ្ពង់ខ្ពស់ជាក្សត្របាននូវរាជសម្បត្តិតែអប្បបញ្ញា ក៏រមែងមិនរស់នៅដោយរាជទាំងពួងបាន។ បញ្ញាជាធម្មជាតិសម្រាប់វិនិច្ឆ័យក្នុងសេចក្តីដែលបានស្តាប់។ បញ្ញាជាគ្រឿងញុំាងកេរ្តិ៍ឈ្មោះ និងលាភសក្ការៈឱ្យរីកចម្រើន។ នរជនប្រកបដោយបញ្ញាក្នុងលោកនេះ សូម្បីតែមានទុក្ខកើតឡើង ក៏រមែងបានសុខទាំងឡាយវិញ។ម្យ៉ាងទៀតបុគ្គលណាមិនស្តាប់ដោយគោរព មិនជឿនូវបុគ្គលជាពហុស្សូត មិនឈ្វេងយល់នូវកិច្ចការដែល



www.elibraryofcambodia.org

ស្ថិតនៅក្នុងសភាវៈ រមែងមិនទទួលបាននូវបញ្ញា។ លុះតែបុគ្គលណា ជាអ្នកដឹងនូវចំណែកនៃធម៌ ប្រឹងប្រែងក្នុងការគួរ ផលកើតអំពីការងារ ទើបសម្រេចដល់បុគ្គលនោះ។ កាលបុគ្គលមិនមានសីល ជាទីកើតនៃលាភ យស សុខ សេពគប់នូវបុគ្គលទ្រុស្តសីល មិនជាទីកើតនៃលាភ យស សុខ ធ្វើការធុញទ្រាន់ ប្រយោជន៍រមែងមិនឱ្យផលដោយប្រពៃទេ។ លុះតែបុគ្គលប្រកបកិច្ចខាងក្នុងសន្ដាន សេពគប់នូវបុគ្គលមានសីលជាទីកើតនៃលាភ យស សុខ ដូច្នោះហើយធ្វើការមិនធុញទ្រាន់ ប្រយោជន៍ឱ្យផលដោយប្រពៃ។ បពិត្រ! សូមព្រះអង្គសេពគប់រកនូវហេតុផលទាំងឡាយនោះ គឺបញ្ញាជាចំណែកនៃសេចក្តីព្យាយាមក្នុងហេតុដែលគួរប្រកប និងការថែទាំទុកនូវទ្រព្យដែលព្រះអង្គបាន។ សូមព្រះអង្គកុំញ៉ាំងទ្រព្យឱ្យវិនាស ដោយការងារមិនគួរ ព្រោះថាបុគ្គលឥតប្រាជ្ញា រមែងលិចចុះក្នុងសេចក្តីវិនាស។ ដោយហេតុជាអ្នកមិនចេះការងារ ដូចផ្ទះដែលគេធ្វើដោយដើមបបុស។ បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ គឺការបម្រើមាតាបិតាទាំងឡាយ។ បពិត្រព្រះរាជាលុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នោះនឹងទៅកាន់ស្ថានសួគ៌។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ គឺការសង្គ្រោះបុត្រភរិយាទាំងឡាយ។ លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ស្ថានសួគ៌។ សូមព្រះអង្គប្រព្រឹត្តចំពោះមិត្តនិងអាមាត្យទាំងឡាយ ចំពោះពាហនៈនិងពលទាំងឡាយ លុះព្រះអង្គប្រព្រឹត្តធម៌នេះហើយ នឹងទៅកាន់ស្ថានសួគ៌។ សូម



www.elibraryofcambodia.org

ព្រះអង្គប្រព្រឹត្តចំពោះជនអ្នកស្រុក អ្នកនិគម ចំពោះអ្នកដែន និង អ្នកជនបទ ចំពោះសមណៈ និងព្រាហ្មណ៍ទាំងឡាយ លុះព្រះអង្គ ប្រព្រឹត្តធម៌ក្នុងលោកនេះ ហើយនឹងទៅកាន់ស្ថានសួគ៌។ សូមព្រះ អង្គប្រព្រឹត្តធម៌ គឺឱ្យអភ័យចំពោះម្រឹគ និងសត្វបក្សីទាំងឡាយ។ សូម ព្រះអង្គប្រព្រឹត្តធម៌ ព្រោះធម៌ដែលព្រះអង្គប្រព្រឹត្តហើយ រមែងនាំ មកនូវសេចក្ដីសុខ។ សូមព្រះអង្គប្រព្រឹត្តធម៌ ព្រោះពួកព្រះឥន្ទ្រ ទេវតា ព្រមទាំងព្រហ្មបានដល់នូវទិព្វសម្បត្តិដោយធម៌ដែលខ្លួន ប្រព្រឹត្តល្អ សូមព្រះអង្គកុំធ្វេសប្រហែសចំពោះធម៌។ នេះជាវត្ថុបទ ក្នុងបញ្ហានេះឯង។ សូមព្រះអង្គសេពគប់នូវបុគ្គលមានបញ្ញា មាន គុណធម៌ល្អ ជ្រាបច្បាស់នូវធម៌ដ៏បរិបូណ៌ដោយព្រះអង្គឯង ប្រព្រឹត្ត តាមពាក្យប្រៀនប្រដៅនេះចុះ។



www.elibraryofcambodia.org

## ១៦. ស្តេចសេកពោធិសត្វ (សាលីកេទារជាតក)[១៩]

កាលពីយូរយារមកហើយ មានព្រះពោធិសត្វបានយោនយកកំណើតជាស្តេចសេកមួយឈ្មោះសាលីកេទារ រស់នៅក្នុងព្រៃភ្នំហេមពាន្ត។ បន្ទាប់ពីបានទទួលការគ្រប់គ្រងហ្វូងសត្វសេកដ៏ធំជាបរិវារ បន្តពីឪពុកចាស់ជរាមក ស្តេចសេកក្មេងតែងតែនាំហ្វូងសេកទាំងឡាយជាបរិវារ ទៅរកចំណីដោយសុខក្សេមក្សាន្តតាមវាលចន្លោះភ្នំដែលសម្បូណ៌ដោយស្រូវសាលីព្រៃដុះពាសពេញ ជាចំណីរបស់បក្សាបក្សីទាំងឡាយ។

ថ្ងៃមួយពួកសត្វសេកជាបរិវារ បានចូលមកជួបស្តេចសេកក្មេង ហើយលើកសំណូមពរថា៖ បពិត្រលោកម្ចាស់ជាទីគោរព! ពេលនេះជារដូវស្រូវសាលីនៅនគរមគធៈទុំបរិបូណ៌ហើយ។ ពួកយើងគួរនាំគ្នាទៅរកស៊ីនៅទីនោះ ព្រោះស្រូវសាលីនគរមគធៈមានរសជាតិឆ្ងាញ់ប្រហើរជាងស្រូវសាលីព្រៃដែលយើងយកជាចំណីអាហាររាល់ថ្ងៃនេះ។ បន្ទាប់មកពួកហ្វូងសេកក៏នាំគ្នាទៅស៊ីរៀងរាល់ថ្ងៃនៅនគរមគធរ:។ ដោយហ្វូងសេកនោះមានគ្នាដ៏ច្រើនលើសលប់ ពេលចុះស៊ីស្រូវម្តង១ ឆ្មាំយាមស្រែពុំអាចដេញសត្វសេកទាំងនោះឱ្យហើរចេញបានឡើយ ក៏បណ្តាលឱ្យស្រូវខូចខាតអស់ជាច្រើន។

---

[១៩] - ក្រុមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, ១៩៩៤, នវមភាគលេខ ៦០, ទំព័រ ១។



www.elibraryofcambodia.org

ដោយខ្លាចទទួលពិន័យកាត់ភោគផលពីម្ចាស់ស្រែ មេថ្នាំក៏នាំដំណឹងនេះទៅជូនលោកសេដ្ឋីកោសិយគោត្រជាចៅហ្វាយនាយខ្លួនថា៖

បពិត្រលោកម្ចាស់ ឆ្នាំនេះផលស្រូវសាលីល្អណាស់ តែខ្ញុំសូមជម្រាបលោកមេត្តាជ្រាបថា៖ មានហ្វូងសត្វសេកជាច្រើនចុះមកស៊ីស្រូវសាលីនេះ ខ្ញុំពុំអាចការពារបាន ក៏បណ្ដាលឱ្យពួកវាស៊ីតាមចិត្តទៅ។ លោកម្ចាស់! គួរឱ្យចម្លែកណាស់ នៅក្នុងចំណោមសត្វសេកទាំងអស់នោះ មានសេកមួយមាឌធំជាងគេ មានរូបចោមពណ៌សម្បុរល្អប្លែកគួរឱ្យចាប់អារម្មណ៍។ ជាងនេះទៅទៀត ជារៀងរាល់ថ្ងៃសេកនេះនៅពេលស៊ីឆ្អែតហើយ តែងពាំស្រូវសាលីជាច្រើនកួរយកទៅទុកស៊ីជាច្រើនថ្ងៃទៀត។ ឮដូច្នោះលោកសេដ្ឋីកោសិយគោត្រគិតថាសេកនេះពិតជាមេគេ ជាស្ដេចសេក ខ្ញុំចង់ឃើញវាណាស់ រួចលោកបញ្ជាទៅនាយថ្នាំថា៖ នាយថ្នាំ! ចូរអ្នកទៅដាក់អន្ទាក់ចាប់សេកនោះឱ្យបានទាំងរស់យកមកឱ្យយើងនៅទីនេះ។

ទទួលបញ្ជាដូច្នោះហើយ នាយថ្នាំក៏ទៅរៀបចំដាក់អន្ទាក់នៅត្រង់កន្លែងដែលមេសេកនោះតែងតែចុះស៊ីស្រូវសាលីរាល់ៗដង។ នាថ្ងៃបន្ទាប់ ពេលព្រលឹមស្រាងៗហ្វូងសត្វសេកដ៏ធំនោះក៏មកដល់ស្រែ ហើយនាំគ្នាស៊ីស្រូវដូចសព្វដង។ ពេលនោះសាលីកេទារក៏ចុះស៊ីស្រូវនៅកន្លែងដដែល។ រំពេចនោះជើងស្ដេចសេកក៏ធ្លាក់ជាប់នឹងអន្ទាក់ ហើយមានការឈឺចុកចាប់យ៉ាងខ្លាំង ទោះបីខំរើបម្រះយ៉ាងណាក៏ពុំរួច។ ដោយខ្លាចសេកទាំងឡាយនាំគ្នាភ័យផ្អើលចោទឡោខាន



www.elibraryofcambodia.org

ស៊ីចំណី ស្ដេចសេកខំអត់ទ្រាំនឹងការឈឺចុកចាប់ ហើយពិចារណាថា៖ តើខ្ញុំបានធ្វើបាបកម្មអ្វីបានជាមកជាប់អន្ទាក់នេះ? លុះដល់ពេលល្មមសមថាសត្វសេកជាបរិវារបានស៊ីចំណីឆ្អែតហើយ ទើបស្ដេចសេកចាប់ស្រែកយំឡើងយ៉ាងគ្រលួច ឱ្យជាសញ្ញាដល់ពួកសេកទាំងអស់ថាខ្លួនមានគ្រោះថ្នាក់ ដោយជាប់អន្ទាក់ហើយ។ ឮសម្រែកនោះសត្វសេកជាបរិវារភិតភ័យភ្ញាក់ផ្អើលជាខ្លាំង ហើយនាំគ្នាហោះហើរឈ្មុលពេញមេឃលើវាលស្រែ។

ស្ដេចសេកនៅជាប់អន្ទាក់តែម្នាក់ឯង ហើយពោលក្នុងចិត្តថា៖

-ពួកគេបានស៊ីឆ្អែត រួចក៏ហើរទៅបាត់អស់ មានតែខ្ញុំទេនៅជាប់អន្ទាក់តែម្នាក់ឯង តើខ្ញុំបានសាងបាបកម្មអ្វីទៅហ្ន៎! ពេលនោះនាយច្បាំមកដល់កន្លែងដាក់អន្ទាក់តែម្ដង គេមានសេចក្ដីរីករាយណាស់ ដោយឃើញស្ដេចសេកជាប់អន្ទាក់របស់ខ្លួនដូចបំណងមែន។

នាយច្បាំពោលថា៖

-នេះពិតជាសេកធំដែលយើងចង់បានមែន! ពោលដូច្នោះហើយ នាយច្បាំដោះសេកចេញពីអន្ទាក់ ចងជើងទាំងពីរជាប់គ្នា រួចក៏ធ្វើដំណើរដោយប្រញាប់ប្រញាល់ទៅកាន់គេហដ្ឋានលោកកោសិយគោត្រនៅភូមិសាលីទ្វិយគ្រាម។ ឃើញស្ដេចសេកភ្លាម លោកកោ-សិយៈមានចិត្តរំភើបត្រេកអរជាខ្លាំង ហើយទទួលយកសេកមកកាន់ដោយថ្នម ដោះខ្សែចំណងពីជើងចេញ រួចសួរសេកថា៖

-អ្នកមានមាឌធំ ពោះធំជាងគេ អ្នកស៊ីស្រូវសាលីយើងឆ្អែត



www.elibraryofcambodia.org

ហើយ តែងពាំស្រូវយើងយកទៅទៀត។ តើអ្នកស្អប់យើងដោយប្រការអ្វីមួយ ឬអ្នកមានជង្រុកធំប៉ុន្មានទៅសម្រាប់ទុកស្រូវនោះ ? ចូរអ្នកប្រាប់យើងឱ្យត្រង់មកចុះ តើយកស្រូវសាលីនោះទៅគរទុកនៅកន្លែងណា ? ពេលនោះស្តេចសេកនិយាយជាភាសាមនុស្សយ៉ាងផ្អែមល្ហែមទៅកាន់លោកសេដ្ឋីថា៖

លោកម្ចាស់កោសិយៈ! ខ្ញុំពុំបានស្អប់លោកម្ចាស់ដោយប្រការអ្វីមួយឡើយ ខ្ញុំក៏ពុំមានឃ្លាំងសម្រាប់គរទុកនូវស្រូវសាលីទាំងនោះដែរ។ នៅពេលដែលខ្ញុំទៅដល់ក្នុងព្រៃ ខ្ញុំយកគ្រាប់ស្រូវសាលីនេះទៅសងបំណុលផង ទៅបណ្តាក់បំណុលឱ្យគេផង (ឱ្យគេខ្ចី) ហើយមួយចំណែកទៀតខ្ញុំទុកក្នុងឃ្លាំងសម្រាប់ពេលក្រោយ។ នេះគឺជាចម្លើយដោយសច្ចៈរបស់ខ្ញុំ។

លោកកោសិយៈសួរបញ្ជាក់ថា៖

-ចូរអ្នកពន្យល់ខ្ញុំឱ្យច្បាស់មក ខ្ញុំពុំយល់ពីអត្ថន័យនៃចម្លើយរបស់អ្នកឡើយ។

ស្តេចសេកឆ្លើយតបថា៖

-ខ្ញុំមានមាតាបិតាចាស់ជរារបស់ខ្ញុំ ដែលលោករហើររកចំណីពុំរួច ទើបខ្ញុំយកកួរស្រូវសាលីនេះទៅចិញ្ចឹមលោកជាការសងបំណុល ដែលលោកបានចិញ្ចឹមថែរក្សា និងចិញ្ចឹមខ្ញុំជរាបវៀងមក។ ខ្ញុំមានកូនតូចៗ ដែលមានស្លាបទន់ខ្ចីនៅឡើយ ហើយរកចំណីខ្លួនឯងពុំទាន់កើត ខ្ញុំមានកាតព្វកិច្ចចិញ្ចឹមពួកគេឱ្យធំឡើងដោយគ្រាប់



www.elibraryofcambodia.org

សាលីនេះ។ នេះហើយជាការបណ្តាក់បំណុលរបស់ខ្ញុំ។ នៅក្នុងព្រៃជាមួយខ្ញុំមានសត្វសេកមួយចំនួនទៀតដែលចាស់ជរា ខ្លះខ្វិន ខ្លះខ្វាក់ភ្នែកហើររកចំណីដោយខ្លួនឯងពុំបាន ទើបខ្ញុំរើលេកស្រូវសាលីមួយផ្នែកសម្រាប់ចិញ្ចឹមពួកគេជាទានរបស់ខ្ញុំសម្រាប់អនាគត។ ខ្ញុំបានជម្រាបលោកម្ចាស់នូវការពិតទាំងអស់ហើយ។ពេលនោះលោកកោសិយៈបានស្តាប់ចម្លើយរបស់ស្តេចសេកដោយរន្ធត់ចិត្ត ក៏មានការស្រឡាញ់ហើយកោតសរសើរជាខ្លាំង។

លោកឆ្លើយទៅកាន់ស្តេចសេកវិញថា៖

-នេះជាឧត្តមគតិដ៏ខ្ពង់ខ្ពស់ណាស់របស់ជីវិត ចូរអ្នកមានសេចក្តីសុខចុះស្តេចសេកដ៏ប្រសើរ ! សូម្បីមនុស្សទាំងឡាយដែលរស់នៅលើផែនដីនេះ ក៏ខ្ញុំពុំដែលបានឮនូវឧត្តមគតិ និងពាក្យពេចន៍ដ៏ពិរោះយ៉ាងនេះឡើយ។ ចូរអ្នកមកចុះ នាំទាំងបរិវារអ្នកទាំងអស់ យើងនឹងប្រគល់ស្រូវសាលីនៃផ្ទៃដីចំនួន១០០០ អា សម្រាប់ពួកអ្នកមកស៊ីចុកតាមសេចក្តីត្រូវការ។ យើងនឹងជួបគ្នាទៀត យើងរក្សាមិត្តភាពដ៏យូរអង្វែងតទៅ។ បន្ទាប់មកលោកកោសិយៈ ក៏យកថ្នាំមកលាបជើងទាំងពីររបស់ស្តេចសេកដែលត្រូវរបួស ហើយឱ្យចំណីដ៏ឆ្ងាញ់ៗដល់ស្តេចសេក។ ស្តេចសេកក៏ថ្លែងអំណរគុណចំពោះលោកកោសិយៈហើយថ្លែងថា៖

-ខ្ញុំបានទទួលនូវចំណីអាហារ និងមិត្តភាពដ៏ប្រសើរអំពីលោក



www.elibraryofcambodia.org

ម្ចាស់ សូមលោកម្ចាស់ថែរក្សាឪពុកម្តាយ និងអ្នកដែលចាស់ជរា ហើយធ្វើបុណ្យទានឱ្យបានចម្រើនគុណធម៌សម្រាប់អ្នក។ ចំពោះអំណោយដ៏ថ្លៃថ្លា ១០០០ អានោះ ជាអំណោយធំធេងណាស់ ខ្ញុំសូមទទួលយកតែ ៨ អា ក៏គ្រប់គ្រាន់សម្រាប់ពួកខ្ញុំទាំងឡាយហើយ។

កោសិយៈបានជូនពរស្តេចសេកថា ៖

-ចូរអ្នកត្រឡប់ទៅវិញដោយសុវត្ថិភាពចុះ ហើយលួងលោមឪពុកម្តាយអ្នកដែលកំពុងសោយសោកដោយបាត់រូបអ្នក។ ស្តេចសេកក៏បានលាលោកកោសិយៈដោយមេត្រីភាព និងជ្រាលជ្រៅជាទីបំផុត។ បន្ទាប់មកបាននាំមកជាមួយនូវកួរស្រូវសាលីមួយចំនួន ជាអំណោយរបស់លោកកោសិយៈត្រឡប់មកកាន់ព្រៃវិញ។ នៅពេលដែលសត្វសេកទាំងឡាយកំពុងជួបជុំគ្នាជាមួយមាតាបិតាចាស់ជរា យំសោកអំពីការបាត់បង់ស្តេចសេក។ រំពេចនោះ ស្រាប់តែស្តេចសេកបានត្រឡប់មកវិញដល់ទីកន្លែងដោយសុវត្ថិភាព។



www.elibraryofcambodia.org

## ១៧. សេកពោធិសត្វ[២០]

មានព្រាហ្មណ៍ម្នាក់ បានរៀបការជាមួយនាងព្រាហ្មណីឈ្មោះថាកោសិយានី។ អ្នកទាំងពីរនាក់គ្មានកូនសោះ តែបានចិញ្ចឹមកូនសេកឈ្មោលពីរក្បាល បងឈ្មោះពោដ្ឋបាទ(ជាព្រះពោធិសត្វ) ឯប្អូនឈ្មោះរាធ។

ថ្ងៃមួយបុរសជាប្តីត្រូវចេញទៅរកស៊ីជួញដូរនៅទីឆ្ងាយ។ មុននឹងចេញទៅ ព្រាហ្មណ៍បានផ្តាំឱ្យមើលថែម្តាយ ហើយផ្តាំទៀតថាបើមានរឿងអ្វីប្លែក ចូរអ្នកណែនាំម៉ែជំនួសឪពុកផង។

នៅពេលប្តីចាកចេញពីផ្ទះ នាងកោសិយានីដែលអស់ក្តីស្នេហាចំពោះប្តី បានប្រព្រឹត្តិក្បត់មិនត្រឹមតែជាមួយមនុស្សក្នុងផ្ទះទេ ថែមទាំងនាំបុរសពីខាងក្រៅចូលមកក្នុងផ្ទះទៀត។ សេករាធជាប្អូនបានពិគ្រោះជាមួយបងថា៖ លោកឪពុកមុនចាកចេញទៅ បានផ្តាំឱ្យពួកយើងមើលអ្នកម្តាយ ព្រោះខ្លាចក្រែងប្រព្រឹត្តិខុសឆ្គង។ ឥឡូវគាត់ខុសហើយ យើងគួរណែនាំអ្នកម្តាយឬយ៉ាងណា? សេកបងជាពោធិសត្វយល់សេចក្តីបានឆ្លើយតបថា៖ ប្អូនឯងនិយាយនេះរបៀបមនុស្សល្ងង់។ ធម្មតាមនុស្សស្រីមិនមានគំនិតស្តាប់នរណាទេ នៅពេលខ្លួនមានចំណង់។

---

[២០] - ក្រុមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, ១៩៩៤, នវមភាគលេខ ៦០, ទំព័រ ១។



www.elibraryofcambodia.org

បោដ្ឋបាទពោលគាថាថា៖ រាធអើយ! អ្នកមិនស្គាល់មនុស្សទាំងឡាយដែលមកក្នុងពេលរាត្រីទេ។ អ្នកនិយាយនេះជាប្រភេទមនុស្សល្ងង់ និយាយក្នុងពេលដែលម៉ែកោសិយានី គ្មានចិត្តស្រឡាញ់ជាមួយឪពុករបស់យើងឡើយ។

## ១៨. សេកពោធិសត្វ (សុវកជាតក)[៦៧]

ក្នុងអតីតកាល ពោធិសត្វកើតជាសេករស់នៅក្នុងព្រៃហេមពាន្តស្ថិតនៅតាមប្រឋច្នេរសមុទ្រ មានសេកច្រើនពាន់ជាបរិវារ។ សេកពោធិសត្វមានកូនមួយ ដល់ពេលធំសេកពោធិសត្វក៏អន់ភ្នែកព្រោះធម្មតាសេកដែលមានកម្លាំងអាចស្ទុះហើររហ័ស តែដល់វេលាចាស់ ភ្នែក នឹងចុះខ្សោយមុនគេ។ កូនរបស់សេកពោធិសត្វ ឱ្យមាតាបិតានៅក្នុងសំបុក ហើយតែងនាំយកអាហារមកចិញ្ចឹម។ ថ្ងៃមួយកូនសេកនោះទៅកន្លែងរកស៊ីលើកំពូលភ្នំ ក្រឡេកមើលទៅសមុទ្រឃើញកោះមួយ លើកោះមានព្រៃស្វាយផ្លែទុំលឿងដូចមាស។ ព្រឹកឡើងវេលាទៅរកស៊ី កូនសេកបានហោះចុះត្រង់ព្រៃស្វាយនោះ ចឹផ្លែស្វាយហើយ បានពាំយកផ្លែស្វាយទុំមកផ្ញើឪពុកម្ដាយ។ សេកពោធិសត្វចឹផ្លែស្វាយទុំ ចង់ចាំរសទើបពោលថា៖ កូនអើយ នេះផ្លែស្វាយទុំនៅ

---

[៦៧] - ក្រុមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, សត្តមភាគលេខ ៥៨ ទំព័រ ១៤១។



www.elibraryofcambodia.org

ក្នុងកោះឯណោះតើមែនឬ? កូនឆ្លើយថា៖ ពិតមែនហើយលោកឪពុក! ស្តាប់ឮពាក្យរបស់កូនឆ្លើយ ទើបនិយាយថា៖ កូនអើយ! ពួកសេកដែលទៅកាន់កោះនោះច្រើន តែពិបាករក្សាអាយុឱ្យបានវែង ចូរកូនកុំទៅកោះនោះទៀត!

កូនសេកមិនជឿពាក្យរបស់ឪពុក គេនៅតែទៅបន្តទៀត។ ពេលមួយ កូនសេកចីផ្លែស្វាយជាច្រើន ហើយពាំផ្លែស្វាយទុំមកផ្ញើម៉ែឪទៀត។ ពេលហើរមកដល់ពាក់កណ្តាលសមុទ្រ ដោយហើរលឿនពេករាងកាយក៏ខ្សោយកម្លាំង ព្រោះភាពចុកចាប់ដែលកំពុងពាំផ្លែស្វាយទុំនឹងចំពុះ ក៏ធ្លាក់ទៅក្នុងទឹកព្រមទាំងខ្លួនផង។ កូនសេកនោះក៏លិចចុះទៅក្នុងទឹក មានត្រីមួយក្បាលបានលេបត្របាក់កូនសេកនោះទៅ។

កាលកូនសេកនោះ មិនបានមកតាមពេលវេលាសេកពោធិសត្វក៏ដឹងថា៖ កូនប្រាកដជាធ្លាក់ក្នុងសមុទ្រស្លាប់ហើយ។ ម៉ែឪរបស់កូនសេកមិនមានអាហារបរិភោគ ស្គមស្គាំងក៏ស្លាប់ទៅ។

ព្រះសាស្តាបាននិទានរឿងនេះរួចហើយ ព្រះអង្គក៏ត្រាស់គាថាថា៖ សត្វហើរ គឺសេកត្រូវដឹងប្រមាណក្នុងភោជនដរាបណា ក៏នឹងបានអាយុវែង បានចិញ្ចឹមមាតាបិតាផងដរាបនោះ។ មួយទៀត សេកនោះចីភោជនលើសលប់កាលណា ក៏លិចចុះក្នុងសមុទ្រនោះឯង ក្នុងកាលនោះ ព្រោះសេកមានៈមិនស្គាល់ប្រមាណ។



www.elibraryofcambodia.org

## ១៩. ក្ងោកមាសពោធិសត្វ (មោរជាតក)[៦២]

សម័យថ្ងៃមួយមានព្រះសង្ឃមួយអង្គចង់សឹកចាកផ្នួស ព្រោះដោយសារឃើញស្ត្រីម្នាក់មានរូបសម្បត្តិល្អពេក។ ដោយទ្រង់ព្រះញាណ ព្រះសមណគោតមមានព្រះបន្ទូលណែនាំថា៖

-ហេតុអ្វីបានជាចង់រកភេទថោកទាប ដោយសារតែកិលេសបោកប្រាស់?

បន្ទាប់មកព្រះពុទ្ធក៏ប្រទានរឿងពីអតីតកាល ដែលព្រះអង្គធ្លាប់ចាប់កំណើតជាសត្វក្ងោកមាសដូចតទៅ៖

តថាគតពីអតីតជាតិ ក៏ធ្លាប់ជួបប្រទះនឹងកិលេសដែរ គឺមានជាតិកំណើតជាសត្វក្ងោកមាសឈ្មោលមួយនៅក្នុងនគរពារាណសី។ ថ្ងៃមួយមានព្រានព្រៃម្នាក់បានទៅដល់ព្រៃហេមពាន្ត ដែលជាទីស្នាក់អាស្រ័យនៅរបស់សត្វក្ងោកមាសនោះ។ ពេលបានជួបនឹងសត្វក្ងោកមាស ព្រានដេញចាប់មិនបានដោយសារខ្លួនចាស់ គាត់ក៏ត្រឡប់មកផ្ទះវិញប្រាប់កូន ដើម្បីឱ្យទៅរុករកចាប់ឱ្យបាន។

សម័យកាលមួយ ព្រះជាយានៃព្រះរាជានគរពារាណសីទ្រង់មានព្រះគភ៌។ ព្រះនាងចាញ់ផ្ទៃខុសគេ គឺចង់ស្តាប់ព្រះធម៌ទេសនារបស់សត្វក្ងោកមាសមួយ។ មូលហេតុគឺដោយសារព្រះនាងបាន

---

៦២ - ក្រុមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, សត្តមភាគលេខ ៥៨ ទំព័រ ៧៣។



www.elibraryofcambodia.org

យល់សុបិនឃើញសត្វក្ងោកមាសមួយចេះសម្ដែងព្រះធម៌គួរឱ្យជ្រះថ្លា។ ព្រះរាជាទ្រង់ចូលចិត្តណាស់ តែក៏បានបញ្ជាឱ្យអាមាត្យដើរទៅស៊ើបសួររកក្ងោកមាសតាមការយល់សុបិនរបស់ព្រះមហេសី។ ដោយសារខ្លាចព្រះរាជអាជ្ញា អាមាត្យក៏ថ្វាយបង្គំលាទៅព្រៃ ប្រកបដោយចិត្តមិនរីករាយដែលដក់ដោយអារម្មណ៍ថា៖

ក្នុងព្រៃនោះកុំថាឡើយមានសត្វក្ងោកមាស សូម្បីតែមនុស្សក៏គ្មានអ្នកចេះទេសនាដែរ។ បន្ទាប់មកអាមាត្យបានដើរប្រមូលព្រានព្រៃដើម្បីសាកសួរ ក្រែងលោមានអ្នកណាធ្លាប់ជួបប្រទះនឹងក្ងោកមាស។ ពេលនោះកូនព្រានព្រៃស្ដាប់ឮ ក៏បានឆ្លើយបញ្ជាក់ប្រាប់អាមាត្យថាឪពុកខ្លួនធ្លាប់និយាយរឿងរ៉ាវនេះប្រាប់ ខ្លួនបានដឹងដែរ។ អាមាត្យក៏បានទៅទូលថ្វាយដំណឹងដល់ព្រះរាជា។ ព្រះរាជាបានចាត់សេនា និងអាមាត្យ ព្រមទាំងព្រានព្រៃទាំងអស់ដើម្បីទៅស្ទាក់ចាប់ក្ងោកមាសនោះឱ្យទាល់តែបាន ព្រះអង្គនឹងប្រទានរង្វាន់ជាទីគាប់ចិត្ត។ រៀងរាល់ថ្ងៃរាល់ពេល ក្ងោកមាសនេះតែងរក្សាសីលសូត្របរិត្តជានិច្ច។

នៅពេលព្រះអាទិត្យរះម្ដង ក្ងោកមាសសូត្របរិត្តមួយគាថាថា៖ **ឧទេ្ធតយញ្ចក្ខុមា ឯករាជា**[៦៣] ពេលព្រះអាទិត្យរៀបអស្ដង្គតក្ងោកមាសសូត្របរិត្តមួយគាថាទៀតថា៖ **អបេតយញ្ចក្ខុមា ឯករាជា** [៦៤] ដូច្នេះជា

[៦៣]-ព្រះអង្គឯកទ្រង់មានព្រះនេត្រ ព្រះអង្គកំពុងរះឡើងគោរពព្រះអាទិត្យសិរីមួយ។
[៦៤]-ព្រះអង្គឯកទ្រង់មានព្រះនេត្រ ព្រះអង្គកំពុងស្ដេចយាងទៅទិសខាងលិចដូច្នេះ។



www.elibraryofcambodia.org

ដើម។ ដោយអំណាចបរិត្តបារមី ទោះបីជាអាមាត្យ ព្រានព្រៃ បាន ដាក់អន្ទាក់គ្រប់ច្រកផ្លូវផ្សេងៗគ្នាច្រើនយ៉ាងណាក៏ដោយ ក៏បរិត្តការ ពារមិនឱ្យអន្តរាយអាចចាប់ក្ងោកមាសនោះបានឡើយ។ ទោះបីជា មានព្រានខ្លះបានចាប់ស្ទាក់រហូតដល់អស់ជីវិតផងក៏មាន។

ដោយហេតុតែមិនបានស្តាប់ព្រះធម៌ទេសនារបស់ក្ងោកមាស ព្រះមហេសីនៃព្រះរាជានោះក៏សុគតទៅ។ ព្រះរាជាខ្ញាល់យ៉ាងខ្លាំង ហើយយល់ថានរណាបានស៊ីសាច់ក្ងោកមាសនឹងមិនចាស់ មានជីវិត អមតៈ។ នៅមុនពេលសុគត ព្រះអង្គបានចារលើសន្លឹកមាសដាក់ក្នុង ហិប ដើម្បីទុកប្រទានពត៌មានចំពោះព្រះរាជាដែលសោយរាជ្យ ក្រោយៗ ដើម្បីខិតខំស្វះស្វែងរកចាប់ក្ងោកមាសនេះឱ្យបាន។ ព្រះរាជា ដែលបានសោយរាជ្យជាបន្តបន្ទាប់ តែងចាត់ចែងបញ្ជាពពួកព្រាន ព្រៃឱ្យទៅចាប់ក្ងោកមាសនោះរហូតដល់ព្រះរាជាទី៦ ក៏នៅតែចាប់ មិនបាន។ ព្រះរាជាទី ៧ មានព្រះតម្រិះដោយយល់ពីបញ្ហាដែលក្ងោក មាសតែងសូត្របរិត្តនោះ គឺជាធម៌ដ៏ប្រសើរទើបធ្វើឱ្យដាក់អន្ទាក់មិន ជាប់ ព្រះអង្គក៏បញ្ជាឱ្យអាមាត្យទៅរកទាក់ក្ងោកញីមួយក្បាល ដើម្បី យកមកប្រលោមលួងលោម។ នៅពេលក្ងោកមាសកំពុងសូត្របរិត្ត ក្ងោកញីតែងទៅជិតនែបនិត្យជានិច្ច។ ដោយសារកិលេសតណ្ហាអុច អាល ចិត្តក្ងោកមាសលង់ខ្លួនភ្លេចប្រតិបត្តិធម៌ ពួកព្រានឃើញឱកាស ល្អហុចឱ្យ គេក៏បានយកអន្ទាក់ទៅដាក់ក្បែរជើងក្ងោកញីក៏បណ្តាល ឱ្យព្រានព្រៃចាប់បានដូចបំណង។



www.elibraryofcambodia.org

ពេលនោះក្ងោកមាសក៏ភ្ញាក់ខ្លួន ហើយសួរទៅពួកព្រានព្រៃថា៖

-អ្នកចាប់យើងដើម្បីយកទ្រព្យឬ ? បើយ៉ាងដូច្នេះមែន ចូរអ្នកកុំសម្លាប់ខ្ញុំ! គឺយកខ្ញុំទៅថ្វាយព្រះរាជាទៅ ពួកអ្នកនឹងបានទ្រព្យហើយ។

## ២០. ស្ដេចក្ងោកពោធិសត្វ ( មហាមោរជាតក)[៦៥]

ស្ដេចក្ងោកពោធិសត្វពោលថា៖

-ម្នាលសម្លាញ់! ប្រសិនបើអ្នកចាប់ខ្ញុំព្រោះហេតុនៃទ្រព្យ ចូរអ្នកកុំសម្លាប់ខ្ញុំ គឺចាប់យកទាំងរស់ ហើយយកខ្ញុំទៅកាន់សំណាក់ព្រះរាជាចុះ អ្នកទំនងជានឹងបានទ្រព្យច្រើន។

កូនព្រានព្រៃពោលថា៖

-ធ្នូ និង ព្រួញដ៏ប្រសើរនេះ ខ្ញុំមិនយិតប្រុងប្រៀបដើម្បីនឹងបាញ់អ្នកក្នុងថ្ងៃនេះទេ តែខ្ញុំបាញ់ផ្ដាច់អន្ទាក់ទេតើ។ ចូរអ្នកទៅតាមសប្បាយចុះ។

ស្ដេចក្ងោក៖

-អ្នកខំទ្រាំស្រេកឃ្លានទាំងយប់ទាំងថ្ងៃ ដើរជាប់តាមខ្ញុំអស់រយៈពេល ៧ ឆ្នាំហើយ។ ដោយសារហេតុអ្វីក៏អ្នកចង់ដោះខ្ញុំដែលកំពុងជាប់អន្ទាក់ ហើយដោះឱ្យរួចទៅវិញ? តើអ្នកទើប

---

[៦៥]- ក្រុមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, ១៩៩៤, នវមភាគលេខ ៦០, ទំព័រ ៣។



www.elibraryofcambodia.org

នឹងវៀរចាកបាណាតិបាតក្នុងថ្ងៃនេះឬ? ឬក៏ឱ្យអភ័យដល់សត្វទាំងពួងដែលកំពុងជាប់អន្ទាក់ឱ្យរួចចាកអន្ទាក់ ?

កូនព្រានព្រៃ៖

_ម្នាលស្តេចក្ងោក ចូរអ្នកប្រាប់អំពីបុគ្គលដែលវៀរចាកបាណាតិបាតផង អ្នកដែលឱ្យអភ័យដល់អ្នកទាំងពួងផង។ ខ្ញុំសូមសួរអ្នកត្រង់សេចក្តីនេះថា៖ តើបុគ្គលនោះពេលច្យុតអំពីលោកនេះទៅនឹងបានសេចក្តីសុខយ៉ាងដូចម្តេច ?

ស្តេចក្ងោក៖

_ខ្ញុំនឹងប្រាប់ពីបុគ្គលដែលវៀរចាកបាណាតិបាតផងនិងអ្នកដែលឱ្យអភ័យដល់សត្វទាំងពួងផង។ បុគ្គលនោះរមែងបាននូវសេចក្តីសរសើរក្នុងបច្ចុប្បន្នផង ហើយលុះបែកធ្លាយសរីរៈទៅនឹងបានទៅកើតនៅស្ថានសួគ៌។

កូនព្រានព្រៃ៖

_សមណៈព្រាហ្មណ៍ខ្លះបានពោលថា៖ ទេវតាទាំងឡាយមិនមានទេជីវៈក្នុងលោកនេះ រមែងដល់នូវសេចក្តីដាច់សូន្យ។ ផលនៃអំពើដែលធ្វើល្អ ធ្វើអាក្រក់ រមែងដល់នូវសេចក្តីដាច់សូន្យដូចគ្នា។ ទន្ទឹមនេះបានពោលថា៖ ទានជាគុណជាត គឺមនុស្សល្ងង់បញ្ញត្តិ ខ្ញុំជឿពាក្យរបស់សមណព្រាហ្មណ៍ទាំងនោះថាជាព្រះអរហន្ត។ ហេតុនេះហើយបានជាខ្ញុំសម្លាប់សត្វស្លាបទាំងឡាយ។



www.elibraryofcambodia.org

ស្តេចក្មេក៖

-ព្រះចន្ទ និង ព្រះអាទិត្យទាំងពីរនេះជារបស់ឃើញងាយភ្លឺរុងរឿងនៅឰដ៏អាកាស។ ព្រះចន្ទ និងព្រះអាទិត្យទាំងនោះជារបស់លោកនេះឬជាលោកដទៃ ? មនុស្សលោកហៅព្រះចន្ទ និង ព្រះអាទិត្យទាំងពីរថាជាអ្វី ?

កូនព្រាហ្មណ៍៖

-ព្រះចន្ទនិងព្រះអាទិត្យជារបស់ឃើញងាយ។ តែព្រះចន្ទ និងព្រះអាទិត្យ មិនមែនជារបស់លោកនេះទេ។ មនុស្សក្នុងលោកហៅព្រះច័ន្ទនិងព្រះអាទិត្យថាជាទេវតា។

ស្តេចក្មេក៖

-សមណព្រាហ្មណ៍ណាមិនពោលពីផលនៃកម្ម ដែលសត្វធ្វើល្អ ធ្វើអាក្រក់ ហើយម្យ៉ាងទៀតមិនពោលថា ទានជាគុណជាតដែលមនុស្សល្ងង់បញ្ញត្តិ សមណៈទាំងនោះជាអ្នកហីនវាទ ត្រូវគេដេញជេរទាល់ក្នុងព្យាករណ៍នេះមិនខាន។

កូនព្រាហ្មណ៍៖

-ពាក្យរបស់អ្នកនេះទៀងពិត ព្រោះទានជាគុណជាតឥតផលដូចម្តេចកើត ! ។ ផលនៃអំពើដែលសត្វធ្វើអាក្រក់ ធ្វើល្អក៏ដូចគ្នា។ ខ្ញុំធ្វើអំពើដូចម្តេច ធ្វើដោយហេតុ និងប្រព្រឹត្តដូចម្តេច ដើម្បីកុំឱ្យធ្លាក់ទៅនរក ។ ម្នាលស្តេចក្មេក សូមអ្នកប្រាប់សេចក្តីនោះដល់ខ្ញុំដោយឧបាយយ៉ាងណា ?



www.elibraryofcambodia.org

ស្តេចក្ងោក ៖

-ពួកសមណៈណាមួយនៅលើផែនដី ជាអ្នកស្លៀកសំពត់កាសាវៈប្រព្រឹត្តក្នុងភេទនៃបុគ្គលក្នុងផ្ទះ ត្រេចទៅបិណ្ឌបាតអំពីព្រឹកក្នុងកាលគួរ វាងចាកកិរិយាត្រេចទៅក្នុងកាលខុស ជាអ្នកស្ងប់រំងាប់។ ចូរអ្នកចូលទៅរកសមណៈទាំងនោះតាមការគួរក្នុងទីនោះទៅ ហើយសាកសួរចុះ ប្រយោជន៍ណាដែលជាទីពេញចិត្តរបស់អ្នក លោកនឹងប្រាប់នូវប្រយោជន៍នោះថាជាប្រយោជន៍ក្នុងពេលនេះ និងក្នុងលោកខាងមុខតាមទំនងនៃការចេះដឹងរបស់លោក។

កូនព្រានបានត្រាស់ជាបច្ចេកពុទ្ធ ហើយក៏សម្តែងថា ៖

-អាត្មាអញបានលះបង់ក្នុងភាពជាព្រានព្រៃក្នុងថ្ងៃនេះហើយ។ អាត្មាអញប្រៀបដូចជាពស់សកនូវសំណកចាស់ជាន់មុន ឬក៏ដូចដើមឈើមានស្លឹកខៀវជម្រុះចោលនូវស្លឹកលឿង។

បន្ទាប់មកបច្ចេកពុទ្ធធ្វើសច្ចៈកិរិយាថា ៖

-ពួកបក្សីច្រើនរយដែលអាត្មាអញបានចងទុកក្បែរ លំនៅរបស់អញ អាត្មាអញនឹងឱ្យនូវជីវិតដល់សត្វទាំងឡាយនោះក្នុងថ្ងៃនេះ។ អាត្មាអញបានរួចចាកកិលេស ហើយសត្វទាំងនោះចូលទៅកាន់លំនៅរបស់ខ្លួនចុះ។

អភិសម្ពុទ្ធគាថា ៖

-ព្រានព្រៃមានអន្ទាក់ក្នុងដៃត្រេចទៅក្នុងព្រៃ ដើម្បីទាក់ស្តេចក្ងោកដែលមានយស។ លុះទាក់បានហើយ ក៏បានរួចចាកក្តីទុក្ខ ដូចតថាគតដែលបានរួចចាកទុក្ខដោយស្វយម្ភូញាណដូច្នោះដែរ។



www.elibraryofcambodia.org

## ២១. ស្វាពោធិសត្វ(មហាកបិជាតក)[២៦]

មានបុរសម្នាក់បានដើរវង្វេងផ្លូវនៅក្នុងព្រៃហេមពាន្ត ហើយធ្លាក់ទៅក្នុងជ្រោះដ៏ជ្រៅទៀតផង។ ពេលនោះមានសត្វស្វាមួយបានទៅប្រទះឃើញ ក៏ជួយស្រោចស្រង់ដោយបោះវល្លិឱ្យគេតោងមកលើវិញ។ នៅពេលបានឡើងមកដល់ខាងលើវិញ ដោយអស់កម្លាំងពេកបុរសនោះក៏លង់លក់ដំណេកទៅ។ នៅពេលភ្ញាក់ពីដេក បុរសល្មើសគុណនោះមានចិត្តប្រទូស្តនឹងស្វាដោយយកដុំថ្មគប់ស្វា តែស្វានោះនៅតែមិនអន្តរាយដល់ជីវិត។ ទោះបីយ៉ាងដូច្នេះក៏ដោយ ស្វានៅតែមិនខឹង។ បន្ទាប់មកបុរសនោះក៏ដើរចុះឡើងៗដើម្បីរកផ្លូវចេញទៅភូមិស្រុកវិញ។

ឃើញដូច្នេះស្វានៅតែអាណិតទៀត ក៏ពោលថា ៖

-ខ្ញុំនឹងជូនអ្នកបានទៅកាន់ភូមិស្រុកវិញ តែយើងទាំងពីរនាក់មិនអាចដើរផ្លូវជាមួយគ្នាទេ គឺអ្នកដើរនៅដី ឯខ្ញុំដើរនៅលើដើមឈើ។

នៅពេលជូនដំណើរដល់ផ្លូវធំ អាចឱ្យគេរកឃើញផ្លូវឈប់វង្វេង ស្វាក៏បែកបុរសនោះមកព្រៃវិញ។ ក្រោយពីបានមកដល់ផ្ទះរស់នៅបានមួយរយៈមក បុរសនោះក៏ស្លាប់ទៅដោយសារកើត

---

[២៦] - ក្រុមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, ១៩៩៤, នវមភាគលេខ ៦០, ទំព័រ ១៤៣។



www.elibraryofcambodia.org

រោគសាច់លឿង។ ពេលស្លាប់ទៅ គេក៏បានកើតទៅជាប្រេត។ ថ្ងៃមួយ ព្រះបាទព្រហ្មទត្តបានយាងទៅក្រសាលក្នុងឧទ្យានមួយ ក៏បានជួបនឹងប្រេតនោះ។

ពេលព្រះអង្គជួបប្រេតនោះ ព្រះអង្គបានមានព្រះបន្ទូលសួរទៅប្រេតថា៖

-រឿងហេតុអី បានជាអ្នកទទួលបាបកម្មកើតជាប្រេតដូច្នេះ?

ប្រេតបានទូលតបវិញថា៖

-ប្រការដែលខ្ញុំព្រះករុណាបានធ្លាក់ខ្លួនជាប្រេតដូច្នេះ ក៏ព្រោះតែការរមិលគុណ គឺមិនស្គាល់គុណអ្នកដែលជួយស្រោចស្រង់ជីវិតរបស់ខ្លួន។

## ២២. ស្វាពោធិសត្វ (មហាកបិជាតក)

ក្នុងកាលកន្លងទៅ ព្រះបាទព្រហ្មទត្តសោយរាជ្យសម្បត្តិនៅក្នុងក្រុងពារាណសី។ កាលនោះមានបុរសម្នាក់កំពុងភ្ជួរស្រែ។ បន្ទាប់ពីភ្ជួរស្រែរួច បុរសនោះបានលែងគោឱ្យស៊ីស្មៅ។ ចំណែកគាត់នៅបន្តកាប់ដីលើកភ្លឺស្រែ។ គោរបស់គាត់ចេះតែដើរស៊ីស្មៅតាមលំដាប់ៗ រហូតចូលទៅក្នុងដងព្រៃដ៏ធំបាត់ទៅ។ កាលដែលបុរសនោះក្រឡេករកមើលគោមិនឃើញ ក៏ធ្វើដំណើររកគោតាមដងព្រៃ។ ការស្វែងរកគោចេះតែធ្វើឱ្យបុរសនោះដើរជ្រុលទៅៗ ហើយបានវង្វេង



www.elibraryofcambodia.org

ផ្លូវចូលដល់ព្រៃហេមពាន្ត ។ ដោយអត់អាហារបរិភោគអស់រយៈពេល៧ថ្ងៃ បុរសនោះក៏ប្រទះឃើញដើមទម្លាប់មួយដុះប្របនឹងជ្រលងជ្រោះជម្រៅ៦០ហត្ថ គាត់ក៏ប្រឹងឈោងបេះ ហើយធ្លាក់ទៅក្នុងជ្រោះ។ គាត់មិនអាចរកឧបាយឡើងមកវិញបានទេ។ ដោយអស់កម្លាំងផង អត់អាហារផង និងផ្លូវឡើងលំបាកទៀត បុរសក៏ស្ថិតនៅទីនោះអស់រយៈពេល១០ថ្ងៃ ដែលជាហេតុបណ្តាលឱ្យសាច់គាត់ឡើងលឿង សរសៃរវាម មុខស្លេកស្លាំងស្ទើរតែផុតដង្ហើមលាចាកលោក។ គ្រានោះ មានពានរមួយដែលលោតពីដើមឈើមួយទៅដើមមួយ ដើម្បីបេះផ្លែឈើបរិភោគ ក៏ប្រទះឃើញ បុរសម្នាក់នៅក្នុងជ្រោះ។

ពានរក៏សាកសួរថា៖

-តើអ្នកជាមនុស្ស ឬ អមនុស្ស ? បានជាស្ថិតនៅទីនេះ ?

បុរសអ្នកស្រែក៏ប្រាប់ដំណើររឿងរបស់ខ្លួនដល់ពានរ។ ពានរដែលជាតួអង្គព្រះពោធិសត្វ មានចិត្តករុណាដ៏ជ្រាលជ្រៅចំពោះបុរសនោះ ហើយក៏ជួយយកអាសារដោយយកខ្សែវល្លិយ៉ាងមាំទៅចងនឹងដុំថ្មខាងលើ ហើយឱ្យបុរសនោះជិះលើខ្នងគោងក ដៃទាំងពីរខំប្រឹងព្យាយាមឡើងមកតាមជ្រលងជ្រោះរហូតមកដល់ខាងលើដូចក្តីបំណង។ ដោយការខំប្រឹងប្រែងដ៏មោះមុតក្នុងការជួយបុរសនោះ ពានរមានការនឿយហត់ អស់កម្លាំងជាពន់ពេក ក៏និយាយទៅកាន់បុរសនោះថា៖

-ចូរអ្នកជួយការពារសត្វសាហាវឱ្យខ្ញុំផង ! ឥឡូវនេះខ្ញុំអស់



www.elibraryofcambodia.org

កម្លាំងណាស់ខ្ញុំត្រូវការសម្រាកមួយស្របក់សិន។ នៅពេលពានរពោធិសត្វដេកលក់មួយសន្ទុះ បុរសក៏កើតមានចិត្តអាក្រក់ឡើងគិតថា៖

-ស្វានេះជាអាហាររបស់ពួកមនុស្ស ដូចពួកម្រឹគដទៃក្នុងព្រៃនេះដែរ។ បើដូច្នេះអាត្មាអញឃ្លានហើយ គប្បីសម្លាប់ពានរនេះធ្វើជាចំណីចី រួចហើយនឹងយកសាច់ធ្វើជាស្បៀង ដើម្បីធ្វើដំណើរទៅផ្ទះវិញ។

កាលគិតរួចហើយ បុរសក៏ចាប់ដុំថ្មគប់ក្បាលពានរមួយ ំហឹង តែដោយបុរសនោះនៅមានកម្លាំងខ្សោយនៅឡើយ ពានរគ្រាន់តែត្រូវរបួស មិនដល់ស្លាប់ឡើយ គ្រាន់តែបែកក្បាលហូរឈាមប៉ុណ្ណោះ ធ្វើឱ្យពានរភ្ញាក់ស្ទុះរត់ឡើងទៅលើដើមឈើយ៉ាងរហ័ស ដោយស្មានថាមានសត្វដទៃមកបៀតបៀនខ្លួន។ តែដោយរកមើលមិនឃើញក៏ប្រាកដក្នុងចិត្តថា៖ បុរសនោះជាអ្នកធ្វើទេតើ!។

ពេលនោះពានរបានតិះដៀលបុរសនោះថា៖

-នែមនុស្សអាក្រក់ ! យើងបានស្រង់ជីវិតអ្នកពីជ្រោះសែនជ្រៅបែបនេះ គឺដូចជានាំអ្នកពីលោកដទៃ ហេតុដូចម្តេចសម្គាល់ថាយើងជាបុគ្គលអ្នកប្រទូស្ត។ អ្នកឯងជាមនុស្សលាមក ជាមនុស្សដ៏អាក្រក់បំផុត ជាមនុស្សអកតញ្ញូ។ តែដោយចិត្តនៅតែករុណារបស់ពានរពោធិសត្វ ពានរក៏បាននាំបុរសនោះទៅរកផ្លូវត្រេចចររបស់មនុស្ស ឱ្យចេញរួចផុតពីការវង្វេងក្នុងព្រៃ។ ពានរពោធិសត្វបានឃើញ



www.elibraryofcambodia.org

បុរសបានដល់ទីសុវត្ថិភាព ហើយក៏វិលត្រឡប់ទៅក្នុងព្រៃវិញទៅ។ ចំណែកបុរសបានធ្វើដំណើរតាមផ្លូវឃើញអន្លង់ទឹកមួយ ក៏ចុះទៅក្បង់ទឹកផឹក ស្រាប់តែទឹកក្លាយទៅជាមានកម្តៅ ហាក់ដូចជាភ្លើងឆេះបោំងផ្ទុះមកប៉ះនឹងសាច់ ធ្វើឱ្យបុរសកើតជំងឺឃ្លង់ស ឃ្លង់ពពាលកើតស្រែង មានសាច់លានចេញដូចជាផ្លែវល្លួសផ្អុង មានដំបៅបុំនផ្លែញ្ញៅមួយចំហៀងពាសពេញខ្លួន ប្រៀបដូចជាប្រេត។ បុរសធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ មានក្លិនស្អុយផ្អាបគួរឱ្យខ្ពើមរអើម។ ធ្វើឱ្យមនុស្សម្នានៅគ្រប់ទីកន្លែង តែងដេញគប់បុរសនោះដោយដុំដី ដុំថ្ម និងដំបង។ល។ បុរសនោះត្រេចចរពីកន្លែងមួយទៅកន្លែងមួយអស់រយៈពេល ៧ ឆ្នាំ ក៏បានទៅសម្រាកក្នុងមិគាជិនឧទ្យានរបស់ព្រះរាជានៃក្រុងពារាណសី។

ព្រះរាជាបានសាកសួរបុរសនោះថា៖

-តើដោយសារហេតុអ្វី ឬមានអ្វីបៀតបៀនទើបអ្នកក្លាយជាយ៉ាងនេះ? បុរសនោះបាននិយាយរឿងសព្វគ្រប់ដូចពោលខាងលើ ហើយផ្តាំថា៖

-ពួកអ្នកដែលមកជួបជុំក្នុងទីនេះ សូមកុំប្រទូស្តពួកមិត្តឡើយ ព្រោះបុគ្គលប្រទូស្តមិត្តជាមនុស្សអាក្រក់។

ក្រោយពីបុរសនោះទូលព្រះរាជាចប់ ផែនដីក៏ស្រូបបុរសនោះទៅ។ បន្ទាប់ពីស្លាប់ទៅ បុរសក៏បានកើតក្នុងអវិចីនរកដោយឧបបាតិកកំណើត។



www.elibraryofcambodia.org

## ២៣. ស្វាពោធិសត្វ (មហាកបិជាតក)

កាលពីអតីតកាលដ៏យូរលង់ណាស់មកហើយ នៅក្នុងដែនកាសី មានស្តេចពានរមួយរស់នៅយ៉ាងសុខសាន្តជាមួយពានរទាំងឡាយចំនួន ៨ ម៉ឺន។ នៅតាមមាត់ទន្លេគង្គានៃព្រៃហេមពាន្ត មានដុះដើម ស្វាយមួយដើមដ៏ធំខ្ពស់ បែកមែកសាខាគួរជាទីមនោរម្យ។ ដើមស្វាយនេះជាជម្រកប្រចាំជីវិត និង ផ្តល់ជាអាហារដល់សត្វពានរ។ នៅក្រោមដើមស្វាយ តែងតែមានផ្លែទុំខ្ចីធ្លាក់ជាចំណីដ៏បរិបូណ៌សម្រាប់ពពួកពានរ។

ថ្ងៃមួយស្តេចពានរពិចារណាថា៖

-ថ្ងៃណាមួយយើងប្រាកដជាមានគ្រោះថ្នាក់ជាក់ជាមិនខាន ព្រោះបើមានស្វាយទុំណាមួយ ដែលនៅខាងលើមែកបែកមកលើមាត់ទន្លេ ហើយធ្លាក់ចុះទៅក្នុងទឹក រួចហូរទៅដល់ភូមិស្រុករបស់មនុស្ស។

គិតដូច្នោះហើយ ស្តេចពានរបានប្រមូលបរិវារទាំងអស់មកប្រាប់ថា៖ នែអ្នកទាំងអស់គ្នា ! ចូរប្រយ័ត្នឱ្យបានហ្មត់ចត់ជាទីបំផុត ដោយកុំឱ្យស្វាយទុំខាងមែកដែលនៅលើមាត់ទន្លេ ជ្រុះធ្លាក់ទៅក្នុងទឹកឱ្យសោះ។ យើងអាចនឹងទទួលគ្រោះថ្នាក់ដល់ជីវិត ប្រសិនបើមានពួកមនុស្សរើសបានផ្លែស្វាយទុំ។ ដូច្នេះចូរអ្នកទាំងឡាយចាប់បេះ ឬកម្ទេចចោលនូវផ្លែខ្ចីៗដែលដុះចេញពីមែកទៅខាងលើមាត់



www.elibraryofcambodia.org

ទន្លេ។ យើងធ្វើយ៉ាងនេះ គឺដើម្បីចៀសវាងកុំឱ្យមានផ្លែណាមួយទុំជ្រុះទៅក្នុងទឹក អាចរសាត់តាមទឹកហូរធ្លាក់ទៅដល់ដៃមនុស្សដែលរស់នៅតាមមាត់ទន្លេផ្នែកខាងក្រោម។ បន្ទាប់មកពួកពានរក៏ខំប្រុងប្រយ័ត្នធ្វើតាមបញ្ជាស្តេចពានរ ហើយរស់នៅយ៉ាងសុខសាន្ត។

ថ្ងៃមួយព្រះបាទព្រហ្មទត្ត ដែលគ្រប់គ្រងព្រះរាជាណាចក្រនៅក្រុងពារាណសីដោយសុខសាន្ត ព្រះអង្គមានព្រះបំណងចង់យាងទៅក្រសាលស្រង់ទឹកទន្លេគង្គា ដែលហូរកាត់មុខព្រះបរមរាជវាំង។ ពួកហែហមមាននាម៉ឺនសព្វមុខមន្ត្រី សេនាប្រុសស្រីមានចិត្តរីករាយក្នុងថ្ងៃសម្រាកនេះជាពន់ពេក ។ អ្នកខ្លះហែល អ្នកខ្លះមុជតាមចរន្តទឹកដ៏ថ្លាច្រង់ ដែលហូរធ្លាក់មកពីភ្នំហេមពាន្ត។ ឯអ្នកខ្លះទៀតស្ទូចត្រី បង់សំណាញ់ រាយមង ឬចែវទូកលេងបញ្ចេញសំឡេងអឺងកងខ្ទៀវខ្ទារព្រួរំពងយ៉ាងសប្បាយពេញទន្លេ។

កំពុងតែស្ថិតក្នុងសេចក្តីសប្បាយរីករាយនេះ ស្រាប់តែមានសេនាពីរនាក់ស្រែកឡើងថា ៖

-នែអ្នករាល់គ្នា ! យើងបង់សំណាញ់ទៅបានផ្លែឈើមួយធំណាស់។ ផ្លែនេះមានក្លិនក្រអូបឈ្ងុយឆ្ងាញ់ពន់ពេក មានរាងខុសប្លែក ចម្លែកណាស់ ពួកយើងពុំដែលជួបប្រទះឡើយ។ បន្ទាប់មកគេក៏យកផ្លែឈើដ៏ចម្លែកនោះទៅថ្វាយព្រះរាជា។ ព្រះអង្គទ្រង់ទតផ្លែឈើនោះ ហើយក៏ព្រះអង្គចូលចិត្តដឹងពីប្រភពនៃផ្លែឈើនោះណាស់។ បន្ទាប់មកព្រះអង្គក៏បានបញ្ជាឱ្យសេនាម្នាក់ទៅកោះអញ្ជើញព្រានព្រៃ



www.elibraryofcambodia.org

មកសួររកពីប្រភពនៃផ្លែឈើនោះ។

ក្រោយពីបានពិនិត្យមើលផ្លែឈើនោះហើយ នាយព្រានព្រៃបានទូលព្រះបាទព្រហ្មទត្តថា៖

-ផ្លែឈើនេះពិតជាផ្លែស្វាយ ដែលដុះតាមមាត់ទន្លេនាព្រៃហេមពាន្តប្រាកដណាស់។ ដោយបានទទួលរាជានុញ្ញាតពីព្រះបាទព្រហ្មទត្ត ព្រានព្រៃក៏បានភ្លក្សផ្លែស្វាយមុនគេ ហើយទូលថ្វាយព្រះរាជាបញ្ជាក់ថា៖

-នេះពិតជារសជាតិផ្លែស្វាយមែន។ ព្រះរាជាព្រមទាំងមន្ត្រីធំៗក៏បានភ្លក្សរសជាតិស្វាយទុំនោះបន្តិចម្នាក់ៗគ្រប់ៗគ្នា។ ដោយសារត្រូវទឹកសន្សើមនៃព្រៃហេមពាន្តវេលាយប់ ហើយមកត្រូវកម្ដៅព្រះអាទិត្យនៅពេលថ្ងៃ ផ្លែស្វាយនោះបង្កើនរសជាតិផ្អែមឈ្ងុយពិសេសអស្ចារ្យ ។ ម៉្យាងទៀតផ្លែស្វាយមានទំហំធំជាងផ្លែស្វាយនានាដែលមានដុះនៅក្នុងក្រុងពារាណសី។ ហេតុដូច្នេះ បានធ្វើឱ្យព្រះទ័យនៃព្រះរាជាជិតអារម្មណ៍ រហូតបណ្ដាលឱ្យរសាប់រសល់ចូលចង់ដឹងពីមូលហេតុនៃផ្លែស្វាយដ៏ចម្លែកនោះ ក៏បណ្ដាលឱ្យព្រះអង្គយល់ព្រះសុបិន។ ក្នុងរាត្រីនោះ ព្រះអង្គបានឃើញទាំងដើម ទាំងផ្លែលឿងទុំបក់រយីងរយោង តាមជំនោរខ្យល់គួរឱ្យរីករាយមេត្រីពន់ពេក។ ព្រឹកឡើងព្រះបាទព្រហ្មទត្តបានត្រាស់បង្គាប់នាយព្រានព្រៃ និងពលសេនារៀបចំក្បួនទ័ពសំដៅដង្ហែព្រះអង្គឡើងទៅកាន់ព្រៃហេមពាន្ត។ ការធ្វើដំណើរចំណាយពេលអស់មួយថ្ងៃគត់។ ក្បួន



www.elibraryofcambodia.org

ទ័ពបានដង្ហែព្រះរាជាមកដល់ដៃទន្លេគង្គានៃព្រៃហេមពាន្ត ដូចសេចក្តីប៉ង់ប្រាថ្នា។

ពេលនោះ នាយព្រានព្រៃបានចង្អុលទូលថ្វាយពីចម្ងាយថា៖

-បពិត្រព្រះរាជា! នោះហើយគឺជាដើមស្វាយទិព្វដែលព្រះអង្គកំពុងស្វែងរក។ ដើមស្វាយមួយហ្នឹងជាដើមឈើដ៏ធំ ហើយខ្ពស់សន្ធឹមជាងដើមឈើនានា មានមែកស៊ុបទ្រុបគ្របមកលើច្រាំងទន្លេ។

ព្រះរាជាត្រេកអរសព្វព្រះហឫទ័យឥតគណនា ហើយមានបន្ទូលថា៖

-ប្រពៃណាស់នាយព្រានព្រៃ តែយើងមិនអាចចូលទៅបេះផ្លែវាបានទេ ព្រោះរាត្រីកាលឈានចូលមកដល់ហើយ។ យើងត្រូវតែបោះជំរំសម្រាកនៅទីនេះសិន ចាំព្រឹកស្អែកយើងនឹងនាំគ្នាទៅបេះឱ្យបានច្រើន។

ខណៈនោះមានអាមាត្យម្នាក់បានទូលថ្វាយថា៖

-បពិត្រព្រះអង្គ! ទូលបង្គំឃើញហ្វូងហាក់មានសត្វស្វាលោតចុះលោតឡើងនៅលើដើមស្វាយនោះ។

ព្រះរាជាក៏ប្រឹងទតសម្លឹងទៅកាន់ដើមស្វាយនោះដែរ រួចមានព្រះបន្ទូលថា៖



www.elibraryofcambodia.org

-យីអើស្វាមែនទេតើ! នៅលើដើមស្វាយមានស្វាច្រើនណាស់។ ពួកវាហ៊ានមកបេះផ្លែស្វាយយើងស៊ីផង ? នែពួកកងទ័ព ! ចូរអ្នកដុតភ្លើងគប់ឱ្យបានច្រើន ដាំលំពែងឱ្យបាន ៥០០ ដើម ព្រមទាំងរៀបចំក្បួនឡោមព័ទ្ធជុំវិញដើមស្វាយ។ ពួកយើងត្រូវយាមការពារដោយប្រុងប្រយ័ត្ន កុំឱ្យពួកវារត់រួច។ លុះដល់ព្រឹកឡើងពួកយើងនឹងបេះផ្លែស្វាយផង ហើយបាញ់ពួកវាយកសាច់ធ្វើជាអាហារទៀត។

សំឡេងអ៊ូអរ និង សកម្មភាពជុំវិញដើមស្វាយរបស់ពលទាហានធ្វើឱ្យស្វាទាំងអស់មានការរន្ធត់ចិត្តភិតភ័យយ៉ាងខ្លាំង។ ពួកគេបានយកគ្រោះថ្នាក់នេះទៅទូលស្តេចពានរថា ៖

-ពេលនេះយើងមានគ្រោះថ្នាក់ដល់ជីវិតហើយ។ ពេលព្រឹកស្អែក ពួកទាហានច្បាស់ជាបាញ់សម្លាប់ពួកយើងមិនខាន។ តើមានមធ្យោបាយយ៉ាងណាដើម្បីគេចខ្លួនឱ្យរួចពីគ្រោះថ្នាក់ដល់ជីវិតគ្រប់ៗគ្នា បើពួកយើងមានគ្នាច្រើនម្លឹង១ ព្រមទាំងមានកូនចៅនៅតូចៗទៀត។

ស្តេចពានរបានពោលអះអាងដោយឥតតក់ស្លុត ចំពោះគ្រោះថ្នាក់នោះថា ៖

-ចូរអ្នកទាំងអស់គ្នាកុំអាលចោឡោ ចូរតាំងចិត្តឱ្យបានស្ងប់ស្ងាត់ធ្វើហាក់ដូចជាមិនបានឃើញព្រឹត្តិការណ៍អ្វីកើតឡើងទៅចុះ។ ខ្ញុំនឹងរកមធ្យោបាយដោះស្រាយជួយសង្គ្រោះជីវិតរបស់អ្នកទាំងអស់គ្នាឱ្យរួចផុតពីគ្រោះថ្នាក់បាន។ ស្តេចពានរពិនិត្យរកហេតុផលដែលនាំឱ្យផ្លែស្វាយជ្រុះធ្លាក់ដល់ដៃមនុស្សទៅតាមមាត់ទន្លេគង្គាដែលនៅ



www.elibraryofcambodia.org

ផ្នែកខាងក្រោម។

ស្តេចពានរបានសង្កេតឃើញសំបុកអង្ក្រងមួយយ៉ាងធំ ទើបរិនិច្ឆ័យថា៖

-សំបុកអង្ក្រងនោះហើយ ដែលមិនអាចបិទបាំងបញ្ហាផ្លែស្វាយទុំនោះ។ ចំពោះស្វាទាំងឡាយគ្មាមិនអាចចូលទៅជិតអង្ក្រងបានទេ។ ពេលផ្លែស្វាយទុំហើយនោះនឹងធ្លាក់ទៅក្នុងទឹក ដែលអាចរសាត់ធ្លាក់ដល់ដៃមនុស្ស ទើបបណ្តាលឱ្យមានគ្រោះថ្នាក់ដូច្នេះឯង។ ពិចារណារួចហើយ ស្តេចពានរក៏ឡើងទៅកាន់មែកស្វាយដែលខ្ពស់ទេរទៅលើមាត់ទន្លេ។ បន្ទាប់មកស្តេចពានរដែលមានកម្លាំងស្មើនឹងកម្លាំងដំរី៤ បានលោតបោះពួយយ៉ាងខ្លាំងសំដៅទៅកាន់ត្រើយម្ខាងទៀតនៃមាត់ទន្លេ។ ស្តេចពានរបានធ្លាក់ចូលទៅក្នុងគម្ពោតព្រៃឫស្សីមួយដ៏ក្រាស់។ ស្តេចពានរបានដកយកវល្លិ៍ផ្តៅធំមួយប្រវែង ១០០ ធ្នូរង្គ យកមកចងព័ទ្ធជុំវិញចង្កេះ រួចឡើងផុតកំពូលដើមឈើមួយដើមទៀតពីត្រើយម្ខាង។ ស្តេចពានរយកវល្លិម្ខាងចងភ្ជាប់នឹងមែកឈើដែលទេរមកកាន់មាត់ទន្លេ រួចស្តេចពានរយោលខ្លួនលោតផ្លោះបោះពួយយ៉ាងខ្លាំងសំដៅទៅកាន់ដើមស្វាយរបស់ខ្លួនវិញ។ តែគួរឱ្យស្តាយណាស់ ស្តេចពានរលោតពុំដល់កន្លែងវិញដូចបំណង ព្រោះវល្លិខ្លីជាងការស្មានទុក។ ស្តេចពានរត្រូវធ្លាក់មកប៉ះចុងមែកស្វាយមួយ ហើយក៏ខំប្រវារតោងជាប់ដោយដៃទាំងពីរ។ ស្តេចពានរបានយកដៃទាំងពីរ មកតោងបន្តភ្ជាប់ជាមួយមែកស្វាយជំនួសវល្លិ៍ផ្តៅវិញ។



www.elibraryofcambodia.org

នៅពេលដែលគោងមែកស្វាយដាច់ហើយ ស្តេចពានរបញ្ជាទៅកាន់ពលសេនារបស់ខ្លួន ឱ្យនាំគ្នាប្រញាប់ប្រញាល់ឆ្លងលើខ្នងរបស់ខ្លួនប្រៀបដូចជាស្ពានបន្តជាមួយវល្លិទៅដល់ត្រើយម្ខាងទៀត។ ក្នុងពេលកំពុងឆ្លងនោះ ពានរទាំងឡាយបាននាំគ្នាឱនគោរពសូមខមាទោសស្តេចរបស់ខ្លួន នាំគ្នាឆ្លងបន្តជាមួយវល្លិទៅកាន់ត្រើយម្ខាងទៀត។ ក្នុងពេលកំពុងឆ្លងនោះ មានពានរជានាយក្រុមមួយឈ្មោះ ទេវទត្តកបិមាន ចិត្តច្រណែននឹងស្តេចពានរពីមុនស្រាប់ក៏ឆ្លៀតឱកាសព្យាបាទនាយរបស់ខ្លួនដោយលោតទម្លាក់ខ្លួនយ៉ាងខ្លាំងលើខ្នងស្តេចពានរ ក៏បណ្តាលឱ្យស្តេចពានរបាក់ឆ្អឹងខ្នង និង ប្រេះបេះដូងមានការឈឺ ចុកចាប់យ៉ាងខ្លាំង។ ពេលនោះស្តេចពានរធ្លាក់ឈាមចេញតាមភ្នែក តាមមាត់ តាមច្រមុះ រងទុក្ខវេទនាយ៉ាងខ្លាំង ។ តែទោះបីមានរបួសធ្ងន់យ៉ាងណាក៏ដោយ ក៏ស្តេចពានរនៅតែខំស៊ូទ្រាំគោងមែកឈើឱ្យបរិវារទាំងអស់ឆ្លងលើខ្នងបន្តទៅទៀត។ ដោយខំប្រឹងគោងមែកស្វាយទប់ខ្លួនឱ្យបរិវារឆ្លងផង និងមានរបួសក្នុងខ្លួនយ៉ាងខ្លាំងផង ស្តេចពានរបានសន្លប់បាត់ស្មារតី តែដៃទាំងពីរនៅតែគោងមែក ឈើដដែលហាក់ដូចជារង់ចាំរហូតពល ទាំងអស់ឆ្លងបន្តទៀត ។ ពេញមួយរាត្រី ស្វាទាំង ៨ ម៉ឺនបានឆ្លងផុតពីគ្រោះថ្នាក់ទាំងអស់គ្នា។

ព្រះបាទព្រហ្មទត្តបានទតឃើញព្រឹត្តិការណ៍ដ៏អស្ចារ្យយ៉ាង



www.elibraryofcambodia.org

នេះ ព្រះអង្គមានព្រះហឫទ័យរន្ធត់ញាប់ញ័រ ស្រក់ទឹកព្រះនេត្រា ស្ញើចសរសើរផង និងអាណិតផង។

ព្រះអង្គពុំបានផ្ទំអស់មួយរាត្រី ដោយពិចារណាហើយមានបន្ទូលថា៖

-នេះគ្រាន់តែជាពានរសោះ ព្យាយាមប្រឹងប្រែងបណ្ដោះគ្នារត់ឱ្យរួចផុតពីគ្រោះថ្នាក់។ សូម្បីជីវិតរបស់ខ្លួនឯងក៏ពុំបានគិតឡើយ។ ព្រះតម្រិះដូច្នេះ ព្រះរាជាបានប្រើឱ្យនាយទាហានដ៏ចំណានយកស្នែងឡើងទៅលើដើមស្វាយ នាំគ្នាគ្រាហ៍យកស្ដេចពានរចុះមកក្រោម។ ព្រះរាជាបានបញ្ជាឱ្យគ្រូពេទ្យព្យាបាលរបួសពានរ។ ពួកគេនាំគ្នាជូតសម្អាតឈាមលើខ្លួន លាបប្រេងក្រអូប និងដណ្ដប់នូវផាហ៊ុំពណ៌លឿង ហើយផ្ដេកស្ដេចពានរទៅលើគ្រែដ៏ប្រណីតមួយ។ ព្រះរាជាគង់នៅក្បែរស្ដេចពានរដែលសន្លប់ពុំដឹងខ្លួន ដោយព្រះទ័យក្ដុកក្ដួលយ៉ាងខ្លាំង។ ព្រះអង្គគង់រង់ចាំដោយសង្ឃឹមថា ស្ដេចពានរនឹងបើកភ្នែករស់ឡើងវិញ។ បន្ទាប់មកប្រមាណជាង២យាមក្រោយមក ស្ដេចពានររើខ្លួនបន្តិចម្ដង១ ហើយបើកភ្នែកមើលជុំវិញខ្លួន។ ព្រះរាជាឃើញដូច្នោះក៏មានព្រះទ័យត្រេកអរជាពន់ពេក ព្រះអង្គឱនជិតត្រចៀកស្ដេចពានរដោយមានព្រះបន្ទូលរំភើបថា៖

-ម្នាលអ្នកពានរ! អ្នកយកដងខ្លួនធ្វើជាស្ពានសម្រាប់ចម្លងជីវិតអ្នកដទៃ ដោយអ្នកសុខចិត្តពលីកម្មជីវិតរបស់អ្នក។ តើអ្នកជានរណាដែរ ទើបសម្ដែងឡើងនូវការមិនតក់ស្លុតបន្តិចបន្តួចសោះអញ្ចឹង?



www.elibraryofcambodia.org

ស្តេចពានរឆ្លើយតបចំពោះព្រះរាជាវិញដោយទន់ភ្លន់ថា ៖

-បពិត្រព្រះរាជាដ៏ជាធំលើអស់ពួកមនុស្សនានានៃដែនកាសី ទូលព្រះបង្គំជាស្តេចពានរ។ ពានរទាំងឡាយនោះជាពលបរិវារកូនចៅរបស់ទូលព្រះបង្គំ។ គេទាំងឡាយផ្ញើសេចក្តីទុកចិត្ត និងវាសនារបស់គេមកលើទូលព្រះបង្គំ។ ទូលព្រះបង្គំមិនបារម្ភពីសេចក្តីមរណៈផ្ទាល់ខ្លួនឡើយ។ ឱ្យតែទូលព្រះបង្គំអាចរកសេរីភាពជូនពលបរិវាររបស់ទូលព្រះបង្គំបាននោះ ទូលព្រះបង្គំសប្បាយចិត្តណាស់ហើយ ព្រោះនាទីជាអ្នកគ្រប់គ្រងរក្សាសុខុមាលភាពរបស់ពួកគេ។ ទូលព្រះបង្គំត្រេកអរណាស់ដែលបានចម្លងពួកគេឱ្យផុតពីក្តីមហន្តរាយ។ ឱព្រះរាជា! ទូលព្រះបង្គំ និងព្រះអង្គមានតួនាទីដូចគ្នា។ បើអំពើរបស់ទូលព្រះបង្គំថ្ងៃនេះអាចចាត់ទុកជាមេរៀនសម្រាប់ព្រះអង្គ និងអ្នកគ្រប់គ្រងព្រះនគរក្នុងលោកទៅអនាគត សូមព្រះអង្គជ្រាបថាមិនមែនព្រះខ័ន ឬមកុដរបស់ព្រះអង្គទេ ដែលធ្វើឱ្យព្រះអង្គក្លាយទៅជាព្រះមហាក្សត្រល្អនោះ។ ផ្ទុយទៅវិញ មានតែសេចក្តីមេត្តា ករុណាចំពោះប្រជានុរាស្ត្រ ដែលធ្វើឱ្យព្រះអង្គក្លាយជាព្រះមហាក្សត្រពិត សូមព្រះអង្គព្រះមេត្តាជ្រាប។ សូមព្រះអង្គកុំយកអំណាចមកគ្រុតគ្រាប្រជានុរាស្ត្ររបស់ព្រះអង្គ។ ផ្ទុយទៅវិញ សូមព្រះអង្គយកធម៌មេត្តា និងករុណាមកអនុវត្តដើម្បីគ្រប់គ្រងព្រះនគរ ទើបប្រសើរជាង។ សូមព្រះមហារាជគ្រប់គ្រងរដ្ឋប្រកបដោយទសពិធរាជធម៌ និងមាននូវសង្គហធម៌ ទាំង៤គឺ ៖ ទាន១ បិយវាចា១ អត្ថចរិយា១ សមានត្តតា១ ចំពោះប្រជានុរាស្ត្ររបស់ព្រះអង្គសព្វកាល។ ពោលបាន



www.elibraryofcambodia.org

តែប៉ុណ្ណោះ មហាពានរក៏បិទភ្នែកផុតដង្ហើមលាចាកលោកនេះទៅ។ ព្រះរាជា និងពលសេនាទាំងប្រុសស្រីនាំគ្នាយំសោកស្តាយមហា-ពានរជាពន់ពេក។ ព្រះបាទព្រហ្មទត្តព្រះអង្គក៏បញ្ជាឱ្យនាំគ្នាដង្ហែសពមហាពានរយក ទៅធ្វើបុណ្យយ៉ាងអធិកអធមអស់រយៈពេល ៧ យប់ ៧ថ្ងៃនៅឯក្រុងពារាណសី។

ដើម្បីរំឭកដល់គុណធម៌ដ៏ខ្ពង់ខ្ពស់របស់មហាពានរ ព្រះរាជាបានសាងមហាចេតីយដ៏ប្រណីតថ្វាយដល់មហាពានរ ដោយចារឹកនាម និងឧទ្ទិសទុកថា " ចេតីយមហាពានរពារាណសី "។ ចាប់តាំងពីពេលនោះមក ព្រះបាទព្រហ្មទត្តបានគ្រប់គ្រងព្រះរាជា-ណាចក្រ ប្រកបដោយធម៌ដ៏ប្រពៃ តាមបណ្តាំស្តេចពានរ។ អំពើដ៏ប្រសើរនេះ នាំឱ្យអ្នកដែលរស់នៅក្នុងរដ្ឋកាសីទាំងមូលកាន់តែជួបនូវសេចក្តីសុខ សេចក្តីចម្រើន រុងរឿង ហើយរីតតែមានកិត្តិយសល្បីល្បាញលើសនគរនានាក្នុងសម័យនោះ។

នៅអវសានកថា ព្រះសម្មាសម្ពុទ្ធព្រះអង្គប្រជុំជាតកថាស្តេចពានរនោះ ជាព្រះពោធិសត្វដែលអន្ទោលជាតិមកកើតជាតួអង្គនៃតថាគតនេះឯង។ ដោយសារការខំសាងបុណ្យបារមីក្នុងជាតិជាបន្តបន្ទាប់។ មិនតែប៉ុណ្ណោះដោយការជាប់ចិត្តស្រឡាញ់គោរពមហាពានរនោះផង ព្រះបាទព្រហ្មទត្តក៏បានយោនយកកំណើតមកកើតជាព្រះអនន្ទត្ថេរនោះឯង។ ចំណែកឯលោលកបិដែលបៀតបៀនស្តេចពានរនោះ បានមកកើតជាទេវទត្ត។



www.elibraryofcambodia.org

## ២៨. ស្វាពោធិសត្វ (វានរិន្ទជាតក)[២៧]

ក្នុងអតីតកាលព្រះពោធិសត្វសោយព្រះជាតិជាស្វា។ ពេលចម្រើនវ័យមានមាឌធំប៉ុនកូនសេះ ពេញដោយភាពក្លៀវក្លាត្រាច់ចុះទៅតាមច្រាំងស្ទឹងម្នាក់ឯង។ កណ្ដាលស្ទឹងនោះមានកោះមួយ សម្បូរផ្លែឈើផ្សេងៗមានស្វាយខ្នុរជាដើម។ ព្រះពោធិសត្វមានកម្លាំងដូចដំរីសារ បរិបូរណ៍ដោយភាពរឹងមាំ តែងហក់លោតពីច្រាំងស្ទឹងម្ខាងទៅច្រាំងស្ទឹងម្ខាងទៀត ហើយឈរលើថ្មដាមួយផ្ទាំងដែលដុះនៅកណ្ដាលទឹកជិតកោះនោះ។ ស្វាក៏តែងផ្លោះពីដុំថ្មឡើងទៅលើកោះមួយទៀត ដើម្បីបេះផ្លែឈើ។ ស្វាពោធិសត្វ តែងចេញដំណើរនៅពេលព្រឹក ហើយរៀងរាល់ពេលល្ងាចទើបហក់ត្រឡប់មកវិញតាមវិធីដដែល។

ថ្ងៃមួយមានសត្វក្រពើមួយក្បាលរស់នៅក្នុងទឹក ប្រពន្ធរបស់គេឃើញស្វាពោធិសត្វលោតផ្លោះទៅមកៗ ក៏កើតត្រូវការចង់ចីបេះដូងរបស់ស្វា។ នាងនិយាយជាមួយប្ដីថា៖ នែលោកប្ដី! ខ្ញុំមានផ្ទៃពោះចង់ចីបេះដូងរបស់ស្វានោះ។ ក្រពើជាប្ដីពោលថា៖ ល្អណាស់! នាងនឹងបានចីបាប់ៗនេះហើយ។ ថ្ងៃនេះបងនឹងចាប់វាយកបេះដូងឱ្យបាន។ និយាយរួចហើយ ក៏ទៅដេកសន្ធឹងលើទឹកដូចផ្ទាំងថ្ម។ ព្រះ

[២៧] - ក្រមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, សត្តមភាគលេខ ៥៨ ទំព័រ ២៥។



www.elibraryofcambodia.org

ពោធិសត្វត្រាច់ទៅក្នុងថ្ងៃនោះនាពេលព្រឹក តែដល់ពេលល្ងាចរៀបហក់មកវិញ ក៏កើតក្ដីចូល់ ឈរសម្លឹងមើលតាមជាយកោះដោយត្រិះរិះថា ៖ ដែនថ្មនេះខ្ពស់ជាងថ្មមុន ព្រោះហេតុអ្វី ? ព្រះពោធិសត្វកំណត់ដឹងថាផ្ទាំងថ្មនិងទឹកខុសប្លែកថ្ងៃមុន កើតក្ដីសង្ស័យទើបនិយាយនឹងដុំថ្មថា៖ ផ្ទាំងថ្មអ្នកដ៏ចម្រើន! តែមិនមានការឆ្លើយតបក៏ពោលទៀតថា៖ ថ្ម! ថ្ម! ថ្ម! និយាយបន្ត ៖ តើត្រូវនិយាយពាក្យដូចម្ដេចទើបឯងនិយាយតប! ស្វាពោធិសត្វនៅតែពោលទៀត ៖ នែថ្មដ៏ចម្រើន ហេតុអ្វីថ្ងៃនេះអ្នកមិននិយាយតបនឹងខ្ញុំដូចថ្ងៃមុនៗ ? ក្រពើស្ដាប់ហើយគិតថា៖ ថ្ងៃមុនៗផ្ទាំងថ្មនេះតែងនិយាយតបនឹងស្វាហើយមើលទៅ ! ឥឡូវអញនឹងឆ្លើយតបចំពោះគេដែរ។

-រំពេចនោះក៏លាន់មាត់ឆ្លើយថា៖ មានរឿងអ្វីឬស្វាដ៏ចម្រើន?

-ព្រះពោធិសត្វសួរថា៖ អ្នកជានរណាហ្នឹង?

-ក្រពើ ៖ យើងជាក្រពើ!

-ព្រះពោធិសត្វ ៖ អ្នកមកដេកនៅទីនេះ ត្រូវការអ្វី ?

-ក្រពើ ៖ យើងត្រូវការបេះដូងរបស់អ្នក !

ព្រះពោធិសត្វគិតថា ៖ យើងមិនមានផ្លូវណាត្រឡប់ទៅវិញទេ។ ថ្ងៃនេះយើងត្រូវល្បួងលោមក្រពើនេះសិន ក៏និយាយជាមួយក្រពើថា៖ ក្រពើជាទីស្រឡាញ់ ! យើងនឹងកាត់រាងកាយឱ្យអ្នកចុះ ចូរអ្នកហាមាត់ទទួលយើង ក្នុងវេលាដែលយើងលោតទៅដល់មាត់អ្នក។ ពោធិសត្វនិយាយយ៉ាងនេះ ព្រោះយល់ថាជាធម្មតាក្រពើពេលហា



www.elibraryofcambodia.org

មាត់តែងធ្មេចភ្នែក។ ឯក្រពើមិនទាន់បានកំណត់ហេតុនោះក៏ហារមាត់។ រំពេចនោះភ្នែករបស់វាក៏បិទជិត ព្រោះវាធ្លាប់ដេកហារមាត់បិទភ្នែក។ ព្រះពោធិសត្វដឹងសភាពដូច្នោះ ក៏ផ្លោះចេញអំពីកោះជាន់លើក្បាលក្រពើ ហើយលោតពីក្បាលក្រពើទៅមាត់ច្រាំងស្ទឹងម្ខាងទៀតរហ័សដូចផ្លេកបន្ទោរ។ ក្រពើឃើញហេតុអស្ចារ្យនោះគិតថា៖ ស្វានេះជាសត្វអស្ចារ្យណាស់។ ភ្លាមនោះក្រពើនិយាយថា៖ ស្វាដ៏ចម្រើន ! ក្នុងលោកនេះ បុគ្គលប្រកបដោយធម៌បួនប្រការរមែងសង្កត់សត្រូវបាន។ ធម៌បួនប្រការដែលអ្នកមានបរិបូរណ៍ពោលគឺ ធម៌ សច្ចៈ ធម្ម ការតាំងក្នុងធម៌យ៉ាងមាំ និងបរិច្ចាគ។

## ២៥. ស្វាពោធិសត្វ (គរិហិតជាតក)[២៨]

ក្នុងអតីតកាលព្រះពោធិសត្វកើតជាស្វាក្នុងព្រៃហេមពាន្ត។ មានព្រានព្រៃម្នាក់បានចាប់ស្វាពោធិសត្វមកថ្វាយព្រះរាជា។ ស្វានោះបានរស់ក្នុងព្រះរាជវាំងអស់កាលដ៏យូរ ក៏បានក្លាយជាមានរបៀបដឹងកិរិយារបស់មនុស្សជាច្រើន ព្រះរាជាពេញព្រះទ័យចំពោះស្វានោះ ក៏ត្រាស់បញ្ជាឱ្យព្រានព្រៃមកគាល់ហើយមានបន្ទូលថា៖ ចូរអ្នកយកពានរនេះទៅលែងនៅក្នុងកន្លែងដែលអ្នកចាប់បាន។ ព្រានបានធ្វើតាមព្រះរាជបញ្ជា ហើយហ្វូងស្វាទាំងឡាយបានដឹងថា ព្រះ

---

[២៨] - ក្រុមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, សត្តមភាគលេខ ៥៨ ទំព័រ ១១៣។



www.elibraryofcambodia.org

ពោធិសត្វត្រឡប់មកវិញ ពួកគេបាននាំគ្នាមកប្រជុំដោយអង្គុយលើថ្មធំមួយផ្ទាំង។ ពេលជួបជុំ គេសួរព្រះពោធិសត្វថា៖ លោកជាទីស្រឡាញ់! លោកទៅនៅទីណាបាត់មិនឃើញអស់ពេលដ៏យូរ។ ព្រះពោធិសត្វតបថា៖ ខ្ញុំទៅរស់នៅក្នុងនគរពារាណសី។ គេសួរបន្តទៀតថា៖ ហេតុដូចម្តេចលោកអាចរួចខ្លួនត្រឡប់មកវិញបាន? ស្វាពោធិសត្វថា៖ ព្រះរាជាធ្វើយើងឱ្យមកជាស្វាប្រឡែងលេង ហើយលោកពេញព្រះទ័យនឹងចរិយារបស់យើង ទើបព្រះអង្គត្រាស់ឱ្យលែងយើង។ ពេលនោះស្វាទាំងឡាយនិយាយនឹងព្រះពោធិសត្វថា៖ លោកដឹងកិរិយារបស់មនុស្សឬទេ? សូមប្រាប់ពួកយើងផង? ពួកយើងចង់ដឹងណាស់។ ព្រះពោធិសត្វតបថា៖ អ្នកកុំសួរកិរិយារបស់មនុស្សនឹងខ្ញុំឡើយ។ ពួកស្វាសង្ស័យចង់ដឹងក៏និយាយថា៖ ប្រាប់មកចុះលោក! ពួកខ្ញុំចង់ស្តាប់! ព្រះពោធិសត្វពោលថា៖ ដែលឈ្មោះថាមនុស្សជាក្សត្រក៏ដោយ ជាព្រាហ្មណ៍ក៏ដោយ សុទ្ធតែនិយាយថារបស់យើង! របស់យើង! តែមិនដឹងថាជារបស់មិនទៀង។ ឥឡូវនេះ ចូរអ្នកស្តាប់ការធ្វើនូវអំពើរបស់មនុស្សអន្ធពាល ហើយពោលគាថាថា៖ វាចាដែលពោលថា ប្រាក់របស់អញមាសរបស់អញ អស់យប់និងថ្ងៃនេះ វាជាវាចារបស់មនុស្សទាំងឡាយដែលឥតប្រាជ្ញា មិនឃើញអរិយធម៌។ ក្នុងផ្ទះមួយមានម្ចាស់ផ្ទះពីរនាក់ បណ្តាម្ចាស់ផ្ទះពីរនាក់នោះ ម្ចាស់មួយមិនមានពុកមាត់ តែមានដោះយារចុះ មានសក់ផ្នួងបួង ហើយមានត្រចៀកចោះសម្រាប់ពាក់ប្រដាប់ដែលគេទិញដោយទ្រព្យដ៏ច្រើន។ ម្យ៉ាងទៀតម្ចាស់ផ្ទះនោះតែងពោលពាក្យចាក់ដោតចំពោះម្ចាស់ម្នាក់ទៀតនោះជានិច្ច។



www.elibraryofcambodia.org

## ២៦. ស្វាពោធិសត្វ (នឡបានជាតក)[២៩]

ក្នុងអតីតកាល មានអារក្សទឹកមួយរស់នៅក្នុងព្រៃក្រាស់មួយកន្លែង តែងស៊ីមនុស្សនិងសត្វដែលចុះទៅក្នុងស្រះបោក្ខរណីដែលខ្លួនថែរក្សា។ ក្នុងកាលនោះព្រះពោធិសត្វកើតជាស្តេចស្វា មានមាឌធំប៉ុនរមាំងនិងមានបរិវារប្រាំបីម៉ឺន។ ស្តេចស្វានោះបានឱ្យឱវាទដល់កូនចៅជាបរិវាររបស់ខ្លួនថា៖ អ្នកទាំងឡាយ! ក្នុងព្រៃនេះមានដើមឈើខ្លះមានពិស ស្រះបោក្ខរណីដែលកើតឯងនេះអាចមានអមនុស្សហួងហែងរក្សា និងមានអមនុស្សខ្លះទៀតក៏មាននៅក្នុងព្រៃជ្រៅៗដែរ។ អ្នកទាំងឡាយត្រូវពិចារណានៅពេលត្រូវការស៊ីផ្លែឈើដែលមិនធ្លាប់ស៊ី ឬត្រូវការផឹកទឹកដែលមិនធ្លាប់បានផឹក គឺត្រូវសាកសួរយើងជាមុនសិន។ ពួកស្វាទាំងនោះបានទទួលយកពាក្យរបស់ព្រះពោធិសត្វដោយចងចាំ។ ថ្ងៃមួយពួកគេបានទៅដល់កន្លែងដែលមិនធ្លាប់ទៅនឹងត្រូវនៅក្នុងទីនោះច្រើនថ្ងៃ។ ពួកគេបានស្វែងរកទឹកផឹក ក៏ឃើញស្រះបោក្ខរណីមួយ តែនៅវេរាមិនទាន់ហ៊ានចុះទៅផឹកទេ ដោយអង្គុយរង់ចាំស្តេចរបស់គេសិន។ ពេលស្តេចស្វាមកដល់ហើយក៏និយាយថា៖ អ្នកទាំងឡាយម្តេចមិនចុះទៅផឹកទឹក? ពួកពលស្វាពោលតបថា៖ ពួកខ្ញុំរង់ចាំដំណើរមកដល់របស់ព្រះអង្គសិន។ ព្រះ

---

[២៩] - ក្រមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, សត្តមភាគលេខ ៥៨ ទំព័រ ៩។



www.elibraryofcambodia.org

ពោធិសត្វពោលថា៖ អ្នកទាំងអស់ធ្វើយ៉ាងនេះល្អណាស់ហើយ។ បន្ទាប់មកស្ដេចស្វាដើរក្រឡឹងស្រះ ដើម្បីត្រួតពិនិត្យមើលក្រែងមានហេតុអន្តរាយ ហើយក៏កំណត់ឃើញតែដានជើងចុះ ដោយមិនឃើញដានជើងឡើងមកវិញ។ ព្រះពោធិសត្វបានដឹងថាស្រះនេះមានអមនុស្សហួងហែងរក្សាដោយមិនសង្ស័យឡើយ ទើបពោលថា៖ អ្នកទាំងឡាយអ្នកមិនផឹកទឹកនេះល្អហើយ ព្រោះស្រះនេះមានអមនុស្សយ៉ាងពិតប្រាកដ។ ចំណែកអារក្សទឹកមិនឃើញហ្វូងស្វាទាំងឡាយចុះ ក៏បានប្លែងខ្លួនជាអមនុស្សពណ៌ខៀវ មុខលឿងបាតដៃក្រហម រូបរាងគួរខ្លាច គួរតក់ស្លុតផុសពីទឹកចេញមកហើយនិយាយថា៖ ព្រោះហេតុអ្វីពួកឯង ទាំងអស់គ្នាមកអង្គុយមិនព្រមចុះក្នុងស្រះផឹកទឹកទៅ? លំដាប់នោះព្រះពោធិសត្វសួរអារក្សទឹកនោះថា៖ អ្នកជាអារក្សទឹកកើតក្នុងស្រះនេះមែនឬ?

-អារក្សទឹក៖ អើ! យើងជាអ្នកកើតក្នុងទីនេះឯង!

-ព្រះពោធិសត្វ៖ អ្នកតែងបានស៊ីមនុស្ស និងសត្វដែលចុះទៅក្នុងស្រះនេះមែនឬ?

-អារក្សទឹក៖ អើ ! យើងបានស៊ីអ្នកដែលមកកន្លែងយើង ! យើងមិនលើកលែងអ្នកណាទេ សូម្បីតែសត្វបក្សីដែលហើរចុះក្នុងស្រះនេះ ហើយសូម្បីតែពួកឯងទាំងអស់នេះក៏យើងនឹងស៊ីដែរ!

-ព្រះពោធិសត្វ៖ ពួកយើងមិនឱ្យអ្នកឯងស៊ីពួកយើងបានទេ។

-អារក្សទឹក៖ ចុះអ្នកទាំងអស់នឹងផឹកទឹកដូចម្ដេចកើត ?



www.elibraryofcambodia.org

-ព្រះពោធិសត្វ៖ ពួកយើងនឹងផឹកទឹកក្នុងស្រះនេះ តែយើងមិនឱ្យធ្លាក់ក្នុងអំណាចរបស់អ្នកឯងទេ?

-អារក្សទឹក៖ បើដូច្នេះពួកអ្នកឯងនឹងផឹកទឹកដោយរបៀបណា?

-ព្រះពោធិសត្វ៖ អ្នកឯងរមែងសំគាល់យើងត្រូវតែចុះទៅផឹកឬ?

និយាយដូច្នោះហើយ ព្រះពោធិសត្វប្រាប់បរិវារទាំងអស់ឱ្យកាន់បំពង់ដើមបបុសមកអធិដ្ឋានមិនឱ្យមានថ្នាំង ហើយឈរពីលើគោកផឹកទឹកក្នុងស្រះ។ បន្ទាប់មកព្រះពោធិសត្វពោលថា៖ យើងធ្វើយ៉ាងនេះអ្នកនឹងមិនអាចស៊ីពួកយើងបានឡើយ ព្រោះយើងឃើញតែដានជើងដែលចុះ តែមិនឃើញដានជើងឡើង យើងផឹកទឹកដោយដើមបបុស អ្នកនឹងសម្លាប់យើងមិនបានឡើយ។



www.elibraryofcambodia.org

## ២៧. ស្វាពោធិសត្វ(តិន្ទុកជាតក)[៣០]

ក្នុងអតីតកាល ព្រះពោធិសត្វកើតជាស្វារស់ក្នុងព្រៃហេមពាន្ត ហើយមានបរិវារជាច្រើន។ ក្នុងចំណោមនោះ មានពួកស្វាខ្លះបានស៊ើបដឹងថានៅកន្លែងមួយទៀត មានមនុស្សរស់នៅនោះ មានផ្លែទន្លាប់ទុំផ្អែមច្រើនណាស់ ដែលគេធ្លាប់ទៅបេះស៊ី។ ស្វានោះក៏បានរាយការណ៍ប្រាប់ស្តេចគេ ដើម្បីទៅពួនបេះស៊ី។ តែមុនសម្រេចចិត្ត ស្តេចស្វាបានសួរពួកកូនចៅនោះថា៖ តើទីនោះមានមនុស្សរស់នៅទេ? កូនចៅឆ្លើយថា៖ មានមនុស្សរស់នៅ! ស្តេចស្វាក៏ឆ្លើយថា៖ បើដូច្នោះយើងមិនគួរទៅទេ! ព្រោះពួកមនុស្សមានល្បិចអាក្រក់ណាស់។ តែកូនចៅបានផ្តល់យោបល់ថា៖ យើងគួរទៅរកពីពេលយប់ដែលជាពេលមនុស្សដេកលក់។ ស្តេចស្វាក៏យល់ព្រមដោយចុះចេញពីព្រៃនាពេលមនុស្សដេកលក់ស្ងាត់។ តែដំបូងពួកស្វាចេញទៅដេកលើផ្ទាំងថ្មសិន។ លុះរាត្រីស្ងាត់ ពួកស្វាក៏នាំគ្នាទៅឡើងដើមទន្លាប់បេះស៊ី។ ថ្ងៃមួយមានបុរសម្នាក់ចេញពីផ្ទះ ដើម្បីទៅបត់ជើងធំ ស្រាប់តែឃើញហ្វូងស្វា គេក៏ដង្ហោយហៅពួកមនុស្ស។ ខ្លះកាន់ធ្នូនិងព្រួញខ្លះកាន់កំណាត់ឈើ និងអាវុធផ្សេងៗ ដោយឈរព័ទ្ធជុំវិញហ្វូងស្វារហូត

---

[៣០] - ក្រមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, សត្តមភាគលេខ ៥៨ ទំព័រ ៨៥។



www.elibraryofcambodia.org

ដល់ពេលព្រឹក។ ពេលនោះហ្វូងស្វាភ័យតក់ស្លុតយ៉ាងខ្លាំងបាននាំគ្នាឡើងទៅរកស្ដេចស្វា ព្រោះយល់ថាក្រៅពីស្ដេចរបស់គេមិនមាននរណាជាទីពឹងឡើយ។

ពោលជាគាថា៖ ពួកយើងត្រូវពួកមនុស្សមានធ្នូ និង បំពង់ព្រួញក្នុងដៃ ខ្ទះកាន់ដាវដ៏មុតព័ទ្ធជុំវិញហើយ តើត្រូវធ្វើដូចម្ដេចដើម្បីរួចខ្លួនបាន! ស្ដេចស្វាឆ្លើយថា៖ សេចក្ដីត្រូវការក្នុងកិច្ចការណាមួយដែលកើតឡើងដល់ពួកមនុស្សនោះ ពួកគេតែងមានកិច្ចការច្រើនពិតពួកគេមិនអាចឈរសម្លឹងចាំមើលយើងយូរទេ។ ដូច្នេះយើងគប្បីរើសប្រមូលផ្លែទន្លាប់បានហើយ ចូរអ្នកទាំងឡាយនាំគ្នាចីផ្លែទន្លាប់នោះទៅ។



www.elibraryofcambodia.org

## ២៨. ត្មាតពោធិសត្វ (គិជ្ឈជាតក)[៣៦]

ក្នុងអតីតកាលព្រះពោធិសត្វបានកើតជាសត្វត្មាត បេះចិញ្ចឹមមាតាបិតាចាស់ជរាដែលមានភ្នែកខ្វាក់នៅក្នុងគិជ្ឈគុហារ តែងនាំចំណីទាំងឡាយមានសាច់គោជាដើមនោះ មកជូនអ្នកមានគុណ។

ក្នុងគ្រានោះ ព្រានម្នាក់ឈ្មោះនិលិយៈបានដាក់អន្ទាក់ក្នុងទីស្មសានក្បែរក្រុងពារាណសី ដោយមិនកំណត់នូវសត្វណាមួយឡើយ។ ព្រះពោធិសត្វបានជាប់អន្ទាក់ ហើយបាននឹកគិតដល់មាតាបិតារបស់ខ្លួន។ ត្មាតបានស្រែកយំជាភាសានៃមនុស្សថា៖ មាតាបិតារបស់អញនឹងញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅយ៉ាងដូចម្តេចហ្ន៎? កាលបើមិនដឹងថាអញជាប់អន្ទាក់ និងជាអ្នកគ្មានទីពឹង មិនមានវិធីណាមួយដើម្បីរួចខ្លួនដូច្នេះពួកគាត់នឹងស្គាំងស្គមស្លាប់នៅក្នុងរូងភ្នំនោះឯង។

ព្រានឮពាក្យនេះហើយ បានពោលថា៖

-មនុស្សលោកនិយាយគ្នាថា៖ ត្មាតរមែងមើលឃើញសាកសពបានចម្ងាយ១០០យោជន៍ ពាក្យនោះតើយ៉ាងដូចម្តេចហ្ន៎! ចុះហេតុអ្វីបានជាអ្នកមកជាប់លបនិងអន្ទាក់ ហើយក៏មិនអាចភ្ញាក់ខ្លួនសោះ។

ព្រះពោធិសត្វពោលថា៖

-ពេលណាដែលមានសេចក្តីវិនាសមកដល់ ពេលនោះសត្វ

---

[៣៦] - ក្រុមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, សត្តមភាគលេខ ៥៨ ទំព័រ ៧៤។



www.elibraryofcambodia.org

ដែលនឹងអស់ជីវិត បើទុកជាមកជាប់លប់និងអន្ទាក់ ក៏មិនអាចភ្ញាក់ខ្លួនបាន។

ព្រានស្តាប់ធម្មកថារបស់ព្រះពោធិសត្វនោះហើយត្រេកអរថា៖

-ស្តេចត្មាតជាបណ្ឌិត កាលបើខ្សឹកខ្សួល ក៏មិនបានខ្សឹកខ្សួលដើម្បីខ្លួនឡើយ តែខ្សឹកខ្សួលដើម្បីមាតាបិតា។ ស្តេចត្មាតនេះមិនគួរសម្លាប់ឡើយ។ ថាដូច្នោះហើយ ក៏ស្រាយអន្ទាក់ចេញពីជើងដោយចិត្តដែលប្រកបដោយសេចក្តីស្រឡាញ់ រួចពោលថា៖

-ចូរអ្នកទៅចិញ្ចឹមមាតាបិតាចាស់ជរា ដែលអាស្រ័យនៅព្នំដ៏ប្រកភ្នំចុះ យើងបានបើកលែងអ្នកហើយ ចូរអ្នកទៅជួបជុំញាតិសន្តានដោយសុវត្ថិភាពចុះ។

ព្រះពោធិសត្វរួចចាកមរណៈទុក្ខហើយ កាលធ្វើអនុមោទនាទើបពោលថា៖

-ម្នាលព្រាន ចូរអ្នករីករាយជាមួយ និង ពួកញាតិទាំងអស់យ៉ាងនេះចុះ ខ្ញុំនឹងចិញ្ចឹមមាតាបិតាចាស់ជរាអាស្រ័យនៅព្នំដ៏ប្រកភ្នំ។

ពោលដូច្នោះហើយ ត្មាតក៏ពាំសាច់ពេញមាត់ ហើយហើរទៅជួបមាតាបិតា។



www.elibraryofcambodia.org

## ២៩. ត្មាតពោធិសត្វ (ទុកនិបាត)[៣២]

ក្នុងអតីតកាល ព្រះពោធិសត្វបានកើតជាសត្វត្មាត ចេះចិញ្ចឹមមាតាបិតានៅក្នុងគិជ្ឈបព៌ត។ គ្រាមួយកើតមានខ្យល់ និងភ្លៀងយ៉ាងខ្លាំង។ ត្មាតទាំងឡាយមិនអាចអត់ទ្រាំនឹងខ្យល់និងភ្លៀងបានក៏ហើរទៅក្រុងពារាណសីញាក់ញ័រព្រោះត្រជាក់ ទំលើទីជិតនៃកំពែងខ្លះ ទីជិតនៃស្នាមភ្លោះខ្លះ។

-ក្នុងកាលនោះសេដ្ឋីក្រុងពារាណសីចេញពីព្រះនគរឃើញពួកត្មាតទាំងនោះកំពុងលំបាក ទើបឱ្យត្មាតទាំងនោះនៅក្នុងទីស្ថានមួយ ហើយបានឱ្យគេដុតភ្លើងបញ្ជូនពួកបុរសទៅទីស្មសានឱ្យនាំយកសាច់គោមកឱ្យត្មាតទាំងនោះ ហើយក៏ចាប់ផ្តើមនូវការថែរក្សា។

ត្មាតទាំងឡាយ កាលបើខ្យល់ និងភ្លៀងបាត់អស់ទៅហើយមានខ្លួនស្រស់បស់ហើយ ក៏ហើរទៅកាន់ភ្នំ និងពិភាក្សាគ្នាថា ៖

-សេដ្ឋីក្រុងពារាណសី បានធ្វើឧបការដល់ពួកយើង ពួកយើងត្រូវតែធ្វើឧបការតប ដល់អ្នកដែលបានឧបការហើយទើបគួរ។ ចាប់ពីថ្ងៃនោះទៅ បណ្តាពួកយើងអ្នកណាបាននូវវត្ថុអ្វីជាសំពត់ក្តីជាគ្រឿងអលង្ការក្តី អ្នកនោះគប្បីនាំវត្ថុទាំងនោះឱ្យធ្លាក់ចុះលើផ្ទះរបស់សេដ្ឋី។ តាំងពីពេលនោះមក ពួកត្មាតត្រូតមើលសេចក្តី

---

[៣២] - ក្រមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, សត្តមភាគលេខ ៥៨ ទំព័រ ៣៨។



www.elibraryofcambodia.org

ប្រមាថនៃមនុស្សទាំងឡាយដែលហាលសំពត់ គ្រឿងអលង្ការទាំងឡាយក្នុងពេលថ្ងៃ ក៏ពាំយាំងប្រញាប់ទៅទម្លាក់លើផ្ទះរបស់សេដ្ឋី។

សេដ្ឋីដឹងថាវត្ថុទាំងនោះ គឺពួកត្មាតនាំមកឱ្យ ទើបរក្សាទុកនូវវត្ថុទាំងនោះដោយឡែកៗពីគ្នា។ ពួកមនុស្សបានក្រាបទូលព្រះរាជាថា៖ ត្មាតទាំងឡាយប្លន់ព្រះនគរ។ ព្រះរាជាទ្រង់ត្រាស់បញ្ជាឱ្យរាជបុរសដាក់លប់ និងអន្ទាក់ ដើម្បីនឹងចាប់ត្មាត។ ព្រះពោធិសត្វក៏ជាប់ក្នុងអន្ទាក់ ពពួកមនុស្សចាប់ព្រះពោធិសត្វបាន ក៏យកទៅថ្វាយព្រះរាជា។ ព្រះរាជាទ្រង់ត្រាស់សួរ និងព្រះសណ្ដាប់នូវហេតុទាំងអស់នោះ ហើយត្រាស់សួរម្ដងទៀតដោយន័យថា ៖ **យន្នុ គិជ្ឈោ យោជន សតំ** ដូច្នេះជាដើម។ ឯត្មាតពោធិសត្វសម្ដែងធម៌ដោយន័យថា ៖ **យា បរាភវោ ហោតិ** ដូច្នេះជាដើម។

ព្រះរាជាទ្រង់សព្វព្រះទ័យក៏ដោះលែង ហើយបានហើរទៅកាន់សំណាក់នៃមាតាបិតា។ បន្ទាប់មកព្រះរាជាបានត្រាស់បញ្ជាសេដ្ឋីឱ្យយករបស់ទាំងឡាយផ្ដល់ដល់ម្ចាស់គ្រប់ៗគ្នាអស់ហោង។



www.elibraryofcambodia.org

## ៣០. កូនក្រួចពោធិសត្វ

ក្នុងអតីតកាល ព្រះពោធិសត្វបានចាប់បដិសន្ធិក្នុងកំណើតជាសត្វក្រួច កើតចេញចាកផ្ទៃមាតាមកក្នុងវេលាទម្លាយសំបកពងមកជាកូនក្រួច មានរូបធំប៉ុនដុំវទេះ។

ក្នុងខណៈនោះ មាតាបិតាទុកព្រះពោធិសត្វឱ្យដេកនៅក្នុងសំបុក ហើយទៅពាំចំណីមកចិញ្ចឹមកូនដោយចំពុះ។ ព្រះពោធិសត្វមិនមានកម្លាំងលាតស្លាបហើរទៅលើអាកាស ថែមទាំងមិនមានកម្លាំងលើកជើងឈានដើរទៅទីដីទៃ។ រីឯភ្លើងព្រៃតែងឆេះក្នុងទីប្រទេសនោះរាល់ៗឆ្នាំ។ ពេលនោះភ្លើងព្រៃកំពុងឆេះរាលដាលមករកសំបុកដែលព្រះពោធិសត្វនៅម្នាក់ឯង។ ពួកបក្សីក្រួចឯទៀតនាំគ្នាចេញចាកសំបុករបស់ខ្លួនទៅកាន់ទីកន្លែងផ្សេងៗដោយសំឡេងស្រែកព្រោះភ័យអំពីមរណៈ។ មាតាបិតារបស់ព្រះពោធិសត្វក៏រត់ចោលព្រះពោធិសត្វ ព្រោះមរណៈភ័យនោះដែរ។ ព្រះពោធិសត្វដេកនៅក្នុងសំបុកតែម្នាក់ឯង អើតកមើលភ្លើងព្រៃកំពុងឆេះរាលមក ទើបគិតរំពឹងថា « បើអញមានកម្លាំង អញនឹងទទះស្លាបហើរចេញទៅឰដ៏អាកាស បើអញមានកម្លាំង អញនឹងលើកជើងឈានដើរគេចចេញទៅទីដីទៃ តែអញគ្មានកម្លាំង មិនអាចទៅទីណារួចទេ។ ឯមាតាបិតារបស់អញ ក៏ពួកគាត់ខ្លាចមរណៈ រត់ចោលអាត្មាអញឱ្យដេកនៅក្នុងសំបុកតែម្នាក់ឯង។ អ្វីៗសម្រាប់ការពារខ្លួនមិនមានវត្ថុដ៏ទៃជាទីពឹងពំនាក់របស់អាត្មាអញក៏មិនមាន តើអាត្មាអញនឹង



www.elibraryofcambodia.org

ធ្វើយ៉ាងណាហ្ន៎ ទើបគួរ ? » លំដាប់នោះព្រះពោធិសត្វរំពឹងគិតដូច្នេះថា៖ គុណនៃសីល គុណនៃសច្ចធម៌ រមែងមានក្នុងលោកនេះ ដែលអញបានបំពេញហើយក្នុងអតីតកាល។

ធម្មតាព្រះសព្វញ្ញុពុទ្ធទាំងឡាយ កាលទ្រង់បំពេញបារមីទាំងឡាយ ប្រថាប់គង់ក្រោមម្លប់ដើមពោធិ៍បានត្រាស់ដឹងដោយប្រពៃ ទ្រង់បរិបូណ៌ដោយសីល សមាធិ បញ្ញា វិមុត្តិ និង វិមុត្តិញាណទស្សនៈនិងទ្រង់ប្រកបដោយសច្ចៈ មេត្តាករុណា ខន្តី តែងមាននៅនឹងគុណរបស់ព្រះធម៌ទាំងឡាយដែលព្រះសព្វញ្ញុពុទ្ធទាំងឡាយនោះ ទ្រង់ត្រាស់ដឹងច្បាស់។ ហេតុនេះអាត្មាអញនឹងរំលឹកដល់អតីតព្រះពុទ្ធទាំងឡាយនិងគុណដែលអតីតព្រះពុទ្ធទាំងឡាយនោះដឹងច្បាស់ផង ថែមទាំងយកសភាពធម៌ គឺសច្ចៈដែលមានក្នុងខ្លួនអញ ។ បន្ទាប់មកក៏ធ្វើសច្ចកិរិយានេះ ដើម្បីការពារភ្លើងព្រៃមិនឱ្យរាលដាលមកដល់ខ្លួន។

ព្រះពោធិសត្វចាប់ផ្ដើមធ្វើសច្ចកិរិយាដូច្នេះថា៖ ខ្ញុំមានស្លាបតែហើរមិនរួច ខ្ញុំមានជើងតែដើរមិនបាន មាតាបិតា របស់ខ្ញុំចេញទៅរកអាហារ នៃភ្លើង! ចូរចេះត្រឡប់ទៅវិញចុះ។ គ្រាន់តែព្រះពោធិសត្វធ្វើសច្ចកិរិយាចប់ ភ្លើងក៏រលត់ភ្លាមក្នុងទីនោះដូចភ្លើងគប់ដែលគេពន្លត់ដោយទឹកដូច្នោះ។



www.elibraryofcambodia.org

# ៣១. ហ្វូងក្រួចពោធិសត្វ

កាលពីព្រេងនាយ ព្រះពោធិសត្វបានចាប់បដិសន្ធិក្នុងកំណើតជាសត្វក្រួច នៅក្នុងព្រៃមួយនាក្រុងពារាណសី ដែលមានសត្វក្រួចជាច្រើនពាន់ នៅក្រោមការដឹកនាំរបស់ក្រួចជាពោធិសត្វ។ កាលនោះមានព្រានព្រៃម្នាក់តែងតែទៅរកទាក់សត្វក្រួច ដោយបញ្ចេញសំឡេងអ៊ីតបន្លំជាសត្វក្រួចវង្វេងជាច់ហ្វូង ហើយយំហៅរកគ្នា។ នៅពេលដែលសត្វក្រួចហើរមកចុះជុំហើយ ព្រានព្រៃប្រញាប់បោះលប់ដើម្បីសង្គ្រប់ចាប់សត្វក្រួចទាំងហ្វូងនោះដាក់ទ្រុង រួចយកទៅលក់ឯផ្សារ។

ថ្ងៃមួយព្រះពោធិសត្វ ជាមេហ្វូងបានដឹងហេតុការណ៍នៃមហន្តរាយនេះក៏ពិចារណាថា៖ អំពើរបស់ព្រានព្រៃនេះ ថ្ងៃណាមួយប្រាកដជាធ្វើឱ្យហ្វូងសត្វក្រួចទាំងអស់វិនាសផុតពូជមិនខាន។ បន្ទាប់មកមេក្រួចបានកោះហៅពួកសត្វក្រួចទាំងអស់ ឱ្យមកចូលរួមប្រជុំដើម្បីរកវិធានការដោះស្រាយពីបញ្ហាគ្រោះថ្នាក់នេះ។

ក្រោយពីបានពិភាក្សាគ្នាហើយ សត្វក្រួចដែលជាពោធិសត្វបានសម្រេចចិត្តថា ចូរអ្នកទាំងឡាយធ្វើតាមបណ្ដាំយើងដូចតទៅ៖

ពីពេលនេះតទៅ បើមានព្រានព្រៃបោះលប់មកលើក្រុមយើងកាលណា ចូរយើងម្នាក់ៗត្រូវតាំងស្មារតីឱ្យបានរឹងប៉ឹងកុំតក់ស្លុតឱ្យសោះ។ យើងត្រូវបញ្ចេញក្បាលតាមចន្លោះលប់ រួចយើងទាំងអស់គ្នាខំប្រឹងទទះស្លាបឱ្យខ្លាំងអស់ទំហឹង។ ធ្វើយ៉ាងនេះ យើងអាចសួយ



www.elibraryofcambodia.org

នាំលប់យកទៅលើអាកាស នឹងនាំលប់នោះទៅជម្រុះចោលក្នុងគុម្ពោតព្រៃណាមួយដែលមានស្លឹកក្រាស់ ហើយពួកយើងក៏អាចគេចចេញពីលប់នោះបាន។ បើយើងធ្វើដូច្នេះឱ្យបានស្រុះគ្នានោះ យើងប្រាកដជាអាចរំដោះខ្លួនរួចពីកម្លាំងដៃនៃព្រានព្រៃដូចបំណងមិនខាន។

សត្វក្រួចទាំងអស់ក៏សន្យា យល់ព្រមធ្វើតាមបញ្ជារបស់មេហ្វូង ដែលជាព្រះពោធិសត្វដោយប្រុងប្រយ័ត្ន ហើយតែងតែគេចខ្លួនរួចពីគ្រោះថ្នាក់ជាដរាបរៀងទៅ។ នៅពេលដែលសត្វក្រួចទាំងអស់ស្ទុះហើរនាំលប់លើអាកាស នាយព្រានព្រៃខំរត់តាមយកលប់ពីក្នុងបន្លាក៏មិនបាន។ រៀងរាល់ថ្ងៃព្រានព្រៃតែងតែត្រឡប់មកផ្ទះវិញដោយដៃទទេ។ ចំណែកប្រពន្ធព្រានព្រៃ កាលបើឃើញប្តីត្រឡប់មកវិញដោយដៃទទេ គ្មានប្រាក់ដូចសព្វដង ក៏កើតក្តីមួហ្មងក្តៅក្រហាយហើយចោទប្តីថា៖

នែលោកប្តី! រាល់ថ្ងៃត្រឡប់មកផ្ទះវិញដៃទទេដូច្នេះ តើអ្នកអាល័យវល់ជាមួយស្រីថ្មីទេដឹង ? ព្រានព្រៃក៏បានឆ្លើយថា៖ ឱអូនសម្លាញ់អើយ! បងគ្មានទៅមានស្រីឯណាទេ! ចូរកែវមាសមេជឿប្តីចុះ។ ការពិតគឺហ្វូងសត្វក្រួចទាំងអស់នោះវាឆ្លាតណាស់ ឥឡូវនេះពួកវាស្រុះស្រួលរស់នៅជាមួយគ្នាដូចក្បាលមួយអញ្ចឹង។ នៅពេលដែលបងបោះលប់គ្របហ៊ុំពទ្ធ័លើពួកវាភ្លាម ពួកវាហើរស្រុះ ហើរគំណាលគ្នា ហើយហើរនាំលប់យកទៅជាមួយ រួចទម្លាក់ចោលលើគុម្ពោតព្រៃដែលមានសុទ្ធតែបន្លា។ ប៉ុន្តែសូមពៅអូនកុំព្រួយ ថ្ងៃណាមួយដែលពួកវាបែកបាក់សាមគ្គីគ្នា ថ្ងៃនោះសូម្បីតែកូនក្រួចមួយ ក៏



www.elibraryofcambodia.org

មិនអាចហក់រួចពីកណ្ដាប់ដៃបងបានដែរ។ ចូរអូនញញឹមសង្ឃឹមទុកចុះ។ ពេលចប់ហើយ នាយព្រានព្រៃក៏ច្រៀងតិចៗដោយរីករាយថា៖

ឱ្យតែពួកឯង នៅខំប្រឹងប្រែង ស្រុះស្រួលនឹងគ្នា ឯងអាចគេចផុត ពីក្ដីមរណា បើឯងឈ្លោះគ្នា ដាច់ថ្ងៃអន្ទ្រា ថ្ងៃនោះហើយណា ឯងជាប់លប់អញ គ្មានរួចមួយឡើយ។

ពេលក្រោយមក មានសត្វក្រួចមួយកំពុងចឹកសំបុកកណ្ដៀររកចំណី ស្រាប់តែរបូតជើងធ្លាក់មកក្រោមប៉ះក្បាលសត្វក្រួចមួយទៀត។ ពេលនោះមានសំឡេងសត្វក្រួចនៅពីខាងក្រោមបានបន្លឺឡើងថា៖

-អាណាជាន់ក្បាលអញហ្នឹង? ក្រួចនៅខាងលើឆ្លើយថា៖

-សូមទោសលោក! ខ្ញុំគ្មានបំណងទេ គឺខ្ញុំរបូតជើងធ្លាក់ពីសំបុកកណ្ដៀរដោយអចេតនាទេ! សូមលោកមេត្តាកុំខឹងអី!

-មិនបានទេ!ឯងនេះព្រហើនណាស់រញ៉េរញ៉ៃបែបឯងនឹងឬដែលជាអ្នកមានកម្លាំងរើខ្លួនឱ្យរួចផុតពីលប់របស់ព្រានព្រៃ? (សម្ដីក្រួចទីពីរនេះឆ្លើយដោយកម្រោល)។

ជម្លោះសត្វក្រួចទាំងពីរចេះតែរាលដាលបន្តទៅទៀត បានបណ្ដាលឱ្យបរិយាកាសកាន់តែអាប់អួរ ដោយមានក្រុមកាន់ជើងគ្នាទាំងពីរខាង កាន់តែច្រើនឡើងៗ។ ដោយពុំអាចសម្រួលបាន ក្រួចដែលជាព្រះពោធិសត្វ យល់ឃើញស្ថានភាពមិនស្រួល ក៏នាំគ្នាមួយក្រុមទៀតហើរចេញពីទីនោះទៅ។ ស្ថិតនៅក្នុងភាពច្របូកច្របល់នោះស្រាប់តែលប់របស់នាយព្រានព្រៃធ្លាក់ប្រឹបលើសត្វក្រួចទាំងពីរក្រុម



www.elibraryofcambodia.org

ដែលកំពុងតែឈ្លោះគ្នានោះ។ ដោយការភិតភ័យតក់ស្លុត ស្រឡាំងកាំងក្នុងភាពអាសន្ន សត្វក្រួចទាំងពីរក្រុមភ្លេចអស់បណ្ដាំព្រះពោធិសត្វ ហើយក៏ស្រែកប្រចាំគ្នាថា៖

-បើឯងពូកែណាស់ ឥឡូវម្ដេចក៏មិនហើរនាំលប់នេះមុនអញទៅ!

ក្រុមមួយទៀតឆ្លើយថា៖ ចុះឯងក៏មិនស្ទុះមុនអញទៅ ?

នៅពេលដែលសត្វក្រួចទាំងពីរក្រុមកំពុងតែឈ្លោះប្រកែកគ្នាដូច្នេះ ព្រានព្រៃក៏ក្រសោបលើកលប់ចាប់ក្រួចទាំងអស់បញ្ចូលក្នុងទ្រុង រួចត្រឡប់ទៅផ្ទះវិញដោយរីករាយ។ ថ្ងៃនេះភរិយារបស់ព្រានព្រៃញញឹមដាក់ប្ដី ព្រោះបានដូចបំណង។

## ៣២. កូនក្រួចពោធិសត្វ (វដ្ដកជាតក)[៣៣]

ព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងធម៌ទេសនាថា៖ ស្លាបខ្ញុំនៅខ្ចីពុំអាចហើរបានដូច្នេះ។ នេះជាព្រះពុទ្ធដីកាដែលព្រះអង្គបន្លឺឡើងតិចៗនៅពេលមួយ ដែលភ្លើងកំពុងឆេះយ៉ាងសន្ធោសន្ធៅ។ ភ្លើងឆេះព្រៃកាន់តែឆាបច្ឆេះខ្លាំងឡើងតម្រង់ឆ្ពោះមកកាន់កន្លែងព្រះអង្គគង់ប្រថាប់។ ព្រះភិក្ខុសង្ឃ និងពុទ្ធបរិស័ទផ្អើលចោឡោភិតភ័យជាខ្លាំង ខ្លះរកវិធីទប់ទល់ពន្លត់ភ្លើង។ ភ្លើងកាន់តែឆេះរាលដាលចូលមកកាន់

---

[៣៣] - ក្រុមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, សត្តមភាគលេខ ៥៨ ទំព័រ ១៦។



www.elibraryofcambodia.org

តែជិតឡើងៗ ភិក្ខុទាំងឡាយក៏នាំគ្នាចូលទៅក្រាបបង្គំទូលព្រះបរមគ្រូថា៖

បពិត្រព្រះអង្គដ៏ចម្រើន ភ្លើងឆេះនៅទីនេះកំពុងតែមានសន្ទុះដូចខ្យល់ព្យុះសង្ឃរា ហើយភ្លឺរន្ទាលពេញផ្ទៃមេឃ ហាក់ដូចជាព្រះសុរិយាកំពុងតែជះកម្តៅនិងរស្មីលើលោក។

តែព្រះសម្មាសម្ពុទ្ធទ្រង់គង់ស្ងៀម ដោយពុំសម្តែងអាការៈភ្ញាក់ផ្អើល ឬតក់ស្លុតបន្តិចបន្តួចឡើយ។ ពេលដែលភ្លើងឆេះមកជិតដល់ នៅសល់១៦ករីស[៣៩] ពីកន្លែងដែលព្រះអង្គទ្រង់គង់នោះ ភ្លើងក៏រលត់សូន្យតែម្តង ហាក់ដូចជាគេយកចន្លុះដែលកំពុងឆេះទៅជ្រលក់ក្នុងទឹក។

នៅចំពោះព្រឹត្តិការណ៍ដ៏អស្ចារ្យនេះ ភិក្ខុទាំងឡាយនេះក៏ចូលទៅថ្វាយបង្គំព្រះសម្មាសម្ពុទ្ធ ហើយពោលសរសើរព្រះតេជៈនៃព្រះអង្គថា៖ ឱហ្ន៎! អស្ចារ្យមែន នេះគឺជាតេជៈបារមីនៃព្រះអង្គហើយ។ សូម្បីតែភ្លើងដែលគ្មានវិញ្ញាណសោះក៏ខ្លបខ្លាចបារមីនៃព្រះអង្គដែរ។ ឱ! បារមីនៃព្រះសម្មា សម្ពុទ្ធរកអ្វីប្រៀបផ្ទឹមពុំបានឡើយ។

ពេលនោះព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់តបទៅនឹងភិក្ខុទាំងឡាយថា៖ ម្នាលភិក្ខុទាំងឡាយ នេះពុំមែនជាបារមីនៃតថាគតបច្ចុប្បន្នទេ ដែលបណ្តាលឱ្យភ្លើងឆេះព្រៃនេះរលត់នោះគឺជាតេជៈបារមីនៃ

---

[៣៩] _ក្នុងអភិធាប្បទីបិកថា៤ អម្ពណៈ គឺ៤៤ ទាឡ្បិស្មើ១ ករីសៈ ត្រូវជា៣៩.៩៨៤ ម៉ែត្រការ៉េ ( កុល ផេង, ២០០៩, *មាគ៌ាជីវិតនៃព្រះពោធិសត្វ*, ទំព័រ២០៤)។



www.elibraryofcambodia.org

អំពើអំពីអតីតកាលរបស់តថាគត ហើយកន្លែងនេះក៏ពុំអាចមាន ភ្លើងឆេះមកដល់បានរហូតដល់កប្បវិនាស។ ព្រោះជាអច្ឆរិយកម្មមួយ ដែលកើតមានពី អតីតកាលមក។

ពេលនោះព្រះអានន្ទត្ថេរ បានយកសង្ឃដីមកក្រាលថ្វាយព្រះ សម្មាសម្ពុទ្ធគង់។ ព្រះអង្គគង់ព្រះភ្នែនសម្រួលឥរិយាបថរួចហើយ ព្រះ ភិក្ខុសង្ឃបង់ជម្រះមន្ទិលចម្ងល់នៃអច្ឆរិយកម្ម ដែលកើតមានឡើង ពីអតីតកាលក៏សូមអារាធនាព្រះបរមគ្រូ សូមព្រះអង្គសម្ដែងហេតុ ដ៏អស្ចារ្យនោះ។

ព្រះបរមគ្រូសម្ដែងនូវរឿងអតីតកាលនោះដូចតទៅ៖ ក្នុង អតីតកាលកន្លងទៅ ព្រះពោធិសត្វបានចាប់កំណើតជាសត្វក្រួចមួយក្នុង រដ្ឋមគធៈ។ នៅពេលកូនក្រួចដ៏តូចនោះ ទើបកើតមកមានស្លាប និងជើងនៅទន់ខ្សី មិនអាចហើរទៅកាន់ទីណាបានឡើយ។ មេបា របស់គេតែងតែទៅរកចំណី ពាំយកមកបញ្ចុកកូននៅក្នុងសំបុករៀង រាល់ថ្ងៃ។ ថ្ងៃមួយស្រាប់តែមានភ្លើងឆេះព្រៃយ៉ាងសន្ធោរសន្ធៅ។ សត្វស្លាបទាំងអស់នៅក្នុងព្រៃនោះ ក៏ផ្អើលឆោឡោហើរចោលសំបុក ទាំងភ្ញាក់ស្លុត។ មេបារបស់កូនក្រួចបានមកអង្រួនកូនឱ្យខំហើរចេញ ពីសំបុកដូចសត្វដទៃដែរ។ ពេលដែលដឹងថាមិនអាចជួយកូនរបស់ ខ្លួនបាន មេបាកូនក្រួចក៏ដាច់ចិត្តហើរចោលកូន និង សំបុកដោយ ទុកឱ្យកូនដែលមានស្លាបខ្សីនោះនៅតែម្នាក់ឯង។ កាលដែលកូនក្រួច នៅក្នុងសំបុកតែម្នាក់ឯង គេខំអើតកចេញពីសំបុក ដើម្បីបិនិត្យមើល



www.elibraryofcambodia.org

ស្ថានភាពខាងក្រៅ ហើយបានឃើញសន្ធុះភ្លើង និងខ្យល់បោកបក់ហាក់ដូចជាព្យុះសង្ឃរាចាបចេះព្រៃ សំដៅឆ្ពោះមកចំកន្លែងរបស់គេ។ ពេលនោះកូនក្រួចគិតក្នុងចិត្តថា៖ ស្លាបខ្ញុំនៅខ្ចីពុំអាចហើរបាន ឡើយ បើសិនជាខ្ញុំអាចទទះស្លាបហើរបានទៅលើមេឃ ឬបើខ្ញុំអាចបោះជំហានដើរបាន ខ្ញុំនឹងរត់ទៅកាន់កន្លែងផ្សេងទៀតដូចសត្វទាំងឡាយដែរ។ ប៉ុន្តែខ្ញុំពុំអាចធ្វើដូច្នេះបានឡើយ។ ដោយខ្លាចនូវសេចក្តីមរណៈ មេបារបស់ខ្ញុំក៏ហើរបោលខ្ញុំដែរ។ នៅពេលនេះពុំមាននរណាមួយអាចជួយខ្ញុំបាន។ រីឯខ្ញុំវិញក៏មិនអាចជួយខ្លួនឯងបានដែរ។ តើខ្ញុំត្រូវធ្វើដូចម្តេចទៅហ្ន៎ នៅពេលនេះ។

នៅគ្រាដ៏មានអាសន្ននោះ កូនក្រួចបានគិតដូច្នេះថា៖ នៅក្នុងលោកនេះមានវត្ថុសក្តិសិទ្ធិជាច្រើន ដូចជាគុណធម៌ សច្ចធម៌ជាដើម។ មានមហាបុរសជាច្រើនរូប ដែលបានត្រាស់ជាព្រះពុទ្ធដ៏មានរិទ្ធិ ក៏ដោយសារបានអនុវត្តនូវគុណធម៌ ដែលលោកបានសាងទុកជាច្រើនអាយុកប្បមកហើយដែរ។ មហាបុរសប្រកបដោយគុណធម៌ទាំងនោះ តែងតែមានសន្តានចិត្តពោរពេញទៅដោយធម៌ មានសច្ចៈ មេត្តា ករុណា មុទិតា និងឧបេក្ខាជាដើម ។ ទន្ទឹមនេះធ្លាប់បានទ្រាំតស៊ូការលំបាកតាំងពីអតីតជាតិមក។ ចិត្តដ៏បរិសុទ្ធរបស់មហាបុរសទាំងនោះ តែងតែផ្តល់ក្តីមេត្តាដល់សត្វលោកទូទៅ ដោយគ្មានរើសមុខ។ ចំពោះខ្ញុំវិញក៏ដូច្នោះដែរ មានតែសច្ចធម៌នេះទេ ដែលជាអមតៈហើយជាជំនឿប្រាកដរបស់ខ្ញុំ។ ហេតុដូច្នេះខ្ញុំត្រូវតែភាវនាចំពោះ



www.elibraryofcambodia.org

មុខគុណសម្បត្តិនៃព្រះពុទ្ធអង្គ ដែលបានសាងរួចមក និង សាងទៅលើជំនឿប្រាកដដ៏ធំក្នុងខ្លួនខ្ញុំ ដើម្បីសម្តែងនូវសច្ចធម៌នេះ។ ដូច្នេះសូមឱ្យភ្លើងដ៏កំណាចបរវៀសចៀសឆ្ងាយពីកន្លែងនេះ ដើម្បីនាំមកនូវសុវត្ថិភាពដល់ខ្លួនខ្ញុំផង និងដល់សត្វទាំងពួងផង។

ពេលនោះក្រួចពោធិសត្វនឹកដល់សច្ចធម៌ និងសីលក្នុងលោកក៏បានពោលថា៖ នៅក្នុងលោកពិតមានសព្វញ្ញូបានត្រាស់ជាគ្រូ លើមនុស្សទេព្តា មានសីលគុណាប្រសើរអស្ចារ្យ ទ្រង់ព្រះនាមថាសម្មាសម្ពុទ្ធ និងសច្ចធម៌បវរបំផុត សោភេយ្យបរិសុទ្ធមានក្នុងលោកា។ សូមភ្លើងរលត់ដោយសច្ចកិរិយាឧត្តមនេះណា ភ្លើងចូរចៀសចេញ។ បន្ទាប់មកក៏ពោលបន្តទៀតថា៖ ខ្ញុំមានស្លាបដែរ តែហើរពុំរួច ជើងខ្ញុំទន់តូច ពុំអាចដើរបាន មេបានៃខ្ញុំ បានរត់ប្រាសប្រាណ អគ្គីហោហានចូរចៀសចេញឆ្ងាយ។

រំពេចនោះភ្លើងព្រៃដែលឆេះនៅប្រមាណ១៦ករីសៈពីសំបុកក៏រលត់បាត់សូន្យឈឹងដូចក្តីប្រាថ្នារបស់កូនក្រួច។ បន្តិចម្តងៗសត្វនានាបានអើតកចេញពីសំបុក ដើម្បីពិនិត្យមើលស្ថានការណ៍។ កង្កែបស្រែកបង្អុកប្រាប់សត្វនានាថា៖ ភ្លើងរលត់ហើយ! រីឯចង្រិតបានផ្លុំកញ្ចែប្រេក។ ជាសញ្ញាឱ្យសត្វនានាចេញពីរន្ធរបស់ខ្លួន។ បន្ទាប់មកសត្វនានាបានយំរត់រកគ្នាលាន់ឮពេញព្រៃ។ មេបារបស់កូនក្រួចបានវិលមកកាន់ទ្រនំវិញ ហើយមានសេចក្តីត្រេកអរឥតគណនា នៅពេលដែលឃើញកូនរបស់ខ្លួនមានជីវិតរស់នៅដោយសុវត្ថិភាព។

បន្ទាប់មកព្រះសម្មាសម្ពុទ្ធទ្រង់បញ្ជាក់ថា៖ កន្លែងដែលគថា



www.elibraryofcambodia.org

គតគង់ប្រថាប់នេះឯង ជាកន្លែងសំបុកកូនក្រួចមានវិទ្ធិរស់នៅ។ រួចព្រះអង្គបានសម្តែងថា៖ ម្នាលភិក្ខុទាំងឡាយ តថាគតបានប្រារព្ធបារមីនៃសច្ចធម៌នោះក្នុងជាតិដ៏ច្រើនទៀត មិនមែនត្រឹមតែក្នុងជាតិជាកូនក្រួចនោះឡើយ។

អវសានកថា ព្រះបរមគ្រូបានបញ្ចប់ព្រះទេសនា ដោយប្រជុំជាតកថា៖ មេបារបស់កូនក្រួចនោះ គឺមាតាបិតារបស់តថាគតសព្វថ្ងៃនេះ។ រីឯកូនក្រួចដែលសម្តែងគុណសច្ចបារមីរបស់ព្រះពុទ្ធអង្គពីអតីតកាលនោះ គឺជាតួអង្គតថាគតនេះឯង[៣៥]។

## ៣៣. ចាបឡៀបតម្បាស[៣៦]

កាលពីអតីតកាល ក្នុងរាជ្យព្រះបាទព្រហ្មទត្តសោយរាជ្យនៅក្រុងពារាណសី មានដំរីពោធិសត្វមួយបានចាប់កំណើត។ នៅពេលធំពេញវ័យ ដំរីនោះមានរូបសម្បត្តិល្អស្អាតគួរឱ្យស្រឡាញ់។ មិនតែប៉ុណ្ណោះដំរីនោះ ជាមេហ្វូងដែលមានដំរីជាបរិវារ៨ម៉ឺនរស់

---

[៣៥] - កំណត់បន្ថែម៖ តាមរឿងជាតកដែលបកប្រែដោយអ្នកនិពន្ធ Tomas William Rhys David បញ្ជាក់ថា៖ តាមសិលាចារឹកនាវត្តជេតពន គេឃើញកំណាព្យមួយវគ្គទាក់ទងនឹងរឿងព្រះមហាសត្វក្រួចគាថា ដេញភ្លើងព្រៃមានសេចក្ដីថា៖ បារមីក្នុងលោក ដែលសត្វស្វែងរក បានដោយកម្រ មានតែសច្ចៈ គុណធម៌បវរ សច្ចាស្មោះស ប្រសើរថ្លៃថ្លា។

[៣៦] - ក្រុមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, ១៩៩៤, អដ្ឋមភាគលេខ ៥៩, ទំព័រ ១០។



www.elibraryofcambodia.org

នៅក្នុងព្រៃហេមពាន្ត។ គ្រានោះមានសត្វចាបជៀបកប្បាសបានធ្វើសំបុក និងក្រាបពងត្រង់ផ្លូវដំរីធ្លាប់ដើររកអាហារ។ ពេលកូនចាបញាស់ ស្លាបនៅមិនទាន់រឹងពុំអាចហោះហើររួច។ មេចាបជៀបកប្បាសឃើញដំរីដើរមក ភ័យណាស់ដោយគិតថា៖ ស្តេចដំរីនេះនឹងជាន់កូនយើងស្លាប់មិនខាន។ ណ្ហើយចុះ! ខ្ញុំនឹងអង្វរបិត្តចំពោះការរក្សាកូនពីស្តេចដំរីដែលប្រកបដោយធម៌ ដើម្បីការពាកូនរបស់ខ្ញុំ។ ពេលនោះសត្វចាបជៀកកប្បាស បានលើកស្លាបទាំងពីរខាងដាក់គង់ដូចសំពះ និងនិយាយចំពោះស្តេចដំរីថា៖ ព្រះអម្ចាស់ជាស្តេចមានកម្លាំង សូមជ្រះថ្លាដែលព្រះអម្ចាស់មានអាយុ៦០ឆ្នាំរស់នៅក្នុងព្រៃបរិបូណ៌ដោយយស និងបរិវារ។ ខ្ញុំម្ចាស់សូមធ្វើអញ្ជលីដោយស្លាបទាំងពីរ សូមលោកកុំសម្លាប់កូនខ្ញុំព្រះអង្គ ព្រោះកូនរបស់ខ្ញុំនៅតូចទន់ខ្សោយគ្មានកម្លាំងអាចហោះហើរបាននៅឡើយទេ។ ដំរីពោធិសត្វពោលថា ៖ នែចាបជៀបកប្បាស! អ្នកកុំគិតខូចចិត្តឡើយ ខ្ញុំនឹងរក្សាកូនតូចៗរបស់អ្នក ។ ខ្ញុំនឹងឈរឃុំត្រង់រាំងដោយជើងទាំង៤ការពារកូនចាបទាំងអស់នោះ មិនឱ្យហ្វូងដំរី៨ម៉ឺនក្បាលដើរជាន់ចាបបានឡើយ។ ដំរីពោធិសត្វពោលបន្តទៀតថា៖ តែចាបជៀបកប្បាសអើយ ! ខ្ញុំរក្សាជីវិតកូនរបស់អ្នកបានតែប៉ុណ្ណោះទេ តែចូរអ្នកប្រយ័ត្ន ព្រោះនៅខាងក្រោយទៀតមានដំរីមួយក្បាល តែងដើរតាមផ្លូវនេះដែរ ដំរីនោះអាចនឹងមិនធ្វើតាមការអង្វររបស់យើងទាំងឡាយទេ។ ទោះបីខ្ញុំនិយាយបញ្ចុះបញ្ចូលជាមួយគេយ៉ាងណា ក៏គេមិន



www.elibraryofcambodia.org

ដែលស្តាប់ដែរ។ តែអ្នកគប្បីនិយាយអង្វរដំរីនោះចុះ ដើម្បីឱ្យផុតពីការភ័យដល់កូនតូចៗ នៅពេលគេដើរមកដល់។ ពោលរួចហើយ ដំរីពោធិសត្វក៏ដើរចេញទៅ។

បន្ទាប់មកដំរីកំណាចក៏ដើរមកដល់ ចំណែកចាបជៀបកប្បាសក៏ទទួលដោយផ្គងអញ្ជលីដែរ ហើយពោលថា៖ ខ្ញុំម្ចាស់សូមថ្វាយបង្គំលោកស្តេចដំរី ដែលដើរទៅក្នុងព្រៃរកអាហារតាមជើងភ្នំ។ ខ្ញុំម្ចាស់ផ្គងអញ្ជលីចំពោះលោកម្ចាស់ដោយស្លាបទាំងពីរ សូមលោកម្ចាស់កុំសម្លាប់កូនតូចៗ ដែលនៅមានកម្លាំងខ្សោយ។ ស្តេចដំរីនោះស្តាប់ពាក្យចាបជៀបកប្បាស ហើយក៏និយាយថា៖ នែសត្វចាបជៀបកប្បាស! យើងនឹងសម្លាប់កូនរបស់ឯងឱ្យខ្ទេចខ្ទី ឯងមានកម្លាំងអាចធ្វើអ្វីយើងបាន ? យើងនឹងទន្ទ្រំជាន់ឈ្លីកូនចាបតូចៗរាប់សែនឱ្យខ្ទេចដោយជើងរបស់យើង!។

កាលដំរីនោះពោលរួចហើយ ក៏យកជើងទន្ទ្រំកូនចាបជៀបកប្បាសទាំងអស់ដោយល្អិតខ្ទេចខ្ទី ថែមទាំងជុះនោមដាក់កូនចាបឱ្យអណ្តែតដោយទឹកនោម ព្រមទាំងស្រែកបន្លឺសំឡេងយ៉ាងខ្លាំង ហើយសើចសប្បាយទើបដើរចេញទៅ។ ឯមេចាបជៀបកប្បាសដែលទំនៅលើមែកឈើបានស្រែកយំ ហើយពោលថា៖ នែដំរីធំ! ពេលនេះអ្នកបន្លឺសំឡេងមុនចុះតទៅទៀតពីរបីថ្ងៃ អ្នកនឹងឃើញទង្វើរបស់ខ្ញុំ អ្នកមិនដឹងពីកម្លាំងប្រាជ្ញាថាធំជាងកម្លាំងកាយប៉ុណ្ណាទេ។ យើងនឹងឱ្យអ្នកដឹងពីកម្លាំងប្រាជ្ញានោះនៅពេលខាងមុខដ៏ឆាប់ៗមិនខាន។ កាល



www.elibraryofcambodia.org

ដែលជេរប្រទេចដីរនោះរួចហើយ បានពោលពាក្យបន្តទៀតថា៖ កិច្ច ដែលធ្វើដោយកម្លាំងកាយ តែងសម្រេចគ្រប់ទីទាំងឡាយ។ ព្រោះកម្លាំង កាយរបស់អ្នកពាល តែងមានតែចំពោះការសម្លាប់អ្នកដទៃ។ នែស្តេច ដីរ! អ្នកណាសម្លាប់កូនតូចៗរបស់យើង ដែលមានកម្លាំងខ្សោយ យើង នឹងធ្វើឱ្យអ្នកមិនមានសេចក្តីសុខចម្រើន នៅពេលខាងមុខនេះមិន ខានឡើយ។

នាងចាបជៀបកប្បាសពោលចប់ហើយ ទើបរកទំនុកបម្រុង ក្អែកមួយក្បាល អស់រយៈពេលពីរបីថ្ងៃល្មមដែលក្អែកនោះត្រេកអរ ពេញចិត្ត។ ក្អែកនោះក៏និយាយថា៖ យើងនឹងធ្វើកិច្ចការអ្វីៗសងជូនអ្នក វិញ។ មេចាបជៀបកប្បាសនិយាយថា៖ កិច្ចដែលយើងចង់ឱ្យអ្នកធ្វើនោះ គឺចូរអ្នកយកចំពុះរបស់អ្នកទៅចោះចឹកភ្នែកទាំងពីររបស់ដីរ ដែលកាច សាហាវធ្លាប់ដើរតាមផ្លូវនេះឱ្យធ្លាយបែក។ ពេលមេចាបជៀបកប្បាស ពោលចប់ហើយ សត្វក្អែកទទួលយល់ព្រម។ បន្ទាប់មក មេចាបជៀប កប្បាសក៏ទៅនិយាយនឹងទំនុកបម្រុងសត្វរុយក្បាលខៀវមួយក្បាល ទៀត។ រុយក្បាលខៀវក៏ទទួលការងារពីមេចាប ដែលបញ្ជាថា៖ អ្នក ចូលទៅពងដាក់ភ្នែកដីរទាំងពីរ នៅពេលដែលក្អែកបានចឹកបំបែកភ្នែក ដីររួច។ បន្ទាប់មកមេចាបក៏ទៅនិយាយនិងទំនុកបម្រុងសត្វកង្កែបមួយ ក្បាលទៀត។ មេចាបសូមឱ្យកង្កែបជួយធ្វើកិច្ចការដោយនិយាយថា៖ ពេលអ្នកឃើញដីរខ្វាក់ដើរស្វែងរកទឹកផឹក អ្នកត្រូវឡើងទៅលើកំពូល ភ្នំ ហើយបង្វែរបន្លឺសំឡេង។ កាលបើដីរនោះឡើងទៅដល់លើកំពូលភ្នំ



www.elibraryofcambodia.org

ចូរអ្នកដើរចុះមកដល់កន្លែងអន្លង់ជ្រោះ ហើយបញ្ចេញសំឡេងឱ្យដំរីឮទៀត។ កង្កែបតបថា៖ ខ្ញុំនឹងទទួលយកការងារនេះធ្វើឱ្យបានសម្រេច។

តមកក្នុងថ្ងៃមួយ ក្អែកបានយកចំពុះទៅចោះទម្លាយភ្នែកដំរីដរាបដល់បែកធ្លាយទាំងពីរ។ ឯសត្វរុយក្បាលខៀវក៏បញ្ចេញពងដាក់ទៅក្នុងភ្នែកដំរី។ ដំរីនោះត្រូវដង្កូវរុកភ្នែក បានសេចក្ដីទុក្ខវេទនា ហើយស្រេកទឹកយ៉ាងខ្លាំង ដំរីបានដើរស្វែងរកទឹកផឹក។ ពេលនោះសត្វកង្កែបលោតទៅលើកំពូលភ្នំ ហើយស្រែកយំ។ ដំរីគិតថាទឹកផឹកច្បាស់ជាមាននៅក្នុងទីនោះ វាក៏ប្រឹងដើរទៅលើកំពូលភ្នំ។ កង្កែបក៏មកបន្លឺសំឡេងនៅជិតមាត់ជ្រោះវិញម្ដង។ ដំរីក៏គិតថា៖ ទឹកផឹកនឹងមានក្នុងទីខាងមុខ ទើបដើរចុះទៅកាន់មាត់ជ្រោះ ហើយក៏ជុំងធ្លាក់ទៅក្នុងជ្រោះស្លាប់ទៅហោង។

គាថាពោលថា៖ ការធ្វើបាបកម្មដោយសប្បាយនឹងទទួលទុក្ខរហូតដល់ស្លាប់មិនខាន។



www.elibraryofcambodia.org

## ៣៤. ចាបពោធិសត្វ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តបានសោយរាជ្យនៅនគរពារាណសី។ ថ្ងៃមួយចាបពោធិសត្វបានសោយផលកម្ម អន្ទោលយកកំណើតជាសត្វចាប។ គ្រានោះមាននាយព្រានម្នាក់បានចាប់សត្វចាបជាច្រើនដែលរស់នៅក្នុងព្រៃ ហើយមកក្រុងទុកនៅក្នុងផ្ទះដើម្បីលក់ចិញ្ចឹមជីវិត។ ចាបពោធិសត្វគិតថា៖ បើយើងស៊ីចំណីគេផឹកទឹកគេ ប្រាកដជាព្រាននេះចាប់យើងលក់ឱ្យគេ។ ពេលនោះចាបពោធិសត្វគិតថា៖ យើងមិនចីចំណីគេ ហើយ មិនផឹកទឹកដែលគេបានដាក់ឱ្យនោះ រូបកាយយើងអាចនឹងស្គាំងស្គម។ ពេលមនុស្សឃើញយើងស្គម គេនឹងមិនទទួលទិញឡើយ។ គិតឧបាយដូច្នេះហើយ ក៏ធ្វើជាឈឺសំកុក មិនបរិភោគចំណី មិនផឹកទឹក រូបកាយក៏ចុះស្គាំងស្គមជាបន្តបន្ទាប់។ ឯពួកមនុស្សក៏គេមិនទទួលទិញមែន ដោយ រូបកាយមានតែស្បែកដណ្តប់ឆ្អឹង។ កាលបើមិនមានមនុស្សទទួលទិញយកហើយចាបផ្សេងៗទៀតគេទិញយកអស់ នាយព្រានឆ្ងល់ណាស់ថាចាបនេះវាយ៉ាងម៉េច ?។ នាយព្រានក៏ចាប់ចាបពោធិសត្វមកកាន់ផ្លៀងផ្លងពិនិត្យមើល ហើយដាក់លើបាតដៃ។ ឱកាសល្អហុចឱ្យព្រោះព្រានភ្លេចខ្លួន ចាបពោធិសត្វក៏រលាស់ស្លាបហើរចេញទៅព្រៃវិញដោយសុវត្ថិភាព។ ហ្វូងចាបដទៃដែលនៅក្នុងព្រៃឃើញព្រះពោធិសត្វអាចវិលមកកាន់ព្រៃវិញដូច្នោះ ក៏សួរនាំថា៖ ហេតុដូចម្តេចបាន



www.elibraryofcambodia.org

ជាអ្នកអាចរស់បានចេញពីទីគ្រោះថ្នាក់ដ៏ធំយ៉ាងនេះ ? ព្រះពោធិសត្វប្រាប់ថា៖ យើងត្រូវនាយព្រានចាប់ទៅក្រុងក្នុងទ្រុង ដើម្បីទុកលក់ តែយើងមិនស៊ីចំណី មិនផឹកទឹកដែលគេដាក់ឱ្យ ទើបរួចខ្លួនបាន។

ព្រះពោធិសត្វពោលជាគាថាថា៖ មនុស្សលោកកាលបើមិនចេះគិតពិចារណា ក៏រមែងមិនបានផលពិសេស។ ចូរមើលនូវផលនៃឧបាយរបស់យើងបានគិតនេះចុះ យើងបានរួចពីស្លាប់ គឺដោយសារប្រាជ្ញានៃការគិត។

## ៣៥. ចាបពោធិសត្វ[៣៧]

ក្នុងអតីតកាល គ្រាដែលព្រះពោធិសត្វយោនយកកំណើតជាសត្វចាបក្នុងសម័យព្រះបាទព្រហ្មទត្ត សោយរាជ្យនៅក្រុងពារាណសី។ ចាបពោធិសត្វតែងហោះហើររកចំណីដោយចឹកតែគ្រាប់ស្មៅ ឬគ្រាប់ធញ្ញជាតិផ្សេងៗដើម្បីចិញ្ចឹមជីវិត ហើយតែងហើរវិលមកក្នុងព្រៃវិញ។ គ្រានោះមានសត្វក្អែកស្គមមួយក្បាល បានស៊ីសាកសពឬសាច់របស់អ្នកស្រុកហាល ក៏នៅតែរកអាហារព្រោះមិនចេះឆ្អែត។ ទន្ទឹមនេះគេក៏តែងតែចូលទៅក្នុងព្រៃ ដើម្បីរកផ្លែឈើធំតូចស៊ីបន្ថែមជាបន្តទៀត។ ពេលមួយបានជួបនឹងចាបពោធិសត្វ ហើយសួរថា៖ អ្នកចីចំណីអ្វីបាន

[៣៧] - ក្រុមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, ១៩៩៤, អដ្ឋមភាគលេខ ៥៩, ទំព័រ ៦៣។



www.elibraryofcambodia.org

ជាធាត់យ៉ាងនេះ? ចាបពោធិសត្វមិនឆ្លើយតបនឹងសំណួរវិញទេ តែបានពោលថា៖ បងក្អែក! បងធីចំណីអាហារសុទ្ធតែល្អ ប្រណីតៗ ដែលមានឱជារសឆ្ងាញ់ៗ តើហេតុអ្វីបានជាបងស្គម ? ក្អែកឆ្លើយតបវិញថា៖ នែចាប ! កាលនៅកណ្ដាលហ្វូងសត្រូវស្វែងរកចំណីឆ្ងាញ់ៗប្រណីតៗមែន តែខ្ញុំស៊ីបណ្ដើរ ខ្ញុំភិតភ័យបណ្ដើរ ព្រោះខ្លាចម្ចាស់គេមកទាន់ ខ្ញុំមានទុក្ខប្រចាំខ្លួនជានិច្ច។ ជួនណាខ្ញុំលួចបានហើយ យកមកលួចដេកស៊ី ក៏នៅតែភិតភ័យមិនស្រណុកចិត្ត ពេលណាក៏កើតទុក្ខ។ ចូរលោកមើលចុះ ពួកក្អែកយើងខ្ញុំសុទ្ធតែរស់នៅក្នុងភាពភិតភ័យ។ ហេតុដូច្នេះហើយ បានជាពួកខ្ញុំគ្មានខ្លាញ់ធំធាត់ដូចបង។

ចាបពោធិសត្វតបវិញថា៖ ជាការពិតហើយ ខ្ញុំរស់នៅដោយគ្មានការភ័យបារម្ភ ព្រោះខ្ញុំធីតែគ្រាប់ស្មៅ គ្រាប់ធញ្ញជាតិដែលមិនមែនជារបស់អ្នកណាម្នាក់។ ខ្ញុំធីដោយសប្បាយ ព្រោះរបស់ទាំងអស់នោះឥតមានម្ចាស់ទេ។ ខ្ញុំធីឆ្អែត ខ្ញុំហើរមកកាន់ទ្រូនំ ដេកលក់យ៉ាងស្រួល។ ដូច្នេះបើអ្នកចង់សុខ ចូរកុំប្រកាន់ចិត្តលោភ និងបំពានទ្រព្យសម្បត្តិរបស់អ្នកដទៃ។



www.elibraryofcambodia.org

# ៣៦. ចាបពោធិសត្វ

មានរឿងតំណាលថា៖ តាំងពីយូរលង់ណាស់មកហើយ មានសត្វចាបមួយហ្វូងរស់នៅដោយសុខសាន្ត នាព្រៃមួយក្បែរក្រុងពារាណសី។ សត្វចាបទាំងនោះ តែងមកស្នាក់អាស្រ័យលើដើមឈើមួយដើម ដែលមានស្លឹកស៊ុបទ្រុប ព្រមទាំងបែកមែកសាខាចេញគ្រប់ទិសទី។

ថ្ងៃមួយមេហ្វូងនៃសត្វចាបបានសង្កេតឃើញពេលខ្យល់បក់មកម្តងៗ នាំឱ្យមែកឈើពីរកួតគ្នាធូលីហុយមកព្រមទាំងមានផ្កាភ្លើងហុយខ្ទាតធ្លាក់លើស្លឹកឈើងាប់ៗ។ ឃើញព្រឹត្តិការណ៍យ៉ាងដូច្នេះ មេហ្វូងចាបក៏ពិចារណាថា៖ ពេលនេះជារដូវប្រាំងក្តៅហួតហែង ផ្កាភ្លើងនេះអាចនឹងបណ្តាលឱ្យមានភ្លើងឆេះព្រៃនៅទីនោះជាមិនខាន។ ឯដើមឈើនេះអាចនឹងក្លាយទៅជាចំណីភ្លើង។ ពួកយើងមិនអាចរស់នៅទីនេះតទៅទៀតបានឡើយ ពួកយើងត្រូវតែហើរស្វែងរកទីកន្លែងថ្មីទៀត។

មេហ្វូងចាបពិចារណាដូច្នេះហើយ ក៏ពោលទៅកាន់ហ្វូងខ្លួនថា៖ ម្នាលអ្នកទាំងឡាយ! ដែនដីបានបង្កើតដើមឈើឱ្យយើងទាំងអស់គ្នាពឹងស្នាក់អាស្រ័យនៅ។ តែដើមឈើនេះនឹងត្រូវភ្លើងឆាបឆេះនៅពេលដ៏ខ្លីខាងមុខមិនខាន។ ដូច្នេះចូរយើងទាំងអស់គ្នា ប្រយ័ត្នប្រញាប់រកទីជម្រក ព្រោះថាទីនេះនឹងក្លាយឱ្យមានគ្រោះថ្នាក់។ ចូរអ្នកទាំង



www.elibraryofcambodia.org

អស់គ្នាហើរចេញពីទីនេះឱ្យបានរួសរាន់ជាទីបំផុត។

ពោលដូច្នោះហើយ មេហ្វូងចាបក៏បានហើរចេញពីទីនោះដោយមានសត្វចាបមួយហ្វូងធំហើរទៅតាមជាមួយ។ រីឯចាបមួយក្រុមទៀតឃើញដូច្នោះ ក៏នាំគ្នាពោលចំអកថា៖ គ្រាន់តែអញ្ចឹងសោះ ក៏នាំគ្នាចោទឡោដែរ! កុំចោតពេកពួកយើង។ អាគាត់ហ្នឹង សូម្បីតែទឹកមួយតំណក់ក៏គាត់មើលឃើញមានក្រពើដែរ។ ពោលរួចហើយ ពួកគេក៏នាំគ្នាសើចអឺងកងឡើង។ សំណើចចំអកក្អាកក្អាយរបស់គេ មិនទាន់ចប់ស្រួលបួលផង ស្រាប់តែភ្លើងព្រៃចាបឆេះសន្ធោសន្ធៅភ្លាមពេញដើមឈើទាំងមូល។ ផ្សែង និង អណ្តាតភ្លើងបានឆេះអួរអាប់ខ្មៅងងឹតបណ្តាលឱ្យសត្វទាំងអស់មានការភិតភ័យតក់ស្លុតស្រឡាំងកាំង រកច្រកហើរចេញពីទីនោះមិនរួច ក៏ត្រូវអណ្តាតភ្លើងចាបឆេះក្សិណក្ស័យក្នុងទីនោះទៅ។

## ៣៧. ព្រាបពោធិសត្វ

កាលពីអតីតកាល ក្នុងរាជ្យព្រះបាទព្រហ្មទត្តសោយរាជ្យនៅក្រុងពារាណសីនោះ ព្រះពោធិសត្វបានយោនយកកំណើតជាសត្វព្រាបមួយ។ ក្នុងសម័យនោះ រាស្ត្រនៅក្រុងពារាណសីនិយមយកកញ្ជើរក្រាលស្មៅធ្វើសំបុក សម្រាប់ឱ្យសត្វបក្សាបក្សីអាស្រ័យនៅតាមផ្ទះរៀងៗខ្លួនព្រោះដោយសេចក្តីប្រាថ្នាយកផលបុណ្យ។



www.elibraryofcambodia.org

កាលនោះមានចុងភៅរបស់សេដ្ឋីម្នាក់ ក៏បានធ្វើសំបុកដាក់ឱ្យសត្វដេកដែរ។ បន្ទាប់មកសត្វព្រាបពោធិសត្វ ក៏ចូលទៅរស់នៅក្នុងសំបុកនោះ។ ពេលព្រឹកព្រាបពោធិសត្វហើរចេញទៅស្វែងរកចំណីពេលល្ងាចវិលមករកទ្រនំវិញ គឺក្នុងទ្រនំដែលចុងភៅបានធ្វើឱ្យ។

ថ្ងៃមួយមានក្អែកមួយក្បាល បានហើរវិលវល់លើរោងចុងភៅរបស់ផ្ទះសេដ្ឋី។ សត្វក្អែកធុំក្លិនឈ្ងុយ ចំណីអាហារត្រីសាច់ដែលចុងភៅបានចម្អិនក៏កើតក្តីលោភៈ។ ក្អែកគិតថា៖ អញនឹងត្រូវនៅជ្រកក្នុងទ្រនំនេះជាមួយគេដែរ ព្រោះនឹងអាចបានអាស្រ័យសាច់ស៊ី។ បន្ទាប់មកក្អែកក៏បានចូលទៅជ្រកនៅក្នុងទីជិតនោះ។ លុះពេលល្ងាច ក៏បានឃើញសត្វព្រាបហើរចូលទៅក្នុងរោងរបស់ចុងភៅ។ ក្អែកក៏បាននិយាយអង្វរព្រាប ដើម្បីសុំជ្រកនៅក្នុងសំបុកជាមួយ។ ពេលនោះព្រាបពោធិសត្វបានពោលថា៖ អ្នកមិនអាចរស់នៅក្នុងសំបុកជាមួយយើងបានទេ ព្រោះអ្នកស៊ីចំណីផ្សេង ឯខ្ញុំស៊ីចំណីផ្សេង។ ដូច្នេះការរស់នៅជាមួយអ្នក យើងពិតជាលំបាកហើយ។ ក្អែកតបវិញថា៖ ពេលអ្នកហើរទៅរកចំណី ខ្ញុំក៏ហើរចេញទៅដូចអ្នកដែរ។ យើងមិនបានហើរទៅរកចំណីជាមួយគ្នាទេ។ ព្រាបតបថា៖ បើអញ្ចឹងល្អហើយ! យើងយល់ព្រមឱ្យអ្នកស្នាក់នៅជាមួយបាន។ តែអ្នកត្រូវទទួលលក្ខខ័ណ្ឌមួយ គឺអ្នកកុំធ្វេសប្រហែល។ ព្រឹកស្អែកឡើងព្រាបពោធិសត្វ និងក្អែកក៏ហើរចេញទៅរកចំណីរៀងៗខ្លួន។ ព្រាបតែងតែទៅរកអាហារជាគ្រាប់ស្មៅ ឬ គ្រាប់ធញ្ញជាតិផ្សេងៗ។ ឯក្អែកក៏ហើរទៅប្រទះគោងាប់ស្អុយរលួយមួយក្បាល។ ក្អែកសប្បាយ



www.elibraryofcambodia.org

ចិត្តណាស់បានចឹកស៊ីផ្លែត ហើយផឹកទឹកឡើងពេញពោះទៀត។ ពេលល្ងាចត្រឡប់មកវិញ ព្រាបសួរក្អែកថា៖ អ្នកស្វែងរកចំណីបានគ្រប់គ្រាន់ទេ? ក្អែកមិននិយាយតបវិញទេ គ្រាន់តែនៅស្ងៀម។

ពេលនោះចុងភៅឃើញមានសត្វពីរក្បាលរស់នៅជាមួយគ្នា ក៏និយាយជាមួយចុងភៅគ្នាគាត់ថា៖ សត្វព្រាបរបស់យើងបាននាំបក្សីដទៃទៀតមកនៅជាមួយហើយ។ ដូច្នេះយើងត្រូវធ្វើសំបុកមួយទៀតឱ្យគេរស់នៅ។ ពួកគាត់ក៏បានធ្វើសំបុកមួយទៀត ដើម្បីឱ្យក្អែកដេកសម្រាក។

ថ្ងៃមួយមានភ្ញៀវយ៉ាងច្រើន បាននាំត្រីសាច់យកមកជូនលោកសេដ្ឋីច្រើនណាស់ដែរ។ ពេលធ្វើម្ហូបអាហាររួចនៅសល់ ចុងភៅក៏បានប្រឡាក់ហាលលើដំបូលរោង ក្អែកឃើញក៏កើតចិត្តលោភៈ។ ស្អែកព្រឹកឡើងក្អែកមិនហើរចេញទៅរកស៊ីដូចសព្វដងឡើយ។ ក្អែកនិយាយប្រាប់ព្រាបថា៖ ព្រឹកនេះយើងមិនចេញទៅរកស៊ីទេ ព្រោះយើងមិនស្រួលខ្លួន។ បន្ទាប់មកក្អែកលែងនិយាយស្តី ហើយដេកសំកុករហូត។ មុននឹងហើរចេញស្វែងរកចំណី ព្រាបបាននិយាយនឹងក្អែកថា៖ ឱក្អែកសម្លាញ់! ចូរអ្នកទៅជាមួយយើង!។ ក្អែកតបថា៖ សូមអ្នកទៅចុះ! ខ្ញុំឈឺពោះណាស់!។ ព្រាបពោលថា៖ សម្លាញ់អើយ! ធម្មតាសត្វក្អែកមិនដែលចេះឈឺពោះទេ! តែយប់មិញខ្ញុំឮអ្នកកូរពោះក្នុងយាមទាំងបី។ មុននឹងហើរចេញទៅ ព្រាបបាននិយាយបញ្ជាក់ប្រាប់ក្អែកទៀតថា៖ ចូរអ្នកកុំប្រាថ្នាស៊ីចំណីរបស់មនុស្សឡើយ! ព្រោះចំណីរបស់មនុស្សជាចំណីដែលអ្នកពុំគួរស៊ីទេ! មកយើងទៅរកស៊ីជាមួយគ្នា! ក្អែកតបបញ្ជាក់វិញ



www.elibraryofcambodia.org

ថា៖ ខ្ញុំមិនអាចទៅបានទេ។ ព្រាបពោធិសត្វដាស់តឿនទៀតថា៖ បើអ្នកប្រព្រឹត្តអ្នកនឹងទទួលកម្មដែលខ្លួនបានសាង អ្នកកុំលុះក្នុងអំណាចនៃសេចក្តីលោភៈឡើយ។ ចូរអ្នកប្រយ័ត្នកុំបីធ្វេសប្រហែស! ។ និយាយចប់ព្រាបក៏ហើរចេញទៅរកស៊ីដូចរាល់ថ្ងៃ។

ចុងភៅនាំគ្នាត្រៀមអាហារផ្សេងៗ មានត្រីសាច់សម្រាប់លោកសេដ្ឋី។ ខណៈនោះក្អែកក៏តាមមើលចុងភៅ គេដឹងថាចុងភៅបានចេញពីផ្ទះទៅក្រៅអស់ហើយ។ គេគិតថា៖ ឥឡូវនេះសេចក្តីប្រាថ្នារបស់អញបានសម្រេចហើយ អញស៊ីអាធំៗមុន។ គិតរួចហើយក្អែកលោតចេញពីសំបុកទៅរកស៊ីសាច់ដុំធំៗ ដែលដាក់ក្នុងរោង។ ពេលក្អែកចឹកស៊ីតែងប៉ះកញ្ជ្រែងឮសូរក្រេស! ក្រេស! ។ ពេលនោះមានចុងភៅម្នាក់គាត់មិនបានចេញទៅក្រៅទេ។ គាត់ស្តាប់ឮសូរក្រេសៗ គាត់ចូលហើយដើរទៅមើលថាជាសូរអ្វី? គាត់ក៏ប្រទះឃើញក្អែកកំពុងចឹកស៊ី។ ពេលមើលឃើញក្អែកកំពុងចឹកស៊ីម្ហូបរបស់លោកសេដ្ឋី គាត់និយាយម្នាក់ឯងថា៖ ក្អែកនេះចិត្តខ្មៅណាស់ ហើយបើបាត់សាច់អស់ អញប្រាកដជាបាត់ជីវិតដែរ។ ពេលដែលក្អែកកំពុងស៊ីសាច់យ៉ាងច្ញាញ់ ចុងភៅបិទទ្វាររោងចាប់ក្អែកបានហើយយកទៅក្រុងទុក។ ពេលល្ងាចព្រាបពោធិសត្វវិលត្រឡប់មកទូនវិញឃើញក្អែកជួបនូវសេចក្តីវិនាស ក៏ពោលពាក្យថា៖ ឱក្អែកឡេះឡោះ! អ្នកមិនជឿពាក្យរបស់យើងប្រាប់ទេ ក៏ព្រោះតែដោយសេចក្តីលោភៈដែលជាហេតុ និងផលទើបជួបនឹងសេចក្តីទុក្ខយ៉ាងនេះ។

ព្រះពុទ្ធបរមគ្រូពោលគាថាថា ៖ បុគ្គលណាវឹងមានៈមិនស្តាប់



www.elibraryofcambodia.org

ពាក្យអ្នកគ្រប់គ្រងថែរក្សានិយាយទូន្មាន ព្រមទាំងមិនធ្វើតាមរបស់អ្នកគ្រប់គ្រងនោះ នឹងត្រូវដេកក្នុងការឃុំឃាំងដូច្នោះហើយ។ ដូចក្អែកមិនធ្វើតាមពាក្យទូន្មានរបស់សត្វព្រាប ត្រូវបានធ្លាក់ក្នុងកណ្តាប់របស់ពួកអមិត្តដែលជាជនពាល។ ឯក្អែកដេកក្នុងទ្រុងបានទឹកស្តាយក្រោយនូវសេចក្តីវិនាសជាវៀងរហូត។

រឿងនេះព្រះពុទ្ធបានបញ្ជាក់ពីជាតិឱ្យឃើញថា៖ ក្អែកក្នុងពេលនោះ ជាតិមុនជាភិក្ខុឡេះឡោះ។ ឯព្រាបបានជាអង្គអាត្មា យើងនៅពេលនេះឯង។

## ៣៨. ព្រាបពោធិសត្វ (រោមជាតក)[៣៨]

ក្នុងអតីតកាល ព្រះពោធិសត្វបានយកកំណើតជាសត្វព្រាប ហើយមានបរិវារយ៉ាងច្រើន រស់នៅក្នុងគុហាភ្នំ។ មានតាបសមួយរូបជាអ្នកមានសីល និងមានមារយាទល្អត្រឹមត្រូវ បានចូលទៅអាស្រ័យរស់នៅក្នុងបច្ចន្តគ្រាម[៣៩] សាងអាស្រមក្នុងទីជិតលំនៅរបស់ព្រាបជាច្រើនលើកំពូលភ្នំ។ ព្រាបពោធិសត្វបានមកកាន់សំណាក់របស់តាបសជាប់ជានិច្ច ដើម្បីស្តាប់រឿងដែលគួរស្តាប់។ តាបសរស់នៅទីនោះអស់

[៣៨] - ក្រមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, សត្តមភាគលេខ ៥៨ ទំព័រ ១៦២។

[៣៩] - ស្រុកចុងដែន ឬ ជនបទធ្លាយ។



www.elibraryofcambodia.org

រយៈកាលដ៏យូរ ទើបចាកចេញពីព្រៃ។ ពេលនោះមានតាបសទ្រុស្តសីល ម្នាក់ទៀត មករស់នៅបន្តក្នុងគុហានោះ។ ព្រាបពោធិសត្វ និងព្រាប ជាបរិវារបានចូលទៅរកតាបសថ្មីនោះ ថ្វាយបង្គំធ្វើបដិសណ្ឋារកិច្ច រួចហើយទើបចាកចេញទៅរកចំណីក្នុងទីផ្សេងៗ។ ដល់ពេលល្ងាចទើប ត្រឡប់មកវិញ។ តាបសថ្មីមករស់នៅក្នុងទីនេះបានជាង៥០ឆ្នាំ។ សម័យ ថ្ងៃមួយអ្នកបច្ចន្តគ្រាម បានទំនុកបម្រុងសាច់ព្រាបប្រគេនដល់តាបស នោះ តាបសក៏ជាប់ចិត្តក្នុងរសសាច់ព្រាប ទើបសួរថា ៖ សាច់អ្វីហ្នឹង? តាបសក៏បានដឹងថាជាសាច់សត្វព្រាប ទើបគិតថាសត្វព្រាបជាច្រើន រស់នៅក្នុងអាស្រមរបស់អញ អញនឹងសម្លាប់ទើបសម។ តាបសនោះ បានបាចអង្ករ នំក្រៀម នំស្រស់...ឱ្យព្រាបក្នុងទ្វារម្ខាង រួចយកដំបង ចីពរឃ្លុំ ហើយអង្គុយនៅទ្វារម្ខាងទៀត ចាំចាប់សម្លាប់សត្វព្រាប។ ព្រាបពោធិសត្វឃើញមារយាទអាក្រក់របស់តាបសនោះ ក៏នឹកគិតថា៖ តាបសកំហូចនេះអង្គុយដោយអាការប្លែកខុសធម្មតា ទើបយើងបាន ដឹងថាតាបសប្រាថ្នានឹងសម្លាប់ពួកយើងស៊ីសាច់ យើងមិនគួរទៅ សំណាក់របស់តាបសនេះទេ។ ព្រាបពោធិសត្វបាននាំព្រាបទាំង ឡាយត្រឡប់ចេញមកវិញ។ តាបសឃើញសត្វព្រាប ទាំងអស់មិនមក នោះ ក៏គិតថា៖ អញគួរនិយាយពាក្យពិរោះជាមួយសត្វព្រាប ហើយ សម្លាប់ពួកវាដែលចូលមកជិត ដើម្បីយកសាច់ស៊ី។ តាបសក៏ពោលគាថា ដូច្នេះថា៖ ម្នាលសត្វស្លាបមានរោម_ក! យើងនៅក្នុងគុហាភ្នំនេះជាង



www.elibraryofcambodia.org

៥០ឆ្នាំ ពួកអណ្ឌជសត្វ[៦០] មិនមានសេចក្តីរង្កៀសជាសត្វមានចិត្តស្លូតត្រង់រមែងមកក្នុងដៃនៃយើងក្នុងកាលមុន។

ម្នាលសត្វមានអវៈយវៈក្លក់ ឥឡូវនេះពួកទ្វិជសត្វ[៦១] ទាំងឡាយឃើញហេតុអ្វីបានជាមានសេចក្តីខ្វល់ខ្វាយគេចចេញពីភ្នំនេះ ទៅក្នុងភ្នំដទៃវិញ ក្រែងពួកបក្សីទាំងនេះទៅឃ្លាតយូរបានជាមិនស្គាល់យើងដូចកាលមុន? ឬពួកបក្សីមិនមែនជាពួកបក្សីទាំងឡាយនោះទេ?

ព្រាហ្មណ៍ពោធិសត្វពោលថា៖ ពួកយើងស្គាល់លោក ពួកយើងមិនប្រឡំទេ លោកគឺលោកដដែល ពួកយើងគឺសត្វទាំងឡាយ មិនមែនជាសត្វដទៃទេ តែចិត្តរបស់លោកប្រទូស្តចំពោះពួកយើង ! នៃអាជីវក ! ព្រោះហេតុនេះបានជាពួកយើងតក់ស្លុតនឹងលោក។

## ៣៩. រឿងសត្វមៀម (ឧលូកជាតក)

ក្នុងចំណោមមនុស្ស គេរើសមនុស្សដែលមានកាយសម្បទាល្អ ហើយនិងមានមារយាទល្អត្រឹមត្រូវ ទើបអភិសេកឱ្យឡើងជាស្តេច។ ពួកសត្វជើងបួនគេតែងតាំងរាជសីហ៍។ ឯសត្វត្រីគេតែងតាំងត្រីឈ្មោះអានន្ទជាស្តេច។ ចុះពួកយើងជាបក្សីតើគួរយកអ្នកគ្រប់គ្រងនឹងមានទីពឹងដូចគេដែរឬយ៉ាងណា?

---

[៦០] - សត្វកើតពីស៊ុត។

[៦១] - កើត២ដង។



www.elibraryofcambodia.org

ពួកគេក៏ប្រឹក្សាគ្នាដើម្បីជ្រើសរើសរកបក្សីណាមួយជាស្តេច។ នៅពេលកំពុងពិចារណា មានពួកបក្សីខ្លះឃើញមៀមមួយក្បាលគួរពេញចិត្ត ទើបពោលថា៖ យើងពេញចិត្តនឹងបក្សីនេះ។ គ្រានោះក៏ប្រកាសបីដងថា៖ ដើម្បីស្គាល់អធ្យាស្រ័យ សូមបក្សីគ្រប់ៗគ្នាអញ្ជើញប្រកាសតវ៉ា តែបើពេញចិត្តសូមនៅស្ងៀម។ តែក្នុងការប្រកាសលើកទីបី មានក្អែកមួយនិយាយថា៖ ឈប់សិនអ្នកទាំងឡាយ! បើក្នុងវេលាអភិសេកព្រះរាជានេះ មុខរបស់មៀមពេលមិនទាន់ក្រោធខឹងឃើញដូចជាក្រោធខឹង។ បើមៀមនេះឡើងសោយរាជ្យ តើមាននរណាហ៊ានចូលគាល់? ខ្ញុំមិនពេញចិត្តយកមៀមនេះធ្វើជាស្តេចទេ ហើយពោលគាថាទី១ថា៖ ពួកញាតិទាំងឡាយបានលើកកោសិយៈ(មៀម) ឱ្យធ្វើជាធំប្រសិនបើពួកញាតិអនុញ្ញាត ខ្ញុំសូមនិយាយពាក្យមួយម៉ាត់នេះ។ គាថាទី២ហ្វូងសត្វស្លាបពោលថា៖ ម្នាលសម្លាញ់! យើងអនុញ្ញាតហើយ ចូរអ្នកនិយាយនូវហេតុ និងពាក្យដែលជាប់ទាក់ទងដោយបវេណីប៉ុណ្ណោះ ត្បិតពួកបក្សីក្មេងៗដែលមានប្រាជ្ញា អាចទ្រទ្រង់នូវសេចក្តីរុងរឿងក៏នៅមានដែរ។ ក្អែកពោលគាថាទី៣ថា៖ សូមអ្នកទាំងឡាយមានសេចក្តីចម្រើនការដែលអភិសេកមៀម ខ្ញុំមិនពេញចិត្តទេ ចូរអ្នកទាំងឡាយមើលមុខមៀមដែលមិនទាន់ខឹង មានលក្ខណៈបែបនេះទៅហើយ ចំណង់បើខឹងទៀតគេធ្វើមុខដូចម្តេចទៅ?



www.elibraryofcambodia.org

## ៤០. រឿងសត្វមៀម[២]

សម័យថ្ងៃមួយ ព្រះពុទ្ធអង្គគង់នៅឥន្ទសាលាគុហារ គ្រានោះមានសត្វមៀមមួយអាស្រ័យនៅក្នុងប្រទេសនោះ លុះបានឃើញព្រះពុទ្ធជាម្ចាស់ក៏កើតចិត្តជ្រះថ្លាចំពោះព្រះអង្គ។ កាលបើព្រះពុទ្ធជាម្ចាស់និមន្តទៅបិណ្ឌបាត សត្វមៀមក៏តាមដង្ហែព្រះអង្គទៅ លុះពាក់កណ្តាលផ្លូវទើបត្រឡប់មកវិញ។ មានកាលមួយនោះមៀមបានឃើញព្រះពុទ្ធអង្គគង់នៅជាមួយភិក្ខុសង្ឃនាពេលល្ងាច មៀមក៏ហើរចុះចូលទៅកណ្តាលជំនុំសង្ឃ សម្របស្លាបទាំងឆ្វេងទាំងស្តាំធ្វើអញ្ជលីកម្មថ្វាយបង្គំដោយស្លាបប្រណម្យ ក្បាលឱនចុះក្រោមហើយធ្វើនមស្សការសម្តេចព្រះសាស្ត្រាចារ្យនិងភិក្ខុសង្ឃដោយគោរព។ សម្តេចព្រះពុទ្ធបានទតឃើញអាការសត្វធ្វើដូច្នេះ ក៏ព្រះអង្គធ្វើព្រះឱស្ឋញញឹមឱ្យប្រាកដ។ គ្រានោះព្រះអានន្ទទតឃើញព្រះអង្គញញឹមហើយក្រាបទូលសួរហេតុញញឹមឱ្យប្រាកដ។ ព្រះអង្គទ្រង់សម្តែងព្យាករណ៍ប្រាប់ថា៖

ម្នាលអានន្ទ! សត្វមៀមនេះមានចិត្តជាអ្នកមានសីលធម៌ដោយគោរព។ លុះទំលាយខណ្ឌពីសត្វមៀមទៅ នឹងបានទៅកើតក្នុងសុគតិភព អន្ទោលជាតិទៅមកតែក្នុងមនុស្ស និង ទេវតានៅនាឋានសួគ៌អស់មួយសែនកប្ប។ លុះដល់ទីជាតិចុងក្រោយនឹងបានត្រាស់ជាបច្ចេកពុទ្ធមួយព្រះអង្គមាននាមថាសោមនស្ស ដោយផលដែលបានឃើញព្រះអរិយៈជ្រះថ្លាធ្វើនមស្សការដោយគោរពនេះឯង។

---

[២] _ឯក ញ៉ឹម ព្រះវិន័យធរ អនុគណធម្មិសាភោ វត្តធម្មិស្សនារាម ខែត្រសៀមរាប។



www.elibraryofcambodia.org

# ៤១. កង្កែបស្តាប់ធម៌

មានតំណាលថា៖ កាលព្រះពុទ្ធសមណគោតមប្រោសប្រទានធម៌ទេសនាដល់បរិស័ទនៅជិតក្រុងចម្ប៉ា ក្បែរមាត់ស្រះបោក្ខរណីឈ្មោះគគ្គរា។ គ្រានោះមានសត្វកង្កែបមួយសម្ងំស្តាប់ធម៌ទេសនារបស់ព្រះអង្គ។ មានអ្នកឃ្វាលគោម្នាក់ដើរមកឈរច្រត់ដំបងពីលើក្បាលកង្កែបដោយពុំដឹងខ្លួន។ តែកង្កែបមិនហ៊ានស្រែកព្រោះខ្លាចពួរំខានដល់ការស្តាប់ព្រះធម៌របស់អ្នកដទៃ កង្កែបក៏បានធ្វើមរណកាល។ ហេតុតែកុសលដ៏ប្រពៃនេះ កង្កែបបានទៅកើតក្នុងភពតាវតិង្ស នៅក្នុងវិមានមាសកម្ពស់១២យោជន៍។ ពេលនោះគេហាក់ដូចជាភ្ញាក់ពីដេក ស្រាប់តែឃើញស្រីទេពអប្សរចោមរោមបម្រើជាបរិវារនៅឋាននោះ។ កង្កែបដែលកើតទៅជាទេវបុត្រ នឹកពីផលក្នុងចិត្តគិតថា៖ យីអើ ! គួរឱ្យចូលជាពន់ពេកហេតុអ្វីបានជាមកកើតក្នុងទីនេះ? រំពឹងគិតសព្វៗទៅមិនឃើញបុណ្យកុសលអ្វីដទៃ ក្រៅពីកិរិយាកាន់យកនូវនិមិត្តក្នុងសម្លេងព្រះធម៌ទេសនារបស់ព្រះពុទ្ធអង្គសោះ។ ទេវបុត្រដែលជាអតីតកង្កែបនោះមិនអស់ចិត្ត គេគិតហោះក៏ហោះបានដូចបំណង ហោះតាមអាកាសវេហាស៍ទំភាល័យព្រមទាំងវិមាន ដើម្បីបានទៅក្រាបថ្វាយបង្គំព្រះសម្មាសម្ពុទ្ធ។ ព្រះពុទ្ធអង្គទ្រង់មានព្រះតម្រាស់ថា៖

អ្នកណាហ្នឹង ! មានឫទ្ធិ មានយសរុងរឿង មានរស្មីបែងចាំងញ៉ាំងទិសទាំង៤ឱ្យភ្លឺស្វាង ហើយមកក្រាបសំពះដល់បាទានៃតថាគត?



www.elibraryofcambodia.org

ទេវបុត្រក្រាបទូលសួរព្រះពុទ្ធអង្គថា៖ ខ្ញុំព្រះករុណាកាលដើមឡើយជាសត្វកង្កែបអាស្រ័យនៅក្នុងទឹកមានវារីជាទីគោចរ។ ពេលមួយខ្ញុំព្រះអង្គកំពុងស្ដាប់ព្រះធម៌ព្រះអង្គ ស្រាប់តែមានអ្នកគង្វាលគោម្នាក់ច្រត់ឈើសង្កត់ខ្ញុំព្រះករុណាស្លាប់ទៅ។

ព្រះសម្មាសម្ពុទ្ធទ្រង់ព្រះសណ្ដាប់ហើយ ក៏ព្រះអង្គប្រោសប្រាប់ថា៖ កាលណោះតថាគតបានសម្ដែងព្រះសទ្ធម្មវិសេសទេសនាទាំងឡាយក្នុង៨ម៉ឺន៤ពាន់ លុះត្រាបានធម្មាភិសម័យ។ ឯទេវបុត្រនេះឯង លុះបានសោតាបត្តិផលហើយ ក៏មានចិត្តរីករាយក្រៃលែង។ បន្ទាប់មកទេវបុត្រក៏ហោះចាកទៅកាន់ទេវលោកនាយវិញនោះទៅ។

ត្រង់នេះសូមបញ្ជាក់ថា ព្រះសម្មាសម្ពុទ្ធដែលទ្រង់ព្រះនាមថា៖ **សត្ថា ទេវមនុស្សានំ** ព្រោះព្រះអង្គជាគ្រូនៃទេវតា និង មនុស្សទូទៅទាំងឡាយហើយ និងសត្វដទៃដូចសេចក្ដីដែលបានពណ៌នាមកនេះឯង។

## ៤២. កង្កែបខៀវ (ហរិតមណ្ឌូកជាតក)[៤៣]

ក្នុងអតីតកាលព្រះពោធិសត្វកើតជាកង្កែបខៀវ។ មានមនុស្សម្នាបានដាក់លបដើម្បីចាប់ត្រីក្នុងស្ទឹង និងតាមផ្លូវទឹកផ្សេងៗដោយពេលនោះ មានត្រីជាច្រើនបានជាប់ក្នុងលបហើយ។ គ្រានោះមាន

[៤៣] - ក្រុមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, សត្តមភាគលេខ ៥៨ ទំព័រ ១២៨ ដាក់ថា ហរិតមាតជាតក។



www.elibraryofcambodia.org

ពស់ទឹកមួយក្បាល ចង់ស៊ីត្រីដែលជាប់ក្នុងលបនោះ ក៏បានចូលទៅក្នុងលបដែរ។ ឯហ្វូងត្រីក្នុងលបទាំងអស់រួមគ្នា ចឹកចិញ្ចៀងប្រទាញស៊ីពស់នោះវិញរហូតរបួសចេញឈាម។ ពស់មិនមានទីពឹងខ្លាចស្លាប់ក៏ស្ទុះចេញតាមមាត់លប បានទទួលភាពឈឺចាប់ក៏ដេកនៅលើផ្ទៃទឹក។ កង្កែបខៀវឡើងទៅលើខ្នងលប ពស់មិនយល់សេចក្ដីឃើញកង្កែបខៀវឡើងទៅលើខ្នងលបនោះទើបសួរថា៖ នែសម្លាញ់កង្កែប ! កិរិយារបស់ត្រីទាំងនេះអ្នកពេញចិត្តខ្លះទេ? ហើយសួរទៀតថា៖ នែ! អ្នកជាកូនហរិតមណ្ឌូកមាតា(កង្កែបខៀវ) ត្រីទាំងឡាយស៊ីយើងដែលយើងជាសត្វមានពិស បានចូលទៅកាត់មាត់លបដោយហេតុយ៉ាងនេះ តើអ្នកពេញចិត្តដែរឬទេ? កង្កែបខៀវតបថា៖ ឥស្សរភាពរបស់បុរសនោះបានប្រព្រឹត្តទៅដរាបណា បុរសនោះរមែងរឹបជាន់ជនដទៃ។ លុះពួកជនដទៃបានឥស្សរភាពវិញ រមែងរឹបជាន់វិញក្នុងកាលណាបុរសអ្នករឹបជាន់នោះ ត្រូវពួកជនដទៃរឹបជាន់គឺអំណាចមានម្នាក់ម្ដង។។ ដូច្នេះយើងគួរចេះថ្លឹងថ្លែងពេលមានអំណាច។



www.elibraryofcambodia.org

# ៤៣. ស្ដេចមាន់ព្រៃ (កុក្កុដជាតក)[44]

ព្រះពោធិសត្វកើតជាមាន់ព្រៃ មានមាន់ព្រៃជាបរិវារច្រើនរយ។ ក្នុងពេលនោះមានមេឆ្មាញីមួយក្បាលអាស្រ័យនៅជិតព្រះពោធិសត្វដែរ។ វាប្រើឧបាយលួងលោមស៊ីមាន់ផ្សេងៗទៀតអស់ជាច្រើន គឺលើកលែងតែមាន់ពោធិសត្វមួយប៉ុណ្ណោះ ដែលវាពុំទាន់បានស៊ី។ ឯមាន់ពោធិសត្វយល់សេចក្ដី ក៏មិនហ៊ានទៅកាន់ព្រៃជ្រៅនោះ វាក៏គិតថា៖ មាន់មួយក្បាលនេះ ល្អលើសមាន់នានា តែវាមិនស្គាល់ថាយើងគ្រាន់បើយ៉ាងណាទេ! យើងក៏ជាអ្នកឆ្លាត មានឧបាយច្រើនដែរតើ! អញគួរលួងលោមមាន់នេះថាអញជាភរិយារបស់វា! ដូច្នេះអញគួរពោលជាពាក្យសុភាសិតសរសើរថា៖ នែអ្នកមានខ្លួនបិទបាំងដោយស្លាបដ៏ល្អវិចិត្រ ជាសត្វមានសិរក្រហមឆ្ពោះទៅកាន់អាកាសបាន ចូរអ្នកចុះអំពីមែកឈើមក ខ្ញុំនឹងប្រគល់ខ្លួនជាប្រពន្ធរបស់អ្នកដោយទទេ។

មាន់ពោធិសត្វតបថា៖ ម្នាលនាងដ៏ល្អជាទីត្រេកអរនៃចិត្ត នាងជាសត្វជើងបួន ខ្ញុំជាសត្វជើងពីរ ពួកម្រឹគ និងបក្សីមិនសមគ្នាទេ ចូរនាងស្វែងរកសត្វឯទៀតជាស្វាមីចុះ។ ពេលនោះក៏មានសំពោចញីមួយមកនិយាយជាមួយផងដែរថា៖ ខ្ញុំនៅជាកុមារី ជាស្រីនិយាយ

---

[44] - ក្រុមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, ១៩៩៤, អដ្ឋមភាគលេខ ៥៩, ទំព័រ ៤៩។



www.elibraryofcambodia.org

ពិរោះពោលពាក្យជាទីស្រឡាញ់ យើងនឹងត្រូវបានជាប្រពន្ធរបស់អ្នក ចូរអ្នកទទួលយកខ្ញុំដែលជាស្ត្រីល្អ ជាព្រហ្មចារិនីនោះ នឹងជាការល្អប្រសើរជាង។

មាន់ពោធិសត្វតិះដៀលថា៖ នែនាងជាសត្វស៊ីសាកសព ដីកឈាម ជាចោរបៀតបៀនមាន់។ នាងឯងមិនមែនចង់បានយើងធ្វើជាប្តីដោយការប្រសើរទេ។

ព្រះពុទ្ធសម្តែងថា៖ នារីទាំងឡាយដែលមានការវៀងវៃ បានឃើញបុរសដ៏ប្រសើរហើយ រមែងដឹកនាំដោយវាចាពិរោះយ៉ាងនេះឯង ដូចជាសំពោចញីប្រលោមមាន់ឈ្មោលមកធ្វើជាប្តីរបស់ខ្លួន។ បុគ្គលណាមិនចាប់យល់ប្រយោជន៍ បុគ្គលនោះរមែងលុះក្នុងអំណាចរបស់សត្រូវ រមែងកើតក្តីក្តៅក្រហាយក្នុងពេលជាខាងក្រោយផង។ ឯបុគ្គលណាគិតចាប់យល់ច្បាស់នូវប្រយោជន៍ដែលនឹងកើតឡើង បុគ្គលនោះរមែងរួចចាកការបៀតបៀនអំពីសត្រូវដូចមាន់ឈ្មោលយ៉ាងនេះឯង។



www.elibraryofcambodia.org

## ៤៤. ស្តេចមាន់ព្រៃនិងសំពោច (កុក្កុដជាតក)[៤៤]

ក្នុងអតីតកាលពោធិសត្វកើតជាមាន់ព្រៃ ហើយមានមាន់ច្រើនក្បាលជាបរិវារ។ ក្នុងព្រៃនោះមានសត្វសំពោចមួយរកឧបាយសម្លាប់មាន់ផ្សេងៗទៀត ស៊ីអស់ហើយនៅសល់តែមាន់ពោធិសត្វមួយទេ ដែលមិនទាន់បានសម្លាប់ស៊ី។ មាន់ពោធិសត្វជាអ្នកមិនចេញទៅរកចំណីតាមពេលវេលា ហើយសត្វសំពោចបានចូលទៅជិតមាន់ពោធិសត្វ រួចនិយាយស្និទ្ធស្នាលថា៖ នែស្តេចមាន់ជាសម្លាញ់! អ្នកកុំខ្លាចខ្ញុំអី ខ្ញុំយកអ្នកធ្វើជាមិត្តចាប់ពីថ្ងៃនេះទៅ យើងជាសម្លាញ់នឹងគ្នា នៅទីខាងណោះសម្បូរចំណីអាហារណាស់ យើងនឹងទៅរស់ក្នុងទីនោះជាមួយគ្នា។

មាន់ពោធិសត្វបដិសេធថា៖ ឱ្យខ្ញុំជឿអ្នកដូចម្តេចកើត! ណ្ហើយចូរអ្នកទៅចុះ! សំពោចសួរថា៖ អ្នកមិនជឿខ្ញុំព្រោះខ្ញុំធ្វើអំពើអាក្រក់ពីមុនឬ? តាំងពីថ្ងៃនេះទៅខ្ញុំមិនធ្វើអាក្រក់ដូចមុនទៀតទេ។ មាន់ពោធិសត្វតបថា៖ ខ្ញុំមិនត្រូវការមិត្តសម្លាញ់ដូចអ្នកទេ ចូរអ្នកទៅចុះ។ មាន់ពោធិសត្វបានហាមសត្វសំពោចដល់ទៅបីដង ហើយបញ្ចេញសំឡេងដោយកងរំពងថា៖ អ្នកណាក៏ដោយមិនត្រូវធ្វើសេចក្តីស្និទ្ធស្នាលជាមួយសត្វសំពោចចង់ស៊ីមាន់ទេ។

---

[៤៤] - ក្រុមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, ១៩៩៤, អដ្ឋមភាគលេខ ៥៩, ទំព័រ ១៨៩។



www.elibraryofcambodia.org

គាថាព្រះពុទ្ធ៖ បុគ្គលមិនគប្បីស្និទ្ធស្នាលនឹងបុគ្គលដែលសាង បាប មិនគប្បីស្និទ្ធស្នាលនឹងបុគ្គលដែលពោលពាក្យឡេះឡោះ មិនគប្បីស្និទ្ធស្នាលនឹងបុគ្គលដែលមានប្រាជ្ញាដែលគិតតែប្រយោជន៍ផ្ទាល់ខ្លួន មិនគប្បីស្និទ្ធស្នាល នឹងបុគ្គលមានពុតត្បុតដែលធ្វើហាក់ដូចជាស្ងប់ស្ងាត់ក្រៃលែង។

## ៩៥. ធនាពោធិសត្វ (តិត្តិរជាតក)[១]

ព្រះពុទ្ធសមណគោតមសោយព្រះជាតិជាសត្វទទាក្នុងព្រៃហេមពាន្ត ទំអាស្រ័យនៅនឹងដើមជ្រៃធំមួយដើមជាលំនៅ។ គ្រានោះមានសត្វជាសម្លាញ់នឹងគ្នាពីរនាក់ទៀត គឺដំរីមួយ ស្វាមួយ រួមជាបីនឹងពោធិសត្វ។

សត្វទាំងបីនៅជាមួយគ្នា តែពេលក្រោយមកទទាពោធិសត្វសួរដំរី និង ស្វាថា៖ ម្នាលសម្លាញ់ទាំងពីរ យើងទាំងបីនាក់នេះ តើអ្នកណាចាស់ជាងគេ។ បើអ្នកណាចាស់ យើងត្រូវនាំគ្នាគោរពអ្នកនោះ។ ដំរីឆ្លើយថា៖ ម្នាលសម្លាញ់ ! កាលខ្ញុំនៅពីតូច ខ្ញុំដើរតាមមេខ្ញុំមកដើមជ្រៃនោះនៅក្រោមពោះខ្ញុំនៅឡើយ ខ្ញុំចាំមិនភ្លេចទេ។ ឯស្វាក៏ឆ្លើយថា៖ ម្នាលសម្លាញ់! កាលខ្ញុំនៅជាកូនស្វាតូចនៅឡើយនោះខ្ញុំមកជាមួយនឹងមេខ្ញុំ ដើមជ្រៃនេះនៅកម្ពស់ស្មើនឹងក្បាលខ្ញុំ ខ្ញុំបាន

[១] _ឯក ញ៉ឹម ព្រះវិន័យធរ អនុគណធម្មិសារពោវត្តធម្មិស្សនារាម ខែត្រសៀមរាប។



www.elibraryofcambodia.org

បេះត្រយជាអាហារ។ ទទាពោធិសត្វឆ្លើយថា៖ ម្នាលសម្លាញ់ទាំងពីរ ក្នុងទីដែលមានដើមជ្រៃមួយធំនោះ ខ្ញុំតែងពាំផ្លែជ្រៃនោះមកស៊ីជាអាហារ ហើយមកបន្ទោរបង់ឧច្ចារៈក្នុងទីនេះឯង។ ដើមជ្រៃនេះដុះពីឧច្ចារៈនៃខ្ញុំ។ ដូច្នេះខ្ញុំត្រូវចាស់ជាងអ្នកទាំងពីរ គឺទទាចាស់ជាងស្វា ស្វាចាស់ជាងដំរី ហើយយើងនឹងគោរពគ្នាតាមលំដាប់វស្សាចាស់ខ្ចី។ ទទាពោធិសត្វក៏ឱ្យស្វា និងដំរីសមាទានសីលប្រាំ។ សត្វទាំងពីរនោះក៏គោរពសត្វទទា។ លុះធ្វើកាលកិរិយាទៅសត្វទាំងបីក៏បានទៅកើតក្នុងឋានសួគ៌ដោយក្តីគោរពគ្នា និងការរក្សាសីលប្រាំជាប់ជានិច្ច។

## ៩៦. បក្សីព្រៃ (អនុសាសិកជាតក)[៤៣]

ពោធិសត្វបានកើតជាបក្សីព្រៃ ដល់ពេលចម្រើនវ័យបានជានាយកក្នុងហ្វូងសត្វ។ មានបក្សីជាច្រើនរយជាបរិវារ ចូលទៅកាន់ព្រៃហេមពាន្ត។ ក្នុងកាលព្រះពោធិសត្វទៅក្នុងព្រៃនោះ នាងបក្សីចណ្ឌាលមួយក្បាលតែងទៅតាមផ្លូវជាមួយ ដើម្បីរកអាហារចី។ នាងបានគ្រាប់ស្រូវគ្រាប់សណ្តែកជាដើម ដែលធ្លាក់ពីរទេះក្នុងទីនោះ។ នាងក៏គិតថា៖ ឥឡូវនេះយើងត្រូវរកវិធីធ្វើឱ្យពួកបក្សីដទៃមិនទៅកន្លែងនោះ។ គិតហើយនាងបានឱ្យឱវាទដល់ហ្វូងបក្សីឯទៀតថា៖

---

[៤៣] - ក្រុមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, សត្តមភាគលេខ ៥៨ ទំព័រ ៥១។



www.elibraryofcambodia.org

ផ្លូវធំក្នុងព្រៃឯណោះ ជាផ្លូវមានភ័យ មានហ្វូងសត្វជាច្រើនដូចជា ដំរី សេះ...កាចសាហាវណាស់ តែងចូលព្រៃមកទីនេះ បើមិនអាចគេចរួចបានទេ គួរកុំទៅទីនោះ។ ហ្វូងបក្សីឯទៀតតាំងឈ្មោះឱ្យនាងនោះថាម៉ែ គឺអនុសាសិក(អ្នកឱ្យឱវាទ)។

ថ្ងៃមួយនាងកំពុងទៅក្នុងផ្លូវធំឆ្ពោះទៅព្រៃ បានឮសូរយានមក នាងក៏ស្ទុះចូលយ៉ាងរហ័សរួចក្រឡេកមើលហើយគិតថា៖ នៅជិតឬនៅឆ្ងាយ? វេលានោះយានក៏មកដល់ខ្លួននាងល្មម ហើយនាងមិនអាចស្ទុះរួច យានក៏កិនរាងកាយនាងស្លាប់ទៅ។ បក្សីដែលជាមេហ្វូងបានកោះហៅប្រជុំក្នុងហ្វូងបក្សី តែមិនបានឃើញនាង ក៏និយាយថា៖ នាងអនុសាសិកមិនឃើញមក ចូរពួកអ្នកទៅរកនាង។ ពួកហ្វូងបក្សីទៅរកនាង ស្រាប់តែឃើញកាយបែកធ្លាយចេញជាពីរកំណាត់នៅកណ្ដាលផ្លូវធំ ក៏នាំគ្នាទៅប្រាប់មេហ្វូង។ មេហ្វូងបានពោលថា៖ នាងហាមអ្នកដទៃ តែខ្លួនឯងមិនធ្វើតាមពាក្យរបស់ខ្លួនឯង ទើបបែកខ្លួនជាពីរចំរៀក ហើយពោលគាថាថា៖ នាងបក្សីអនុសាសិកបានប្រដៅអ្នកដទៃជារឿយៗ តែខ្លួនឯងមិនមានប្រក្រតីតែងត្រាច់ទៅដោយសេចក្ដីល្មោភ ទើបត្រូវកង់រទេះកិន ហើយបែកមុខមាត់ខ្ទេចខ្ទីយ៉ាងដូច្នេះ។



www.elibraryofcambodia.org

## ៤៧. ស្តេចបក្សី (ឃតាសនជាតក)[៩៩]

ព្រះពោធិសត្វកើតជាស្តេចបក្សី មានបរិវារជាច្រើន ហើយអាស្រ័យនៅនឹងដើមឈើធំមួយបែកមែកសាខា ស្លឹកស៊ិបទ្រុបក្បែរមាត់ស្រះធម្មជាតិក្នុងព្រៃ។ ពួកបក្សីតែងនាំគ្នាទំលើមែកឈើដែលទេរទៅខាងទឹក ហើយតែងនាំគ្នាជុះអាចម៍ដាក់ក្នុងទឹកស្រះនោះ ដែលមាន នាគរាជដ៏កាចសាហាវនៅ។ នាគរាជពោលថា៖ បក្សីទាំងនេះនាំគ្នាជុះដាក់ស្រះដែលជាទីលំនៅរបស់អញ។ ដូច្នេះអញត្រូវធ្វើឱ្យភ្លើងឆេះចេញអំពីទឹក ហើយបន្តទៅឆេះដើមឈើនោះ ដើម្បីឱ្យពួកវាចៀសចេញទៅ។ ស្តេចនាគនោះមានចិត្តខឹងក្នុងកណ្តាលរាត្រី បំពេលពួកបក្សីមកជួបជុំគ្នាដេករលើមែកឈើ នាគក៏បណ្តាលឱ្យទឹកខ្ពុរឡើងដូចគេលើកស្រះឡើងដាក់តាំងលើចង្ក្រានភ្លើងដូច្នោះឯង។ នាគបានធ្វើឱ្យកើតមាននាគ្រាទី១ គ្រាទី២ គ្រាទី៣...ភ្លើងនេះតែងឆេះកម្ពស់ដើមត្នោត។ ព្រះពោធិសត្វឃើញភ្លើងឆេះសន្ធោសន្ធៅចេញពីទឹក ក៏ពោលថា៖ ម្នាលគ្នាយើងជាហ្វូងបក្សីទាំងឡាយ! ធម្មតាភ្លើងដែលឆេះឡើងយើងតែងនាំគ្នាយកទឹករំលត់ តែឥឡូវនេះទឹកនោះឯងប្រែក្លាយជាភ្លើងឆេះយ៉ាងខ្ពស់ពួកយើងមិនអាចនៅទីនេះបានទៀតទេ យើងត្រូវនាំគ្នាទៅទីដទៃវិញ។

ពោលគាថាថា៖ សេចក្តីក្សេមមាននៅទីណា ទីនោះតែងមាន

---

[៩៩] _ក្រុមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, សត្តមភាគលេខ ៥៨ ទំព័រ ៥៩។_



www.elibraryofcambodia.org

សត្រូវមករុកគួន។ ភ្លើងឆេះនៅកណ្ដាលទឹកក្នុងថ្ងៃនេះ និងនៅលើដើមឈើ យើងមិនអាចប្រៀបដូចដែនដីបានឡើយ។ ចូរពួកយើងនាំគ្នាហើរទៅតាមទិសផ្សេងៗគ្នាចុះ ព្រោះកន្លែងនេះមិនជាទីពឹងរបស់ពួកយើង ដែលអាចកើតមានភ័យបាន។

## ៤៨. បក្សីអាចម៍បំណេះ (សកុណគ្ឃជាតក)[៩៩]

ក្នុងអតីតកាល ព្រះពោធិសត្វបានជាកើតជាសត្វប្រចៀច[១០០] រកស៊ីតាមអាចម៍បំណេះដែលគេភ្ជួរនាកន្លែងរបស់ខ្លួន។

ថ្ងៃមួយក៏នឹកឃើញចាកចេញទៅរកស៊ីនៅទីផ្សេង ជាទីដែលខ្លួនមិនធ្លាប់ទៅ ហើយស្ថិតនៅទីឆ្ងាយទៀត។ ពេលនោះមានសត្វខ្លែងមួយស្ទុះចុះមកចាបចាប់បានយកទៅ។ សត្វប្រចៀចស្រែកយំដោយគិតថា៖ បើយើងនៅក្នុងដែនដីរបស់យើង ម្ល៉េះសមយើងបានសុខ សត្វខ្លែងមិនអាចចាប់យើងបាន។ តែពេលនេះយើងបានឃ្លាតឆ្ងាយពីពុកម៉ែ ទើបខ្លែងចាប់បាន។ ប្រការនេះកើតឡើងដោយហេតុព្រហើន ហើយក៏ជាអ្នកបរិបូណ៌ដោយឧបាយត្រេកអរក្នុងទីគោចរ

---

[៩៩] - ក្រុមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, សត្តមភាគលេខ ៥៨ ទំព័រ ៨០។

[១០០] - ប្រចៀច ឬ ប្រជៀច ៖ ឈ្មោះសត្វស្លាបតូច ជើងវែង ចំពុះវែង សំបុរស្រដៀងនឹងទទា ច្រើនរកស៊ីតាមដីគ្រោក ឬ អាចម៍បំណេះ ចូលចិត្តបរិភោគជន្លេន។



www.elibraryofcambodia.org

យល់ឃើញថាខ្លួននឹងបានប្រយោជន៍ មិនស្តាប់ពាក្យបណ្តាំពុកម៉ែដែលធ្លាប់ប្រាប់ថាឱ្យដើរតាមខាងក្រោម ដោយមិនឱ្យឡើងលើអាចម៍បំណះទៀត។ បើខ្ញុំស្តាប់បណ្តាំឪពុកម្តាយ ម្ល៉េះសមខ្ញុំមិនមានសត្រូវ ហើយអាចរស់នៅដោយសុខសប្បាយជាមិនខាន។

ព្រះសាស្តាពោលគាថាថា៖ សត្វខ្លែងបោះពួយចុះមកដោយកម្លាំងរហ័ស ចាបនូវសត្វប្រចៀចដែលទំនៅលើអាចម៍បំណះដែលជាទីគោចររបស់ខ្លួន ប្រចៀចក៏ដល់នូវសេចក្តីស្លាប់ ព្រោះដោយហេតុព្រហើននោះឯង។

## ៤៩. បក្សីត្រសេះ (កន្ទគលកជាតក)[៥៧]

ក្នុងអតីតកាល ព្រះពោធិសត្វកើតក្នុងកំណើតជាបក្សីត្រសេះឈ្មោះ ខទិរវនិយ រស់ក្នុងព្រៃហេមពាន្តជាមួយសម្លាញ់ជាសត្វត្រសេះមួយទៀត ឈ្មោះ កន្ទគលក តែងត្រាច់ទៅរកស៊ីក្នុងព្រៃ។ ថ្ងៃមួយកន្ទគលក បានជួប ខទិរវនិយ។ ខទិរវនិយ សប្បាយរីករាយយ៉ាងខ្លាំងបាននិយាយថា៖ សម្លាញ់មកហើយ! យើងនឹងនាំបក្សី កន្ទគលក ឯងចូលទៅក្នុងព្រៃរបស់យើង។ ពេលចូលទៅដល់ព្រៃហើយ ខទិរវនិយប្រើចំពុះចោះឈើ បានសត្វដែលចេញអំពីឈើមកឱ្យសម្លាញ់ស៊ី។ បក្សី

[៥៧] - ក្រុមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, សត្តមភាគលេខ ៥៨ ទំព័រ ១០៧។



www.elibraryofcambodia.org

កន្ទុគលក ចឹកស៊ីសាច់ដែលសម្លាញ់ឱ្យហើយ យូរៗទៅ ក៏កើតចិត្តមានៈ ឡើងថា៖បក្សីខទិរវនិយនេះក៏កើតក្នុងកំណើតសត្វត្រសេះ អញក៏មាន កំណើតដូចគ្នា អញមិនអាស្រ័យចំណីដែលគេឱ្យទេ អញនឹងចោះឈើ យកចំណីដោយខ្លួនឯង។ កន្ទុគលក ពោលនឹងខទិរវនិយថា៖ សម្លាញ់អើយ! កុំលំបាកឡើយ អញនឹងរកស៊ីដោយខ្លួនអញវិញ។ លំដាប់មក ខទិរវនិយ និយាយតបថា៖ នែសម្លាញ់! ការរកស៊ីក្នុងព្រៃឈើមិនមានខ្លឹមដូចដើម រកាជាដើមនោះមិនថ្វីទេ តែដើមឈើអស់នេះមានខ្លឹមរឹង អ្នកកុំចោះ ! ខ្ញុំមិនឱ្យអ្នកចោះឡើយ! បក្សី កន្ទុគលក តប ថា៖ អញមិនកើតក្នុង កំណើតត្រសេះទេឬ? គេមិនជឿពាក្យរបស់បក្សីខទិរវនិយ ក៏ស្ទុះហើរ យកចុងចំពុះចោះឈើ។ រំពេចនោះចុងចំពុះរបស់ កន្ទុគលក បាក់មួយ រំពេច ភ្នែកលៀន ក្បាលបែក មិនអាចចាប់ដើមឈើជាប់ ក៏ធ្លាក់មក លើដី រួចពោលគាថាទី១ថា៖ ម្នាលត្រសេះ ខទិរវនិយ ដ៏ចម្រើន! អាបែង ក្បាលយើង បែកដោយការប្រហារតែម្តង។ ដើមឈើដែលមានស្លឹក ល្អិតប្រកបដោយបន្លា តើដើមឈើនោះឈ្មោះអ្វី? ខទិរវនិយ ពោលគាថា ទី២ថា៖ ឱហ្ន៎! ត្រសេះនេះ កាលចោះឈើក្នុងព្រៃរបស់ខ្លួន ហើយតែង ហើរទៅរកពួកឈើមិនមានខ្លឹម ជាចំណែករបស់ខ្លួន។ គេមិនយល់ថា អាចមានឈើស្ងួតក្នុងពេលខាងមុខទេ។ បន្ទាប់មកគេក៏បានហើរមក បោកក្បាលរបស់ខ្លួននឹងដើមសង្កែ ដោយមិនយល់ថាជាឈើមានខ្លឹម អំពីកំណើត។



www.elibraryofcambodia.org

## ៥០. ក្រសេះពោធិសត្វ (ជវសកុណជាតក)[៥២]

ក្នុងអតីតកាល ព្រះពោធិសត្វកើតជាក្រសេះរស់ក្នុងព្រៃហេមពាន្ត។ គ្រានោះមានរាជសីហ៍មួយ ចីឆ្អឹងស្លាក់ជាប់បំពង់ករហូតដល់ហើយមិនអាចយកចេញបាន មិនអាចចីចំណីបាន ជួបសេចក្តីវេទនាយ៉ាងខ្លាំង។ ពេលនោះមានសត្វក្រសេះមួយហើរស្វែងរកចំណី ហើយបានទៅទំលើមែកឈើរួចសួររាជសីហ៍ថា៖ សម្លាញ់! អ្នកមានទុក្ខព្រោះអ្វី? រាជសីហ៍តបថា៖ សម្លាញ់អើយ យើងស៊ីសាច់ទាំងឆ្អឹងនាំឱ្យស្លាក់បំពង់ក។ ក្រសេះធានាថា៖ យើងនឹងជួយយកឆ្អឹងចេញពីបំពង់កឱ្យបាន តែយើងមិនអាចចូលទៅក្នុងមាត់របស់លោក ព្រោះខ្លាចលោកស៊ីខ្ញុំ។ រាជសីហ៍តបថា៖ អ្នកកុំខ្លាច ខ្ញុំមិនស៊ីអ្នកទេ ចូរជួយជីវិតខ្ញុំផងចុះ។ ក្រសេះតបថា៖ ល្អណាស់! រួចហើយឱ្យរាជសីហ៍ដេកផ្អៀងដោយគិតថា អ្នកណាដឹងថានឹងមានហេតុអ្វីកើតដល់យើង! ក្រសេះក៏យកកំណាត់ឈើទល់មាត់រាជសីហ៍ខ្ទាស់ទុក កុំឱ្យក្របាក់បាន ហើយយកចុងចំពុះគោះយកឆ្អឹងចេញ ឆ្អឹងបានធ្លាក់ចុះមក រួចហើយទើបដកកំណាត់ឈើចន្ទល់មាត់ចេញ ហើយហើរទៅទំលើមែកឈើ។ ថ្ងៃមួយពេលរាជសីហ៍ជារោគកំពុងស៊ីសាច់ក្របីព្រៃមួយក្បាល ដែលខ្លួនបានសម្លាប់ ក្រសេះគិតថាយើងនឹងពិសោធន៍រាជ សីហ៍លមើល!

---

៥២ - ក្រុមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, សត្តមភាគលេខ ៥៨ ទំព័រ ១៩៣។



www.elibraryofcambodia.org

ទើបហើរទៅទំលើមែកឈើជិតរាជសីហ៍នោះ ហើយពោលគាថាទី១ ថា៖ កម្លាំងរបស់យើងមាន ហើយយើងបានធ្វើកិច្ចដល់អ្នកតាមកម្លាំងនោះ។ បពិត្រមិត្តរាជសីហ៍! ខ្ញុំសូមថ្វាយបង្គំអ្នក តើខ្ញុំអាចត្រូវបានសាច់បន្តិចបន្តួចខ្លះទេ? គាថាទី២ រាជសីហ៍តបថា៖ អ្នកឯងចូលទៅតាមចន្លោះធ្មេញរបស់ខ្ញុំ ដែលជាអ្នកស៊ីសាច់ និងឈ្លាមធ្វើនូវអំពើអាក្រក់ទូទៅជានិច្ចនោះមក យើងរស់នៅដោយរបៀបណា គឺត្រូវមានសាច់នោះច្រើនណាស់។

គ្រសេះពោលថា៖ សេចក្តីដឹងគុណដែលគេធ្វើហើយ មិនមានក្នុងចិត្ត បុគ្គលណាសេពគប់នឹងបុគ្គលជាអ្នករមិលគុណ ដែលគេបានធ្វើ ហើយមិនតបស្នងសងគុណដល់អ្នកដែលធ្វើគុណដល់ខ្លួននោះ គឺជាការឥតប្រយោជន៍។ បណ្ឌិតមិនបានមិត្តធម៌ដោយសារគុណដែលខ្លួនសន្សំ ហើយបណ្ឌិតក៏មិនត្រូវមានចិត្តប្ញស្យា មិនត្រូវជេរ តែត្រូវគេចចេញពីបុគ្គលនោះដោយសន្សឹមៗ។

## ៥១. គ្រលេងគ្រលោងពោធិសត្វ (កុដិទុសកជាតក)[៥៣]

គ្រលេងគ្រលោងពោធិសត្វពេលចម្រើនវ័យធំហើយ បេះធ្វើសំបុកការពារភ្លៀងលើមែកឈើ ត្រង់ទីដែលខ្លួនពេញចិត្តក្នុងព្រៃ

[៥៣] - ក្រុមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, សត្តមភាគលេខ ៥៨ ទំព័រ ២០៨។



www.elibraryofcambodia.org

ហេមពាន្ត។ នៅរដូវវស្សាមានភ្លៀងស្រក់មិនដាច់ សត្វនានាត្រូវទទួលរងនូវភាពរងា។ គ្រានោះមានស្វាមួយក្បាល អង្គុយរណ្តំធ្មេញលើមែកឈើជិតគ្រលេងគ្រលោងពោធិសត្វ។ ពោធិសត្វឃើញស្វាស្ថិតក្នុងភាពយ៉ាងដូច្នោះ ក៏និយាយថា៖ នែពានរ! ក្បាល ដៃ ជើងរបស់អ្នកដូចជាមនុស្សដែរ ហេតុអ្វីបានជាគ្មានផ្ទះនៅ? ពានរតបថា៖ នែគ្រលេងគ្រលោង! ដៃ ជើង ក្បាលរបស់ខ្ញុំដូចមនុស្សមែនហើយ តែប្រាជ្ញាដែលបុរាណាចារ្យពោលថា ប្រសើរក្នុងពួកមនុស្សប្រាជ្ញាដ៏ប្រសើរនោះខ្ញុំមិនមានទេ។ គ្រលេងគ្រលោងតបថា៖ ធម្មតាអ្នកមានចិត្តមិននឹងធឹង របិលរប៉ូចជាអ្នកប្រទូស្តចំពោះមិត្ត មាន មារយាទមិនទៀងទាត់ជានិច្ច តែងមិនបានក្តីសុខទេ។ ចូរអ្នកពានរឯងធ្វើខ្លួនឯងដើម្បីឱ្យកើតបញ្ញា ហើយចូរផ្លាស់មារយាទអាក្រក់ចេញ រួចធ្វើខ្ទមជាគ្រឿងការពារគ្រជាក់ និង ខ្យល់ទៅ។

## ៥២. ប្រទីក (ចក្កវាកជាតក)[៥៤]

ក្នុងអតីតកាលមានក្អែកមួយក្បាលជាសត្វល្មោះល្មោះ ដើរស៊ីសាកសពផ្សេងៗក្នុងនគរពារាណសី គេស៊ីមិនចេះឆ្អែតឡើយ។ គេគិតថា អញនឹងត្រាច់ទៅស៊ីត្រីស្លាប់ក្នុងស្ទឹងគង្គាបានពីរបីថ្ងៃ ហើយចូល

---

[៥៤] - ក្រុមជំនុំព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយជាតក, ១៩៩៤, អដ្ឋមភាគលេខ ៥៩, ទំព័រ ១៥០។



www.elibraryofcambodia.org

ទៅដល់ព្រៃហេមពាន្តស៊ីផ្លែឈើតូចធំផ្សេងៗ រួចចូលទៅដល់ស្រះឈូកធំ១ ដែលមានត្រី និងអណ្តើកជាច្រើន។ ពេលនោះគេបានជួបប្រវឹកពីរក្បាល មានពណ៌ដូចមាសកំពុងស៊ីសារាយក្នុងស្រះនោះ វគបានគិតថា បក្សីប្រវឹកពីរក្បាលនេះមានសម្បុរល្អក្រៃលែងគ្មានបក្សីប្រៀប បក្សីនេះប្រាកដជាមានភោជនាហារពេញចិត្ត។ អញនឹងសួរនូវរឿងភោជនាហារទាំងនោះ ហើយស៊ីតាមបក្សីទាំងពីរនេះឱ្យមានសម្បុរដូចមាសដែរ។ ក្អែកក៏ហើរទៅកាន់សំណាក់បក្សីប្រវឹក ដោយធ្វើបដិសណ្ឋារកិច្ច ហើយទំត្រង់ចុងមែកឈើមួយកន្លែង រួចនិយាយថា៖ ខ្ញុំសូមសួរពួកអ្នកទាំងពីរ ដែលមានសម្បុរដូចសំពត់ជ្រលក់ដោយទឹកអម្ពត់ អ្នកជាសត្វមានចិត្តរីករាយត្រាច់ទៅទាំងគូ។ ចុះពួកអ្នកកើតក្នុងកំណើតជាអណ្ឌជៈ(សត្វកើតពីស៊ុត) និងមនុស្សទាំងឡាយ តើគេសរសើរនូវកំណើតអណ្ឌជៈណា ចូរអ្នកប្រាប់នូវហេតុនោះមកមើល! ប្រវឹកតបថា៖ ម្នាលក្អែកជាសត្វបៀតបៀនមនុស្ស ពួកគេតែងពោលសរសើរយើងជាប្រវឹកថា ជាសត្វប្រព្រឹត្តសមគួរក្នុងចំណោមមនុស្សទាំងឡាយ គេទាំងនោះបានសន្មតយើងថាជាសត្វមានភាពល្អក្នុងចំណោមសត្វស្លាបទាំងឡាយ ពួកយើងជាសត្វឥតមានភ័យ តែងត្រាច់ទៅទីផ្សេងៗក្នុងស្រះឈូក ពួកយើងមិនជឿបាបព្រោះតែហេតុចំណីឡើយ។ ក្អែកសួរទៀតថា៖ ម្នាលប្រវឹក! អ្នកមិនបោកទាប អ្នកទាំងឡាយបរិភោគផ្លែឈើអ្វី ទំពារស៊ីសាច់អ្វី បរិភោគភោជនអ្វីក្នុងស្រះបានជាកម្លាំង និង សម្បុរមានសភាពខ្លាំង ? ប្រវឹកឆ្លើយថា៖ នែក្អែក!



www.elibraryofcambodia.org

ផ្លែឈើទាំងឡាយមិនមានក្នុងស្រះទេ ពួកប្រវឹកបានសាច់អ្វីស៊ី! ពួកយើងជាអ្នកបរិភោគតែសារាយ ផឹកតែទឹកមិនល្អក់ ពួកយើងមិនធ្វើបាបព្រោះហេតុតែចំណីឡើយ ពួកយើងមានសភាពជាអ្នកឥតភ័យ ត្រាច់ទៅទីផ្សេងៗក្នុងស្រះ។ ក្អែកតបថា៖ ម្នាលប្រវឹក! ភោជនទេះមិនគាប់ចិត្តយើងទេ ខ្លួនអ្នកមានសភាពប្រហែលនឹងភោជនក្នុងលំនៅនេះ កាលដើមខ្ញុំមានសេចក្ដីត្រិះរិះយ៉ាងនេះដែរ តែពេលក្រោយមក ខ្ញុំមានសេចក្ដីត្រិះរិះផ្សេង សេចក្ដីសង្ស័យរបស់ខ្ញុំក៏កើតមានក្នុងហេតុនោះ ដោយប្រការដូច្នោះឯង។ ខ្លួនយើងតែងបរិភោគសាច់និងផ្លែឈើទាំងឡាយផងចំណីអាហារដែលលាយអំបិល និង ប្រេងទាំងឡាយផង។ ម្យ៉ាងទៀតយើងក៏តែងបានបរិភោគនូវរសជាតិរបស់ពួកមនុស្ស ដែលជាបុគ្គលក្លៀវក្លាបានឈ្នះក្នុងសង្គ្រាម។ ម្នាលប្រវឹកអើយ! សម្បុររបស់ខ្ញុំមិនដូចសម្បុររបស់អ្នកទេ! ប្រវឹកឆ្លើយថា៖ អ្នកជាសត្វមានអាហារមិនស្អាតតែងលោភលទន់លួចចក់ក្នុងខណៈពេលដែលគេធ្វេសប្រហែល អ្នកឯងតែងបានចំណីអាហារ នឹងទឹកផឹកដោយលំបាក។ ម្យ៉ាងទៀតក្អែកឯងមិនត្រេកអរនឹងផ្លែឈើទាំងឡាយ ហើយក៏មិនត្រេកអរនឹងសាច់ទាំងឡាយណាដែលមានក្នុងព្រៃស្មសាន។ ម្នាលក្អែក! បុគ្គលណាជាអ្នកលបលួចចក់ក្នុងខណៈដែលគេធ្វេសប្រហែល បាននូវភោគៈទាំងឡាយនោះ ដោយអំពើអាក្រក់ហើយ អ្នកផងតែងតិះដៀលបុគ្គលនោះហើយរមែងសាបសូន្យចាកសម្បុរនិងកម្លាំង។ បុគ្គលណាបានបរិភោគរបស់ត្រជាក់ឥតទោស សូម្បីតិចតួចក៏ដោយ តែជាអ្នកមិនបៀតបៀន



www.elibraryofcambodia.org

ជនដទៃដោយអំពើអាក្រក់ កម្លាំង និងសម្បុរតែងកើតមានដល់បុគ្គល នោះ ព្រោះថាសម្បុរទាំងអស់មិនមែនសុទ្ធតែសម្រេចមកពីអាហារ នោះទេ។

## ៥៣. សត្វភេពីរ

ក្នុងអតីតកាលមានភេពីររកស៊ីជាមួយគ្នា តែភេមួយដើររក ចាប់ត្រីខាងទឹករាក់ ឯមួយទៀតរកចាប់ត្រីខាងទឹកជ្រៅ។ ថ្ងៃមួយ ភេខាងទឹកជ្រៅចាប់បានត្រីធំមួយក្បាល។ ភេទាំងពីរដណ្តើមយក ចំណែកខាងក្បាលតែរៀងៗខ្លួន។ ពួកគេកើតជម្លោះមិនដាច់ស្រេច ក៏បានទៅជួបចចកមួយឱ្យជួយដោះស្រាយ។ ចចកបានអះអាងអួត ប្រាប់ថាខ្លួនគេជាអ្នកបែងចែក ប្រកបដោយយុត្តិធម៌ណាស់។ បន្ទាប់ មកចចកកាត់ត្រីជាពីរចំណែកមិនឱ្យស្មើគ្នា ដោយឱ្យចំណែកខាង ក្បាលតិចជាងទៅភេខាងទឹកជ្រៅ។ ភេខាងទឹកជ្រៅដែលបានចំណែក តិចមិនយល់ព្រម។ ចចកក៏ខាំស៊ីផ្នែកខាងកន្ទុយឱ្យតិចជាងវិញម្តង។ ភេខាងទឹករាក់ក៏មិនយល់ព្រមវិញម្តង ព្រោះបានចំណែកតិចជាង។ ចចកក៏ខាំស៊ីផ្នែកខាងក្បាលម្តងទៀត។...ចចកខាំស៊ីម្តងខាងក្បាល ម្តងខាងកន្ទុយ គឺខាំស៊ីមិនឱ្យស្មើគ្នាជារៀងរហូត។

ចុងបញ្ចប់ចចកបានស៊ីត្រីស្ទើរអស់ គឺនៅសល់តែឆ្អឹងក្បាល និងកន្ទុយ ទើបភេទាំងពីរភ្ញាក់ខ្លួន យល់ព្រមទទួលយកចំណែក រៀងៗខ្លួន។

ភេទាំងពីរមានវិប្បដិសារីទឹកស្តាយក្រោយយ៉ាងខ្លាំង។



www.elibraryofcambodia.org

# ៥៤. កំប្រុកពោធិសត្វ

ក្នុងអតីតកាល ពោធិសត្វបានកើតជាសត្វកំប្រុកឈ្មោល ហើយបានកំប្រុកញីជាប្រពន្ធនឹងមានកូនមួយ។

រាត្រីថ្ងៃមួយមានព្យុះភ្លៀងធំបោកបក់យ៉ាងខ្លាំង ក៏បណ្តាលឱ្យធ្លាក់សំបុកព្រមទាំងកូនទៅក្នុងទឹកសមុទ្រ។ មេបាកំប្រុកទាំងពីរនាំគ្នាយកកន្ទុយបាចទឹកសមុទ្រប្រកបដោយក្តីមេត្តានិងក្តីព្យាយាម។ ប៉ុន្តែទោះបីជាខិតខំបាចទឹកសមុទ្រល្ហល្ហេវយ៉ាងណាក៏ដោយ ក៏មិនរីងដែរ។

ប៉ុន្តែដោយសារការកសាងបារមីវីរិយៈ(សេចក្តីព្យាយាម) នៃកំប្រុកឈ្មោលពោធិសត្វជាយូររាប់រយសិបជាតិមុន បានបណ្តាលឱ្យក្តៅដល់អាសនៈព្រះឥន្ទ្រ ព្រះអង្គក៏យាងចុះមកជួយស្រង់យកកូនបាន ហើយប្រគល់ឱ្យទៅកំប្រុកជាបិតាវិញ។



www.elibraryofcambodia.org

# ៥៥. ការសេពនិងមិនសេព ពាលនិងបណ្ឌិត

មានកូនសេកពីរ ត្រូវខ្យល់ព្យុះកំបុតត្បូងផាត់ទៅធ្លាក់ក្នុងទីផ្សេងៗពីគ្នា។ បណ្តាលឱ្យកូនសេកទាំងពីរនោះបែកគ្នា កូនសេកមួយបានធ្លាក់ទៅក្នុងចន្លោះនៃគ្រឿងសស្ត្រាវុធក្នុងផ្ទះរបស់ចោរ ព្រោះដោយសារធ្លាក់ក្នុងទីនោះ ទើបពួកចោរដាក់ឈ្មោះថាសត្តិគុម្ពៈបានធំធាត់ឡើងហើយក្នុងចន្លោះនៃពួកចោរទាំងនោះ។ ឯកូនសេកមួយទៀតបានធ្លាក់ទៅក្នុងចន្លោះនៃផ្កាឈើ លើផ្ទៃនៃវាលដីខ្សាច់ក្បែរអាស្រម ព្រោះហេតុដែលធ្លាក់ទៅក្នុងទីនោះ ទើបបានពួកឥសីដាក់ឈ្មោះឱ្យថាបុប្ផកៈគឺក្នុងគុម្ពផ្កាដោយបានធំធាត់ឡើងហើយ ក្នុងចន្លោះនៃពួកតាបសឥសី។

ក្នុងគ្រាព្រះរាជាព្រះនាមបញ្ចាលនៃនគរឈ្មោះឧត្តរបញ្ចាលទ្រង់ប្រដាប់គ្រឿងអលង្ការសព្វគ្រប់ហើយ ព្រះអង្គបានយាងឡើងព្រះរាជរថដើម្បីទៅកាន់ព្រៃបរបាញ់សត្វ ហើយទ្រង់មានព្រះរាជឱង្ការថា៖ អើ! បើសត្វម្រឹគរត់ចេញតាមប្រឡោះនៃបុគ្គលណា បុគ្គលនោះឯងនឹងត្រូវមានទោស។ មានព្រះបន្ទូលដូច្នោះហើយស្តេចក៏យាងចុះអំពីព្រះរាជរថកាន់ធ្នូទៅទីកំបាំង។ ក្នុងខណៈនោះ ម្រឹគទ្រាយ (សត្វជើងបួន) កាលបើពួកមនុស្សកំពុងវាយគុម្ពោត ក៏បានក្រោកឡើងសំឡឹងមើលផ្លូវដើម្បីនឹងចេញទៅ។ វាក៏ឃើញថា ទីឋានដែលព្រះរាជាគង់នៅទីនោះជាទីស្រឡះ ទើបបែរមុខឆ្ពោះទៅទិសនោះ ហើយស្ទុះ



www.elibraryofcambodia.org

បោលគេចទៅ ។ ពួកមនុស្សក៏បានធ្វើការចំអកចំពោះព្រះរាជា ។ ព្រះអង្គបានតាំងព្រះទ័យថា ៖ អញនឹងចាប់ម្រឹគទ្រាយនោះឱ្យបានក្នុងពេលឥឡូវនេះ! ទើបព្រះអង្គស្ដេចយាងឡើងព្រះរាជរថដេញតាមម្រឹគទ្រាយទៅយ៉ាងលឿន ។ ឯពួកបុរសមិនអាចតាមជាប់ព្រះអង្គបានឡើយ ។ ព្រះរាជាទ្រង់យាងជាមួយនាយសារថី ទតមិនឃើញម្រឹគទ្រាយ ទើបស្ដេចយាងត្រឡប់មកវិញ ទ្រង់ស្រង់ទឹក និង សោយទឹកក្នុងជ្រោះភ្នំដែលជាទីគួរមនោរម្យ ហើយព្រះអង្គបានផ្ទំក្រោមម្លប់ឈើក្បែរផ្ទះចោរ។

គ្រានោះពួកចោរបានចូលទៅកាន់ព្រៃទាំងអស់គ្នាឯខាងក្នុងផ្ទះនៅសល់តែសេកឈ្មោះសត្តិគុម្ពៈ និង ចុងភៅម្នាក់ ។ សេកសត្តិគុម្ពៈហើរចេញពីផ្ទះ បានឃើញព្រះរាជាកំពុងផ្ទំយ៉ាងដូច្នោះ ហើយក៏ហើរចូលផ្ទះវិញ រួចនិយាយជាភាសាមនុស្សនឹងអ្នកដាំស្លថា៖ ពួកយើងនឹងសម្លាប់ព្រះរាជាចោល ប្រមូលយកសំពត់ និង គ្រឿងអលង្ការរបស់ព្រះអង្គហើយ ចាប់ព្រះអង្គត្រង់កព្រះបាទទាញអូសចេញ យកស្លឹកឈើទាំងឡាយមកគ្របបិទបាំងក្នុងទីកន្លែងមួយ ។ ព្រះរាជាទ្រង់តើនពីព្រះបន្ទំដោយព្រះសណ្ដាប់សំឡេងនោះ ព្រះអង្គជ្រាបថា ៖ ទីកន្លែងនេះមានភ័យចំពោះមុខ ព្រះអង្គមានព្រះទ័យភ័យខ្លាច ទើបស្ដេចឡើងកាន់ព្រះរាជរថចៀសចេញពីទីនោះ ដោយយាងទៅដល់អាស្រមរបស់តាបសឥសី។

ក្នុងគ្រានោះពួកតាបសឥសីចេញក្រៅអស់ដើម្បីទៅរកផល្លានុផលក្នុងអាស្រម នៅសល់តែសត្វសេកឈ្មោះបុប្ផកៈបុណ្ណៈ។ សត្វសេក



www.elibraryofcambodia.org

នោះ ពេលឃើញព្រះរាជាក៏បានធ្វើនូវបដិសណ្ឋារៈជាអាទិ៍ថា៖ បពិត្រព្រះមហារាជ ! ព្រះអង្គស្ដេចយាងមកប្រពៃហើយ ! មួយទៀតព្រះរាជដំណើររបស់ព្រះអង្គក៏មិនមែនទើសទាល់ដែរ។ ព្រះរាជាមានព្រះទ័យជ្រះថ្លាក្នុងបដិសណ្ឋារៈរបស់សត្វសេកឈ្មោះបុប្ផកៈនោះហើយ ទ្រង់ត្រាស់សរសើរសត្វសេកឈ្មោះបុប្ផកៈ ហើយបានតិះដៀលសេកឈ្មោះសត្តិគុម្ពៈដោយព្រះតម្រិះថា ៖ សត្វបក្សីនេះជាតិនេះ ជាសត្វដ៏ល្អប្រកបដោយធម៌ក្រៃលែង តែចំណែកបក្សីសេកក្រៅពីនេះ និយាយតែពាក្យអាក្រក់។ សេកបុប្ផកៈស្ដាប់ព្រះរាជឱង្ការនោះហើយ ក៏បានក្រាបទូលថា៖ បពិត្រព្រះមហារាជ ! ទូលព្រះបង្គំមានមាតាជាមួយនឹងសត្វសេកសត្តិគុម្ពៈនោះ។ ប៉ុន្តែសត្វសេកសត្តិគុម្ពៈនោះបានធំធាត់ឡើងក្នុងសំណាក់នៃពួកមនុស្សមិនល្អ ត្រូវពួកមនុស្សមិនល្អទាំងនោះដឹកនាំហើយដោយចោលធម៌។ ចំណែកទូលព្រះបង្គំធំធាត់ឡើងក្នុងសំណាក់នៃពួកមនុស្សល្អទាំងនេះដឹកនាំ ហើយដោយសីលធម៌។ ហេតុនេះទើបទូលព្រះបង្គំទាំងពីរផ្សេងពីគ្នាដោយធម៌។ ពោលចប់ហើយ ក៏សម្ដែងធម៌ថ្វាយព្រះរាជាតាមគាថាទាំងនេះថា៖

បពិត្រព្រះរាជា ! ពិតណាស់បុគ្គលសេពគប់រកនូវបុគ្គលបែបណា។ ទោះជាសប្បុរស ឬអសប្បុរសមានសីល ឬឥតសីល រមែងលុះក្នុងអំណាចបុគ្គលនោះឯង។ បុគ្គលយកបុគ្គលបែបណាមកជាមិត្តនឹងចូលទៅសេពគប់រកបុគ្គលបែបណា បុគ្គលនោះក៏មានអាការៈដូចគ្នាព្រោះកិរិយានៅរួម ក៏រមែងប្រាកដដូច្នោះ។



www.elibraryofcambodia.org

អាចារ្យត្រូវកូនសិស្សសេពគប់រក រមែងប្រឡាក់នូវកូនសិស្ស អ្នកសេពគប់នោះ។ ប្រៀបឧបមាដូចជាកូនសរដែលជ្រលក់ដោយថ្នាំពិស តែងប្រឡាក់បំពង់សរដូច្នោះឯង។ ដោយសារការភ័យខ្លាចអំពីការប្រឡាក់ទើបអ្នកប្រាជ្ញមិនយកបុគ្គលលាមកជាសម្លាញ់។ ជនណាខ្ចប់ត្រីស្អុយដោយចុងស្បូវភ្លាំង ក៏មានក្លិនស្អុយភាយចេញទៅដែរ។ ជនណាខ្ចប់ខ្លឹមក្រស្នាដោយឈើ សូម្បីស្លឹកឈើក៏មានក្លិនក្រអូបសាយចេញទៅដែរ។ យ៉ាងណាមិញការចូលទៅសេពគប់នូវអ្នកប្រាជ្ញក៏យ៉ាងដូច្នោះដែរ។ ហេតុនេះបុគ្គលជាបណ្ឌិតដឹងច្បាស់នូវបញ្ញាចាស់ទុំរបស់ ខ្លួនដូចជាកញ្ចប់ស្លឹកឈើ។ គេមិនគួរសេពគប់នូវពួក អសប្បុរស គួរសេពគប់ពួកសប្បុរស ត្បិតពួកអសប្បុរសតែងនាំ ទៅកាន់នរក ពួកសប្បុរសតែងផ្តល់នូវសុគតិ។



www.elibraryofcambodia.org

# សេចក្ដីសន្និដ្ឋាន

មតិខ្លះយល់ថា៖ ប្រទេសកម្ពុជាបានស្រុតធ្លាក់ចុះខ្លាំងនៅចុងសតវត្សទី១៣ គឺបណ្ដាលមកពីការកសាងប្រាសាទដ៏ច្រើនរបស់ព្រះបាទជ័យវរ្ម័នទី៧។ ព្រោះការកសាងនេះ បានចំណាយទ្រព្យធនអស់ច្រើនសន្ធឹកសន្ធាប់ និងបង្ខិតបង្ខំប្រជាជនឱ្យបំពេញកាតព្វកិច្ចជាច្រើនអនេកជាហេតុធ្វើឱ្យបាក់កម្លាំងកាយ និង កម្លាំងចិត្ត។

ចំពោះមតិនេះយើងយល់ថា ៖ ប្រសិនបើកើតឡើងដោយការបង្ខិតបង្ខំ ម្ល៉េះសមប្រាសាទទាំងអស់នោះមិនមានលក្ខណៈល្អប្រណីតឥតខ្ចោះ និងក្លាយទៅជាបេតិកភណ្ឌអច្ឆរិយៈដ៏ល្បីល្បាញនោះឡើយ។ ប្រការនេះវាត្រូវតែចេញពីទឹកចិត្ត ដែលមានសទ្ធាជ្រះថ្លា និងជំនឿខ្លាំងណាស់ (បុណ្យ)។ ពោលគឺមិនខុសពីសម័យបច្ចុប្បន្នដែលបានកសាងវត្តអារាម វិហារ កុដិ...ដ៏ច្រើនដូច្នោះដែរ។ ឯប្រការដែលធ្វើឱ្យប្រទេសកម្ពុជាស្រុតធ្លាក់ចុះ បញ្ហាសំខាន់គឺការបែកបាក់សាមគ្គីផ្ទៃក្នុងដែលជាឱកាសល្អសម្រាប់សត្រូវសៀម វាយទន្ទ្រានមកលើចក្រភពអង្គរ។ ហេតុផលមួយទៀត ដោយសារទំនាស់រវាងមនោគមវិជ្ជាសាសនានៃមេដឹកនាំបន្តបន្ទាប់ ធ្វើឱ្យស្ថានភាពនយោបាយរបស់ប្រទេសជួបវិបត្តិរីករាវ ច្របូកច្របល់ជាដើម...។ល។ ដូច្នេះហើយបានបង្កឱ្យអ្នកមានជំនឿលើព្រាហ្មណ៍ មានវិវាទជាមួយអ្នកមានជំនឿលើព្រះពុទ្ធសាសនា។ ប្រតិកម្មខ្លាំងបែបនេះគឺពួកអ្នក



www.elibraryofcambodia.org

កាន់ព្រហ្មញ្ញសាសនា បានបំផ្លិចបំផ្លាញព្រះពុទ្ធបដិមាដែលជាទីគោរពសក្ការៈក្នុងរាជព្រះបាទជ័យវរ្ម័នទី៧។ ទន្ទឹមនោះ ក៏ដោយសារនយោបាយត្រដាក់របស់សត្រូវឈ្លានពានសៀមផងដែរ។

ព្រះបាទជ័យវរ្ម័នទី៧ ព្រះអង្គមិនមែនជាក្សត្រមានមហិច្ឆតាលោភលន់ទេ ជាក់ស្តែងគឺក្រោយពេលព្រះបាទសុរិយាវរ្ម័នទី២សោយព្រះទីវង្គតក្នុងគ.ស.១១៥០ ព្រះបាទធរណិន្ទ្រវរ្ម័នទី២ ជាព្រះបិតារបស់ព្រះអង្គនឹងត្រូវជាព្រះអនុជជីដូនមួយរបស់ព្រះបាទសុរិយាវរ្ម័នទី២ បានឡើងសោយរាជ្យបន្ត។ ពេលនោះដែរ ចាមនៅតែបន្តសង្គ្រាម។ ព្រះបាទជ័យវរ្ម័នទី៧ បានជួយច្បាំងព្រះបិតា ហើយទៅច្បាំងនៅស្រីវិជ័យប្រទេសចាមទៀត។ ក្នុងពេលកំពុងច្បាំងនោះ ព្រះអង្គដឹងថាព្រះបិតារបស់ព្រះអង្គសុគត(គ.ស ១១៦០)។ ឯស្តេចសោយរាជ្យបន្តគឺព្រះបាទយសោវរ្ម័នទី២ តែព្រះអង្គគង់នៅស្ងៀម ហើយបន្តសង្គ្រាមដើម្បីសង្គ្រោះប្រទេសបន្តទៅទៀត ។ សូម្បីព្រះរាជបុត្ររបស់ព្រះអង្គគឺព្រះស្រិន្ទ្រកុមារ ក៏មានព្រះទ័យដូចទ្រង់ដែរ បានជួយសង្គ្រោះព្រះជន្មរបស់ព្រះបាទយសោវរ្ម័នទី២ ឱ្យរួចផុតគ្រោះថ្នាក់ពីពួកករតភាហូដែលបង់ធ្វើឃាត។ ព្រះបាទយសោវរ្ម័នទី២ សោយរាជ្យបានតែ៥ឆ្នាំ ក៏ត្រូវស្តេចស្រីភវន្តអាទិត្យវរ្ម័នធ្វើឃាតហើយឡើងសោយរាជ្យបន្ត ។ ពួកកងទ័ពចាម បានចូលមកដល់បឹងទន្លេសាបដោយមានជនជាតិចិនជួយនាំផ្លូវ(មានចម្លាក់នៅប្រាសាទបាយ័នផ្នែកថែវខាងត្បូងជៀងខាងកើត) ចូលមកដល់ក្រុងអង្គរធំទទួលបានជ័យជំនះនៅ គ.ស១១៧៧ ហើយ



www.elibraryofcambodia.org

ត្រួតត្រាខ្មែររយៈពេល៥ឆ្នាំ ។ ឯការរួចផុតពីការត្រួត ត្រារបស់ចាម គឺស្នាព្រះហស្តព្រះបាទជ័យវរ្ម័នទី៧វាយយកក្រុងអង្គរធំបានឡើងវិញនៅ គ.ស.១១៨១។ ក្រោយពេលបានឯករាជ្យ ព្រះអង្គបានឡើងសោយរាជ្យ ហើយកសាងទីក្រុងអង្គរធំឡើងវិញ ។ ពួកបច្ចាមិតបានដឹកជញ្ជូនយក ទ្រព្យទៅអស់ ហើយដុតបំផ្លាញរាជធានីអង្គរ។ ព្រះអង្គមិនបានកសាង តែប្រទេសជាតិទេ តែបានកសាងព្រលឹងខ្មែរឱ្យរស់មានជំនឿលើខ្លួនឯង តាមមាគ៌ារបស់ព្រះពុទ្ធសាសនា ។ នៅសម័យនោះ បានកសាងមជ្ឈ-មណ្ឌលវប្បធម៌ សេដ្ឋកិច្ច សង្គមកិច្ច សន្តិសុខ អប់រំ សុខាភិបាល គមនាគមន៍ សាសនា សិល្បៈ ស្ថាបត្យករចនាសម្ព័ន្ធ ឡើងវិញបានយ៉ាង ឆាប់រហ័ស នេះក៏អាស្រ័យលើមនសិការស្នេហាជាតិ និងការរួបរួមសាមគ្គី គ្នាក្នុងផ្លូវតែមួយជាមួយព្រះមហាក្សត្រដែរ/។

យើងដឹងរួចមកហើយថា ព្រះបាទជ័យវរ្ម័នទី៧ បានដឹកនាំប្រជា រាស្ត្រឱ្យដើរតាមមាគ៌ារបស់ព្រះពុទ្ធ។ ព្រះអង្គតែងផ្សព្វផ្សាយព្រហ្ម វិហារធម៌ ៖ មេត្តា ករុណា មុទិតា និងឧបេក្ខា ដែលមានកំពូលព្រហ្ម មុខ៤ នៅតាមប្រាសាទនានាជា គោលការណ៍។ ព្រះអង្គមានព្រះទ័យ ខ្វល់ខ្វាយចំពោះទុក្ខវេទនារបស់ប្រជារាស្ត្រ ហើយមានព្រះរាជបំណង ឱ្យរាស្ត្របាកផុតទុក្ខភ័យទាំងអស់នោះ តាមរយៈ មាគ៌ាព្រះធម៌របស់ព្រះ ពុទ្ធអង្គ ដែលជាព្រះបរមគ្រូនៃពុទ្ធសាសនិកជន ជាអាទិ៍មានព្រះធម៌ មិនឱ្យចងអាឃាត ហើយរួបរួមសាមគ្គីភាពនឹងគ្នា។ ទង្វើរបស់ព្រះអង្គ ក្នុងនោះមានកសាងអរោគ្យសាលាឬមន្ទីរពេទ្យចំនួន១០២កន្លែង ដែល



www.elibraryofcambodia.org

ប្រជារាស្ត្រគ្រប់មជ្ឈដ្ឋាន អាចចូលព្យាបាលរោគបានទាំងអស់ ដោយមិនប្រកាន់វណ្ណៈឡើយ។ ក្នុងមន្ទីរពេទ្យនោះក៏មានអ្នករៀបចំផ្គត់ផ្គង់ម្ហូបសម្រាប់អ្នកជំងឺ។ ទន្ទឹមនឹងនោះ មិនមានតែពេទ្យសម្រាប់ព្យាបាលជំងឺទេ តែមានអ្នកដើររកថ្នាំ អ្នកផ្សំថ្នាំទៀតផង។ ព្រះអង្គបានកសាងធម្មសាលា ឬហៅថាសាលាសំណាក់សម្រាប់ទុកជូនអ្នកដំណើរស្នាក់អាស្រ័យជាប់ហូរហែតាមផ្លូវ មានចំនួនសរុប១២១។ តែគេអាចដឹងថាមានផ្លូវចេញពីទីក្រុងអង្គរធំទៅកាន់ទីក្រុងនៃប្រទេសចម្ប៉ា (អតីតនគរចាម) មាន៥២ សាលា និងចេញពីទីក្រុងអង្គរធំទៅភីម៉ាយ (អតីតទឹកដីខ្មែរក្នុងសម័យចក្រភពអង្គរ) មាន៤៤សាលា។ នៅទីនោះក៏មានភ្លើងដុតបំភ្លឺនៅវេលាយប់ទៀត។ អ្នកការទូតចិន ជីវ តាក្វាន់ ដែលមកក្រោយរាជ្យព្រះបាទជ័យវរ្ម័នទី៧ គឺនៅក្នុងគ.ស.១២៩៦ បានលើកពីស្នាព្រះហស្តរបស់ព្រះរាជាមុន។ គាត់បានកត់ត្រាថា៖ មានផ្ទះសំណាក់សម្រាប់អ្នកដំណើរ ដែលជាកន្លែងសាធារណៈស្នាក់នៅបណ្ដោះអាសន្ន។ ដូច្នេះអាគារនោះ នៅតែបន្តមានសារប្រយោជន៍សម្រាប់ប្រជារាស្ត្រ។ ម្យ៉ាងទៀតក្នុងបច្ចុប្បន្នកាល តាមរយៈសមិទ្ធផលនៃស្នាព្រះហស្តរបស់ព្រះបាទជ័យវរ្ម័នទី៧ រួម និងស្នាព្រះហស្តរបស់ព្រះរាជាមុនៗផងនោះ ក្នុងបណ្ដាប្រទេសនៅតំបន់ភូមិភាគអាស៊ីអាគ្នេយ៍ គឺមានតែខ្មែរទេ ដែលមានស្នាដៃដ៏មហាសាលល្បីរន្ទឺ។ ប្រសិនបើគ្មានស្នាដៃទាំងអស់នេះទេគេមិនត្រឹមតែមិនស្គាល់ តែបើគេស្គាល់ គេអាចនឹងចាត់ទុកថាជាពូជទន់ទាប ព្រៃផ្សៃ កាប់ចាក់សម្លាប់តែគ្នាឯងដើម្បី



www.elibraryofcambodia.org

មហិច្ឆតាអំណាច។ តែដោយយោងលើកេរតំណែលទាំងអស់នេះ ហើយទើបអាចឱ្យគេទទួលស្គាល់ថា ជាពូជមានអរិយធម៌ខ្ពង់ខ្ពស់ មានទេពកោសល្យ មានបញ្ញាញាណ មានចំណេះដឹង ។ ទន្ទឹមនេះដែរ កេរតំណែលទាំងនោះ ក៏ជាប្រភពសេដ្ឋកិច្ច សម្រាប់លើកស្ទួយជីវភាពប្រជារាស្ត្រ ប្រសិនបើយើងចេះបែងចែក ថ្លិតថ្នមថែរក្សា ឱ្យបានល្អ និងឱ្យបានស្ថិតស្ថេរគង់វង្ស។

ក្រោយពេលព្រះបាទជ័យវរ្ម័នទី៧សោយព្រះទីវង្គត ព្រះបាទឥន្ទ្រវរ្ម័នទី២ ឡើងសោយរាជ្យបន្ត ពេលនោះគេមិនឃើញមានការកសាងប្រាសាទទេ ។ ឯព្រះរាជាសោយរាជ្យបន្ត គឺព្រះបាទជ័យវរ្ម័នទី៨ ពីគ.ស.១២៤៣-១២៩៥នោះ គេឃើញមានកសាងប្រាសាទតូចមួយឈ្មោះមង្គលាថ៌ ដែលជាប្រាសាទចុងក្រោយកសាងអំពីថ្មភក់។ ទន្ទឹមនេះព្រះអង្គបែរមកកាន់ព្រហ្មញ្ញសាសនាវិញ ដែលកើតប្រតិកម្មប្រឆាំងនឹងព្រះពុទ្ធសាសនាដោយដាប់បំផ្លាញសមិទ្ធផលទាំងឡាយសម្រាប់ឧទ្ទិសខាងពុទ្ធសាសនា។ មិនតែប៉ុណ្ណោះព្រះរូបខាងពុទ្ធសាសនាដែលកសាងមុនព្រះបាទជ័យវរ្ម័នទី៧ ក៏គេធ្លៀតដាប់បំផ្លាញចោលដែរ។

ព្រះបាទឥន្ទ្រវរ្ម័នទី៣ បានឡើងសោយរាជ្យនៅគ.ស.១២៩៥-១៣០៨ ដោយសារការបង្ហឹព្រះបាទជ័យវរ្ម័នទី៨ ជាបិតាក្មេកឱ្យប្រគល់រាជ្យ។ ព្រះរាជាអង្គនេះ បានបែរមកកាន់ពុទ្ធសាសនាឡើងវិញ តែតាមនិកាយហីនយាន។ បន្ទាប់មកព្រះបាទឥន្ទ្រវរ្ម័នទី៤ សោយរាជ្យបន្តនៅគ.ស.១៣០៨-១៣២៧។ ឯព្រះរាជាចុងក្រោយដែលបញ្ចប់រាជ្យ



www.elibraryofcambodia.org

វង្សវរ្ម័ន គឺព្រះបាទជ័យវរ្ម័នទី៩ សោយរាជ្យពីគ.ស.១៣២៧_១៣៣៦។

ក្រោយរាជ្យព្រះបាទជ័យវរ្ម័នទី៧ មានវិបត្តិធ្ងន់ធ្ងរ គឺវិបត្តិនយោបាយបែកបាក់គ្មានសាមគ្គីភាព ហើយចង់គំនុំសងសឹករវាងខ្មែរនឹងខ្មែរ ដែលបើកឱកាសឱ្យសត្រូវចូលលុក។ លទ្ធផលគឺប្រទេសកម្ពុជាកាន់តែតូចរួមទៅៗ។ រួមផ្សំនឹងកត្តានៃមហិច្ឆតារបស់សត្រូវជិតខាងដែលជាប្រទេសទើបកើតថ្មី នាំគ្នាហែកហួរដើម្បីលេបទឹកដីកម្ពុជា។

យោងលើប្រវត្តិសាស្ត្រ ដែលបានបង្ហាញនូវភាពវិនាសច្រំដែលៗដោយជាក់ស្តែងនេះ គួរកូនខ្មែរត្រូវពិចារណាឡើងវិញ។ យើងគួរដើរតាមមាគ៌ាដ៏ត្រឹមត្រូវរបស់ព្រះបាទជ័យវរ្ម័នទី៧។ ព្រះអង្គតែងកសាងកុសលតាមព្រះធម៌របស់ព្រះពុទ្ធ ដែលតែងបំពេញបារមីជាកុសលរាល់កប្ប ទើបអាចសម្រេចត្រាស់ដឹងចាក់ធ្លុះអស់ធម៌អាថ៌កំបាំងក្នុងធម្មជាតិ។ ឯចំពោះយើងដែលជាមនុស្សសាមញ្ញក៏ត្រូវខិតខំប្រឹងកសាងកុសលឱ្យបានល្អ ដោយពុះពារជំនះចំពោះរាល់គ្រប់ការងារល្អៗនោះ ឱ្យបានសម្រេចមគ្គផលប្រកបដោយធម៌ខន្តី គឺសេចក្តីអំណត់ និង ធម៌វិរយៈ គឺសេចក្តីព្យាយាម ព្រមទាំងកាន់ធម៌សច្ចៈ។ ទាំងអស់នេះ វាគឺជាគ្រឿងអលង្ការ សម្រាប់លម្អមនុស្ស និងប្រកបដោយ សេចក្តីថ្លៃថ្នូរទៀតផង។

ពាក្យណែនាំប្រៀនប្រដៅរបស់ព្រះពុទ្ធ គឺមិនត្រឹមតែជា ពាក្យពិតដែលព្រះអង្គបានរកឃើញចាក់ធ្លុះតែប៉ុណ្ណោះទេ ថែមទាំងមានប្រយោជន៍ណាស់សម្រាប់មនុស្សលោកគ្រប់កាល គឺ តាំងពី



www.elibraryofcambodia.org

អតីតកាលរហូតដល់បច្ចុប្បន្នកាល និង ទៅអនាគតកាលទៀត។ នេះជាជំនឿដែលទាងខ្ញុំធ្លាប់ជួបប្រទះ និង យល់ឃើញច្បាស់ជាក់ស្តែង ។ លោកអ្នកជឿចុះថា អ្នកកសាងបាបកម្មទាំងឡាយអាចនឹងយល់ច្បាស់ពេលបាបចាន ពេញគ្រប់គ្រាន់ហើយនោះ ផល នឹងផ្តល់ឱ្យមិនចាំបាច់ដល់អនាគតជាតិទេ តែក៏បានផ្តល់ឱ្យគេក្នុងជាតិនេះផងជាក់ជាមិនខាន។

បច្ចុប្បន្នបានបង្កើតនូវមជ្ឈមណ្ឌលបណ្តុះបណ្តាលអប់រំកុលបុត្រកុលធីតាខ្មែរ ដោយការបំបួសជាសាមណេរឬសីលវន្ត និងសីលវតីជាលំដាប់រៀងរាល់ឆ្នាំមែនពិត។ តែសូមក្មួយៗ ចៅៗទាំងឡាយ ខិតខំចងចាំនូវរាល់ដំបូន្មានក្នុងពេលសាងផ្នួស ដោយរក្សាមាគ៌ាតាមពុទ្ធឱវាទជារៀងរហូតកុំបីអាក់ខាន ក្រោយពីលាចាកផ្នួស ទោះបីក្នុងទេសកាលណាក៏ដោយ។



www.elibraryofcambodia.org

## អត្ថបទបន្ថែម

# របាំត្បោកប៉ៃលិន

មុននឹងអធិប្បាយអំពីរបាំត្បោកប៉ៃលិន យើងខ្ញុំសូមអនុញ្ញាតរៀបរាប់ពីប្រវត្តិនៃការហូរចូលមកកាន់តំបន់ប៉ៃលិនរបស់ពួកជនជាតិ **កុឡា** នេះបន្តិច។

អ្នកប្រវត្តិវិទូក៏ដូចជាអ្នកបុរាណវិទូជាដើម តែងផ្ដល់ពត៌មានថាជនជាតិឥណ្ឌា ជនជាតិចិន ជនជាតិហ្រ្គិក-រ៉ូម៉ាំង បានធ្វើពាណិជ្ជកម្មតាមសមុទ្រមកកាន់តំបន់អាស៊ីអាគ្នេយ៍តាំងពីមុនគ្រិស្តសករាជម្ល៉េះ។ ដោយឡែកអ្នកជំនួញឥណ្ឌាខ្លះពេលមករកស៊ីជួញដូរម្ដងៗ ក៏តែងមានព្រះសង្ឃនិមន្តមកជាមួយ ដោយមានតួនាទីក្នុងការដឹកនាំព្រះពុទ្ធសាសនាចេញពីឥណ្ឌាទៅកាន់តំបន់នានា។ ម្យ៉ាងទៀតគេចាត់ទុកថា ព្រះសង្ឃទាំងនោះថាមានភារកិច្ចរួមចំណែកក្នុងការថែរក្សាសុវត្ថិភាពរបស់ពួកគេ។ ទន្ទឹមនេះ ក្រោយពេលព្រះពុទ្ធយាងចូលនិព្វានប្រមាណជាង២០០ឆ្នាំ គឺតាំងពីស.វ.ទី៣នៃពុទ្ធសករាជ ឥទ្ធិពលសាសនារបស់ឥណ្ឌាក៏ផ្សាយចូលមកតំបន់នានានៅអាស៊ីអាគ្នេយ៍។ ក្នុងតំបន់អាស៊ីអាគ្នេយ៍នេះ មានកំពង់ផែដែលបានបម្រើសកម្មភាពយ៉ាងសកម្ម។ ដូចជា កំពង់ផែប្រទេសហ្វូណន ឬនគរភ្នំ ដែលមានឈ្មោះល្បីនោះ គឺកំពង់ផែអូរកែវ (បច្ចុប្បន្ននៅក្នុងប្រទេសវៀតណាម) និងកំពង់ផែអ៊ូថង(បច្ចុប្បន្នស្ថិត



www.elibraryofcambodia.org

នៅក្នុងប្រទេសថៃ)។ ឯនៅប្រទេសផ្សេងៗទៀត ក៏មានកំពង់ផែដែរ ដូចជា ៖ កំពង់ផែតាំព្រលីងនៅម៉ាឡេស៊ី កំពង់ផែតក្កោលៈតេនស្ស- រិមវសុង្គនៅប្រទេសភូមា កំពង់ផែបង្កានៅកោះស៊ូម៉ាត្រាជាដើម។

បច្ចុប្បន្ននេះប្រជាជននៃប្រទេសភូមាភាគច្រើនកាន់ព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួន ដូចប្រជាជនភាគច្រើននៃប្រទេសកម្ពុជាដែរ។ ប៉ុន្តែប្រភពដើមនៃគម្ពីរនោះ បានប្រែឡើងពីការរៀបរៀងដោយភិក្ខុនៃប្រទេសនានាមានការខុសប្លែកពីគ្នាខ្លះៗដែរ។ ទោះបីក្រោយមក គេបានរៀបរៀងបញ្ចូលគ្នាឱ្យនៅក្នុងទម្រង់តែមួយ ដូចដែលយើងបានឃើញគម្ពីរព្រះត្រៃបិដកមាននៅក្នុងគ្រាបច្ចុប្បន្ននេះ។

អាស្រ័យហេតុនេះហើយ បានជារបាំក្ងោកប៉ៃលិនមានការខុសប្លែកពីរឿងក្ងោកមាសពោធិសត្វ(មោរជាតក) ក្នុងសត្តមភាគលេខ៥៨ នៃព្រះត្រៃបិដកខុទ្ទកនិកាយជាតក។

ក្នុងរឿងព្រះពោធិសត្វយោនយកកំណើតជាសត្វក្ងោកនេះដែរ បច្ចុប្បន្នសាលាវិចិត្រសិល្បៈ និងនាយកដ្ឋានសិល្បៈទស្សនីយភាពរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈតែងសម្តែងរបាំ មួយឈ្មោះ «របាំក្ងោកប៉ៃលិន»។ របាំនេះបានស្រាវជ្រាវពីជនជាតិកុឡានៅតំបន់ប៉ៃលិនអំឡុងឆ្នាំ១៩៦៥។ ជនជាតិកុឡា គឺជាជនជាតិមួយក្រុមរស់នៅក្នុងរដ្ឋសហព័ន្ធភូមា តែបច្ចុប្បន្នគេហៅថា មីយ៉ាន់ម៉ា ដែលគោរពព្រះពុទ្ធសាសនាណាស់។ ពួកកុឡានេះបានចាប់ផ្តើមមករស់នៅកកើតជាភូមិស្រុកក្នុងតំបន់ប៉ៃលិនតាំងពីគ.ស.១៨៧៦។



www.elibraryofcambodia.org

ពួកគេមករស់នៅក្នុងបំណាងដីកយកត្បូង ដែលមាននៅក្នុងដីត្រង់ជ្រលងភ្នំនៃភូមិភាគនេះ។ ពិតមែនតែត្រង់នេះជាទឹកដីខ្មែរ តែកាលណោះស្ថិតនៅក្នុងអំណាចសៀមនៅ ឡើយ។ នៅគ.ស.១៩០៤ ទើបសៀមប្រគល់ដីខេត្តបាត់ដំបង ម្លូព្រៃ ស្ទឹងត្រែងមកឱ្យខ្មែរដែលកាលណោះតំបន់ប៉ៃលិនស្ថិតក្នុងខេត្តបាត់ដំបង ហើយក៏ត្រូវរាជការបាំងកំពុងត្រួតត្រាស្រុកខ្មែរ នោះគេបានកាន់កាប់ដោយតាំងប្រតិភូប្រចាំខេត្តបាត់ដំបង។

ជនជាតិកូឡានេះ ក៏មិនពីខុសជនជាតិខ្មែរដែរ ថ្វីត្បិតតែបញ្ជាក់ថាជាពុទ្ធសាសនិកជន តែពួកទាំងនោះនៅមានជំនឿគោរពបូជាបែបជីវចលនិយម ពិសេសគេគោរពម្ចាស់ទឹកម្ចាស់ដី មានលោកតាយ៉ាត និងលោកយាយយ៉ាត ដែលស្ថិតលើភ្នំ។ ឯរបាំក្ងោកប៉ៃលិនគឺជារបាំប្រពៃណីរបស់បងប្អូនកូឡា បានជាប់ទាក់ទងទៅនឹងជំនឿផង ហើយក៏ជាប់នឹងព្រះពុទ្ធសាសនាផងដែរ។

ចំពោះទំនាក់ទំនងរឿងនោះមានតំណាលថា៖ មានព្រះរាជបុត្រីក្សត្រមួយអង្គ បានសុបិនឃើញក្ងោកឈ្មោលដ៏សង្ហាមួយបានមកទេសនាយ៉ាងពិរោះថ្វាយព្រះនាងស្តាប់។ ព្រះនាងដក់ព្រះទ័យជ្រះថ្លានឹងព្រះធម៌ជាពន់ពេក។ តែដល់តើនឡើង ទើបដឹងថានេះ គឺជាការយល់សុបិនរបស់ព្រះនាងសោះ។ តែដោយសារអារម្មណ៍នៅតែជិតជាប់នឹងព្រះធម៌ពេក ព្រះនាងក៏ក្លាយជាភ្លេចអស់ការសោយការផ្ទុំ រហូតដល់ធ្លាក់ព្រះកាយប្រឈួនជាទម្ងន់។



www.elibraryofcambodia.org

ព្រះបិតាវិជ្ជយព្រះទ័យនឹងជំងឺរបស់ព្រះរាជបុត្រីយ៉ាងខ្លាំង។ ព្រះអង្គបានត្រាស់សួររកមូលហេតុដែលបណ្តាលឱ្យព្រះរាជបុត្រីមានព្រះរោគ។ ឯព្រះរាជបុត្រីទូលពីព្រះទ័យដែលបានជ្រះថ្លានិងព្រះធម៌តាមការយល់សុបិន ដោយចង់បានក្ងោកមានសីលនោះមកទេសនាថ្វាយព្រះនាងស្តាប់ជាបន្តទៀត។ ព្រះរាជាជ្រាបដូច្នោះ ក៏កោះហៅអាមាត្រឱ្យចាំវគង ចាំវឃ្មោះ រកព្រានព្រៃដែលខ្លាំងពូកែដើម្បីទៅព្រៃរកចាប់សត្វក្ងោកចេះទេសនានោះ ឱ្យបានជាច់ខាត។ ក្នុងពេលនោះមានព្រានព្រៃចំណានៗជាច្រើនរូប បានដើរស្វះស្វែងចូលទៅក្នុងព្រៃរកចាប់ក្ងោកសីលនោះ ទៅតាមសុបិនរបស់ព្រះរាជបុត្រីគ្រប់ទិសទី។

ទីបំផុតមានព្រានម្នាក់ បានរកឃើញក្ងោកមានសីលនោះមែន ប៉ុន្តែគេចាប់ពុំបាន។ រៀងរាល់ព្រឹក គេសង្កេតឃើញក្ងោកសីលនោះតែងតែភាវនាបែរមុខទៅទិសខាងកើត គឺទិសព្រះអាទិត្យរះ។ ឯរាល់ពេលល្ងាច ក្ងោកសីលតែងភាវនាបែរមុខទៅរកទិសខាងលិច គឺទិសព្រះអាទិត្យលិច។ ព្រានគិតថាក្ងោកសីលនោះមានបារមីខ្លាំងពូកែ គឺដោយសារការស្វាធ្យាយព្រះធម៌។ គេក៏មានគំនិតរកមធ្យោបាយចាប់ក្ងោកនេះឱ្យទាល់តែបាន គឺត្រូវរកវិធីបន្សាបសីលក្ងោកនេះជាមុនសិន។ គិតឃើញដូច្នេះហើយ ព្រានក៏យកក្ងោកញីដ៏ស្អាតមួយក្បាល មកបង្ហាត់យ៉ាងស្ទាត់ដើម្បីធ្វើជាធ្នាក់។ ក្ងោកញីតែងទៅបែចង់ក្ងោកឈ្មោល ទីបំផុតក្ងោកឈ្មោលក៏ភ្លេចអស់ការ



www.elibraryofcambodia.org

ភាវនាធម៌ ។ ដោយធ្លាក់ក្នុងអន្លង់ស្នេហ៍របស់នាងក្ងោកញី គេក៏ចាប់ក្ងោកសីលនោះបានដូចប្រាថ្នា។

ក្រោយពីព្រានព្រៃនាំយកក្ងោកឈ្មោលទៅថ្វាយដល់ព្រះរាជា និងព្រះបុត្រី ហើយក្ងោកបានរក្សាពាក្យសច្ចៈដោយសន្យាថា៖ នឹងមកសម្ដែងធម៌ទេសនារៀងរាល់ថ្ងៃសីល ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ហើយ ព្រះអង្គសព្វព្រះរាជហឫទ័យណាស់ ក៏បានថ្លែងអំណរគុណចំពោះក្ងោកសីលព្រមទាំងបានដោះលែងក្ងោកសីលឱ្យមានសេរីភាពឡើងវិញ។ ឯចំណែកព្រះរាជបុត្រីក៏បានស្រាកស្រាន្តពីជំងឺរោគាសះស្បើយដូចដើមវិញ។

ចំពោះឈុតក្ងោកប៉ៃលិនដែលបានសម្ដែងក្នុងពេលបច្ចុប្បន្ននេះ បានលើកអន្លើត្រង់ក្ងោកញី ក្ងោកឈ្មោលកំពុងពត់ពេនបង្អួតសម្រស់ ហើយរាំចែចង់គ្នាដោយក្ដីស្នេហា។ នេះជាប្រភពដើមដែលបណ្ដាលឱ្យក្ងោកឈ្មោលធ្លាក់ខ្លួនក្នុងភ្លើងស្នេហ៍។ ឯការតុបតែងកាយមានលក្ខណៈប្រាកដនិយមច្រើន ពោល គឺគេពាក់លើក្បាលក្ងោកធ្វើពីក្រដាសស្នាច់ និងពាក់ស្លាប ព្រមទាំងកន្ទុយធ្វើដោយថ្នីងឫស្សីពាសដោយសាច់កំណាត់លាបពណ៌ និងគូរជាលំនាំសត្វក្ងោក។ សំលៀកបំពាក់ និងគ្រឿងលំអច្នៃចម្លងតាមរូបសត្វក្ងោក។ ចំពោះអ្នករាំអម និងអ្នកចំរៀងស្លៀកពាក់តាមលក្ខណៈជាជនជាតិកុឡា។ ឯឧបករណ៍ភ្លេងមាន៖ ស្គរដៃយាំមួយ ជនជាតិកុឡាហៅថាកង់កូនយ៉ាំ ស្រឡៃមួយមានលក្ខណៈរបៀបត្រែកុឡាហៅថានៃកូនម៉ង់មួយ



www.elibraryofcambodia.org

កូឡាហៅថាមង់ ធាប និងឈើង កូឡាហៅថាសែង និងបន្ថែមស្គរ យោលភ្លោះមួយគូទៀត។

បងប្អូនកូឡានៅតំបន់ប៉ៃលិននិយមរាំរបាំនេះក្នុងពិធីបុណ្យចូលឆ្នាំ ឬពិធីផ្សេងៗក្នុងស្រុក។ ទន្ទឹមនេះ ក៏មានរាំក្នុងពិធីបុណ្យតាមគ្រួសារ។ ពិសេសរាំនៅថ្ងៃសីលក្នុងទីវត្តអារាម ដើម្បីសុំពរជ័យសិរីសួស្តីសុភមង្គលរុងរឿងរកស៊ីមានបាន។ ប្រការសំខាន់គឺការរកឃើញឱ្យបានច្រើន និងល្អនូវត្បូងពេជ្រពណ៌ក្នុងតំបន់ប៉ៃលិន។

## ព្រះបដិមា ព្រះនាងឥន្រ្ទទេវី និង ជ័យរាជទេវី ?

«ព្រះបដិមា ឬរូបចម្លាក់របស់ព្រះនាងទេពីទាំងពីរ ដែលជាអគ្គមហេសីរបស់ព្រះបាទជ័យវរ្ម័នទី៧ យើងអាចបញ្ជាក់ដោយឥតភាន់ច្រឡំថារូបចម្លាក់ណាមួយជារូបរបស់ព្រះនាងឥន្រ្ទទេវី។ ឯរូបមួយទៀត ជារូបរបស់ព្រះនាងជ័យរាជទេវី។ ដោយហេតុថាព្រះនាងទាំងពីរនេះជាបងប្អូនបង្កើតនឹងគ្នា មួយវិញទៀតចំពោះខ្មែរបុរាណ រូបចម្លាក់បុព្វបុរសដែលជាព្រះរាជវង្សានុវង្សរបស់ព្រះរាជាខ្មែរ ត្រូវបានគេស្ថាបនាឡើងក្រោមរូបភាពរបស់ព្រះវិស្ណុ ព្រះសិវៈ ព្រះព្រហ្ម ឬទេវតាផ្សេងៗទៀត។ សូមជម្រាបថា គឺតាមរូបចម្លាក់ទាំងនេះ យើងអាចឃើញនូវលក្ខណៈទេវៈ និងភាពអមតៈរបស់ដូនតា ដែលបានក្លាយទៅជាអាទិទេពក្រោយពីទទួលអនិច្ចកម្ម ហើយត្រូវបាន



www.elibraryofcambodia.org

គេគោរពបូជា។

តែទោះបីជាយ៉ាងណាក៏ដោយ ក៏ការវិភាគនូវរូបរាងរបស់ចម្លាក់ទាំងពីរ ពោលគឺរូបទី១ នៅសារមន្ទីរជាតិភ្នំពេញ និងមួយទៀតនៅសារមន្ទីរហ្គីមេនៃទីក្រុងប៉ារីស។ យើងអាចសម្គាល់បានថា រូបទីពីរដែលមានរាងស្គមកម្រ្លឹង ប្រហែលជារូបរបស់**ព្រះនាងជ័យរាជទេវី** ។ ចំណែករូបមួយទៀត គឺជាចម្លាក់នៅសារមន្ទីរ ជាតិភ្នំពេញ ប្រហែលជាតំណាង **ព្រះនាងឥន្ទ្រទេវី** (ក្របខាងមុខ) ពីព្រោះមានលក្ខណៈស្រស់ប្រិមប្រិយជាង ព្រះភ័ក្ត្រក៏ញញឹមញញែមជាង។

តាមពិតយើងពិបាកនឹងដឹងការពិតណាស់ អំពីប្រវត្តិនៃចម្លាក់ទាំងពីរនេះ ព្រោះមានលក្ខណៈប្រហាក់ប្រហែលគ្នា។ ទន្ទឹមនេះក៏តំណាងឱ្យប្រាជ្ញាបារមិតាផងដែរ»[៩៩]។

ទន្ទឹមនឹងបញ្ហានេះ បានធ្វើឱ្យយើងពិចារណាផងដែរ ដែលនៅពេលភ្ញៀវទៅទស្សនានៅប្រាសាទព្រះខ័នម្តងៗ មានអ្នកស្រុកសៀមរាបក្មេងចាស់ប្រុសស្រីខ្លះ តែងប្រាប់យើងឬនាំយើងឱ្យទៅអុជធៀនធូប ចំពោះរូបស្ត្រីពីរនាក់នៅក្នុងប្រាសាទនេះ ដោយនិយាយថាជារូបស្ត្រីគ្រប់លក្ខណ៍។ តាមជំនឿខ្មែរបុរាណជឿថា ស្ត្រីដែលមានផ្នត់កពីរឬបីជាន់ និងផ្នត់ក្បាលពោះពីរឬបីជាន់ដែរ នោះគឺសុទ្ធតែជាស្ត្រីមានសំណាងខ្ពស់ ប្រកបដោយយស ទ្រព្យសម្បត្តិនិង

[៩៩] _បណ្ឌិត មីសែល ត្រាណេ, *ប្រវត្តិសាស្ត្រ នៃព្រះរាជាណាចក្រកម្ពុជា បក្រែកពក្តុមដទេស ពីស.វ.ទី៩ _ ទី១៣ នៃគ.ស* , ភ្នំពេញ, ២០០៦។



www.elibraryofcambodia.org

គ្រប់លក្ខណ៍។ ចំពោះរូបចម្លាក់ស្ត្រីពីរនាក់នេះ បានបង្ហាញឱ្យយើងឃើញពីផ្នត់កនិងផ្នត់ក្បាលពោះបីឬបួនជាន់ មានភាពខុសពីចម្លាក់នាដកាដទៃដ៏ច្រើនរាប់រយរាប់ពាន់ទៀត។ ជាមួយគ្នានេះ រូបចម្លាក់ស្ត្រីពីរនាក់នេះមានការស្លៀក និង ពាក់គ្រឿងអលង្ការក្នុងភាពជាមនុស្សដូចនាដកាទាំងឡាយដែរ តែការតាក់តែងទ្រង់គ្រឿងល្អស្អកស្កះច្រើនជាងចម្លាក់នាដកានានា។ នៅលើចិញ្ចើមគេឃើញមានរន្ធតូចៗ ដែលបញ្ជាក់ប្រាប់ថារន្ធនេះត្រូវបានគេដាំត្បូង តែនៅពេលក្រោយមកមានការគាស់ចេញជាដើម...។ម្យ៉ាងទៀតយើងកម្រឃើញរូបនាដកាឈរម្នាក់ឯង ជាន់លើឬអង្គុយលើរតនបល្ល័ង្កជាផ្កាឈូក។ រតនបល្ល័ង្កនេះ អាចឈរជាន់ ឬអង្គុយលើបានលុះត្រាតែអ្នកបានសម្រេចសីលថ្នាក់ខ្ពស់។ ចំពោះរូបចម្លាក់ស្ត្រីពីរនាក់នេះស្ថិតក្នុងវ័យចំណាស់ជាងរូបនាដកាផ្សេងៗទៀត ដែលក្នុងសម័យរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ភាគច្រើនមានវ័យក្មេងៗ ឬវ័យជំទង់។ ឯចម្លាក់ស្ត្រីទាំងពីរនេះ ម្នាក់មាឌតូចច្រឡឹង ឯម្នាក់ទៀតមាឌធំនោះ មានវ័យចំណាស់ជាងគេ គឺអាចក្នុងវ័យប្រមាណជា៤០ឆ្នាំ។ យើងក៏បានសង្កេតឃើញចម្លាក់ស្ត្រីមាឌធំនេះ នៅប្រាសាទបាយ័នដែរ គឺមានលំនាំមុខដដែល និងមានសត្វសេកដ៏ធំទំនៅលើស្មា ហើយសំយុងកន្ទុយធ្លាក់ចុះយ៉ាងវែង(រូបលេខ១៣៨)។ចម្លាក់សត្វសេកនេះមានទំហំធំជាងសត្វនានាដែលទំនៅលើស្មានៃនាដកាផ្សេងទៀត។ យើងក៏តាមសង្កេតបន្តទៀតនោះ យើងឃើញរូបស្ត្រីតូចច្រឡឹងអង្គុយ



www.elibraryofcambodia.org

លុតជង្គង់រួមជាមួយបុរសម្នាក់ (ឆ្លាក់នៅថែវខាងត្បូងធៀងខាងកើត ជួរលើនៃប្រាសាទបាយ័ន(រូបលេខ៥៤) ក្នុងលក្ខណៈគុហតែងកាយ បង្ហាញពីភាពខ្ពង់ខ្ពស់។ បុរសកាន់ផ្កាឈូករីក ឯស្ត្រីទ្រដើងពាន តម្កល់វត្ថុដ៏មានតម្លៃលើកថ្វាយដល់បារមីជាទីសក្ការៈ ?

លក្ខណៈដែលបានរៀបរាប់ខាងលើនេះ យើងយល់ថានាដកា មាឌធំ អាចទំនងជាព្រះនាងឥន្ទ្រទេវី លោកកាំរៀងសេកពោធិសត្វ ផ្ទាល់ព្រះអង្គ។ ទន្ទឹមនេះ យើងក៏សង្កេតឃើញសេសសល់ជើងធូប ដែលអាចមានមនុស្សខ្លះសន្និដ្ឋានដូចយើង មកដុតធូបថ្វាយបង្គំ ។ ឯរូបចម្លាក់បុរសស្ត្រីពីរនាក់នោះ អាចទំនងជារូបព្រះបាទជ័យវរ្ម័ន ទី៧ (ពេលព្រះអង្គមិនទាន់ឡើងគ្រងរាជ្យ) ឬស្ងួនរួមជាមួយស្ត្រីតូច ប្រឡីងអាចទំនងជាព្រះនាងជ័យរាជទេវី កំពុងថ្វាយបង្គំសុំពរជ័យ ជាមួយព្រះស្វាមី មុនពេលយាងចេញទៅច្បាំងជាមួយសត្រូវ?។ តែ រូបខាងក្រោយខ្នងរបស់ព្រះអង្គ ជារូបកងទ័ពបែរងាកទៅក្រោយ អាចក្នុងលក្ខណៈត្រៀមចេញដំណើរ...?

ជាមួយគ្នានេះដែរ យើងខ្ញុំសង្កេតឃើញថាបុព្វបុរសខ្មែរ ដែលជាអ្នកគូរ ហើយឆ្លាក់នោះសុទ្ធតែមានថ្វីដៃចំណានចំពោះការ ត្រងយករូបភាពពិតៗ។ យោងតាមការសង្កេត យើងខ្ញុំក៏បានប្រទះ ឃើញនាដកានៅក្មេងៗស្រស់ប្រិមប្រិយ មានសភាពពិតៗ ប្លែកៗ យ៉ាងច្រើន ដែលមានឆ្លាក់នៅរចនាប័ទ្មប្រាសាទបាយ័ន និង មាន វ័យចំណាស់តិចតួចបំផុត។



www.elibraryofcambodia.org

# ផែនប្រាសាទនិងរូបភាព

ចំពោះការសិក្សាស្រាវជ្រាវនេះ យើងខ្ញុំបានជ្រើសរើសយកតែប្រាសាទប្រាំមកពិចារណា ដោយសង្ឃឹមថាអស់លោកអ្នកជំនាន់ក្រោយ នឹងស្វះស្វែងរកមើលតាមប្រាសាទនានាដ៏ច្រើន ដែលកសាងក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ បន្ថែមទៀត ។ បញ្ហានេះកើតឡើងគឺដោយសារភាពស្មុគស្មាញ ឬ ថ្មបែកបាក់ និង ចរឹកាមានកំណត់ ។ម្យ៉ាងទៀតយើងខ្ញុំ មិនអាចដាក់រូបចម្លាក់នាងទាដកាធំៗភ្ជាប់ជីវិត និង រូបសត្វនានានោះអស់ឡើយ ។ ប៉ុន្តែ យើងខ្ញុំបានគូសគំនូស និង ដាក់លេខលើផែនប្រាសាទនីមួយៗ ដើម្បីលោកអ្នកងាយស្រួលតាម ពិនិត្យរកមើលរូបនាដកាទាំងអស់នោះ ។



www.elibraryofcambodia.org

# I. ផែនប្រាសាទតាព្រហ្ម
Plan of Ta Prum Temple




ប្រភព/Source : Glaize, 1997 : 142

១_ រូបត្រី ២_ រូបកង្កែប ៣_ រូបប្រវឹក
៤_ រូបត្រលេងត្រលោង ៥_ រូបសេកពីរ ៦_ រូបកូនក្របី (ប៉ែក)
៧_ រូបទទា ៨_ រូបមាន់ ៩_ រូបត្រសេះ



www.elibraryofcambodia.org

# II. ផែនប្រាសាទព្រះខ័ន

Plan of Preah Khan Temple




ប្រភព/Source : Glaize, 1997 : 174

| | | |
|---|---|---|
| ១០_រូបស្វា | ១១_រូបមាន់ | ១២_ រូបក្អែក(ពង) |
| ១៣_រូបសេក (បាក់ទង) | ១៤_រូបព្រាប | ១៥_រូបហង្ស (កក្កុង) |
| ១៦_រូបក្អែក (កន្ទុយវែង) | ១៧_រូបមាន់ | ១៨_រូបសេកពីរ |
| ១៩_រូបប្រវឹក | ២០_រូបហង្ស | ២១_រូបចាបប្រចៀច[៦១] |
| ២២_រូបត្មាត | ២៣_រូបចាបជៀបកប្បាស[៦២] | |

---

[៦១] _ចាបប្រចៀច ឬ ប្រជៀច ៖ សត្វស្លាបតូចជើងវែង ចំពុះវែង កន្ទុយបះៗ ចូលចិត្តស៊ីដង្កូវតាមអាចម៍ដីបំណះ។

[៦២] _ចាបជៀបកប្បាស ៖ មានខ្លួនតូចជាងចាបទាំងពួង។ អ្នកខ្លះហៅថាចាបដង្កូវព្រោះចូលចិត្តស៊ីដង្កូវ។ ចាបនេះច្រើនធ្វើសំបុកនៅគុម្ពោតព្រៃឬក្រោមមែកឈើទាបៗ។



www.elibraryofcambodia.org

## III. ផែនប្រាសាទបាយ័ន
Plan of Bayon Temple




ប្រភព/Source : Glaize, 1997 : 84

| | | |
|---|---|---|
| ២៤_សេក | ២៥_សេក | ២៦_សេក |
| ២៧_សេក | ២៨_សេក | ២៩_សេក |
| ៣០_ក្រាប និង ក្អែក | ៣១_សេក | ៣២_សេក |
| ៣៣_សេក | ៣៤_សេក | ៣៥_សេក |
| ៣៦_សេក | ៣៧_កេពីរ | ៣៨_សេកធំជាងគេ |
| ៣៩_សេក | ៤០_សេក | |



www.elibraryofcambodia.org

## IV. ផែនប្រាសាទបន្ទាយក្ដី

Plan of Banteay Kdey Temple




ប្រភព/Source : Glaize, 1997 : 151

៤១_រូបគ្នាត	៤២_រូបទទា

៤៣_សេក	៤៤_សេក

៤៥_សត្វស្លាបបែកបាក់...?	៤៦_ក្រាប



www.elibraryofcambodia.org

# V. ផែនប្រាសាទតាសោម

## Plan of Ta Som Temple




ប្រភព/Source : World Monuments Fund/Ta Som Joint Conservation Project

៤៧_សត្វស្លាបបែក ៤៨_រូបកូនក្រុម្ប ៤៩_កូនមៀម

៥០_រូបកំប្រុក ៥១_រូបហង្ស ៥២_ព្រាប

៥៣_ក្អែកពីរ



www.elibraryofcambodia.org






www.elibraryofcambodia.org



លេខ ២ រូបកង្កែប



www.elibraryofcambodia.org



លេខ ៣ រូបប្រវឹក



www.elibraryofcambodia.org



លេខ ៤ រូបគ្រលេងគ្រលោង



www.elibraryofcambodia.org



លេខ ៧ រូបទទា



www.elibraryofcambodia.org






www.elibraryofcambodia.org



លេខ ៩ រូបត្រសេះ



www.elibraryofcambodia.org



លេខ ១០ រូបស្វា



www.elibraryofcambodia.org



លេខ ១២ រូបក្បោក (បើកពង់)



www.elibraryofcambodia.org



លេខ ១៤ រូបក្រាប



www.elibraryofcambodia.org



លេខ ១៥ រូបហង្ស



www.elibraryofcambodia.org



លេខ ១៦ រូបក្បាក់ (កន្ទុយវែង)



www.elibraryofcambodia.org



លេខ ១៨ រូបក្ងួនសេកពីរ



www.elibraryofcambodia.org



លេខ ២១ រូបចាបប្រចៀច



www.elibraryofcambodia.org






www.elibraryofcambodia.org



លេខ ២៣ រូបចាបថៀបកប្បាស



www.elibraryofcambodia.org



លេខ ៣០ រូបព្រាប និងក្អែក



www.elibraryofcambodia.org



លេខ ៣៧ រូបកេពីរ



www.elibraryofcambodia.org



លេខ ៤១ រូបត្បាត



www.elibraryofcambodia.org



លេខ ៤៨ រូបកូនក្រួច



www.elibraryofcambodia.org



លេខ ៤៩ រូបកូនមៀម



www.elibraryofcambodia.org



លេខ ៥០ រូបកំប្រុក



www.elibraryofcambodia.org



លេខ ៥៣ រូបក្អែកពីរ



www.elibraryofcambodia.org

## VI. ព្រះរូបបដិមា ៖



លេខ ៣៨ រូបព្រះនាងឥន្ទ្រទេវីរាំ? (ប្រាសាទបាយ័ន)



www.elibraryofcambodia.org



លេខ ៥៤ រូបព្រះនាងឥន្ទ្រទេវី? ប្រាសាទព្រះខ័ន(រូបស្រីគ្រប់លក្ខណ៍)



www.elibraryofcambodia.org



លេខ ៥៥ រូបព្រះនាងជ័យរាជទេវី? ប្រាសាទព្រះខ័ន(រូបស្រីគ្រប់លក្ខណ៍)



www.elibraryofcambodia.org



លេខ ៥៦ រូបព្រះបាទជ័យវរ្ម័នទី ៧ និង ព្រះនាងជ័យរាជទេវី?



www.elibraryofcambodia.org






www.elibraryofcambodia.org






www.elibraryofcambodia.org






3 006036 08200693 00603

www.elibraryofcambodia.org






www.elibraryofcambodia.org



www.elibraryofcambodia